ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



- ជីវិតក្នុងគារាពលិចថ្កល់
- អង្គការសង្គមស៊ីវិលអំពាវនាវឲ្យមានបទដ្ឋានអន្តរជាតិសម្រាប់តុលាការខ្មែរក្រហម

លេខ៥៤ ខែមិថុនា ឆ្នាំ២០០៤

# ស្វែងរកការពិត

ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ៥៦ ខែសីហា ឆ្នាំ២០០៤


## មាតិកា


◆ សំបុត្រៈ ........................................................................ ១

**ផ្នែកឯកសារ**

◆ អតីតប្រធានសន្តិសុខតំបន់៤២.............................................២

◆ បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរ ស-២១..........៦

◆ ដំណើរការកសាងប្រទេសរបស់កម្ពុជាប្រជាធិបតេយ្យ...............៨

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ ស្តាប់រឿងរ៉ាវរបស់ជនរងគ្រោះវ័យចំណាស់ម្នាក់ទៀត.......... ១៣

◆ មានទោសដោយសារប្តី.................................................. ១៦

◆ ភូមិមេម៉ាយ................................................................១៩

◆ អតីតកងទ័ពខ្មែរក្រហមម្នាក់ព្រមធ្វើសាក្សីក្នុងតុលាការ............២១

**ផ្នែកច្បាប់**

◆ សេចក្តីប្រកាសពត៌មានរបស់ការិយាល័យអ្នកនាំពាក្យ..............២៣

◆ សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្ម...................................២៤

**វេទិកាពិភាក្សាសាធារណៈ**

◆ អគ្គការសង្គមស៊ីវិលអំពាវនាវ......................................... ៣២

◆ ការផ្សះផ្សានៅកម្ពុជា...................................................៣៤

**ទំព័រស្វែងរកគ្រួសារ**

◆ ភាពរន្ធត់និងការឈឺចាប់.................................................៥៤

◆ ខ្ញុំបានឃើញឈ្មោះបងស្រី...............................................៥៩




នួន ហុង អតីតកងការពារអ្នកទោសនៅមន្ទីរ ស-២១



វិលត្រឡប់មកភូមិកំណើតវិញនៅឆ្នាំ១៩៧៩


# រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ

ក្រសួងពត៌មាននៃរាជរដ្ឋាភិបាលកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងពត៌មាន

លេខ ០២៩១ពម/៩៩

ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា

និង សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង



**ស្នេរលេខនេះ:** យិន នាន, អឿ រតនា, ឡុង ដានី, ឌឿ សេរីវឌ្ឍន, ឈន ច័ន្ទមករា, ស៊ូហ្សាណា លីនគុន **អ្នកនិពន្ធនិងស្រាវជ្រាវ:** លី សុផល, សូហ្វារីណា **ជំនួយការនិពន្ធនាយក:** សាន កល្យាណ **និពន្ធនាយករង:** សួ ប៊ុនស៊ូ **អ្នកបកប្រែ:** អេង កុកថាយ **និពន្ធនាយកទូទៅ:** ឆាំង យុ **ក្រាហ្វិកកុំព្យូទ័រ:** ស៊ឹម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយ:** មាស ប៊ុនថាន

*សំបុត្រៈ*

# ជីវិតក្នុងភាពនឹងថ្កល់

នៅក្នុងរយៈពេល២៥ឆ្នាំក្រោយពីការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យមក យើងបានរៀនសូត្រជាច្រើនអំពីបុគ្គលទាំងឡាយដែលបានចូលរួមដឹកនាំរបបនេះ ។ គោលដៅរបស់បុគ្គលទាំងនេះគឺកាស់រំលើងមូលដ្ឋានគ្រឹះនៃសង្គមកម្ពុជារចនាសម្ព័ន្ធគ្រួសារសង្គមនិងមូលដ្ឋាននៃតម្លៃនិងវប្បធម៌ ។ បច្ចុប្បន្នយើងដឹងថាខ្មែរក្រហមមានគ្រួសារនិងជីវិតឯកជនដូចប្រជាជនកម្ពុជាទូទៅដែរ ។ ខ្មែរក្រហមព្យាយាមបំបាត់ចោលគ្រួសាររបស់ប្រជាជន ប៉ុន្តែបែរជារក្សាររបៀបរបបនៃការរស់នៅជាគ្រួសារសម្រាប់ខ្លួនឯងទៅវិញ ។

រាល់គ្រួសារកម្ពុជាទាំងអស់ តាំងពីព្រះមហាក្សត្ររហូតដល់ប្រជាកសិករក្រីក្រ មានសមាជិកយ៉ាងហោចណាស់មួយរូបបានស្លាប់ ឬ បាត់ខ្លួននៅក្នុងរបបដ៏ឃោរឃៅរបស់ខ្មែរក្រហម ។ សូម្បីតែមកដល់ឆ្នាំ២០០៤នេះហើយ ក៏គ្រួសារជាច្រើនមិនមានភាពពេញលេញទេ គឺដោយសារឥទ្ធិពលនៃមនោគមវិជ្ជាមួយដែលទាមទារឲ្យមានការលុបបំបាត់ចោលនូវប្រពៃណីទំនៀមទម្លាប់ វប្បធម៌ និងតម្លៃសង្គម ។ ប្រជាជនជិតពីរលាននាក់ត្រូវបានប្រហារជីវិត បង្អត់អាហារឲ្យស្លាប់ ឬត្រូវបង្ខំឲ្យធ្វើការបាក់កម្លាំងរហូតដល់ស្លាប់ ។

កម្ពុជាជានិមិត្តរូបនៃគ្រួសារបែកបាក់ដ៏ធំមួយ ដែលការព្យាបាលឲ្យដូចដើមវិញត្រូវចំណាយពេលវេលាជាច្រើនជំនាន់ ។ នៅក្នុងគ្រួសាររបស់ខ្ញុំផ្ទាល់ មា មីង និងជីដូនជីតា ទាំងខាងឪពុកនិងម្តាយ បានស្លាប់បាត់បង់ជីវិត ។ នៅក្នុងពេលដ៏ឆាប់ខាងមុខនេះ មជ្ឈមណ្ឌលឯកសារកម្ពុជានឹងបោះពុម្ពផ្សាយសៀវភៅ "ជីវិតក្នុងភាពនឹងថ្កល់" ដែលមិនមែនរៀបរាប់អំពីជនរងគ្រោះទេ ប៉ុន្តែអំពីរឿងរ៉ាវនៃគ្រួសាររបស់ជនដៃដល់ដែលជាអ្នកបង្កឲ្យមានសោកនាដកម្មមកលើយើងទាំងអស់គ្នា ។ រឿងរ៉ាវទាំងនេះបញ្ជាក់អំពីសារសំខាន់នៃគ្រួសារ ហើយបង្រៀនខ្ញុំឲ្យយល់អំពីប្រយោជន៍នៃការទទួលស្គាល់ភាពជាមនុស្សនៃរាល់ជនរួមជាតិទាំងអស់ អំពីភាពចាំបាច់នៃការគោរពសិទ្ធិមនុស្សរបស់ពលរដ្ឋគ្រប់រូបដោយមិនគិតគូរអំពីឧក្រិដ្ឋកម្មដែលពលរដ្ឋនោះបានប្រព្រឹត្ត និងភាពខុសគ្នារវាងបុគ្គលនិងបុគ្គល ។ រឿងទាំងនេះក៏បង្ហាញអំពីកម្លាំងចិត្តមនុស្សដែលអាចទ្រទ្រង់បាននូវបន្ទុកមិនកំណត់មួយ ។ ប្រសិនបើប្រទេសកម្ពុជាត្រូវប្រែខ្លួនឲ្យទៅជាសង្គមប្រជាធិបតេយ្យពិតប្រាកដមួយ ការជំរុញឲ្យគោរពសិទ្ធិមនុស្សចំពោះបុគ្គលទាំងអស់ គឺជាចំណុចគន្លឹះដ៏សំខាន់បំផុត ។

**ឆាំង យុ**



សោម នឹម
អតីតយុទ្ធនារីនៅមន្ទីរព្រៃស



ឆាំង យុ
និង ហ៊ឹម ហ៊ុយ អតីតកងការពារអ្នកទោសនៅមន្ទីរ ស-២១

*(អត្ថបទសង្ខេបចេញពីចម្លើយសារភាព)*

# អតីតប្រធានមន្ទីរសន្តិសុខតំបន់៤២

មាស សុខ មានឈ្មោះបដិវត្តន៍ សៅ មានស្រុកកំណើតនៅភូមិថ្មី ឃុំស្វាយទាប ស្រុកកំពង់សៀម (បច្ចុប្បន្នឃុំស្វាយទាបស្ថិតក្នុងស្រុកចម្ការលើ) ខេត្តកំពង់ចាម តំបន់៤១ ។ នៅក្នុងរបបខ្មែរក្រហម សុខ មានតួនាទីជាប្រធានសន្តិសុខតំបន់៤២ ។ ដើម្បីបញ្ជាក់ថាខ្លួនពិតជាបានក្បត់បដិវត្តន៍មែននោះ សុខ បានបញ្ជាក់ថាធ្លាប់ធ្វើជាគិញស៊ើបការណ៍អំពីបដិវត្តន៍ខ្មែរក្រហមតាំងពីពាក់កណ្តាលឆ្នាំ១៩៦៧ម្ល៉េះ តាមការញុះញង់របស់អ្នកជិតខាងពីរនាក់ ។ សុខ ត្រូវអង្គការចាប់ខ្លួនហើយបញ្ជូនមកមន្ទីរឃុំឃាំង ស-២១ នៅខែតុលា ឆ្នាំ១៩៧៧ ។

នៅអាយុ១៥ឆ្នាំ ម្តាយរបស់ សុខ បាននាំគាត់មកស្នាក់នៅវត្តកោះរកាជាមួយសង្ឃព្រះនាម វ៉ាត់ និង មួង ។ នៅវត្តបានមួយឆ្នាំ ព្រះតេជគុណ វ៉ាត់ បានបំបួស សុខ ជាសង្ឃ ។ ក្រោយពីបួសបានតែមួយឆ្នាំ សុខ បានសឹកមកនៅផ្ទះជាមួយម្តាយនិងដើរស៊ីឈ្នួលជម្រះស្មៅចម្ការនិងលក់ថ្នាំបុរាណវិញ ។

នៅពាក់កណ្តាលឆ្នាំ១៩៦៧ លន់ និង ពុត ដែលជាអ្នកជិតខាងរបស់ សុខ បាននិយាយអំពីបដិវត្តន៍ខ្មែរក្រហមឲ្យ សុខ ស្តាប់ និងស្នើឲ្យ សុខ ជួយធ្វើការងារឲ្យខ្លួនដោយសន្យាឲ្យប្រាក់២០០ រៀលក្នុង១ខែ ហើយឲ្យបំពេញភារកិច្ចមួយចំនួនដូចជា ពង្រីកកម្លាំងគិញនៅតាមភូមិ ស្រាវជ្រាវរកអ្នកផ្តល់ស្បៀងឲ្យខ្មែរក្រហម និងស្វែងរកអ្នកដើរបោះត្រាក់ធ្វើនយោបាយក្នុងជួរប្រជាជន ។

សុខ បានដើរស៊ើបការណ៍នៅក្នុងឃុំស្វាយមាស ហើយកសាងកម្លាំងបាន៤នាក់ដែលជាមនុស្សចូលចិត្តផឹកស៊ីសប្បាយ ។ សុខ បានណែនាំកិច្ចការឲ្យអ្នកទាំង៤នោះធ្វើ ។ សុខ ចាប់បានឈ្មោះ សែន ដែលជាអ្នកបញ្ចេញស្បៀងឲ្យខ្មែរក្រហមហើយបញ្ជូនមកឲ្យមេឃុំ លន់ ប៉ុន្តែក្រោយមកក៏ដោះលែងទៅវិញ ។

នៅឆ្នាំ១៩៦៨ មេឃុំ លន់ បានណែនាំ សុខ ឲ្យស្គាល់ឈ្មោះ ហុង និង សន ដើម្បីធ្វើការជាមួយគ្នា ។ សុខ និង សន កសាងកម្លាំងបាន២នាក់ហើយណែនាំឲ្យតាមដានរកខ្មែរក្រហម និងអ្នកបាចត្រាក់ផង ។ ជាលទ្ធផល សុខ ចាប់បានមនុស្ស៥នាក់ ដែលជាអ្នកបញ្ចេញស្បៀងឲ្យខ្មែរក្រហម ។

ក្រោយរដ្ឋប្រហារឆ្នាំ១៩៧០ មេឃុំ លន់ បានដាក់ភារកិច្ចមួយចំនួនទៀតឲ្យ សុខ អនុវត្តគឺ កសាងកម្លាំងគិញនៅក្នុងអង្គភាពកងទ័ព ពិនិត្យរកជំរំកងទ័ពរស់នៅ ពិនិត្យមើលឃ្លាំងជាពិសេសឃ្លាំងអាវុធនិងគ្រាប់ និងបំផុសយុវជន-យុវនារីក្នុងជួរឲ្យរត់មកសមរភូមិក្រោយវិញ ។ សុខ បានបង្កប់ខ្លួនធ្វើជាឈ្លបនៅឃុំទ្រាន ហើយបានរាយការណ៍ពីទីតាំងទ័ពនៅភូមិត្រពាំង ទើបធ្វើឲ្យយន្តហោះមកទម្លាក់គ្រាប់បែកដាក់ភូមិនេះខ្ទេចខ្ទីអស់ ។ សុខ បំផុសបំផុលប្រជាជនអំពីការលំបាករបស់បដិវត្តន៍ ការព្រាត់ប្រាសគ្រួសារ និងការហូបចុកមិនគ្រប់គ្រាន់ ។

មេឃុំ លន់ បានប្រាប់ សុខ ឲ្យទាក់ទង កែវ នៅភូមិតាមាង ដើម្បីធ្វើការជាមួយគ្នា ។ សុខ កសាងកម្លាំងបានម្នាក់ទៀតឈ្មោះ ច្រឹង ដែលជាគិញចេញពីកំពង់ចាមដែរ ។ សុខ, ច្រឹង និង កែវ បានជួបពិភាក្សាគ្នាអំពីភារកិច្ចដែលត្រូវធ្វើហើយ កែវ ជាអ្នករាយការណ៍ឲ្យ លន់ បន្តទៀត ។ ណែត ដែលជាប្រធានសេដ្ឋកិច្ចស្រុកចម្ការលើតំបន់៤២ បានពន្យល់ប្រាប់ សុខ ថាបដិវត្តន៍បំបិទសិទ្ធិសេរីភាពប្រជាជន ទាំងប្រពៃណី ទាំងសាសនា ។ សូម្បីតែសិទ្ធិរៀបចំគ្រួសាររវាងយុវជន-យុវនារីក៏គ្មានដែរ ព្រោះរវល់តែទៅសមរភូមិមុខ ។

នៅខែ១១ ឆ្នាំ១៩៧២ សុខ បានចូលរួមក្នុងកម្មវិធីមួយដែលមានរៀបចំតុបតែងផ្កាភ្ញីចម្រុះពណ៌ និងទង់ជាតិរូបផ្កាយនិងប្រាសាទពណ៌លឿង ខៀវ ក្រហម ស ដោយមាន គៀម, ប៊ួន និង ណែត ចូលរួមផង ដែលនេះជាពិធីបញ្ចូលសមាជិកថ្មីទៅក្នុងអង្គការសេ.អ៊ី.អា ។ ដំណើរការកម្មវិធីមាន ១) គោរពទង់ជាតិ

២) ប្រកាសមូលហេតុនៃការបញ្ចូលជាសេ.អ៊ី.អា ៣) គៀម ឡើង ធ្វើសេចក្តីណែនាំអំពីការចូលសេ.អ៊ី.អា ៤) ប៊ួន ណែនាំបន្ថែម ៥) សមាជិកថ្មីធ្វើសច្ចាប្រណិធាន ៦) គៀម ដាក់ផែនការ ការងារ ។ បន្ទាប់មក គៀម បានណែនាំឲ្យ សុខ សហការនឹងកម្លាំង ៥ នាក់ទៀតដើម្បីធ្វើសកម្មភាព ។ សុខ ជ្រើសរើសកម្លាំង៤នាក់ គឺ ហេង, សែ, វ៉ូង និង សែន ជួយបំផុសក្នុងជួរប្រជាជន យុវជន-យុវនារីឲ្យចូលខាងសេ.អ៊ី.អា និងណែនាំភារកិច្ចមួយ ចំនួនគឺ ១) បំផុសយុវជនមិនឲ្យទៅសមរភូមិមុខ ២) ដុតបំផ្លាញ ឃ្លាំងអាវុធគ្រាប់រំសេវ និងរារាំងយុវជនមិនឲ្យចូលសមរភូមិ ហើយទាក់ទាញយុទ្ធជននៅសមរភូមិមុខឲ្យមកក្រោយវិញ ។

នៅឆ្នាំ១៩៧៣ សុខ, មាន និង ហង់ បានជួបប្រជុំគ្នានៅ មន្ទីរសន្តិសុខភូមិពព្រេង ស្តីអំពីផែនការដកទុកពួករដ្ឋការដែល មូលដ្ឋានបញ្ជូនមកដើម្បីទុកធ្វើជាកម្លាំងត្រៀមទៅថ្ងៃអនាគត ។ នៅឆ្នាំដដែល សុខ, មាន, ហេង និង សែ បានជួបជុំគ្នានៅមន្ទីរឃុំ ស្តីអំពីផែនការដុតបំផ្លាញស្រូវប្រហែល២០០ថាំងរបស់ឃុំ ដែលទុកនៅអូរទួងក្រោម ។ កម្លាំងរបស់ សុខ បានដុតជង្រុកស្រូវ ឆេះអស់តែពាក់កណ្តាល ដោយសារប្រជាជនមកពន្លត់ទាន់ពេល វេលា ។

នៅដើមឆ្នាំ១៩៧៤ ហង់ បានចាត់តាំងឲ្យ សុខ ធ្វើជា ប្រធានក្រុមការងារនៅមន្ទីរសន្តិសុខ ។ សុខ, ហង់ និង ឡាន បានលើកផែនការកសាងកម្លាំងនៅក្នុងអង្គភាព ដើម្បីក្តាប់ចរិត មនុស្សតាមដានអ្នករដ្ឋការចាស់ដែលបញ្ជូនមកពីមូលដ្ឋាន បំផុស យុវជន-យុវនារីឲ្យមានការច្របូលច្របល់គ្នា ជាពិសេសនៅ ពេលអង្គការប្រមូលទៅសមរភូមិមុខ ។ ការធ្វើសកម្មភាពណាមួយ លុះត្រាតែមានការចាត់តាំងពីថ្នាក់លើ បើគ្មានការចាត់តាំងមិន ត្រូវធ្វើផ្តេសផ្តាសឡើយ ។ បន្ទាប់មក អង្គប្រជុំក៏ឧទ្ទេសនាម កម្លាំង៣នាក់ទៀត ។ សុខ និងកម្លាំងរបស់ខ្លួន បានពិភាក្សាគ្នា អំពីផែនការដុតឃ្លាំងគ្រាប់របស់ភូមិភាគឧត្តរ ព្រមទាំងកំណត់ថ្ងៃ និងយុទ្ធវិធីក្នុងការដុតបំផ្លាញ ។ ជាលទ្ធផល ឃ្លាំងគ្រាប់កាំភ្លើងដៃ ត្រូវបានកម្ទេច ។ ក្រោយមក សុខ បានលើកផែនការថ្មីទៀតគឺ កសាងកម្លាំងក្នុងមន្ទីរដោយរើសយក ឈ្មោះ ងើ, សូត្រ និង នាគ ធ្វើជាកម្លាំងបង្កប់ព្រោះអ្នកទាំងបីជាមនុស្សចូលចិត្តសប្បាយ ។ នៅឆ្នាំដដែល ពេលដែលអង្គការប្រមូលយុវជនទៅសមរភូមិមុខ ហង់ បានចាត់តាំង សុខ ឲ្យទាក់ទងជាមួយ ហ៊ាង ខាងសង្កាត់ស្ពឺ ដើម្បីធ្វើសកម្មភាពតាមផែនការគឺបញ្ចុះបញ្ចូលយុវជនឲ្យត្រឡប់ ទៅផ្ទះ ហើយមួយចំនួនទៀតឲ្យត្រឡប់ទៅសមរភូមិក្រោយវិញ ។ ស៊ឹម ជាជីទប់លេខ២ នៅឃុំស្វាយទាបដែលបានបញ្ជូនមកមន្ទីរ សន្តិសុខស្រុក ត្រូវកម្លាំងរបស់ សុខ អប់រំឲ្យធ្វើជាកម្លាំងបង្កប់ និងធ្វើសកម្មភាពក្នុងចំណោមប្រជាជន និងឲ្យប្តូរទីស្នាក់ការមក ស្រុកចម្ការលើ ។

នៅខែ៨ ឆ្នាំ១៩៧៤ អង្គការបានដក ហង់ ឲ្យទៅសមរភូមិ និង សុខ ឲ្យមកមន្ទីរសន្តិសុខតំបន់៤២ ។ ហង់ បានផ្តាំឲ្យ សុខ ទាក់ទងកម្លាំងចាស់នៅតាមមូលដ្ឋានឲ្យជាប់ ។ ៥ ថ្ងៃបន្ទាប់ពី ហង់ ចាកចេញទៅ គៀម បានមកមន្ទីរសន្តិសុខស្រុកហើយហៅ សុខ និង ឡាន មកពិភាក្សានិងណែនាំឲ្យទាក់ទងឈ្មោះ ទឹម ប្រធាន សន្តិសុខតំបន់៤២ ឲ្យបន្តភារកិច្ចសម្ងាត់តទៅទៀត ។

សុខ, ទឹម, ឆន និង មាន បានជួបប្រជុំគ្នានៅមន្ទីររបស់ ទឹម ហើយបានលើកផែនការកសាងកម្លាំងក្នុងអង្គភាព បំផ្លាញ សម្ភារ យកចិត្តទុកដាក់ប្រមូលអ្នករដ្ឋការចាស់ និងបំផុសប្រជាជន ឲ្យមានទំនាស់ជាមួយអង្គការ ។ បន្ទាប់មក ទឹម បានឧទ្ទេសនាម កម្លាំង១១នាក់ទៀតដែលត្រូវទាក់ទងធ្វើការជាមួយគ្នា ។

នៅចុងឆ្នាំ១៩៧៤ ទឹម បានចាត់តាំងកម្លាំង៣នាក់ឲ្យធ្វើជា កម្លាំងបង្កប់ព្រោះថា ទាំងបីនាក់ជាមនុស្សមានធាតុសេរីនិង មិនសូវយកចិត្តទុកដាក់នឹងកិច្ចការបដិវត្តន៍ ហើយក៏ដាក់ភារកិច្ច មួយចំនួនឲ្យធ្វើ គឺក្តាប់អ្នករដ្ឋការក្នុងមន្ទីរសន្តិសុខ និងបំផុស ទំនាស់រវាងយុវជន-យុវនារីឲ្យប្រឆាំងនឹងបដិវត្តន៍ ។ ពីខែ១ដល់ ខែ៨ ឆ្នាំ១៩៧៥ សុខ បានជួប ខាត់ ប្រធានសង្កាត់ចម្ការអណ្តូង ដើម្បីពិភាក្សាគ្នាអំពីការលួចទម្លាយទំនប់ទឹកនៅភូមិតាដៃដើម្បីកុំ ឲ្យស្ទូងស្រូវបាន ។ លទ្ធផលដែលកម្លាំងរបស់ សុខ សម្រេចបានគឺ បំផ្លាញគ្រាប់និងជង្រុកស្រូវអស់ជាច្រើន បំផុសយុវជនមិនឲ្យទៅ សមរភូមិមុខ បំផុសប្រជាជនឲ្យបង្កទំនាស់ជាមួយអង្គការអំពី បញ្ហារួមនិងឯកជន ហើយប្រឆាំងនឹងគោលការណ៍ប្រមូលទ្រព្យ

សម្បត្តិដាក់រួម ។

ក្រោយការរំដោះទូទាំងប្រទេសនៅឆ្នាំ១៩៧៥ អង្គការមានផែនការឲ្យបោសសម្អាតខ្មាំង ។ សុខ និងកម្លាំងបានដាក់ផែនការដូចជា ១) ដោះលែងអ្នកទោស ពិសេសអ្នកដែលមានបណ្តាស័ក្តិដើម្បីឲ្យដើរបន្តុបតាមសហករណ៍ ២) បោសសម្អាតកុំឲ្យស្អាតគឺធ្វើឲ្យប្រជាជនភ្ញាក់ផ្អើល ៣) បើឆែកបានអាវុធត្រូវលាក់ទុក ។ ជាលទ្ធផល កម្លាំងរបស់ សុខ ដកហូតបានកាំភ្លើងខ្លី២ដើម បាញ់ទម្លាយកង់ឡានធ្វើឲ្យស្ទះដល់ការដឹកជញ្ជូន និងលាក់ទុកអ្នកមានបណ្តាស័ក្តិ៨នាក់ ប៉ុន្តែរក្សាទុក២នាក់ ចំណែក៦នាក់ទៀតត្រូវអង្គការចាប់ខ្លួន ។

នៅខែ៩ ឆ្នាំ១៩៧៥ ខឹម បានណែនាំ សុខ ឲ្យស្គាល់និងសហការជាមួយ ហោ ដែលជាអនុប្រធានរោងជាងម៉ាស៊ីនដើម្បីធ្វើឲ្យរាំងស្ទះដល់ការផ្គត់ផ្គង់ម៉ាស៊ីន និងមិនឲ្យទាន់សំណូមពររបស់អង្គការ ។ ខែ១០ ខឹម, ឆុន, ហ៊ាង និង សុខ បានមកជួបពិភាក្សាគ្នានៅមន្ទីរសង្កាត់ស្ពឺដើម្បីបំផ្លាញដំណាំស្រូវដោយយោងតាមសភាពការណ៍ខ្វះខាតស្រូវ ។ ហ៊ាង បានដឹកនាំកម្លាំងដុតបំផ្លាញស្រូវ ប៉ុន្តែត្រូវអង្គការពន្លត់ទាន់ពេល ។ ដល់ខែ១១ ខឹម បានចាត់តាំងឲ្យ សុខ, ឆុន និង ចេន (អនុប្រធានមន្ទីរសន្តិសុខ) ទៅឈ្លបមើលឃ្លាំងគ្រាប់នៅភូមិប្រីបណ្តើសនៅវេលាម៉ោង១០យប់ ប៉ុន្តែត្រូវបែកការណ៍ ហើយអ្នកទាំងបីបានរត់រួចមកដល់កន្លែងវិញ ។

នៅខែ២ ឆ្នាំ១៩៧៦ សុខ បានចូលរួមប្រជុំនៅមន្ទីរចាត់ការរបស់តំបន់៤២ក្រោមការដឹកនាំរបស់ បួន ។ អ្នកចូលរួមប្រជុំមាន៥នាក់ ហើយខ្លឹមសារប្រជុំគឺលើកអំពីការគាបសង្កត់របស់បក្សកុម្មុយនិស្តកម្ពុជាមកលើប្រជាជន ជាពិសេសការរឹបអូសយកទ្រព្យសម្បត្តិរបស់ប្រជាជនមកដាក់ជារបស់រួម ។ ដូច្នេះត្រូវតែតស៊ូដើម្បីធ្វើឲ្យសង្គមសម្បូរសប្បាយដូចពីដើមវិញ ។ បន្ទាប់មកបានលើកផែនការមួយចំនួនដូចជាៈ ១) ត្រូវកសាងកម្លាំងតាមអង្គភាពនិងផ្នែកនីមួយៗ ២) បំផ្លាញឃ្លាំងអាវុធនិងគ្រាប់រំសេវ និង ៣) បំផុសយុវជន-យុវនារីនិងប្រជាជនឲ្យមានទំនាស់នឹងអង្គការបដិវត្តន៍ ។ ប្រហែលនៅខែ៣ ខឹម និង សុខ បានជួបជាមួយ វ៉ន នៅកន្លែងចិញ្ចឹមត្រី ហើយបានលែងត្រីអស់មួយចំនួន និងបំពុលត្រីដែលអង្គការចិញ្ចឹមទុកអស់មួយចំនួនទៀត ។ បន្ទាប់មកបានដាក់ឲ្យអនុវត្តផែនការបំផ្លាញកូនកៅស៊ូនិងការដាំដុះ ។

នៅខែ៥ ឆ្នាំ១៩៧៦ ហ៊ាង (នៅសង្កាត់តាប្រុក) បានមកធ្វើជាប្រធានពាណិជ្ជកម្ម ស្រុកចម្ការលើ ហើយ ខឹម, សុខ និង ឆុន បានមកជួប ហ៊ាង ដើម្បីដាក់ផែនការផ្តល់សម្ភារឲ្យប្រជាជនមិនគ្រប់គ្រាន់តាមតម្រូវការ និងមិនស្មើគ្នារវាងឃុំនីមួយៗ ដើម្បីឲ្យប្រជាជនមានទំនាស់ជាមួយអង្គការ ។ កម្លាំងរបស់ សុខ បានរួមធ្វើសកម្មភាពជាមួយ ឃន ចលនាប្រជាជនការដ្ឋាន៧៣ឲ្យរត់មកសង្កាត់ជយោជាង៤០គ្រួសារ ។ ខែ៨ សុខ, ខឹម និង ញ៉ាន បានលើកផែនការធ្វើឲ្យរាំងស្ទះដល់ការដកស្ទូងដោយកៀរកម្លាំងឲ្យរត់មកខាងក្រោយវិញ ។ បន្ទាប់មក សុខ និង ខឹម បានចុះមកមើលកម្លាំងនៅស្រែក្រោម ។

សុខ បានចូលរួមអប់រំ ថុន ជាយុវជនមន្ទីរសន្តិសុខតំបន់៤២ ដោយលើកពីគុណវិបត្តិរបស់បដិវត្តន៍ថាតឹងតែងមិនសេរី បន្ទាប់មកក៏តែងតាំង ថុន ជានិរសារសម្រាប់ទាក់ទងខ្សែរយៈ ។

នៅខែ៩ ឆ្នាំ១៩៧៦ សុខ និងកម្លាំងរបស់ខ្លួន ព្រមទាំង ស៊ុម ប្រធានពាណិជ្ជកម្មតំបន់៤២ បានមកប្រជុំនៅមន្ទីរចាត់ការតំបន់៤២ដោយលើកខ្លឹមសារ៤យ៉ាង ១) សភាពការណ៍លំបាករបស់ប្រជាជនក្រោយពីរំដោះ ២) បំផុសប្រជាជនឲ្យទំនាស់ជាមួយអង្គការអំពីបញ្ហាមិនដោះស្រាយស្បៀងឲ្យប្រជាជនជុំវិញការងារឲ្យក្តៅ កសាងកម្លាំង ប្រមូលអាវុធតាមមន្ទីរដើម្បីត្រៀមទុកពេលផ្ទុះអាវុធ ៣) ណែនាំអំពីការធ្វើសកម្មភាព ៤) ខុទ្ទេសនាមខ្សែឲ្យទាក់ទង ។

បន្ទាប់ពីក្តាប់បានផែនការហើយ ខឹម បានហៅកម្លាំងក្នុងក្រសួងសន្តិសុខមកប្រជុំដើម្បីប្រាប់បន្ថែមមួយចំណុចទៀតគឺរៀបចំអាវុធក្នុងមន្ទីរដើម្បីត្រៀមផ្ទុះនៅខែ៩ ឆ្នាំ១៩៧៦ ។ ខឹម បានចាត់តាំង សុខ និង ឆុន ឲ្យមកទាក់ទងជាមួយ ហុក នៅមន្ទីរឃុំបុសខ្នុរ ដើម្បីក្តាប់សភាពការណ៍និងសួរបញ្ជាក់អំពីការត្រៀមស្រូវ ។ ហុក បានបញ្ជាក់ថាស្រូវដែលត្រូវត្រៀមមាន

ប្រហែល១ពាន់ថាំង ។

នៅខែ១១ ឆ្នាំ១៩៧៦ មូលដ្ឋានបានបញ្ជូនអ្នករដ្ឋការពីរនាក់មកមន្ទីរសន្តិសុខតំបន់៤២ ប៉ុន្តែ សុខ បានដោះលែងអ្នកទាំងពីរនោះ ហើយទុកឲ្យបង្កប់ខ្លួនក្នុងសហករណ៍អូរសោម ឃុំស្វាយទាប ស្រុកចម្ការលើ ក្រោមការឃ្លាំមើលរបស់ឈ្មោះ ហុក ។

នៅឆ្នាំដដែល ខឹម ត្រូវអង្គការដកមកភាគ ចំណែក ឆុន ត្រូវអង្គការចាត់តាំងឲ្យធ្វើជាប្រធានសន្តិសុខតំបន់៤២ ។ នៅខែ១២ សុខ និង ឆុន បានមកជួប ហ៊ាង នៅមន្ទីរជួសជុលដើម្បីសាកសួរអំពីការត្រៀមឡាន ។ ហ៊ាង បានប្រាប់ថា ខ្លួនត្រៀមបានឡានបីគ្រឿង ហើយពីរគ្រឿងទៀតកំពុងតែដំឡើង ។

ឆុន បានចាត់តាំងឲ្យ សុខ មកជួបជាមួយ ឃន ដើម្បីសាកសួរអំពីជីវភាពប្រជាជននិងចំនួនស្រូវនៅការដ្ឋាន ។ ឃន បានរាយការណ៍ថា ប្រជាជនមានជីវភាពធម្មតា ហើយយើងកំពុងតែត្រៀមស្រូវចំនួន១ពាន់ថាំង ។

នៅខែ១ ឆ្នាំ១៩៧៧ សុខ និងកម្លាំង៩នាក់ទៀតបាននាំគ្នាមកប្រជុំនៅមន្ទីរតំបន់អំពីការមិនបានផ្ទុះអាវុធនៅខែ៩ ឆ្នាំ១៩៧៦ គឺបណ្តាលមកពីការរៀបចំកម្លាំងមិនបានល្អ ។ ខ្លឹមសារប្រជុំលើកនេះគឺ ១)ណែនាំឲ្យត្រៀមអាវុធ ស្បៀង និងពង្រឹងកម្លាំងតាមផ្នែកនីមួយៗដើម្បីត្រៀមផ្ទុះអាវុធនៅខែ៤ ឆ្នាំ១៩៧៧ ស្របពេលបុណ្យចូលឆ្នាំខ្មែរ ។

នៅខែ២ ឆ្នាំ១៩៧៧ អង្គការបានចាប់កម្លាំងរបស់ សុខ ជាបន្តបន្ទាប់ធ្វើឲ្យការផ្ទុះអាវុធត្រូវខកខានទៀត ។

ឆុន បានខ្ទេសនាមឈ្មោះ ទៀង លេខាស្រុកចម្ការលើ ដើម្បីដឹកនាំសកម្មភាពបន្ត ។ ទៀង បានរាយការណ៍ថា បច្ចុប្បន្នគ្រប់កន្លែងទាំងអស់កំពុងរៀបចំខ្សែរយៈឡើងវិញហើយដើម្បីត្រៀមផ្ទុះអាវុធជាថ្មី ។

នៅខែ៨ ឆ្នាំ១៩៧៧ ឆុន, ទៀង និង ថន លេខាតំបន់៤៣ នៅទំនប់១មករា បានរៀបចំផែនការត្រៀមកម្លាំងយោធា អាវុធ និងស្បៀង ដើម្បីផ្ទុះអាវុធនៅខែ៩ ឆ្នាំ១៩៧៧ ។ បន្ទាប់ពីទទួលផែនការនេះ សុខ និង ឆុន បានអប់រំយុវជន-យុវនារីនៅក្នុងមន្ទីរដោយឃោសនាបញ្ចិតបញ្ចៀងថាការរៀបចំអាវុធនេះគឺត្រៀមនៅពេលមានខ្មាំងធ្វើសកម្មភាព និងណែនាំយុវជន-យុវនារីមិនឲ្យចេញដើរទៅណារហេតរហូតទេ ។

ការផ្ទុះអាវុធមិនបានធ្វើឡើងតាមការគ្រោងទុកទេ ព្រោះអង្គការចាប់បានកម្លាំងបះបោរជាបន្តបន្ទាប់ ។ ខែតុលា ឆ្នាំ១៩៧៧ សុខ ត្រូវអង្គការចាប់ខ្លួនបញ្ជូនមកមន្ទីរឃុំឃាំង ស-២១ ។ សុខ បានសារភាពអំពីសកម្មភាពរបស់ខ្លួនកន្លងមក និងបញ្ជាក់អំពីសមាសភាពពាក់ព័ន្ធដែលត្រូវអង្គការចាប់ខ្លួនបានជាហូរហែ ។ ចម្លើយសារភាពរបស់ សុខ ត្រូវបានកត់ត្រាដោយយុទ្ធជនសួរចម្លើយឈ្មោះ ជន ឆាយ ។

**សូ ហ្វារីណា**

## សេចក្តីជូនដំណឹងស្តីអំពីការបើកឱ្យប្រើប្រាស់
# ការិយាល័យពត៌មានសាធារណៈ
## របស់មជ្ឈមណ្ឌលឯកសារកម្ពុជា

ការិយាល័យពត៌មានសាធារណៈរបស់មជ្ឈមណ្ឌលឯកសារកម្ពុជានឹងចាប់បើកទ្វារបម្រើសាធារណជនពីថ្ងៃនេះតទៅ ។ ការិយាល័យពត៌មានសាធារណៈគឺជាទីតាំងសម្រាប់អានឯកសារដែលទាក់ទងនឹងរបបខ្មែរក្រហម ទស្សនាខ្សែភាពយន្តឯកសារខ្មែរក្រហម និងចូលរួមកម្មវិធីពិភាក្សាជាមួយអ្នកច្បាប់និងអ្នកសិក្សាស្រាវជ្រាវអំពីប្រធានបទខ្មែរក្រហម យុត្តិធម៌ និងការផ្សះផ្សាបង្រួបបង្រួមជាតិ និងប្រធានបទដទៃទៀត ។ ទិសដៅសំខាន់ពីររបស់ការិយាល័យពត៌មានសាធារណៈគឺ ១)ផ្តល់ពត៌មាននិងអប់រំប្រជាជនខ្មែរអំពីរបបខ្មែរក្រហម ២)ផ្សព្វផ្សាយពត៌មានអំពីដំណើរការអង្គជំនុំជម្រះក្តីអតីតមេដឹកនាំខ្មែរក្រហមជូនសាធារណជនឲ្យបានទូលំទូលាយ ។

ការិយាល័យពត៌មានសាធារណៈរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាមានទីតាំងនៅផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ។ ពត៌មានបន្ថែមស្តីអំពីការិយាល័យពត៌មានសាធារណៈ សូមទាក់ទង **សុខា អ៊ីរ៉ែន** ទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។ សូមអរគុណ ។

# បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរ ស-២១ (គុកទួលស្លែង)

**រៀបចំនិងចងក្រងដោយៈ យិន នាន**

**(តពីលេខមុន)**

| ល.រ | ឈ្មោះ | តួនាទី | កន្លែងយក | ថ្ងៃចូល | ថ្ងៃកម្ទេច |
|---|---|---|---|---|---|
| ១៥៤៨ | ឆេង តិចហាក់ | កម្មករចាស់ | រទេះភ្លើង | ២០-១១-៧៦ | ២៨-១-៧៧ |
| ១៥៤៩ | គន់ ធី | ប្រជាជន | តំបន់២៥ | ១៤-១១-៧៦ | ២៨-១-៧៧ |
| ១៥៥០ | យុត ម៉ារីន ហៅ សំបាត់ | កម្មករថ្មី | រទេះភ្លើង | ២០-១០-៧៦ | ២៨-១-៧៧ |
| ១៥៥១ | ម៉ី ម៉ុច ហៅ ជឿន | យុទ្ធជន | កងពល៣១០ | ១១-១២-៧៦ | ២៨-១-៧៧ |
| ១៥៥២ | នៅ ដុនគុន | គ្រូបង្រៀន | ស្រុកបារាំង | ២៨-១០-៧៦ | ២៨-១-៧៧ |
| ១៥៥៣ | ខែក ស៊ីថា ហៅ សុផាត | កម្មករថ្មី | អគ្គិសនី | ២៨-១០-៧៦ | ២៨-១-៧៧ |
| ១៥៥៤ | ម៉ុក ម៉ុន | កម្មករចាស់ | រទេះភ្លើង | ២៥-១១-៧៦ | ២៨-១-៧៧ |
| ១៥៥៥ | តុប ម៉ុង ហៅ ឆ្នូវឡេង | កម្មករចាស់ | អគ្គិសនីទី២ | ៨-១០-៧៦ | ២៨-១-៧៧ |
| ១៥៥៦ | យុន អ៊ិត | យុទ្ធជន | រទេះភ្លើង | ១១-១២-៧៦ | ២៨-១-៧៧ |
| ១៥៥៧ | កា យា | ប្តី ប៊ិល សឿន | រទេះភ្លើង | ២៨-១០-៧៦ | ២៨-១-៧៧ |
| ១៥៥៨ | កង ណូ | កូន យស់ សារឿន | រទេះភ្លើង | ២៩-១០-៧៦ | ២៨-១-៧៧ |
| ១៥៥៩ | សេង សំអុល | កូន សេង ឌឿន | រទេះភ្លើង | ២៩-១០-៧៦ | ២៨-១-៧៧ |
| ១៥៦០ | វ៉ាន់ រដ្ឋសំកុំ ហៅ កំឡោះ | និស្សិតពេទ្យ | ស្រុកបារាំង | ២៨-១០-៧៦ | ២៨-១-៧៧ |
| ១៥៦១ | គាំ ថេត | និស្សិត | ស្រុកបារាំង | ២៣-១០-៧៦ | ២៨-១-៧៧ |
| ១៥៦២ | អ៊ូ សារុន | កម្មករចាស់ | អគ្គិសនីទី២ | ២៨-១០-៧៦ | ២៨-១-៧៧ |
| ១៥៦៣ | មុម ហឿន | ចោរព្រៃ | ពេជនិល | ១១-១១-៧៦ | ២៨-១-៧៧ |
| ១៥៦៤ | ឌី អាត | ប្រជាជន | កំពង់ឆ្នាំង | ១៣-៩-៧៦ | ២៨-១-៧៧ |
| ១៥៦៥ | ឆើយ ណាវ៉ាង | កម្មករចាស់ | រទេះភ្លើង | ២៨-១០-៧៦ | ២៨-១-៧៧ |
| ១៥៦៦ | វ៉ាន់ សាងសំបាត់ | និស្សិត | ស្រុកបារាំង | ២៨-១០-៧៦ | ២៨-១-៧៧ |
| ១៥៦៧ | កែវ រីម ហៅ រ៉ុម | យុទ្ធជន | កងពល៣១០ | ៤-១២-៧៦ | ២៨-១-៧៧ |
| ១៥៦៨ | អ៊ូ ខុន | កម្មករចាស់ | អគ្គិសនីទី២ | ២៨-១០-៧៦ | ២៨-១-៧៧ |
| ១៥៦៩ | សារី ស៊ីផាន់គីផាត់ | និស្សិត | ស្រុកបារាំង | ២៨-១០-៧៦ | ២៨-១-៧៧ |
| ១៥៧០ | ប្រាក់ ភន ហៅ ឌុន | ចោរព្រៃ | ពេជនិល | ១៤-១១-៧៦ | ២៨-១-៧៧ |
| ១៥៧១ | អ៊ឹម ម៉ុល ហៅ ផល | យុទ្ធជន | កងពល៣១០ | ៤-១២-៧៦ | ២៨-១-៧៧ |
| ១៥៧២ | ជ្រេង ឆ្នួន | ប្តី សៀង ហេង | អគ្គិសនីទី១ | ២៨-១០-៧៦ | ២៨-១-៧៧ |
| ១៥៧៣ | នុត សាន | កម្មករចាស់ | រទេះភ្លើង | ២០-១០-៧៦ | ២៨-១-៧៧ |
| ១៥៧៤ | ឯម សេង | ប្តី ម៉ម មុត | រទេះភ្លើង | ២៨-១០-៧៦ | ២៨-១-៧៧ |
| ១៥៧៥ | សឿ យ៉ាត | ប្រជាជន | តំបន់៣៣ | ៣-៩-៧៦ | ២៨-១-៧៧ |

| | | | | | |
|---|---|---|---|---|---|
| ១៥៧៦ | អ៊ឹម ដុត | ប្ដី ម៉ុម ម៉ៃ | អគ្គិសនីទី១ | ២៨-១០-៧៦ | ២៨-១-៧៧ |
| ១៥៧៧ | រ៉ែត ឈុន | ប្ដី អ៊ុក សារី | រទេះភ្លើង | ២៨-១០-៧៦ | ២៨-១-៧៧ |
| ១៥៧៨ | សេង ស្រេង ហៅ ចិត | យុទ្ធជន | កងពល៣១០ | ៤-១២-៧៦ | ២៨-១-៧៧ |
| ១៥៧៩ | ញឹម សុង ហៅ វ៉ាន់ | យុទ្ធជនចល័ត | តំបន់៣៣ | ៤-១២-៧៦ | ២៨-១-៧៧ |
| ១៥៨០ | ប៊ុន បេងលី | ក្រសួងមហាផ្ទៃ | ស្រុកបារាំង | ២៨-១០-៧៦ | ២៨-១-៧៧ |
| ១៥៨១ | កូវ ផល្លា ហៅ សែម | យុទ្ធជន | កងពល៣១០ | ៤-១២-៧៦ | ២៨-១-៧៧ |
| ១៥៨២ | ជា អន ហៅ រឿន | យុទ្ធជន | កងពល៣១០ | ៤-១២-៧៦ | ២៨-១-៧៧ |
| ១៥៨៣ | ឈួន ឈឿន | ប្ដី ចាន់ សាយ | រទេះភ្លើង | ២៨-១០-៧៦ | ២៨-១-៧៧ |
| ១៥៨៤ | អ៊ុង សុន | ប្ដី ព្រាប រ៉េន | អគ្គិសនីទី២ | ២៨-១០-៧៦ | ២៨-១-៧៧ |
| ១៥៨៥ | វ៉ាន់ យ៉ុម ហៅ សារឿន | អនុក្រុម | កងពល៣១០ | ៥-១២-៧៦ | ២៨-១-៧៧ |
| ១៥៨៦ | ឈុន ស៊ន ហៅ យ៉ាំ | យុទ្ធជន | កងពល៣១០ | ៤-១២-៧៦ | ២៨-១-៧៧ |
| ១៥៨៧ | ឡុង ស៊ីផូ ហៅ ផាន | កម្មករចាស់ | អគ្គិសនីទី១ | ២៨-១០-៧៦ | ២៨-១-៧៧ |
| ១៥៨៨ | យួន សារី | កម្មករថ្មី | រទេះភ្លើង | ២០-១១-៧៦ | ២៨-១-៧៧ |
| ១៥៨៩ | ហេង នេង | និស្សិត | ស្រុកបារាំង | ២៨-១០-៧៦ | ២៨-១-៧៧ |
| ១៥៩០ | ទូច ថុង | ក្រសួងមហាផ្ទៃ | ស្រុកបារាំង | ២៨-១០-៧៦ | ២៨-១-៧៧ |
| ១៥៩១ | កែ ហុន ហៅ បឿន | អនុកងហ | កងពល១៤ | ១៨-១២-៧៦ | ២៨-១-៧៧ |
| ១៥៩២ | គង់ សារ៉ុម | កូន គង់ សុក | រទេះភ្លើង | ២០-១២-៧៦ | ២៨-១-៧៧ |
| ១៥៩៣ | គង់ សុក | កម្មករចាស់ | រទេះភ្លើង | ២០-១២-៧៦ | ២៨-១-៧៧ |
| ១៥៩៤ | ស្រ៊ី ដុប | ប្រជាជន | តំបន់២៥ | ១៤-១១-៧៦ | ២៨-១-៧៧ |
| ១៥៩៥ | យ៉ត ដន | ប្ដី លី រ៉ែត | រទេះភ្លើង | ២៨-១០-៧៦ | ២៨-១-៧៧ |
| ១៥៩៦ | ចាន់ បូរ៉ាន | ប្ដី ថោង យាន | អគ្គិសនីទី១ | ២៨-១០-៧៦ | ២៨-១-៧៧ |
| ១៥៩៧ | អ៊ីញ ជី ហៅ នៅ លីមហេន | យុទ្ធជន | កងពល៣១០ | ៦-១២-៧៦ | ២៨-១-៧៧ |
| ១៥៩៨ | ង៉ុយ ប៉ោសេង | កម្មករចាស់ | រទេះភ្លើង | ២០-១២-៧៦ | ២៨-១-៧៧ |
| ១៥៩៩ | យ៉ា ម៉ាន ហៅ ថាន | យុទ្ធជន | ស-២១យ | ២០-១២-៧៦ | ២៨-១-៧៧ |
| ១៦០០ | ទូច ហ៊ុន | យានដ្ឋាន | ផែកំពង់សោម | ២២-១០-៧៦ | ២៨-១-៧៧ |
| ១៦០១ | កង ប៉ូច | កម្មករថ្មី | រទេះភ្លើង | ២២-១០-៧៦ | ២៨-១-៧៧ |
| ១៦០២ | ស្មាន់ នៃ ហៅ ឆន | យុទ្ធជន | មន្ទីរពិការទួលគោក | ១៣-១០-៧៦ | ២៨-១-៧៧ |
| ១៦០៣ | ហាស់ វេន ហៅ សារិទ្ធ | វរសេនាតូច | កងពល១៧០ | ១៧-៩-៧៦ | ២៨-១-៧៧ |
| ១៦០៤ | មុំ ហ៊ុម | ចោរព្រៃ | ពេជនិល | ១១-១១-៧៦ | ២៨-១-៧៧ |
| ១៦០៥ | សាំង សុន ហៅ សុង | មេពួក | រោងចក្រប្រេងកាត | ១៣-១០-៧៦ | ២៨-១-៧៧ |
| ១៦០៦ | អ៊ុម សារ៉ាត | យានដ្ឋាន | ផែកំពង់សោម | ២២-១០-៧៦ | ២៨-១-៧៧ |
| ១៦០៧ | អ៊ុម ប៊ុនណា | កម្មករចាស់ | រោងចក្រក-២ | ២០-១១-៧៦ | ២៨-១-៧៧ |

**(នៅមានត)**

(ឯកសារខ្មែរក្រហម)

# ដំណើរការកសាងប្រទេសរបស់កម្ពុជាប្រជាធិបតេយ្យ

**១) កិច្ចដំណើរការគមនាគមន៍ដឹកជញ្ជូន**

ក) សំណូមពរៈ ជាទិសតម្រង់

◆ បម្រើការងារចំពោះមុខជាចាំបាច់ ពិសេសគឺផ្លូវដឹកជញ្ជូន កំពង់សោម-ភ្នំពេញ ភ្នំពេញ-កំពង់សោម ហើយផ្លូវទាក់ទង និងភ្នំពេញជាមួយភូមិភាគនានា ។

◆ ខំរៀបចំគមនាគមន៍ឲ្យកាន់តែរីកចម្រើននិងកាន់តែសម័យ ។ សំណូមពរមានទាំងពីរគឺដើម្បីបម្រើសំណូមពរផលិតកម្ម និងខស្សរាហកម្មបម្រើពាណិជ្ជកម្មបម្រើជីវភាពប្រជាជនគ្រប់ផ្នែក និងកិច្ចបម្រើការពារប្រទេស ។

ខ) ដំណើរការជាជំហានៗ

ជំហានដំបូងពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៨២ ។

◆ ជួសជុលគមនាគមន៍ចាស់ដែលចាំបាច់ ដែលខូចខាតក្នុងសង្គ្រាមនិងមធ្យោបាយដឹកជញ្ជូនជាចាំបាច់ ពិសេសភ្នំពេញទៅកំពង់សោម និងពីភ្នំពេញទៅភូមិភាគនានា ។

◆ ត្រូវប្រើផ្លូវទឹកជាសំខាន់ កុំប្រើឡាន ឡានយើងពិបាកដោះស្រាយខាងថាមពលហើយថ្លៃណាស់ ។ បន្ទាប់គឺរទេះភ្លើង ។ ក្រៅពីនេះគឺមធ្យោបាយដឹកជញ្ជូនតាមលក្ខណៈមជ្ឈដ្ឋានដូចជារទេះសេះនិងរទេះគោ ។

◆ តែចម្រើននិងបន្ថែមផ្លូវគមនាគមន៍និងមធ្យោបាយខ្លះទៀត ពិសេសផ្លូវទឹកនិងផ្លូវដែក ។

◆ ប្រើផ្លូវទឹកជាធម្មតាជាអតិបរមា កែលម្អជាបណ្តើរៗ ព្រមជាមួយនេះក៏ត្រូវប្រើប្រាស់ព្រែកជីក តូចធំ ចាស់ថ្មីតាមមូលដ្ឋាននានា ។

◆ ផ្លូវដែកៈ ត្រូវខំជួសជុលផ្លូវដែកភ្នំពេញកំពង់សោម ។ ទន្ទឹមនឹងនេះក៏ត្រូវគិតគូរផ្លូវដែកភ្នំពេញបាត់ដំបងដែរ ។

◆ ផ្លូវគោកៈ គិតគូរផ្លូវជាយុទ្ធសាស្ត្រសំខាន់ៗដំបូងសិននិងដែលចាំបាច់ ។ ទន្ទឹមនឹងនេះផ្លូវតាមមូលដ្ឋាន ។

◆ ជួសជុលនិងពង្រីកមធ្យោបាយម៉ាស៊ីនតាមលទ្ធភាពរបស់យើងជាបណ្តើរៗ ហើយនិងមធ្យោបាយប្រជាជនឲ្យបានអតិបរមាផង ដូចជា ទូក រ៉ឺម៉ក កាណូត រទេះសេះ រទេះគោ កង់ ។ល ។ ទន្ទឹមនឹងនេះមានទិញថ្មីចូលមួយកម្រិតតាមលទ្ធភាព និងការចាំបាច់របស់យើង ។

គ) មាគ៌ាដំណើរការមួយចំនួន

១) យកចិត្តទុកដាក់បញ្ហាបក្សដឹកនាំគ្រប់ផ្នែកនយោបាយ សតិអារម្មណ៍ ចាត់តាំង និងបច្ចេកទេស ។

២) គិតគូរខាងជំហរខ្លួនទុកខ្លួនជាបណ្តើរៗ លើគ្រប់ផ្នែកទាំងអស់នៃគមនាគមន៍ដឹកជញ្ជូន ត្រូវការមកពីក្រៅតែបញ្ហាណាដែលយើងដោះស្រាយពុំទាន់បាន ។

៣) ត្រូវដំណើរការដោយមានផែនការតាមជំហានៗតាមទិសនិងសកម្មភាពរបស់បក្ស កុំធ្វើពាសវាលពាសកាល ។

៤) យកចិត្តទុកដាក់សន្សំសំចៃខាងសម្ភារ ខាងលុយកាក់ ខាងកម្លាំងពលកម្មកម្រិតខ្ពស់បំផុត ។

**២) កិច្ចដំណើរការពាណិជ្ជកម្ម**

ប្រភេទពាណិជ្ជកម្មនៃប្រទេសកម្ពុជាមានពីរគឺ ÷

ទី១) ពាណិជ្ជកម្មរដ្ឋផ្តាច់មុខធ្វើទាំងអស់ និងទី២) ពាណិជ្ជកម្មសហករណ៍ដែលទាក់ទងជាមួយរដ្ឋទាក់ទងនឹងសហករណ៍គ្នាឯងផង ។

ប្រភេទពាណិជ្ជកម្មទាំងពីរនេះមានភារកិច្ចបម្រើផលិតកម្មទាំងកសិកម្មខស្សរាហកម្ម ទាំងសិប្បកម្ម បម្រើជីវភាពប្រជាជន និងបម្រើកិច្ចការពារប្រទេស ។

គោលនយោបាយពាណិជ្ជកម្មក្នុងប្រទេសៈ

ទាក់ទងរវាងក្រុងនិងជនបទ ទាក់ទងរវាងកសិកម្មនិងខស្សរាហកម្ម ។ ទាំងនេះគឺដើម្បីបម្រើផលិតកម្ម បម្រើជីវភាពប្រជាជននិងកិច្ចការពារប្រទេស ។

គោលនយោបាយពាណិជ្ជកម្មក្រៅប្រទេសៈ

ត្រូវចេញអ្វី ហើយចូលអ្វីមកវិញ?

គឺចេញផលិតផលផ្សេងៗរបស់ប្រជាជនរបស់ជាតិយើង ដែលលើសសេចក្តីត្រូវការរបស់យើង ។

ការចាត់តាំងក្របខ័ណ្ឌពាណិជ្ជកម្មៈ

◆ ពាណិជ្ជកម្មកណ្តាលៈ សម្រាប់ទូទាំងប្រទេសមានភារកិច្ចធ្វើពាណិជ្ជកម្មធំក្នុងប្រទេសនិងពាណិជ្ជកម្មក្រៅប្រទេស ។

◆ ពាណិជ្ជកម្មភូមិភាគមានភារកិច្ចចាត់ចែងពាណិជ្ជកម្មគ្រប់ខណ្ឌភូមិភាគ ហើយទាក់ទងជាមួយពាណិជ្ជកម្មកណ្តាល ។

◆ ពាណិជ្ជកម្មតំបន់មានភារកិច្ចចាត់ចែងពាណិជ្ជកម្មក្នុងតំបន់និងទាក់ទងពាណិជ្ជកម្មភូមិភាគ ។

◆ ពាណិជ្ជកម្មស្រុក ឃុំ សហករណ៍ មានភារកិច្ចចាត់ចែងពាណិជ្ជកម្មក្នុងក្របខណ្ឌរបស់ខ្លួនរៀងៗ និងទាក់ទងជាមួយពាណិជ្ជកម្មថ្នាក់លើផ្ទាល់របស់ខ្លួន ។

ក) មាគ៌ាដំណើរការមួយចំនួន

◆ យកចិត្តទុកដាក់បញ្ហាបក្សដឹកនាំគ្រប់ផ្នែកនយោបាយ សតិអារម្មណ៍ ចាត់តាំង និងបច្ចេកទេស ។

◆ យកចិត្តទុកដាក់បំភ្លឺឲ្យជាប់នូវគោលជំហរខ្លួនទីពឹងខ្លួនគ្រប់ផ្នែកនិងសន្សំសំចៃកម្រិតខ្ពស់តាំងពីការថែទាំ ការពារ ប្រើប្រាស់កុំឲ្យខូចអន្តរាយឬខ្ជះខ្ជាយ ។

**កំណត់សំខាន់ៈ** ក្នុងបញ្ហានេះត្រូវមានអង្គការបក្សក្របខ័ណ្ឌនីមួយៗសម្រេចការប្រើប្រាស់ មិនមែនការចាត់ចែងប្រើប្រាស់តាមអង្គការពាណិជ្ជកម្មឬភ្នាក់ងារពាណិជ្ជកម្មនីមួយៗទេ ។

◆ ត្រូវមានផែនការហ្មត់ចត់តាមរយៈកាលនីមួយៗ ។

## ៣) កិច្ចដំណើរការខាងហិរញ្ញវត្ថុ

ក) បញ្ហាប្រាក់រៀលៈ ត្រូវយកចិត្តទុកដាក់ការពារជាអតិបរមា ។

◆ បញ្ហាផ្សាយនិងប្រមូលឲ្យបានល្អ

◆ ធានានូវតម្លៃឲ្យបានល្អ

◆ មានបោះថែមទៀតឲ្យបានល្អតាមការចាំបាច់ ។

ខ) បញ្ហាចាត់តាំងដំណើរប្រាក់រៀល

◆ ត្រូវមានឃ្លាំងទុកដាក់ការពារធានាអះអាងគ្រប់ផ្នែក លួច ប្លន់ ភ្លើងឆេះ សើមទទឹក និងកណ្តៀរស៊ី ។ល ។

មានធនាគារចាត់ចែងប្រាក់រៀលៈ ធនាគារកណ្តាល ភូមិភាគ និងតំបន់ ។

គ) បញ្ហាចំណូលថវិកា

ចំណូលមានពីរប្រភេទៈ ចំណូលផ្នែករដ្ឋ និងចំណូលសហករណ៍ និងគ្រួសារ ។

◆ ត្រូវមានរបបរិភាគទានដែលបានចំណូលមកពីពាណិជ្ជកម្ម ។

◆ ត្រូវឃើញក្របខ័ណ្ឌរួមនិងក្របខ័ណ្ឌដោយឡែក ។

ឃ) ចំណាយៈ

ចំណាយប្រភេទទី១គឺដើម្បីផលិតកម្មគ្រប់ផ្នែក ។ ចំណាយប្រភេទទី២គឺជីវភាពខាងសម្ភារខាងវប្បធម៌សង្គមកិច្ច ។ ចំណាយប្រភេទទី៣គឺការពារប្រទេស ។ និងចំណាយប្រភេទទី៤គឺកិច្ចការផ្សេងៗដូចជាកិច្ចការបរទេស កិច្ចការអគាររដ្ឋបាល ។ល ។

**កំណត់សំខាន់ៈ** សូមលើកគម្រោងដូចតទៅៈ

◆ ប្រភេទចំណាយខាងផលិតកម្ម មាន៦០ភាគរយ

◆ ប្រភេទចំណាយទី២ ១៥ភាគរយ

◆ ប្រភេទចំណាយទី៣ ១៥-២០ភាគរយ

◆ កិច្ចការផ្សេងៗ ៥ភាគរយ

ង) ប្រាក់បំណាច់និងប្រាក់ខែ

ក្នុងជួរបដិវត្តជាតិភូមិភាគ យុទ្ធជនយុទ្ធនារីគ្រប់ប្រភេទ ។ ពលករគ្រប់ប្រភេទក្រៅជួរ ។

ច) មាគ៌ាដំណើរការមួយចំនួន

◆ ត្រូវយកចិត្តទុកដាក់បញ្ហាបក្សដឹកនាំគ្រប់ផ្នែក នយោបាយ សតិអារម្មណ៍ ចាត់តាំង និងបច្ចេកទេស ។ សំខាន់គឺបំពាក់ឲ្យគេជ្រួតជ្រាបនៅលើមាគ៌ាហិរញ្ញវត្ថុរបស់បក្សគ្រប់ផ្នែក ព្រោះបញ្ហានេះជាបញ្ហាថ្មីដែលបក្សយើងត្រូវគ្រប់គ្រងនិងចាត់ចែងក្នុងឋានៈជាអ្នកកាន់កាប់រដ្ឋអំណាចប្រទេសជាតិទាំងស្រុង ត្រូវសន្សំសំចៃឲ្យដល់កម្រិតខ្ពស់បំផុត ទាំងរដ្ឋ ទាំងសហករណ៍ ទាំងគ្រួសារ ។

◆ ពង្រឹងគោលជំហរខ្លួនទីពឹងខ្លួនឲ្យខ្ពស់បំផុតដោយអនុវត្តនយោបាយចំណូលនិងចំណាយផ្អែកលើផលិតកម្មនិងពាណិជ្ជកម្មរបស់យើង កុំគិតគូរសុំតែបរទេស ។

## ៤) កិច្ចដំណើរការសុខាភិបាលសង្គមកិច្ច

បញ្ហាដែលត្រូវគិតគូរគឺៈ

ក) មានសម្លៀកបំពាក់ ស៊ីចុក មុងកន្ទេល ផ្ទះសម្បែង អនាម័យ សុខាភិបាលជាពេទ្យហ្មគ្រប់ប្រភេទ ថ្នាំសង្កូវ ហើយជាពិសេសកម្ចាត់ជំងឺគ្រុនចាញ់និងជំងឺសង្គមផ្សេងៗ ។

ខ) ចិញ្ចឹមទារកនិងកុមារ

ការចិញ្ចឹមថែបំប៉នយុទ្ធជនពិការគ្រប់ប្រភេទ គ្រួសារយុទ្ធជនកម្មាភិបាលដែលរងគ្រោះក្នុងការតស៊ូបដិវត្ត កសាងសង្គមបដិវត្ត ហើយដែលគ្មានលទ្ធភាពខាងកម្លាំងកាយប្រកបជីវភាពធម្មតាបាន ។

គ) សំណូមពរជាទិសតម្រង់

សំណូមពរចំពោះមុខគឺ ធ្វើឲ្យជីវភាពប្រជាជនបានដោះស្រាយជាបឋមលើបញ្ហាចាំបាច់ដូចជា ស្បៀងអាហារ អង្ករអំបិល បញ្ហាស្លៀកពាក់គ្រប់ដណ្តប់ ផ្ទះសម្បែង ថ្នាំសង្កូវ ពេទ្យហ្ម ។ល ។ ទន្ទឹមនឹងនេះក៏ត្រូវរៀបចំផ្នែកសង្គមកិច្ចនិងសុខាភិបាលរបស់បក្សជាខ្សែសង្វាក់តាមប្រភេទបញ្ហាដូចបែងចែកខាងលើ ដើម្បីបម្រើជីវភាពប្រជាជនឲ្យកាន់តែល្អនិងបម្រើកិច្ចការពារប្រទេសកាន់តែល្អ ។

ឃ) ដំណើរការជាជំហានៗៈ ដំបូងត្រូវគិតគូរ ÷

◆ រៀបចំនិងដំណើរការឲ្យបានជាបឋមនូវប្រភេទកិច្ចការសង្គមកិច្ចនិងសុខាភិបាលទាំងពីរដូចបានចែងខាងលើ ។

◆ រៀបចំជាបឋមនូវមណ្ឌលទារកនិងកុមាររបស់ប្រជាជនកម្មករ សហករណ៍ ព្រមទាំងមន្ទីរ ដើម្បីរំដោះកម្លាំងផលិតកម្មឲ្យបានច្រើនជាអតិបរមាដើម្បីងាយស្រួលក្នុងការថែរក្សាសុខភាពទារកនិងកុមារ ។

◆ រៀបចំមណ្ឌលយុទ្ធជនពិការនិងគ្រួសារអ្នកបដិវត្តដែលអស់លទ្ធភាពធ្វើការធម្មតាបាន ។

ង) មាគ៌ាដំណើរការ

◆ គិតគូរអំពីបញ្ហាបក្សដឹកនាំគ្រប់ផ្នែក ។ នយោបាយសតិអារម្មណ៍ ចាត់តាំងបច្ចេកទេស ។

◆ ផ្អែកលើមជ្ឈដ្ឋាននិងផ្អែកលើរដ្ឋផងដើម្បីដំណើរការខាងសង្គមនិងសុខាភិបាល ។

◆ យកចិត្តទុកដាក់វណ្ណៈមូលដ្ឋានជាសំខាន់ ។ ទន្ទឹមនឹងនេះក៏ត្រូវគិតគូរខាងវណ្ណៈផ្សេងៗដែរ ។

◆ ត្រូវខ្នះខ្នែងបត្តម្ភខ្លួនកម្រិតខ្ពស់លើគ្រប់ផ្នែក ។ ក្រៅពីនេះត្រូវឆ្លៀតរៀនពិសោធន៍ល្អពីបរទេសដែលសមស្របនឹងយើង ។

◆ ជួរកម្មាភិបាល ភ្នាក់ងារសង្គមកិច្ច សុខាភិបាល ត្រូវធានាក្នុងការបម្រើបដិវត្តនិងប្រជាជនឲ្យបានល្អដាច់ខាត ។

## ៥) កិច្ចដំណើរការអប់រំសិក្សាធិការវិទ្យាសាស្ត្រ

សំណូមពរជាទិសតម្រង់ៈ

◆ បម្រើសេចក្តីត្រូវការចំពោះមុខ ។

◆ រៀបចំជាបណ្តើរៗជាខ្សែសង្វាក់ទៅថ្ងៃមុខដើម្បីបម្រើបដិវត្ត ខាងផលិតកម្ម កសិកម្ម ឧស្សាហកម្ម ខាងជីវភាពប្រជាជន និងកិច្ចការប្រទេស ។

◆ យកចិត្តទុកដាក់ផ្នែកជាសំខាន់មាន វប្បធម៌ អប់រំមហាជន សិក្សាធិការ និងផ្នែកវិទ្យាសាស្ត្របច្ចេកទេស ។

ក) ដំណើរការជាជំហានៗ

◆ ផ្នែកវប្បធម៌ៈ ត្រូវបន្តបោសសម្អាតវប្បធម៌ចាស់របស់ចក្រពត្តិអាណានិគម សក្តិភូមិ នាយទុន ។ល ។ ម្យ៉ាងទៀតត្រូវថែរក្សាវប្បធម៌ជាតិនិងប្រជាជនដែលជាសម្បត្តិរបស់ប្រជាជននិងប្រពៃណីរបស់ប្រជាជនយើង ។ ទន្ទឹមនឹងនេះត្រូវកសាងថ្មីជាបណ្តើរៗតាមជំហរនិងលក្ខណៈបដិវត្តរបស់យើង គឺបម្រើផលិតកម្មថ្មី បម្រើជីវភាពរបស់ប្រជាជនបម្រើកិច្ចការពារប្រទេស ។

◆ ផ្នែកអប់រំមហាជនៈ អប់រំប្រជាជនខាងទស្សនៈ ខាងនយោបាយ ខាងគោលជំហរ សំដៅកសាងលោកទស្សនៈបដិវត្តថ្មី បំពាក់បំប៉ននយោបាយបដិវត្ត លោកទស្សនៈចាស់ផ្សេងៗបំពាក់បំប៉នគោលជំហរនិងទស្សនៈព្រមទាំងស្មារតីពលកម្មបង្កបង្កើនផល បំពាក់បំប៉នគោលជំហរទស្សនៈកសាងជីវភាពថ្មីបដិវត្តនិងស្អាតស្អំសំបូរសប្បាយក្នុងសង្គមស្មើភាពគ្មានជិះជាន់គ្នា ។

◆ ផ្នែកសិក្សាធិការៈ រៀបចំការសិក្សាឲ្យកុមារាកុមារីប្រជាពលរដ្ឋចាស់ក្មេង យុវជនយុវនារីឲ្យចេះអានចេះសរសេរចេះគិតគូរលេខធំៗឡើងទៅ ។ ក្នុងរយៈកាលជាជំហានដំបូងកម្ចាត់ការមិនចេះអក្សរជាទូទៅឲ្យបានអាចធ្វើពី៨០ ទៅ៩០ភាគរយ ។ ការសិក្សាត្រូវលៃលកកុំឲ្យដាច់ពីពលកម្មបង្កបង្កើន

ផល ។

## ៦) ផ្នែកវិទ្យាសាស្ត្របច្ចេកទេស

ត្រូវគិតគូរជាបណ្តើរៗ ខាងវិទ្យាសាស្ត្រនិងបច្ចេកទេស តាមទិសពីរយ៉ាងៈ ទិសទី១គឺផ្នែកវិទ្យាសាស្ត្របច្ចេកទេសតាមលក្ខណៈមហាជន ទិសទី២ វិទ្យាសាស្ត្របច្ចេកទេសមានលក្ខណៈស្រាវជ្រាវនិងរិះរក ។ ទាំងអស់នេះគឺដើម្បីបម្រើផលិតកម្ម បម្រើសុខាភិបាល បម្រើកិច្ចការពារប្រទេស ។ គ្រប់ផ្នែកទាំងអស់ គឺយើងដើរជើងពីរ ។

ក) មាគ៌ាដំណើរការមួយចំនួន

◆ យកចិត្តទុកដាក់អំពីបញ្ហាបក្សដឹកនាំគ្រប់ផ្នែក នយោបាយសតិអារម្មណ៍ ចាត់តាំង បច្ចេកទេស ។ បញ្ហានេះមានតួនាទីសំខាន់បំផុត ។ ផ្នែកវប្បធម៌នេះហាក់ដូចជាតូច ប៉ុន្តែបញ្ហាវាធំ ពីព្រោះវាជាបញ្ហាសង្គម វាទាក់ទងដល់នយោបាយដល់គោលជំហរសតិអារម្មណ៍ ។

◆ ត្រូវយកចិត្តទុកដាក់ជំហរវណ្ណៈកម្មកររបស់បក្ស ការតស៊ូវណ្ណៈរបស់បក្សក្នុងកិច្ចដំណើរការផ្នែកវប្បធម៌ អប់រំ សិក្សាធិការ និងវិទ្យាសាស្ត្របច្ចេកទេស ។

◆ ត្រូវឈរលើបទពិសោធន៍សម្បូររបស់មហាជនយើង ក្នុងចលនាបដិវត្តផ្ទើសង្គ្រាមរំដោះជាតិ ក្នុងការធ្វើបដិវត្តប្រជាជាតិក្នុងការបង្កបង្កើនផល ។ល ។

◆ កុំចម្លងពីបរទេសព្រោះវាគ្រោះថ្នាក់ណាស់ ។

ខ) សំណួមពរជាទិសតម្រង់ចំពោះមុខ

បន្តកម្ចាត់និងបោសសម្អាតវប្បធម៌ចាស់ពុករលួយ អ្វីដែលមិនបដិវត្ត ។

ប្រជាជនជម្លៀស ទោះបីវណ្ណភាពល្អក៏ដោយ ក៏នាំយកវប្បធម៌ពុករលួយទៅតាមដែរ ពិសេសមើលងាយពលកម្ម លើកតម្លៃបញ្ហាមាសពេជ្រ ឡាន ។ ម្យ៉ាងទៀត វប្បធម៌ជាតិរបស់ប្រជាជនដែលចម្រើនត្រូវរក្សាទុក ។

### បញ្ហាផ្សេងៗ

១) ចំពោះបញ្ហាលោកសង្ឃដែលនៅក្នុងតំបន់ខ្មាំងកាន់កាប់បណ្តោះអាសន្ន ត្រូវសឹកចេញទាំងអស់ ពីព្រោះប្រភេទនេះទទួលឥទ្ធិពលពីខ្មាំងច្រើន ចំពោះលោកសង្ឃណាដែលជាប់ក្នុងចលនាតស៊ូបដិវត្តហើយរស់នៅក្នុងតំបន់ខ្មាំងក៏ត្រូវសឹកចេញដែរដើម្បីលត់ដំជំហរក្នុងការធ្វើពលកម្ម ។

២) ប្រជាជនជម្លៀសក្នុងដំណើរការជំហានដំបូងចំនួនបីឆ្នាំ ទោះបីជាមានវណ្ណភាពណាក៏ដោយ ក៏ក្លាយទៅវណ្ណភាពកម្មករកសិកររបស់បក្សក្នុងរយៈពេល៣ឆ្នាំនេះទាំងអស់ ៧៥ - ៧៨ ។

៣) របបសហករណ៍ផលិតកម្មចាត់ជាកម្លាំង៤ប្រភេទ ។

កម្លាំងទី១ៈ ពី១៥ឆ្នាំទៅលើ ១ឆ្នាំចំនួន១៥ថាំង ។

កម្លាំងទី២ៈ ពី១៥ចុះមក១២ឆ្នាំ ១ឆ្នាំចំន១៣ថាំង ។

កម្លាំងទី៣ៈ ពី១២ឆ្នាំចុះមក១០ឆ្នាំ ១ឆ្នាំចំនួន១០ថាំង ។

កម្លាំងទី៤ៈ ពី១០ចុះមក៨ឆ្នាំរហូតដល់ក្រោម ស៊ីចំនួន៨ថាំង១ឆ្នាំ ។

**(ឯកសារ D ២១៩១០)**

## ស្តាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតឲ្យមានកម្មវិធីអានអត្ថបទទស្សនាវដ្តីស្វែងរកការពិតដែលចាក់ផ្សាយរៀងរាល់ថ្ងៃពុធនិងព្រហស្បតិ៍ វេលាម៉ោង៣ៈ៣០ - ៣ៈ៤៥នាទី តាមរយៈវិទ្យុ FM១០២ MHz របស់មណ្ឌលព័ត៌មានស្ត្រីកម្ពុជា ។

មជ្ឈមណ្ឌលក៏បានបង្កើតកម្មវិធីដូចគ្នានេះផ្សាយតាមស្ថានីយ៍វិទ្យុ FM៩៣.២៥MHz ខេត្តកំពតជារៀងរាល់ថ្ងៃ នៅម៉ោង៧ - ៧ៈ៣០នាទីព្រឹក និងម៉ោង៧ - ៧ៈ៣០នាទីល្ងាចនិងស្ថានីយ៍វិទ្យុ FM៩៩MHz ខេត្តព្រះវិហារ នៅម៉ោង៧ - ៧ៈ៣០នាទីព្រឹក និងម៉ោង៦ៈ៣០ - ៧នាទីល្ងាច ។

នៅក្នុងពេលដ៏ខ្លីខាងមុខនេះ មជ្ឈមណ្ឌលឯកសារកម្ពុជានឹងផ្សាយកម្មវិធីដូចគ្នានេះនៅគ្រប់បណ្តាស្ថានីយ៍វិទ្យុខេត្តនៃព្រះរាជាណាចក្រកម្ពុជា ។

យើងខ្ញុំសង្ឃឹមថា កម្មវិធីនេះនឹងចូលរួមចំណែកក្នុងការផ្តល់ឱកាសឲ្យប្រជាជនកម្ពុជាស្វែងយល់អំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមនិងទប់ស្កាត់ការកើតមានឡើងវិញនៃរបបនេះ ។

**ផាត រចនា និង លី សុផល**



ការគាស់ឆ្អឹងរបស់ជនរងគ្រោះនៅក្នុងរបបខ្មែរក្រហម

# ស្តាប់រឿងរ៉ាវរបស់ជនរងគ្រោះជ័យចំណាស់ម្នាក់ទៀត

អំឡុងទសវត្សរ៍ឆ្នាំ១៩៤០ មុី សុឹម ហៅ ងើះ ជានារីម្នាក់ដែលមានសម្រស់ល្អបណ្តាច់នៅក្នុងភូមិព្រៃគុយ ។ គាត់ជាកូនទី៣ក្នុងចំណោមបងប្អូនស្រី៣នាក់ប្រុស៥នាក់ ។ ឪពុករបស់គាត់ឈ្មោះ ជុំ ជាអាចារ្យកាន់ពេលា ចំណែកម្តាយឈ្មោះ ម៉ែន ជាស្ត្រីមេផ្ទះ ។ រាល់ពេលទៅកាន់ពេលាការបុក៏ធ្វើដំណើរទៅទីណាក្តី លោកតាជុំ តែងតែនាំ យាយម៉ែន ទៅជាមួយមិនដែលខាន ។ ក្រៅពីធ្វើជាអាចារ្យកាន់ពេលា លោកតាជុំ ចេះដេញឧបករណ៍សាដៀវយ៉ាងពីរោះ និងបានចូលវាំងប្រគំថ្វាយព្រះករុណាជាញឹកញាប់ ព្រមទាំងបានទទួលការសរសើរនិងរង្វាន់ខាន់ខោជាច្រើន ។ ជីតារបស់ ងើះ ឈ្មោះ អែម គឺជាមន្ត្រីធំនៅក្នុងព្រះបរមរាជវាំង ។ គាត់មានភាពប៉ិនប្រសប់ខាងគូរគំនូរ ហើយគំនូរនៅលើជញ្ជាំងសាលារាជសេនាគឺជាស្នាដៃរបស់គាត់ ។ តាអែម ឧស្សាហ៍នាំចៅៗទៅលេងក្នុងវាំងជារឿយៗពេលមានពិធីបុណ្យជាតិធំៗដូចជាបុណ្យចូលឆ្នាំ បុណ្យអុំទូក អកអំបុក បុណ្យតាំងតុជាដើម ។

រំឭករឿងរ៉ាវកាលពីពេលនោះ យាយងើះ ដែលឥឡូវនេះមានអាយុ៧៣ឆ្នាំ បង្ហាញភាពរីករាយហាក់ដូចជារឿងរ៉ាវកាលនោះទើបនឹងកើតឡើងថ្មីៗ ។ គាត់និយាយទាំងញញឹមញញែមថា “ជីតាខ្ញុំនាំទៅលេងនៅភ្នំពេញញឹកណាស់ ឃើញគ្រប់មុខលោកអើយ តាំងពីព្រះខ័ន តាំងពីគ្រឿងមាសគ្រឿងប្រាក់ ដើរលុកលុយក្នុងវាំងគ្រប់កន្លែងសប្បាយណាស់ ។ ខ្ញុំទៅលេងតាយសុីវជាមួយគេស្រីៗក្រចកដៃវែងៗស្អាតៗណាស់ ឲ្យតែមានបុណ្យទានអ៊ីចឹងស្តេចបើកឲ្យលេងហើយ ។ ខ្ញុំទៅមើលស្មៀនឈិននិងនាងស្រទុំច្រៀងអាយ៉ៃនៅផ្សារកណ្តាល ពីរោះណាស់ ហើយបានទៅលេងភ្នំបូកគោម្តង ។ ជីតាខ្ញុំគាត់ឃើញខ្ញុំស្អាតគាត់ចង់បាន គាត់សុំតែឪខ្ញុំអត់ឲ្យ ។ ខ្ញុំសក់រួញអង្កាដី បានមុខបានរាង បានសាច់ អ្នកណាក៏ស្រលាញ់ដែរ ។ មួយភូមិព្រៃគុយហ្នឹងខ្ញុំស្អាតជាប់គេ ។”

ឪពុករបស់ ងើះ បានទុកដាក់ឲ្យ ងើះ មានប្តីជាបុរសចំណាស់ម្នាក់ឈ្មោះ ឃួន ។ ទាំងពីរនាក់ប្តីប្រពន្ធប្រកបរបរធ្វើស្រែចម្ការនិងដាំម្លូលក់ ។ ងើះ មានកូនបួននាក់ ប៉ុន្តែកូនប្រុសច្បងពីរនាក់បានស្លាប់តាំងពីតូចៗ នៅសល់តែកូនស្រីពីរនាក់ឈ្មោះ មិន ចាន់ និង មិន រ៉េត ។ នៅឆ្នាំ១៩៦៩ ឃួន បានស្លាប់ដោយជំងឺក្អករ៉ាំរ៉ៃនិងឫសដូងបាត ។ មិន ចាន់ អាយុ៥៣ឆ្នាំ បានរំឭកថា “កាលហ្នឹងឪខ្ញុំគាត់មានជំងឺធ្ងន់ស្រាប់ទៅហើយ ដល់ចោរចូលលួចគោអស់រលីង គាត់ស្ទុតពេកនិយាយលែងរួច រំលងបានតែពីរថ្ងៃគាត់ស្លាប់” ។

ក្នុងអំឡុងឆ្នាំ១៩៧១ ងើះ បាននាំកូនស្រីទាំងពីរនាក់ភៀសខ្លួនទៅទីរួមខេត្តតាកែវ ដើម្បីគេចពីការវាយប្រហាររបស់ខ្មែរក្រហម ចំណែកឪពុកម្តាយរបស់គាត់គឺ តាជុំ និង យាយម៉ែន មិនព្រមភៀសខ្លួនទេ ។ គាត់និយាយថា គាត់សុខចិត្តស្លាប់នៅលើផ្ទះ ។ តាជុំ បានចងក្បួនគម្ពីរនិងសាស្ត្រាស្លឹករឹតជាបាច់ឲ្យ ងើះ ទូលយកទៅដាក់នៅវត្តដើម្បីកុំឲ្យគម្ពីរទាំងនោះបាត់បង់ ។ មួយសប្តាហ៍ក្រោយមក យាយងើះ ក៏នាំកូនត្រឡប់មកភូមិវិញ ឃើញសាកសពនៅរាយប៉ាយជះក្លិនស្អុយអសោចពេញភូមិ ប៉ុន្តែឪពុកម្តាយរបស់គាត់នៅរស់នៅលើផ្ទះដដែល ។ ក្នុងឆ្នាំ១៩៧២ តាជុំ បានទុកដាក់ ងើះ ឲ្យមានប្តីជាលើកទី២ជាបុរសម្នាក់ឈ្មោះ ផន ជាអតីតសង្ឃរាជវត្តអង្គតាសោមដែលបានសឹកទៅធ្វើទាហានលន់ណុល ។ ផន ជាមនុស្សល្អមានអត្តចរិតស្លូតបូតនិងស្រលាញ់កូនដើមដូចជាកូនបង្កើតរបស់ខ្លួន ប៉ុន្តែ ចាន់ មិនពេញចិត្តហើយស្អប់ឪពុកចុងជាខ្លាំង ។

ប្រហែលមួយឆ្នាំក្រោយមក (ឆ្នាំ១៩៧៣) ឪពុករបស់ ងើះ បានស្លាប់ដោយជំងឺរាក ។ នៅចុងឆ្នាំដដែលនេះ ទាហានលន់ណុលបានកៀរប្រជាជននៅក្នុងឃុំលាយបូរទៅទីរួមខេត្តតាកែវ ក្នុងនោះក្រុមគ្រួសាររបស់ ងើះ ក៏ត្រូវកៀរទៅដែរ ។ នៅទីរួមខេត្តតាកែវ កូនស្រីច្បងឈ្មោះ មិន ចាន់ បានរៀបការជាមួយទាហានលន់ណុលម្នាក់ឈ្មោះ ទេព ចន ហើយក៏ដើរតាមប្តីទៅគ្រប់សមរភូមិ ។ ចំណែកប្តីរបស់ ងើះ ឈ្មោះ ផន ក៏ជាប់ដៃ

នៅក្នុងសមរភូមិប្រយុទ្ធមិនបាននៅថែរក្សាក្រុមគ្រួសារឡើយ ដូច្នេះ ង៉េះ នៅជាមួយម្តាយនិងកូនស្រីពៅ ។

ប្រហែលនៅឆ្នាំ១៩៧៤ ង៉េះ ត្រូវអំបែងគ្រាប់កាំភ្លើងធំបំផ្លិចកន្លងបណ្តាលឲ្យគាត់ជួបនឹងការលំបាករហូតដល់សព្វថ្ងៃ ។ យាយ ង៉េះ ពិពណ៌នាថា “កាលហ្នឹងថ្ងៃពេញបូណ៌គេបាញ់ផ្កាចំណាំផ្លោងខ្លាំងណាស់ ។ ខ្ញុំអង្គុយក្នុងត្រង់សេត្រាំទឹក ចុះត្រង់សេដក់ទឹកភ្លៀង ខ្ញុំចេះតែទ្រាំទៅ រស់ទៅហើយមិនគួរណាព្រឹកឡើងវាផ្លោងមកត្រូវ ។ រាល់ដងតែពេលបាញ់អីចឹងទាហានគេប្រាប់ហើយ ថាន៎អ៊ុំអ្ហាចូលត្រង់សេទៅ ។ ដល់លែងបាញ់ហើយម៉ោង៧ព្រឹកចេញមក ស្រាប់តែវាផ្លោងមកប៉ក់ ក្ចាំង! ដួលខ្ពោក ។


យាយ ង៉េះ និង មិន ចាន់ ព្រមទាំងចៅទួត (ថតឆ្នាំ២០០៤)

ពួកទាហានបិទថ្នាំបិទអីឲ្យ សែងទៅពេទ្យធំ ៗ” ទាហានលន់ណុលបានបញ្ជូន ង៉េះ ទៅសង្គ្រោះនៅមន្ទីរពេទ្យខេត្ត ប៉ុន្តែគ្រូពេទ្យមិនមានលទ្ធភាពវះយកអំបែងគ្រាប់ចេញពីឆ្អឹងខ្នងរបស់គាត់ឡើយ គឺគ្រាន់តែព្យាបាលមុខរបួសឲ្យសះតែប៉ុណ្ណោះ ។ នៅពេលមុខរបួសសះស្ងៀយហើយ ទាហានលន់ណុលក៏បញ្ជូន ង៉េះ តាមឧទ្ធម្ភាគចក្រមកមន្ទីរពេទ្យរុស្ស៊ីនៅទីក្រុងភ្នំពេញដើម្បីទទួលការវះកាត់យកអំបែងគ្រាប់ចេញ ។ បន្ទាប់ពីបានពិនិត្យ ថតឆ្លុះមុខរបួស និងបន្ទាប់ពីមានការពិភាក្សារវាងគ្រូពេទ្យជំនាញនៅក្នុងមន្ទីរពេទ្យរួចមក គ្រូពេទ្យបានប្រាប់ ង៉េះ ថា អំបែងគ្រាប់នេះបានបុកចំសរសៃសំខាន់មួយដែលនាំឈាមទៅចិញ្ចឹមរាងកាយផ្នែកខាងស្តាំ ប្រសិនបើវះយកអំបែងគ្រាប់នេះចេញគាត់នឹងត្រូវពិការមួយចំហៀងខ្លួនខាងស្តាំ ។ គ្រូពេទ្យបានឲ្យយោបល់ថាគួរកុំវះប្រសើរជាង ព្រោះកាលៈទេសៈនេះប្រទេសកំពុងតែមានសង្គ្រាម ម្យ៉ាងគាត់គ្មានកូនចៅច្រើននៅថែរក្សាផង បើវះហើយពិការនោះពិតជាលំបាកមិនខាន ។ ដូច្នេះ ង៉េះ ក៏រស់នៅជាមួយនឹងអំបែងគ្រាប់ដែលដោតជាប់នឹងឆ្អឹងខ្នងរបស់គាត់អស់រយៈពេលជាងសាមសិបឆ្នាំមកហើយ ។ អំបែងគ្រាប់នេះបានធ្វើឲ្យគាត់ពិបាកក្នុងខ្លួនជាខ្លាំង ។ ង៉េះ មិនអាចកម្រើកខ្លួនបានស្រួលទេ ព្រោះឆ្អឹងខ្នងត្រូវខ្ទាស់ ឈឺចុកចាប់គ្រប់សរសៃ និងរងាញ័ររញាក់ស្ទើរតែរៀងរាល់យប់ថ្ងៃ ។ ពេលថ្ងៃ ង៉េះ អង្គុយអាំងកម្តៅថ្ងៃ ហើយពេលយប់គាត់សម្រាន្តនៅលើគ្រែឫស្សីក្រោមផ្ទះដោយដុតភ្លើងពីក្រោមតិចៗដើម្បីឲ្យកក់ក្តៅ ។

ក្រុមគ្រួសាររបស់ ង៉េះ ស្នាក់នៅទីរួមខេត្តតាកែវរហូតដល់ពេលខ្មែរក្រហមគ្រប់គ្រងអំណាចទូទាំងប្រទេស ទើបវិលត្រឡប់មកភូមិកំណើតវិញ ប៉ុន្តែត្រូវខ្មែរក្រហមចាត់ទុកជាប្រជាជន១៧មេសា ហើយមិនអនុញ្ញាតឲ្យរស់នៅក្នុងភូមិកំណើតទេ គឺជម្លៀសទៅកន្លែងផ្សេង ។ ចាន់ដែលជាកូនច្បងបានទៅរស់នៅជាមួយប្តីនៅសហករណ៍អន្លង់ទៀនក្នុងឃុំព្រៃផ្គរ ។ ប្តីរបស់ ង៉េះ ឈ្មោះ ផន ធ្វើការនៅកងចល័តបុរសចំណាស់ហើយមិនដែលបានមកជួបមុខប្រពន្ធកូនទេ ។ កូនស្រីពៅឈ្មោះ មិន រ៉េត ធ្វើការនៅកងចល័តស្រួច ចំណែក ង៉េះ ត្រូវខ្មែរក្រហមចាត់តាំងឲ្យមើលកុមារ៥នាក់ ។ ម្តាយរបស់ ង៉េះ ស្លាប់នៅចុងឆ្នាំ១៩៧៥ ។

ក្រោយមកប្រធានសហករណ៍ផ្លាស់ ង៉េះ ឲ្យទៅស្ទូងស្រូវនិងរែកដី ទោះជាដឹងថាខ្នងរបស់គាត់ឈឺមិនអាចធ្វើការធ្ងន់បានក៏ដោយ ។ ង៉េះ មិនហ៊ានតវ៉ានឹងបញ្ជារបស់អង្គការទេ គាត់សុខ

ចិត្តទៅធ្វើការទាំងឈឺទាំងជា ។ ប្រជាជនមូលដ្ឋានដែលដឹងថា ង៉េះ មានរបួសនៅនឹងភ្លៅខ្លួន ក៏មានចិត្តអាណិតអាសូរគាត់ មិនហ៊ានកាប់ដីដាក់ឲ្យគាត់រែកច្រើនទេ គឺដាក់ដីឲ្យតែបន្តិចៗ ប៉ុណ្ណោះ ។ ប្រហែលចុងឆ្នាំ១៩៧៦ ប្តីរបស់ ង៉េះ ដែលនៅកង ចល័ត បានស្លាប់ដោយជំងឺ ។ ង៉េះ បានដឹងអំពីមរណភាពរបស់ ប្តីគាត់ដោយសារប្រជាជនមូលដ្ឋានលួចខ្សឹបប្រាប់ ។

នៅអន្លង់ទៀន ទេព ចន ខិតខំលាក់ប្រវត្តិរូបមិនហ៊ានឲ្យ នរណាដឹងថាខ្លួនធ្លាប់ធ្វើទាហានទេ ព្រោះខ្លាចក្រែងអង្គការយក ទៅសម្លាប់ ។ នៅទីបំផុត ចន នៅតែចៀសមិនផុតពីត្រូវអង្គការ យកទៅសម្លាប់ដដែល ។ នៅខែ១០ ឆ្នាំ១៩៧៨ ឈ្លបបានមក ហៅ ចន ទៅដាំដូងនៅស្រុកលើ ហើយ ចន ក៏បាត់ខ្លួនរហូត ។ ប្រជាជនទាំងអស់នៅក្នុងសហករណ៍ គ្មាននរណាម្នាក់ដឹងថាស្រុក លើនោះនៅឯណាទេ ហើយក៏មិនដឹងថាចម្ការដូងដែលត្រូវដាំ នោះនៅកន្លែងណាដែរ ដឹងតែថា អ្នកដែលត្រូវអង្គការហៅ ទៅដាំដូងគឺមិនដែលឃើញវិលត្រឡប់មកវិញឡើយ ។ ប្រជាជន ខ្សឹបខ្សៀវគ្នាថា អ្នកដែលហៅទៅដាំដូងនៅស្រុកលើគឺយក ទៅសម្លាប់ ។ ដូច្នេះ ចាន់ ក៏សន្និដ្ឋានថា ប្តីរបស់គាត់ត្រូវខ្មែរ ក្រហមសម្លាប់បាត់ទៅហើយ ។ បន្ទាប់ពីប្តីត្រូវខ្មែរក្រហមយក ទៅ ចាន់ ខំធ្វើការងារកាន់តែខ្លាំងជាងមុខ និងខំយកចិត្តយកថ្លើម ប្តីប្រពន្ធប្រធានឈ្លប ដើម្បីកុំឲ្យគាត់យកទៅសម្លាប់ទៀត ។ ចាន់ និយាយថា ពេលនោះគាត់ភិតភ័យជាប់ជាប្រចាំ ។ ថ្ងៃមួយនៅចុង ឆ្នាំ១៩៧៨ ប្រធានឈ្លបបាននាំ ចាន់ ទៅមើលមន្ទីរសន្តិសុខ មួយនៅក្នុងឃុំព្រៃផ្តៅ ដែលនៅទីនោះមានលលាដ៍ក្បាលខ្មោច ច្រើនរាប់មិនអស់ត្រូវបានដោតខ្សែតម្រៀបជាជួរៗ នៅក្នុងអគារ ធំវែងមួយ ។ ចាន់ និយាយថា ពេលដែលឃើញលលាដ៍ក្បាល ខ្មោចទាំងនោះ គាត់តក់ស្លុតត្រជាក់ដៃត្រជាក់ជើងស្ទើរតែស្ទះ ដង្ហើម ហើយក៏កាន់តែខ្លាចរអាប្រធានឈ្លបនោះថែមទៀត ។ ចាន់ គិតថា ក្នុងចំណោមលលាដ៍ក្បាលទាំងនោះប្រហែលជាអាច មានលលាដ៍ក្បាលប្តីរបស់គាត់ដែរហើយមើលទៅ ។ ទោះជា ចាន់ ខំប្រឹងធ្វើការនិងខំយកចិត្តយកថ្លើមប្រធានឈ្លបយ៉ាងណា ក៏ដោយ ក៏គាត់នៅតែត្រូវអង្គការយកទៅដាក់នៅមន្ទីរប្រមូល ផ្តុំស្ត្រីមេម៉ាយដែរ ។ ជារៀងរាល់ថ្ងៃ ចាន់ ឃើញស្ត្រីមេម៉ាយជា ច្រើននាក់ត្រូវដឹកចូលមកក្នុងមន្ទីរ ហើយក៏ឃើញស្ត្រីមេម៉ាយ ជាច្រើនត្រូវដឹកចេញពីមន្ទីរវិញដែរ ។ ចាន់ និយាយថា “អ្នកដែល ត្រូវដឹកចេញគឺសុទ្ធតែយកទៅសម្លាប់ហើយ” ។ ចាន់ មានសំណាង បានរស់រានមានជីវិត ដោយសាររបបខ្មែរក្រហមត្រូវដួលរលំ នៅខែមករាឆ្នាំ១៩៧៩ ហើយគាត់ក៏រត់ចេញពីមន្ទីរប្រមូលផ្តុំ ត្រឡប់មករកម្តាយនៅភូមិកំណើតវិញ ។

ចំណែកនៅសហករណ៍ដែល ង៉េះ រស់នៅ ប្អូនប្រុស២នាក់ របស់គាត់និងប្អូនថ្លៃម្នាក់ឈ្មោះ កង ណុប ក៏ត្រូវខ្មែរក្រហមហៅ ទៅដាំដើមដូងនៅឯស្រុកលើនៅចុងឆ្នាំ១៩៧៨ដែរ ហើយអ្នក ទាំងបីក៏បាត់ដំណឹងឈឹងតាំងពីពេលនោះមក ។ ក្រោយមកមិនយូរ ប៉ុន្មាន ប្រធានសហករណ៍ឈ្មោះ យ៉ាប បានខ្សឹបប្រាប់ ជុំ អ៊ីក ដែលជាប្អូនស្រីរបស់ ង៉េះ និងជាប្រពន្ធរបស់ កង ណុប ថា ណុប ត្រូវឈ្លបចាប់វះពោះយកថ្លើមប្រមាត់ទាំងរស់ដោយសារតែបាន តដៃជាមួយឈ្លបក្នុងបំណងដោះខ្លួនរត់ ។

ក្រោយការដួលរលំនៃរបបខ្មែរក្រហម ក្រុមគ្រួសាររបស់ ង៉េះ បានវិលមកភូមិកំណើតវិញ រស់នៅត្រង់ទីដីដែលជាកេរ ពីឪពុករបស់គាត់ ។ ចាន់ បានរៀបការម្តងទៀត និងមាន កូនប្រុសម្នាក់ ប៉ុន្តែអាពាហ៍ពិពាហ៍ក្រោយនេះស្ថិតស្ថេរមិនបាន ប៉ុន្មានឆ្នាំផងក៏បែកបាក់ទៅវិញ ។ សព្វថ្ងៃ កូនប្រុសនិងកូនប្រសា របស់ ចាន់ ធ្វើជាកម្មកររោងចក្រនៅទីក្រុងភ្នំពេញ ។ ចំណែក ចាន់ រស់នៅឯភូមិកំណើតជាមួយម្តាយនិងចៅស្រីម្នាក់ដែលមាន អាយុ៣ឆ្នាំ ។ បច្ចុប្បន្ននេះ យាយង៉េះ មានអាយុ៧៣ឆ្នាំហើយ សុខភាពរបស់គាត់ទ្រុឌទ្រោមជាខ្លាំង ដោយសារច្រើនឆ្នាំចុង ក្រោយនេះអំបែងគ្រាប់នោះមានច្រែះហើយធ្វើទុក្ខក្នុងខ្លួនគាត់ កាន់តែខ្លាំងជាងមុន ។

យាយង៉េះ និង មិន ចាន់ មិនចងគំនុំចំពោះខ្មែរក្រហមទេ ព្រោះគាត់គិតថានេះគឺកម្មរបស់គាត់ដែលកសាងមិនល្អពីជាតិមុន មក ។ គាត់មិនចង់សងសឹកចំពោះខ្មែរក្រហមទេ ប៉ុន្តែគាត់ជឿ ជាក់ថា អ្នកទាំងនោះនឹងទទួលកម្មពៀររបស់ខ្លួននៅពេលដែល ស្លាប់ទៅ ។ រាល់ថ្ងៃនេះគាត់សុំតែសេចក្តីសុខប៉ុណ្ណោះ ហើយគាត់ បន់ស្រន់កុំឲ្យរបបបែបនោះវិលត្រឡប់មកវិញជាថ្មីម្តងទៀត ។

**សាន់ កល្យាណ**

# មានទោសដោយសារប្តីជាប់ទោស

រូបថតសខ្មៅមួយកំណាត់ខ្លួនរបស់នារីម្នាក់ដែលពាក់អាវពណ៌ខ្មៅ សក់ខ្លី មានសរសេរអក្សរពណ៌ក្រហមពីក្រោមថា ឈុំ រីម ស្ថិតនៅលាយឡំជាមួយនឹងរូបថតអ្នកទោសជាច្រើនទៀត ដែលតាំងនៅលើជញ្ជាំងអគារនៅក្នុងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ។ នោះគឺជារូបថតដែល រីម បានថតពេលដែលអង្គការចាប់គាត់យកទៅឃុំឃាំងនិងសួរចម្លើយនៅគុកទួលស្លែង ។ ឈ្មោះពិតរបស់ ឈុំ រីម គឺ ឈុំ ធឿន ។


ឈុំ រីម នៅគុកទួលស្លែង ឆ្នាំ១៩៧៦

បើតាមការចងចាំរបស់ រីម គាត់បានមកដល់គុកទួលស្លែងជាលើកដំបូងនៅឆ្នាំ១៩៧៦ ជាមួយនឹងកូនស្រីរបស់គាត់ដែលទើបតែមានអាយុបីខែ ។ រីម ត្រូវអង្គការចាប់បញ្ជូនមកពីកន្លែងបង្កបង្កើនផលកៀនឃ្លាំងជាមួយនឹងប្រពន្ធរបស់កម្មាភិបាលខ្មែរក្រហម៥នាក់ទៀតដែលអង្គការចោទថាជាក្រុមក្បត់ ។ ពាក់កណ្តាលអធ្រាត្ររថយន្តដែលបិទដំបូលជិតដោយក្រណាត់ខ្មៅបានដឹកស្ត្រីទាំង៦នាក់មកឈប់នៅកន្លែងមួយដែល រីម អះអាងថាជាគុកទួលស្លែង ។ រីម ត្រូវសន្តិសុខបណ្តើរចុះពីឡានចូលទៅជាន់ផ្ទាល់ដីនៃអគារមួយ ។ នារី៥នាក់ដែលមកជាមួយគាត់ត្រូវបញ្ជូនទៅកន្លែងផ្សេង ។ តាមរយៈពន្លឺភ្លើងអំពូលម៉ែត្រដែលដាក់នៅតាមផ្លូវដើរនៃអគារ រីម បានឃើញគំនរខោអាវនិងស្បែកជើងនៅក្នុងបន្ទប់ដែលស្ថិតនៅសងខាងនោះ ។ មួយសន្ទុះក្រោយមក សន្តិសុខបាននាំ រីម ចូលទៅក្នុងបន្ទប់មួយដែលធុំក្លិនស្អុយស្ទើរតែទ្រាំមិនបាន ។ សន្តិសុខបានបញ្ជាឲ្យគាត់អង្គុយនៅលើគ្រែមួយទល់មុខអ្នកសួរចម្លើយដែលកំពុងអង្គុយនៅលើកៅអី និងមានតុមួយនៅកណ្តាល ។ អ្នកសួរចម្លើយបានទាញមេសោនៅលើតុមកវាយព្ស្បូរផ្សូងមុននឹងចាប់ផ្តើមសួរសំណួរអំពីប្រវត្តិរូបផ្ទាល់ខ្លួននិងសកម្មភាពមុននិងក្រោយពេលចូលបដិវត្តន៍របស់ រីម ។ បន្ទាប់មកអ្នកសួរចម្លើយចាប់ផ្តើមសួរអំពីប្រវត្តិរូបនិងសកម្មភាពក្បត់របស់ប្តីគាត់ ។ រីម ឆ្លើយថាគាត់មិនបានដឹងអំពីប្រវត្តិនិងសកម្មភាពក្បត់របស់ប្តីគាត់ទេ ព្រោះគាត់ទើបតែរៀបការតាមបញ្ជារបស់អង្គការបានរយៈពេលមួយឆ្នាំប៉ុណ្ណោះ ហើយមុនពេលរៀបការគាត់មិនដែលបានស្គាល់ប្តីរបស់គាត់ទាល់តែសោះ ។ ដោយមិនទាន់ទទួលនូវចម្លើយដែលខ្លួនចង់បាន អ្នកសួរចម្លើយបានសួរនូវសំណួរដដែលៗ ហើយសម្លុតគំរាមកំហែងថានឹងធ្វើទារុណកម្មបើ រីម នៅតែចចេសមិនព្រមសារភាព ។

ប្តីរបស់ រីម ឈ្មោះ ថោង ហ៊ិន មាននាទីជាប្រធានគ (នៅក្នុងប្រវត្តិរូបបានសរសេរថា ថោង ហ៊ិន មានមុខងារជាប្រធានអនុសេនាធំ) ។ ហ៊ិន ត្រូវអង្គការចាប់ខ្លួនបន្ទាប់ពីបានទទួលលិខិតអញ្ជើញមួយច្បាប់ពីសេនាធិការឲ្យទៅប្រជុំរៀនសូត្រនិងធ្វើទស្សនកិច្ចនៅកំពង់សោម ។ ៦ថ្ងៃក្រោយពេលដែល ហ៊ិន ចេញទៅប្រជុំ រីម រួមទាំងប្រពន្ធរបស់កម្មាភិបាលប្រមាណ ៣០នាក់ទៀត ត្រូវអង្គការហៅទៅប្រជុំប្រាប់ថា ប្តីរបស់គាត់ជាសមាសភាពមិនល្អ មានផែនការក្បត់ជាតិ ចង់លក់ទឹកដីឲ្យបរទេស ។ រីម តក់ស្លុតយ៉ាងខ្លាំងពេលដែលឮដូច្នេះ ។ ចិត្តមួយនឹកអាណិត ហ៊ិន មិនដឹងជាសុខទុក្ខយ៉ាងណា ចិត្តមួយទៀតនឹកភ័យអំពីវាសនារបស់ខ្លួនឯងនិងកូនស្រីដែលនៅតូច ។ រំលងបានបីថ្ងៃ ខ្មែរក្រហមបានមកប្រាប់ រីម ទាំងយប់ថា អង្គការចាត់តាំងឲ្យទៅនៅសហករណ៍ ។ រីម ត្រូវបង្ខំឲ្យចាកចេញទាំងប្រញាប់ប្រញាល់ដោយមិនបានយកអីវ៉ាន់ទៅជាមួយផងទេ សូម្បីតែទឹកដោះគោសម្រាប់កូនបៅក៏មិនបានយកទៅដែរ ។ រីម គ្មានឱកាសនឹងប្រកែកតវ៉ាឬសួរដេញដោលរកហេតុផលអ្វីទាំងអស់ព្រោះខ្មែរក្រហមបានបញ្ជាថា «បើអង្គការចាត់តាំងថ្មើរម៉ោង

ត្រូវតែអនុវត្តតាមថ្នើរនោះ កុំចចេសពេក មិនបាច់រៀបចំអីវ៉ាន់អីច្រើនទេ នៅកន្លែងអង្គការមិនខ្វះទេ បើអង្គការហៅទៅ អង្គការចេះដោះស្រាយឲ្យហើយ» ។ ពេលឃើញអាកប្បកិរិយា និងសម្ដីបែបនេះ រីម កាន់តែភិតភ័យ គិតថាខ្លួនពិតជាស្លាប់នៅពេលនេះហើយ ។

ក្រោយពេលសួរចម្លើយជាច្រើនដងក្នុងយប់នោះ សន្តិសុខបាននាំ រីម មកថតរូប ។ មុនពេលថត រីម ត្រូវបានសន្តិសុខដកហូតយកអីវ៉ាន់ទាំងអស់ដែលមាននៅជាប់នឹងខ្លួន សូម្បីតែក្រមានិងស្បែកជើងដែលកំពុងពាក់ក៏ត្រូវដកហូតដែរ ។ បន្ទាប់មក រីម ត្រូវបានយកឃុំទុកក្នុងបន្ទប់មួយតែឯង ដោយពុំមានដាក់ខ្នោះដៃជើងទេ ។ ស្អែកឡើង អ្នកសួរចម្លើយបានមកសួរគាត់ម្ដងទៀតប៉ុន្តែគឺជាមនុស្សផ្សេងពីយប់ម្សិល ។ នៅយប់ទីពីរនេះ រីម ត្រូវសួរចម្លើយបួនដងមុននឹងត្រូវបញ្ជូនទៅគុកព្រៃស ។ រីម ត្រូវអ្នកសួរចម្លើយសម្ភួតសួរសំណួរដដែលៗដូចយប់មុន ហើយគាត់នៅតែឆ្លើយដដែលៗថាគាត់មិនដឹងរឿងរបស់ ហ៊ុន ទេ ។ រីម ត្រូវអ្នកសួរចម្លើយទះកំផ្លៀងមួយដៃដួលផ្ទប់នឹងជញ្ជាំង ហើយចាប់សក់បោកក្បាលរបស់គាត់នឹងជញ្ជាំងបន្ថែមទៀតរាល់ពេលដែលគាត់ឆ្លើយមិនដឹងទាំងគំរោះគំរើយ ។ ក្រោយពេលសួរចម្លើយរួចហើយ ម៉ោង១២យប់ រីម និងកូនស្រី ត្រូវបានបញ្ជូនចេញទៅព្រៃសជាមួយនារីម្នាក់ទៀត ។ រីម មិនបានដឹងអំពីវាសនារបស់នារីផ្សេងទៀតដែលមកជាមួយគាត់ទេ ។



ឈុំ រីម ឆ្នាំ២០០៤

ពេលមកដល់ព្រៃសមិនទាន់បានសម្រាកបាត់ហត់ផង រីម ត្រូវប្រធានកងបញ្ជាឲ្យចេញទៅធ្វើការនៅម៉ោង៣ព្រឹកដូចអ្នកទោសដទៃទៀតដែរ ។ ជារៀងរាល់ថ្ងៃ រីម សែនធុញទ្រាន់នឹងសំឡេងកញ្ចែដាស់ឲ្យក្រោកតម្រង់ជួរទៅកាប់ដី ជីកប្រឡាយស្ទូងស្រូវ តាំងពីម៉ោង៣ភ្លឺរហូតដល់ម៉ោង៨យប់ ពេលខ្លះរហូតដល់ម៉ោង១២អធ្រាត្រក៏មាន ។ ជួនកាលមានផែនការក្ដៅ អ្នកទោសទាំងអស់ត្រូវចេញទៅធ្វើការតាំងពីម៉ោង១ភ្លឺ ហើយលទ្ធផលនៃ ការខំប្រឹងប្រែងធ្វើការនេះ អ្នកទោសបានទទួលត្រឹមតែបបររាវៗប៉ុន្មានវែកដែលហូបមិនឆ្អែតក្នុងមួយថ្ងៃពីរពេលតែប៉ុណ្ណោះ ។ រីម និយាយថា «ធ្វើការងារធ្ងន់ធ្ងរ ហើយទទួលបានត្រឹមតែបបរមួយហុត ម្នាក់ៗហេវហត់អស់កម្លាំងស្ទើរតែស្លាប់ទៅហើយ» ។ ដោយសារតែភាពស្រេកឃ្លាន គ្រប់គ្នាអាចហូបបានទាំងអស់នូវអ្វីដែលបានប្រទះឃើញហើយអាចដាក់ចូលក្នុងមាត់បាន ទោះជាដឹងថាការធ្វើរបៀបនេះនឹងត្រូវទទួលទោសឬក៏បណ្ដាលឲ្យមានជំងឺក៏ដោយ ។ នៅវាលស្រែ ប្រសិនបើមានកណ្ដូបឬក៏ក្ដាមមួយវារកាត់មុខ អ្នកទោសរត់ប្រញាប់ដណ្ដើមគ្នាចាប់យកមកហូបទាំងឆៅ ។ មានអ្នកទោសខ្លះត្រូវឈ្លបខ្មែរក្រហមចាប់គក់រហូតទាល់តែចេញក្អួត ឬក៏ចាប់ខ្ទេះយកក្ដាមឬត្រីចេញពីមាត់វិញ ដោយចោទថាហូបអត់មានរបៀបរបប មិនខំប្រឹងធ្វើការ ។ អ្នកទោសម្នាក់ត្រូវមេកងទះកំផ្លៀងធ្លាក់ពីលើរហាត់ទឹក ពេលដែលគាត់កំពុងតែជាន់រហាត់ទឹកហើយរើសបានត្រីស្លាតងាប់មួយយកមកទំពា ។ ប្រសិនបើអ្នកទោសណាម្នាក់អវត្តមាននៅកន្លែងធ្វើការជាច្រើនដង ប្រាកដជាបាត់ខ្លួនមិនខាន ។ សូត្រ ត្រូវបញ្ជូនមកព្រៃសបន្ទាប់ពីគាត់វះកាត់ពោះវៀនដុះខ្នែងរួចបានមួយយប់ ។ រីម មិនបានស្គាល់ សូត្រ ច្បាស់ទេ គ្រាន់តែដឹងថា សូត្រ ត្រូវអង្គការបញ្ជូនមកពីក្រសួងណាមួយ ។ ស្អែកឡើង អ្នកគ្រប់គ្រងបានមកហៅ សូត្រ ឲ្យទៅធ្វើការនៅម៉ោង៣ព្រឹក ។ សូត្រ បានអង្វរករមេកងថាខ្លួនមិនអាចធ្វើការបានទេ ព្រោះនៅឈឺមុខរបួសដែលទើបនឹងវះកាត់រួច ប៉ុន្តែមេកងមិនបានស្ដាប់ហេតុផលរបស់គាត់ឡើយ ហើយបានចាប់ទាញគាត់ទម្លាក់ពីលើផ្ទះធ្លាក់តាមជណ្ដើរកម្ពស់១២កាំ ធ្លាយមុខរបួសស្លាប់ភ្លាមមួយរំពេច ។

ពេលវេលាទាំងអស់របស់ រីម ត្រូវចំណាយទៅលើការងារ ។ រីម គ្មានពេលនៅមើលថែរក្សាកូនស្រីតូចរបស់គាត់ដែលទើបតែមានអាយុ៣ខែនោះទេ ។ មុនពេលចេញទៅធ្វើការ រីម ត្រូវយកកូនទៅដាក់នៅកន្លែងមើលក្មេងដែលមានយាយចាស់ម្នាក់ជាអ្នកមើលក្មេងៗ៦០នាក់ ។ នៅព្រៃសបានមួយខែ សុខភាពកូនស្រី

របស់ រីម មានសភាពកាន់តែទ្រុឌទ្រោមទៅៗ មុខរបស់នាង ស្លេកស្លាំង ថ្ពាល់ផត ខ្លួនប្រាណស្គមល្វិតល្វៃព្រោះគ្មានអ្វីហូប ។ រីម គ្មានទឹកដោះឲ្យកូនបៅទេ មួយថ្ងៃៗកូនរបស់គាត់បានទទួល ត្រឹមតែទឹកបបររាវៗ ឬជួនកាលទឹកឆៅប៉ុន្មានតំណក់ដែលគាត់ បន្តក់ឲ្យមុននិងក្រោយពេលទៅធ្វើការតែប៉ុណ្ណោះ ។ អាហារ ទាំងនេះមិនអាចទ្រទ្រង់រាងកាយរបស់ទារកបានយូរឡើយ នៅទីបំផុតកូនស្រីរបស់គាត់ក៏ស្លាប់ដោយសារកង្វះអាហារ ។ រីម នៅតែនឹកឃើញជានិច្ចនូវរាងកាយដ៏តូចរបស់កូនស្រីដែលស្លាប់ នៅលើដៃគាត់ ។ អារម្មណ៍ភ័យខ្លាចដែលមាននៅក្នុងចិត្តរបស់ រីម តាំងពីត្រូវខ្មែរក្រហមបង្ខំឲ្យចេញពីកន្លែងបង្កបង្កើនផល នៅតែស្ថិតនៅក្នុងខួរក្បាលរបស់គាត់ជានិច្ច ។ រីម តែងតែគិតថា គាត់ត្រូវបញ្ជូនទៅស្លាប់នៅរាល់ពេលដែលអង្គការបញ្ជូនគាត់ ចេញពីកន្លែងមួយទៅកន្លែងមួយទៀត ។ នៅព្រៃស រីម បាន ឃើញអ្នកទោសត្រូវបញ្ជូនចេញទាំងឡានៗ ហើយអ្នកទោស ថ្មីៗជាច្រើននាក់ក៏ត្រូវបញ្ជូនចូលមកស្ទើរតែរាល់ថ្ងៃ ។ រីម និយាយថា «អ្នកដែលគេបញ្ជូនចេញគឺយកទៅសម្លាប់ហើយ ខ្ញុំរស់នៅទីនោះរង់ចាំតែថ្ងៃស្លាប់ប៉ុណ្ណោះ ថ្ងៃនេះគេ ថ្ងៃក្រោយ យើង ទោះបីជាយើងចង់ចៀសក៏ចៀសមិនផុតដែរ» ។

រីម ជាប់នៅគុកព្រៃសរហូតដល់ឆ្នាំ១៩៧៩ ពេលដែលកងទ័ព វៀតណាមចូលមកដល់ទីក្រុងភ្នំពេញ ។ ពេលនោះកម្មាភិបាល ខ្មែរក្រហមនិងអ្នកទោសទាំងអស់បានរត់គេចចេញទៅរស់នៅក្នុង ព្រៃនិងនៅតាមព្រំដែន ។ រីម បានធ្វើដំណើរដោយថ្មើរជើង ចេញពីភ្នំពេញរហូតដល់ខេត្តកោះកុង ដើរកាត់វាលចូលព្រៃឡើង ភ្នំ រស់នៅដោយលាក់ខ្លួនពួនអាត្មា រត់ចុះរត់ឡើង គ្មានទីជម្រក ពិតប្រាកដ គ្មានអាហារហូបគ្រប់គ្រាន់ គ្មានថ្នាំពេទ្យព្យាបាល ជំងឺ ។

នៅឆ្នាំ១៩៨០ រីម បានសម្រេចចិត្តវិលត្រឡប់មកស្រុក កំណើតដែលស្ថិតនៅស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ។ បច្ចុប្បន្ន រីម មានអាយុ៥២ឆ្នាំ មានកូនចំនួន៥នាក់ក្រោយពេលដែល គាត់រៀបការជាមួយនឹង សឹត សាន ។ រីម ឧស្សាហ៍និយាយ ពីប្រវត្តិរបស់គាត់នៅក្នុងរបបខ្មែរក្រហមប្រាប់បងប្អូនកូនចៅនិង អ្នកភូមិបានដឹង ហើយគាត់និងក្រុមគ្រួសារតែងតែចូលទៅ ទស្សនាសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែងរាល់ ពេលដែលគាត់ធ្វើដំណើរមកទីក្រុងភ្នំពេញដើម្បីទៅមើលភ័ស្តុតាង ដែលបន្សល់ទុកពីរបបខ្មែរក្រហម ជាពិសេសគឺរូបថតរបស់គាត់ ដែលដាក់តាំងនៅទីនោះ ។ រីម បានសុំរូបថតរបស់គាត់ពី សារមន្ទីរ ប៉ុន្តែអ្នកគ្រប់គ្រងនៅទីនោះមិនអនុញ្ញាត ។

ពេលដែលរំឭកទៅដល់រឿងអតីតកាល រីម និយាយថា «ខ្ញុំសោកស្តាយណាស់ដែលជឿតាមការឃោសនារបស់គេ ខិតខំតស៊ូបម្រើបដិវត្តន៍តាំងពីឆ្នាំ១៩៧៣ មិនខ្លាចហត់នឿយ រត់កាត់គ្រាប់កាត់ភ្លៀងដើម្បីរំដោះជាតិមាតុភូមិ សង្ឃឹមថា នឹងបានរស់នៅសុខស្រួលទាំងអស់គ្នា តែលទ្ធផលចុងក្រោយ បានត្រឹមតែចូលគុកដោយមិនដឹងខ្លួនថាខ្លួនឯងប្រព្រឹត្តអ្វីខុស សោះ» ។ ឥឡូវនេះ រីម ចង់ឃើញតុលាការយុត្តិធម៌និងត្រឹមត្រូវ មួយកើតឡើង ដើម្បីកាត់សេចក្តីមេដឹកនាំខ្មែរក្រហមធំៗដែល បានធ្វើខុសចំពោះប្រជាជនកម្ពុជារាប់លាននាក់ ព្រោះអ្នក ដែលប្រព្រឹត្តខុសគួរតែទទួលទោសឲ្យស័ក្តិសមនឹងកំហុសដែល បានធ្វើ គឺមិនមែនចាប់អ្នកដែលគ្មានកំហុសយកទៅដាក់គុកធ្វើ ទារុណកម្មដើម្បីជម្រិតយកចម្លើយនិងសម្លាប់ចោលដូចនៅក្នុង របបខ្មែរក្រហមនោះទេ ។

**អឿ រតនា**

## រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជា គ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាននិងកំពុងសរសេរ អត្ថបទឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមក មជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោមៈ

ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥
ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨
Email: dccam@online.com.kh
Home page: www.dccam.org

# ភូមិមេម៉ាយ

ប្រជាជនភាគច្រើននៅក្នុងភូមិព្រះឱង្ការគឺជាស្ត្រីមេម៉ាយ ព្រោះប្តីៗរបស់គាត់ត្រូវខ្មែរក្រហមយកទៅសម្លាប់ចោលអស់ហើយ ។ បច្ចុប្បន្ននេះ ស្ត្រីមេម៉ាយទាំងនោះកំពុងតែទន្ទឹងរង់ចាំថ្ងៃដែលសាលាក្តីដើម្បីជំនុំជម្រះទោសមេដឹកនាំជាន់ខ្ពស់នៃរបបខ្មែរក្រហម លេចជារូបរាងឡើង ។ នៅពេលដែលឱកាសនោះមកដល់ ស្ត្រីមេម៉ាយនៅភូមិព្រះឱង្ការចង់សួរទៅអតីតមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមទាំងនោះថា តើហេតុអ្វីបានជាអង្គការយកប្តីនិងកូនប្រុសរបស់គាត់ទៅសម្លាប់ ។

ភូមិព្រះឱង្ការស្ថិតនៅក្នុងឃុំម្រោម ស្រុកអង្គរជ័យ ចម្ងាយប្រមាណ៧គីឡូម៉ែត្រខាងជើងផ្សារតានី ។ ពីឆ្នាំ១៩៧០ដល់ឆ្នាំ១៩៧២ ភូមិព្រះឱង្ការស្ថិតក្រោមការគ្រប់គ្រងរបស់របបសាធារណរដ្ឋខ្មែរ ។ នៅពេលខ្មែរក្រហមវាយដណ្តើមកាន់កាប់ស្រុកអង្គរជ័យបានទាំងស្រុងនៅចុងឆ្នាំ១៩៧២ រដ្ឋអំណាចខ្មែរក្រហមបានចាត់ចែងរៀបចំប្រជាជនដែលរស់នៅតាមភូមិតាមឃុំឲ្យចូលរួមធ្វើជាសហករណ៍ (គឺរស់នៅតាមផ្ទះរៀងៗខ្លួន ប៉ុន្តែធ្វើការរួមនិងហូបរួម) ។ នៅពេលនោះ អង្គការក៏ចាប់ផ្តើមបែងចែកប្រជាជនទៅតាមវណ្ណៈផ្សេងៗពីគ្នា ដូចជា អ្នកមាន អ្នកក្រ អ្នករស់នៅតំបន់ខ្មាំង និងអ្នករស់នៅតំបន់ដែលគ្រប់គ្រងដោយខ្មែរក្រហម ។

អ្នកដែលរស់ក្នុងភូមិព្រះឱង្ការត្រូវចាត់ទុកថាជាប្រជាជនរស់នៅតំបន់ខ្មាំង ។ នៅមុនរបបខ្មែរក្រហម អ្នកភូមិព្រះឱង្ការភាគច្រើនមានជីវភាពធូរធារ និងសម្បូរទៅដោយផ្ទះធំៗសង់អំពីឈើប្រក់ក្បឿង ។ ដោយសារភូមិព្រះឱង្ការមានលក្ខណៈអំណោយផលពីធម្មជាតិ ប្រជាជនអាចធ្វើស្រែចម្ការនិងដាំដំណាំហូបផ្លែផ្សេងៗដូចជា ម្រេច ដូង ស្វា ក្រូច ស្វាយ មាក់ប្រេង មាក់ប្រាង ខ្នុរ ទៀប ម្នាស់ ចេក ជាដើម ។ ក៏ប៉ុន្តែចាប់តាំងពីខ្មែរក្រហមចូលមកកាន់កាប់ ភូមិព្រះឱង្ការលែងមានភាពរស់រវើកដូចមុនទៀតហើយ ។ អង្គការបានចេញបញ្ជាឲ្យប្រជាជនបោះបង់ចោលទាំងអស់នូវរបរធ្វើចម្ការនិងដាំដំណាំផ្សេងៗ ហើយឲ្យប្រជាជនធ្វើស្រែតែមួយរ៉ាងប៉ុណ្ណោះ ។ ចំណែកផ្ទះសម្បែងរបស់ប្រជាជនដែលសង់អំពីឈើប្រក់ក្បឿងនិងមានទំហំធំៗនោះ ត្រូវអង្គការបញ្ជាឲ្យរុះរើយកឈើទៅធ្វើស្ពាននិងធ្វើអុសដុត ។

បើតាមសម្តីរបស់អ្នកភូមិព្រះឱង្ការបានឲ្យដឹងថា គណៈស្រុកអង្គរជ័យឈ្មោះ យន់ និង បូ ។ គណៈឃុំម្រោមឈ្មោះ ហុន និង ឆុន ជាមនុស្សមកពីចម្ងាយ គឺមកពីស្រុក១០៥ (ស្រុកត្រាំកក់ ខេត្តតាកែវ) ។ យន់, បូរ, ហុន និង ឆុន បានកោះហៅប្រជាជននៅភូមិព្រះឱង្ការទៅប្រជុំជាញឹកញាប់អំពីផែនការលើកទំនប់ជីកប្រឡាយនិងធ្វើស្រែដើម្បីកសាងប្រទេសជាតិឲ្យបានរីកចម្រើនឆាប់រហ័ស ។ នៅពេលប្រជុំម្តងៗ រដ្ឋអំណាចខ្មែរក្រហមនិយាយជាញយៗថា បើអ្នកណាដើរមិនទាន់កង់ប្រវត្តិសាស្ត្រទេ កង់ប្រវត្តិសាស្ត្រនឹងវិលកិនហើយ ប៉ះដៃដាច់ដៃ ប៉ះជើងដាច់ជើង និយាយរួមគឺប៉ះចំកន្លែងណាដាច់កន្លែងហ្នឹង ។ អ្នកភូមិព្រះឱង្ការបានឲ្យដឹងទៀតថា ពេលដែលរដ្ឋអំណាចខ្មែរក្រហមកោះហៅប្រជាជនឲ្យចូលរួមប្រជុំម្តងៗ ពួកគេតែងតែកត់ឈ្មោះនិងកត់សម្គាល់ភិនភាគរបស់ប្រជាជនម្នាក់ៗជានិច្ច ។

នៅឆ្នាំ១៩៧៤ ខ្មែរក្រហមបានចាប់ផ្តើមចាប់ប្រជាជនដែលរស់នៅតាមភូមិស្រុកយកទៅសម្លាប់ដោយចោទពីបទឧក្រិដ្ឋផ្សេងៗដូចជាសេ.អ៊ី.អារបស់អាមេរិកាំង ជាមេដប់ខ្លួន ឬមេហាសិបខ្លួនជាដើម ។ ក្នុងរយៈពេលប្រមាណតែ២ខែប៉ុណ្ណោះ បុរសៗដែលរស់នៅក្នុងភូមិព្រះឱង្ការត្រូវអង្គការចាប់យកទៅសម្លាប់ចោលស្ទើរតែទាំងអស់ ។ បុរសៗដែលបានរួចផុតពីការសម្លាប់របស់ខ្មែរក្រហមមានចំនួនតែ១៦នាក់ប៉ុណ្ណោះ គឺឈ្មោះ ឡូយ, អ៊ី, ត្រាន់, ឈួន, នូវ, ក្រិច, គ្រៀង, កប, អាន, ញ៉ី, ង៉ន, អាយ, ដាន, ដូ, ដុន និង ថាំង» ។

យាយ ប៉ាន់ គ្រីស អាយុ៨០ឆ្នាំ, អ៊ឹស្រី ឈូក សើន អាយុ៦៦ឆ្នាំ និងមីង ហង់ គ្រិន អាយុ៥២ឆ្នាំ ជាស្ត្រីមេម៉ាយដោយសារខ្មែរក្រហម ។ ប្តីរបស់ យាយគ្រីស ឈ្មោះ ហង់ នាក់ និងកូនប្រុសឈ្មោះ ហង់ ផាត ត្រូវខ្មែរក្រហមយកទៅសម្លាប់នៅ

ឆ្នាំ១៩៧៤ ។ យាយគ្រីស បានរៀបរាប់ថា *"តាំងពីដើមរៀងមក ក្នុងគ្រួសារខ្ញុំមិនដែលមានអ្នកណាធ្វើនយោបាយអីទេ គឺគិតតែខំធ្វើស្រែចម្ការនិងរកស៊ីចិញ្ចឹមគ្រួសារប៉ុណ្ណោះ ។ ស្រាប់តែនៅឆ្នាំ១៩៧៤ ខ្មែរក្រហមចាប់ប្ដីនិងកូនប្រុសខ្ញុំយកទៅដោយចោទថាជាខ្សែ សេ.អ៊ី.អារបស់អាមេរិកាំង ។"* ពេលនោះ យាយគ្រីស បានសួរគណៈឃុំឈ្មោះ ហុន ថា *"យកប្ដីនិងកូនប្រុសរបស់ខ្ញុំទៅណា?"* ។ ហុន ឆ្លើយថា *"អង្គការមិនយកទៅណាទេ គឺឲ្យគាត់ទៅរៀនសូត្រកសាងខ្លួន"* ។

ប្ដីរបស់ ឈូក សើន ឈ្មោះ ឈុន តាន់ ត្រូវខ្មែរក្រហមយកទៅសម្លាប់នៅវត្តភ្នំឆ្នារក្នុងឃុំម្រោម ។ គណៈឃុំបានប្រាប់ សើន និងកូនៗថាយក តាន់ ទៅរៀនសូត្រ ។

ហង់ គ្រិន បាននិយាយថា *"តាំងពីឆ្នាំ១៩៧០ ពេលដែលខ្ញុំរៀបការជាមួយប្ដីខ្ញុំឈ្មោះ អ៊ន់ ង៉ូវ រហូតដល់មានកូនបីនាក់ ខ្ញុំមិនដែលដឹងនិងមិនដែលបានឃើញប្ដីរបស់ខ្ញុំទាក់ទងជាមួយអ្នកណាអំពីរឿងនយោបាយឡើយ ។ គាត់គិតតែពីខំប្រឹងប្រែងធ្វើស្រែចម្ការនិងដាំដំណាំផ្សេងៗសម្រាប់ផ្គត់ផ្គង់គ្រួសារតែប៉ុណ្ណោះ ។"* គ្រិន បានបន្តទៀតថា នៅអំឡុងឆ្នាំ១៩៧៤ គណៈស្រុកអង្គរជ័យឈ្មោះ យន់ និងគណៈឃុំម្រោមឈ្មោះ ហុន និង ឆុន ចុះមកប្រជុំជាមួយប្រជាជនជាញឹកញាប់ ក្នុងមួយសប្ដាហ៍យ៉ាងហោចណាស់២ដងដែរ ។ នៅក្នុងពេលប្រជុំម្ដងៗ ឈ្លបឃុំតែងតែមកចាប់ប្រជាជន ជួនកាល៥-៦នាក់ ជួនកាល ៩-១០នាក់យកទៅសម្លាប់ ។

យិន ស៊ី អាយុ៦៥ឆ្នាំ បាននិយាយថា *"គ្រួសារខ្ញុំរស់នៅប្រកបមុខរបរតែធ្វើស្រែចម្ការ មិនដែលមានការពាក់ព័ន្ធជាមួយនយោបាយឡើយ ។ ស្រាប់តែនៅឆ្នាំ១៩៧៤ គណៈឃុំឈ្មោះ ហុន បានហៅប្ដីរបស់ខ្ញុំឈ្មោះ ហ៊ាង ហ៊ី ពីកន្លែងប្រជុំនៅរោងបាយរបស់ភូមិយកទៅបាត់រហូតមកដល់សព្វថ្ងៃ ។"*

យាយ នឹម ជ្រឹម អាយុ៧៣ឆ្នាំ ក៏បានប្រាប់យើងដែរថា *"ប្ដីខ្ញុំជាចាស់ទុំនៅក្នុងភូមិព្រះឧិង្ការ គាត់ជាកសិករសុទ្ធសាធ ចុះហេតុអ្វីបានជាអង្គការហៅគាត់ទៅយកទៅសម្លាប់?"* ។

មានប្រជាជនមួយចំនួនទៀតត្រូវខ្មែរក្រហមយកទៅសម្លាប់ទាំងគ្រួសារតែម្ដង ក្នុងនោះមានគ្រួសារ តាម៉ុកធន់-យាយយ៉ែម, គ្រួសារ តាប៊ិន-យាយយ៉ប់ និងគ្រួសារ តានឹមកាន-យាយផាត ។ តាម៉ុកធន់ និង តាប៊ិន ជាមនុស្សចាស់មានជំងឺ ដេកតែនៅលើកន្ទេល ក៏ត្រូវរដ្ឋអំណាចខ្មែរក្រហមបញ្ជាឲ្យឈ្លបមកសែងគាត់យកទៅសម្លាប់ដែរ ។

មឹងគ្រិន បានឲ្យដឹងថា *"ការដែលមានសាលាក្ដីដើម្បីជំនុំជម្រះទោសអតីតមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមនេះវាគ្រាន់តែធ្វើឲ្យខ្ញុំរំសាយចិត្តបានខ្លះប៉ុណ្ណោះ មិនអាចធ្វើឲ្យខ្ញុំបំភ្លេចនូវការឈឺចាប់ដែលខ្មែរក្រហមបានបំផ្លាញអស់នូវសុភមង្គលដែលគ្រួសារខ្ញុំធ្លាប់មានពីមុនមកឡើយ"* ។ មឹងគ្រិន បានបន្ថែមទៀតថា *"ក្នុងរយៈពេល២៥ឆ្នាំកន្លងមកនេះខ្ញុំមើលថែទាំកូនតូចៗទាំង៣នាក់ផង និងត្រូវប្រឈមមុខនឹងជីវភាពប្រចាំថ្ងៃផង"* ។

អ្វីដែលដែល មឹងគ្រិន និងអ្នកភូមិព្រះឧិង្ការបានបាត់បង់ទៅ មិនមានអ្វីអាចមកបំពេញឲ្យគ្រប់បានឡើយ មានតែសាលាក្ដីដើម្បីជំនុំជម្រះទោសអតីតមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមតែមួយគត់ដែលអាចជួយឲ្យ មឹងគ្រិន និងអ្នកភូមិព្រះឧិង្ការ រសាយពីការឈឺចាប់ និងទទួលយកការផ្សះផ្សារជាតិមួយបាន ។

**ឡុង ដានី**

## ពន្យល់ពាក្យខ្មែរក្រហម

◆ ***គោលជំហរមោទនភាព:*** គឺជាគោលជំហរពេញចិត្តពេញថ្លើម ស្រឡាញ់ចង់បានរបស់អ្វីមួយ ពេញចិត្តពេញថ្លើមនឹងប្រព្រឹត្តអំពើអ្វីមួយ ។

*(យុវជន-យុវនារីបដិវត្ត លេខពិសេសខែសីហា-កញ្ញា ១៩៧៤)*

◆ **ប្រតិកិរិយា:** ការបម្រើផលយក្រោយហួសសម័យ ប្រាសដើង ។

◆ **ប្រត្តិបត្តិ:** ការអនុវត្តតាម ធ្វើតាមលុះដោយសុឆន្ទៈ ។

◆ **ប្រតិកម្ម:** ធ្វើឲ្យមានសកម្មភាព ។

◆ **ប្រតិសកម្ម:** សកម្មភាពដែលមានដំណើរទៅមុខ និងដំណើរកំពុងអនុវត្ត ។

*(កំណត់ហេតុរបស់សមមិត្ត អ៊ីវ ពេជ្រ)*

◆ **និន្នាការ:** លម្អៀងទៅតាមគេគ្មានសេចក្ដីផ្ដើមគំនិតខ្លួនឯង ។

*(កំណត់ហេតុលេខ ១០)*

# អតីតកងទ័ពខ្មែរក្រហមម្នាក់ព្រមធ្វើជាសាក្សីនៅក្នុងតុលាការ

ញ៉ែម សុម ហៅ ញ៉ែម ប៉ោង អាយុ៥០ បាននិយាយថា "ខ្ញុំព្រមទៅធ្វើជាសាក្សីឲ្យតែការពារសុវត្ថិភាពខ្ញុំបានច្បាស់លាស់ មិនមែនទៅធ្វើសាក្សីហើយត្រឡប់មកវិញគេចាប់ដាក់គុកទេ" ។ ប៉ោង ធ្លាប់បម្រើការក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងធ្លាប់ត្រូវកាត់ទោសម្តងនៅក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ។ ប៉ោង ធំពេញវ័យក្នុងពេលដែលប្រទេសកើតសង្គ្រាម ហើយបានចូលបម្រើបដិវត្តន៍នៅពេលមានអាយុ២០ឆ្នាំ (ឆ្នាំ១៩៧៤) ។ កាលណោះប្រធានឃុំគរឈ្មោះ សន បានកេណ្ឌយុវជនក្មេងៗនៅក្នុងភូមិដោយលើកទ្រឹស្តីថា "ប្រទេសជាតិត្រូវការកម្លាំងយុវជនត្រូវការពារទឹកដីខ្មែរ រំដោះទឹកដីពីអំពើពុករលួយរបស់របប លន់ ណុល ។ យុវវ័យត្រូវធ្វើកងទ័ពចៀសមិនផុតទេ បើយើងមិនធ្វើក៏មិនហៅថាអ្នកស្នេហាជាតិដែរ" ។ ឪពុកម្តាយគ្មានសិទ្ធិជំទាស់ឡើយ ។ សន បានបញ្ជូន ប៉ោង និងយុវជនក្នុងភូមិ៤នាក់ទៀត ឲ្យទៅជួបជុំគ្នានៅឃុំគរជាមួយនឹងយុវជនយុវនារីចំនួន១០០នាក់ផ្សេងទៀតដែលប្រមូលមកពីឃុំដទៃ ។ បន្ទាប់មកទើបបញ្ជូនទៅហ្វឹកហាត់ក្បួនទ័ពនៅព្រៃទទឹងរយៈពេល ១៥ថ្ងៃ ហើយបញ្ជូនទៅហ្វឹកហាត់បន្តនៅស្រុកជើងព្រៃរយៈពេល៥ថ្ងៃទៀត ។ ក្នុងអំឡុងពេលហ្វឹកហាត់ យុវជនយុវនារីហូបបាយជាមួយអំបិល ។

ប្រាំថ្ងៃក្រោយមក អង្គភាពរបស់ ប៉ោង ត្រូវបញ្ជូនមកឈរជើងទៅព្រៃកក្តាមដើម្បីរង់ចាំទទួលបញ្ជាពី តាអឿន ប្រធានកងពល៣១០វាយចូលទីក្រុងភ្នំពេញ ។ អង្គភាពរបស់ ប៉ោង គឺវរសេនាតូចលេខ១០៣ ។

ក្រោយពីទទួលបានជ័យជម្នះថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ អង្គការបានបញ្ជូន ប៉ោង មកធ្វើស្រែនៅស្រុកជើងព្រៃ ។ ប៉ោង គឺជាអ្នកបញ្ចូលទឹកទៅក្នុងស្រែ ។ មួយរយៈក្រោយមក អង្គការក៏បញ្ជូនកងវរសេនាតូច១០៣ទាំងមូលធ្វើស្រែនៅឃុំកំបូល (ខេត្តកណ្តាល) រយៈពេល៦ខែ ។

ចុងឆ្នាំ១៩៧៦ ប៉ោង បានទៅដឹកស្រូវនៅខេត្តកំពង់ឆ្នាំង និងកំពង់ស្ពឺ យកមកទីក្រុងភ្នំពេញ ។ ប៉ោង មិនដឹងថាស្រូវទាំងនោះត្រូវយកបន្តទៅណាទៀតឡើយ ។ នៅឆ្នាំ១៩៧៧ តាអឿន ដែលជាប្រធានកងពលធំ៣១០ ត្រូវអង្គការចាប់ខ្លួនពីបទចោទប្រកាន់ថាមានផែនការផ្តួលរំលំអង្គការបដិវត្តន៍ ។ ក្រោយពី តាអឿន ត្រូវចាប់ខ្លួន ប៉ោង ត្រូវអង្គការបញ្ជូនទៅលត់ដំនៅបឹងបាយ៉ាប ខាងលិចទីក្រុងភ្នំពេញអស់រយៈពេលពីរខែ បន្ទាប់មកបញ្ជូនទៅធ្វើការនៅការដ្ឋានសំណង់ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង ។ ប្រធានដឹកនាំអង្គភាពឈ្មោះ សន ។ នៅពីលើ សន ឈ្មោះ ញ៉ មកពីនិរតី ។ ក្រៅពីកម្មករខ្មែរ ប៉ោង បានឃើញជនជាតិចិនជាច្រើនពាន់នាក់ធ្វើការនៅទីនោះដែរ ។ ជនជាតិចិនទាំងអស់នោះសុទ្ធតែជាអ្នកបច្ចេកទេស ។ ប៉ោង រំពឹកថា ការងារនៅព្រលានយន្តហោះមានសភាពធូរស្រាលជាងនៅបឹងបាយ៉ាប ព្រោះគាត់ធ្វើការតែ៨ម៉ោងក្នុងមួយថ្ងៃ ហើយមានពេលជជែកគ្នាលេងទៀតផង ចំណែកនៅបឹងបាយ៉ាបវិញធ្វើការច្រើនម៉ោងគ្មានពេលសម្រាកទេ ។

ចុងឆ្នាំ១៩៧៨ អង្គការបានបញ្ជូន ប៉ោង ទៅប្រយុទ្ធជាមួយវៀតណាមនៅសមរភូមិក្រែក ប៉ុន្តែខាងខ្មែរក្រហមបានបរាជ័យ ។ អង្គការក៏បញ្ជូនអង្គភាពរបស់ ប៉ោង ទៅភ្នំក្រវាញក្នុងខេត្តពោធិសាត់ ។ ប៉ោង មិនព្រមទៅតាមអង្គភាពឡើយ គាត់នៅធ្វើស្រែជាមួយប្រជាជននៅភូមិខ្វាវក្នុងខេត្តសៀមរាប ។ ប្រហែល ៥-៦ខែក្រោយមក គឺនៅឆ្នាំ១៩៧៩ កងទ័ពវៀតណាមបានចូលទៅដល់ភូមិខ្វាវ ហើយបានចាប់ខ្លួនកងទ័ពខ្មែរក្រហមចំនួន ៥១នាក់ក្នុងនោះមាន ប៉ោង ដែរ បញ្ជូនទៅអប់រំ ។ អតីតកងទ័ពខ្មែរក្រហមទាំង៥១នាក់ត្រូវរៀនសូត្រនយោបាយរយៈពេលកន្លះខែនៅឃុំដំដែក ស្រុកសូទ្រនិគម ខេត្តសៀមរាប ។ ខ្លឹមសារនៃការអប់រំគឺឲ្យអតីតកងទ័ពខ្មែរក្រហមទាំងអស់ចូលមករួមរស់ជាមួយប្រជាជនដើម្បីកសាងប្រទេសកម្ពុជាឡើងវិញ ។ ក្រោយ

ពីបញ្ចប់វគ្គរៀនសូត្រហើយ ប៉ោង និងអតីតកងទ័ពខ្មែរក្រហម៥០នាក់ទៀតត្រូវបញ្ជូនទៅកាត់ទោសនៅក្នុងតុលាការប្រជាជនខេត្តសៀមរាប ។ តុលាការបានផ្តល់សិទ្ធិឲ្យប្រជាជនលើកដៃសម្រេចថាតើត្រូវសម្លាប់អតីតកងទ័ពខ្មែរក្រហមទាំងអស់នេះឬមិនសម្លាប់ ប៉ុន្តែគ្មាននរណាម្នាក់លើកដៃអនុម័តឲ្យសម្លាប់ទេ ។ បន្ទាប់ពីការកាត់ទោស អតីតកងទ័ពខ្មែរក្រហមទាំង៥១នាក់ត្រូវបានអនុញ្ញាតឲ្យវិលត្រឡប់ទៅស្រុកកំណើតវិញ ។

ឆ្នាំ១៩៨០ ប៉ោង បានត្រឡប់មកភូមិកំណើតជួបជុំគ្រួសារវិញទើបដឹងថាឪពុកនិងប្អូនពីរនាក់បានស្លាប់នៅក្នុងរបបខ្មែរក្រហម ហើយពីរនាក់ទៀតបាត់ខ្លួន ។ ប៉ោង អះអាងថា នៅក្នុងរបបខ្មែរក្រហម គាត់មិនបានដឹងថាមានការសម្លាប់មនុស្សទេ ។ គាត់ទើបតែដឹងក្រោយពេលវិលត្រឡប់មកស្រុកកំណើតវិញហើយ បានឮក្រុមគ្រួសារនិងប្រជាជននិយាយប្រាប់ និងដោយបាយឃើញផ្ទាល់ភ្នែកនូវរណ្តៅសាកសពរួមជាច្រើនកន្លែង ។ ប៉ោង ផ្តែផ្តាំកូនៗថា «រឿងទាហានមិនបាច់ធ្វើទេ បើឈ្នះគេហៅយើងថាអ្នកស្នេហាជាតិ បើចាញ់គេថាយើងក្បត់ជាតិ» ។ ប៉ោង បាននិយាយថា គាត់បានឮតាមវិទ្យុអំពីការបង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ គាត់បន្ថែមថា «គ្រាន់តែឮប៉ុន្តែដូចមិនឃើញកាត់សោះ ។ បើគិតទៅគេបង្កើតតុលាការហ្នឹងវាត្រឹមត្រូវហើយ ។ ខ្ញុំជឿថា [មេដឹកនាំខ្មែរក្រហម]មានកំហុស ជាអ្នកក្តាប់រដ្ឋាភិបាលទាំងមូល ទោះបីថាមិនបានធ្វើផ្ទាល់ដៃក៏ដោយ ក៏ត្រូវតែមានកំហុសដែរ ។»

ប៉ោង ពេញចិត្តធ្វើជាសាក្សីប្រសិនបើតុលាការត្រូវការគាត់ ។

**លី សុផល**

# វេទិកាថែរក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

មជ្ឈមណ្ឌលឯកសារកម្ពុជានិងសមាគមអ្នកនិពន្ធខ្មែរនឹងរៀបចំកម្មវិធី «វេទិកាថែរក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ» លើកទី២ ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៤ ដល់ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៥ ។ កម្មវិធីនេះសូមអំពាវនាវដល់សិស្ស និស្សិត ប្រជាជនកម្ពុជា និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលកំពុងរស់នៅទាំងក្នុងនិងក្រៅប្រទេស ឲ្យសរសេរអត្ថបទស្តីអំពីរឿងរ៉ាវរបស់ខ្លួននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ពត៌មានទាំងឡាយស្តីអំពីរបបកម្ពុជាប្រជាធិបតេយ្យដែលលោកអ្នកបានដឹងឮ និងទស្សនៈផ្ទាល់ខ្លួនចំពោះរបបកម្ពុជាប្រជាធិបតេយ្យ ដើម្បីរួមចំណែកចងក្រងប្រវត្តិសាស្ត្រនៃរបបនេះឲ្យកាន់តែពិស្តារ ។

វេទិកានេះមានគោលបំណងសំខាន់ៗដូចតទៅ÷

- រួមជាចំណែកថែរក្សាប្រវត្តិសាស្ត្រទុកសម្រាប់កូនចៅជំនាន់ក្រោយឲ្យបានដឹងនិងសិក្សារៀនសូត្រ ។
- ជាវិធីមួយដើម្បីរំងាប់អារម្មណ៍ដោយយកហេតុការណ៍ សេចក្តីទុក្ខការខឹងគុំកួន មកតម្កល់ជាឯកសារប្រវត្តិសាស្ត្រដើម្បីបម្រើដល់ការស្រាវជ្រាវតទៅអនាគត ។
- ការចងចាំគឺជាសន្តិវិធីមួយក្នុងការទប់ស្កាត់មិនឲ្យអំពើប្រល័យពូជសាសន៍កើតឡើងជាថ្មីម្តងទៀតនៅក្នុងសង្គមមនុស្ស ។
- ជួយដល់ការស្វែងរកយុត្តិធម៌ជូនដល់ប្រជាជនកម្ពុជាដែលបានស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម និងជួយលើកកម្ពស់ការគោរពសិទ្ធិមនុស្សនៅកម្ពុជា ។

ប្រធានបទខាងលើនេះតម្រូវឲ្យលោកអ្នកសរសេរបែបប្រវត្តិសាស្ត្រចាប់ពី១០ទំព័រឡើងទៅ ។ មជ្ឈមណ្ឌលឯកសារកម្ពុជានិងសមាគមអ្នកនិពន្ធខ្មែរនឹងមានកិត្តិយសចុះផ្សាយស្នាដៃរបស់លោកអ្នកនៅលើទំព័រទស្សនាវដ្តីស្វែងរកការពិត ព្រមទាំងផ្តល់ថវិកាដល់ម្ចាស់អត្ថបទដែលនឹងត្រូវសរសេរបន្ថែមទៀតដើម្បីបោះពុម្ពជាសៀវភៅ ។ លោកអ្នកអាចផ្ញើអត្ថបទមកសមាគមអ្នកនិពន្ធខ្មែរដែលមានទីស្នាក់ការនៅវត្តបទុមវតី ឬមជ្ឈមណ្ឌលឯកសារកម្ពុជា ប្រអប់សំបុត្រលេខ១១១០ភ្នំពេញ ឬតាមរយៈអ៊ីមែលៈ dccam@online.com.kh ។

សូមទាក់ទងពត៌មានបន្ថែមតាមរយៈទូរស័ព្ទលេខៈ ០២៣ ២១១ ៨៧៥ ។

សូមអរគុណ ។

# សេចក្តីប្រកាសពត៌មានរបស់ការិយាល័យអ្នកនាំពាក្យ នៃរាជរដ្ឋាភិបាលកម្ពុជា ស្តីពីសម័យប្រជុំពេញអង្គរបស់គណៈរដ្ឋមន្ត្រី ថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៤

(សេចក្តីដកស្រង់)

### *កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈពេលនៃកម្ពុជាប្រជាធិបតេយ្យ*

កិច្ចព្រមព្រៀងនេះត្រូវបានមហាសន្និបាតអង្គការសហប្រជាជាតិលើកទី៥៧ អនុម័តនៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៣ ហើយបច្ចុប្បន្ននៅរង់ចាំតែការផ្តល់សច្ចាប័ននៃភាគីកម្ពុជាតែប៉ុណ្ណោះ ។ កិច្ចព្រមព្រៀងនេះបានគោរពស្មារតីនៃព្រះរាជក្រមលេខ ន.ស.រកម ០៨០១/១២ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ដោយគ្រាន់តែបានបញ្ជាក់នូវខ្លឹមសារមួយចំនួនដែលមានស្រាប់ក្នុងច្បាប់នេះ ដោយសម្របសម្រួលរចនាសម្ព័ន្ធតុលាការ និងកែសម្រួលកិច្ចការតុលាការខ្លះដូចជាៈ

ក) កិច្ចព្រមព្រៀងនេះត្រូវអនុវត្តដូចជាច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្រោយពីទទួលសច្ចាប័នសមស្របតាមច្បាប់ផ្ទៃក្នុងរបស់កម្ពុជាស្តីពីសមត្ថកិច្ចក្នុងការចុះសន្ធិសញ្ញា ។

ខ) រាជរដ្ឋាភិបាលកម្ពុជានឹងមិនស្នើសុំឲ្យមានការលើកលែងទោសឬអនុគ្រោះទោសដល់ជនទាំងឡាយណាដែលអាចនឹងត្រូវស៊ើបអង្កេត ឬនឹងត្រូវផ្តន្ទាទោសអំពីឧក្រិដ្ឋកម្មដែលមានចែងក្នុងកិច្ចព្រមព្រៀងនេះ ។ អង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាឯកភាពគ្នាថា វិសាលភាពនៃការលើកលែងទោសនេះនឹងត្រូវសម្រេចដោយអង្គជំនុំជម្រះវិសាមញ្ញ ។

គ) សមាសភាពរបស់អង្គជំនុំជម្រះមានៈ

- ◆ អង្គជំនុំជម្រះសាលាដំបូងដែលមានចៅក្រមខ្មែរ០៣រូប និងចៅក្រមអន្តរជាតិ០២រូប
- ◆ អង្គជំនុំជម្រះតុលាការកំពូលដែលមានចៅក្រមខ្មែរ០៤រូប និងចៅក្រមអន្តរជាតិ០៣រូប ដែលជាកន្លែងទទួលពាក្យបណ្តឹងឧទ្ធរណ៍ផង និងជាកន្លែងចេញសេចក្តីសម្រេចបិទផ្លូវតវ៉ាផង ។

ឃ) នីតិវិធីត្រូវសមស្របជាមួយច្បាប់កម្ពុជា ។ នៅពេលណាដែលច្បាប់កម្ពុជាពុំអាចដោះស្រាយបានចំពោះបញ្ហាពិសេសណាមួយ ឬមានភាពមិនច្បាស់លាស់ទាក់ទងនឹងការបកស្រាយ ឬការអនុវត្តន៍បទបញ្ញត្តិណាដែលពាក់ព័ន្ធនឹងច្បាប់កម្ពុជា ឬក៏មានបញ្ហាទាក់ទងនឹងភាពសមស្របគ្នារវាងបទបញ្ញត្តិបែបនេះទៅនឹងបទដ្ឋានអន្តរជាតិ គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ ។

ង) អង្គជំនុំជម្រះវិសាមញ្ញត្រូវអនុវត្តច្បាប់មនុស្សធម៌អន្តរជាតិ ច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងត្រូវអនុវត្តយុត្តាធិការរបស់ខ្លួន និងដំណើរការសមស្របរបស់ច្បាប់ដូចមានចែងក្នុងមាត្រា១៤និង១៥នៃអនុសញ្ញាអន្តរជាតិឆ្នាំ១៩៦៦ស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយដែលកម្ពុជាជាភាគីហត្ថលេខីដែរ ។

ភ្នំពេញ, ថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៤

រាជរដ្ឋាភិបាលកម្ពុជា

ការិយាល័យអ្នកនាំពាក្យ

# សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្ម

## មាត្រា២ មាត្រា៣ មាត្រា៩ មាត្រា១០ មាត្រា១១ មាត្រា១៤ មាត្រា១៧ មាត្រា១៨ មាត្រា២០ មាត្រា២១ មាត្រា២២ មាត្រា២៣ មាត្រា២៤ មាត្រា២៧ មាត្រា៣១ មាត្រា៣៣ មាត្រា៣៤ មាត្រា៣៥ មាត្រា៣៦ មាត្រា៣៧ មាត្រា៤០ មាត្រា៤២ មាត្រា៤៣ មាត្រា៤៤ មាត្រា៤៥ មាត្រា៤៦ និងមាត្រា៤៧ នៃច្បាប់ស្តីអំពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ

### មាត្រាតែមួយ

មាត្រា២ មាត្រា៣ មាត្រា៩ មាត្រា១០ មាត្រា១១ មាត្រា១៤ មាត្រា១៧ មាត្រា១៨ មាត្រា២០ មាត្រា២១ មាត្រា២២ មាត្រា២៣ មាត្រា២៤ មាត្រា២៧ មាត្រា៣១ មាត្រា៣៣ មាត្រា៣៤ មាត្រា៣៥ មាត្រា៣៦ មាត្រា៣៧ មាត្រា៤០ មាត្រា៤២ មាត្រា៤៣ មាត្រា៤៤ មាត្រា៤៥ មាត្រា៤៦ និងមាត្រា៤៧ នៃច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៨០១/១២ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ ត្រូវបានធ្វើវិសោធនកម្ម ដូចតទៅៈ

### មាត្រា២ថ្មី

ត្រូវបានបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងរចនាសម្ព័ន្ធតុលាការដែលមានស្រាប់ ពោលគឺសាលាដំបូងនិងតុលាការកំពូល ដើម្បីជំនុំជម្រះមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់កម្ពុជាដែលពាក់ព័ន្ធនឹងអំពើឧក្រិដ្ឋ ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិនិងទម្លាប់អន្តរជាតិ និងការរំលោភទៅលើអនុសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ១៧ មេសា ១៩៧៥ ដល់ថ្ងៃ៦ មករា ១៩៧៩ ។

មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យនិងអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះអំពើឧក្រិដ្ឋខាងលើនេះហៅថា "ជនសង្ស័យ" ។

### មាត្រា៣ថ្មី

អង្គជំនុំជម្រះវិសាមញ្ញមានអំណាចវិនិច្ឆ័យទោសជនសង្ស័យដែលបានប្រព្រឹត្តបទឧក្រិដ្ឋដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ១៧ មេសា ១៩៧៥ ដល់ថ្ងៃ៦ មករា ឆ្នាំ១៩៧៩ៈ

-មនុស្សឃាត មាត្រា៥០១, ៥០៣, ៥០៤, ៥០៥, ៥០៦, ៥០៧ និង មាត្រា៥០៨

-ទារុណកម្ម មាត្រា៥០០

-ការវាយប្រហារលើសាសនា មាត្រា២០៩ និងមាត្រា២១០ ។

អាជ្ញាយុកាលនៃបណ្តឹងអាជ្ញានៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ដែលទាក់ទងដល់បទល្មើសខាងលើ ត្រូវបានពន្យារពេលបន្ថែម៣០ឆ្នាំទៀតទៅលើអាជ្ញាយុកាលនៃបណ្តឹងអាជ្ញាសម្រាប់ឧក្រិដ្ឋកម្មទាំងឡាយខាងលើដែលស្ថិតក្នុងសមត្ថកិច្ចអង្គជំនុំជម្រះវិសាមញ្ញ ។

ទោសបញ្ញត្តិចែងក្នុងមាត្រា២០៩, ៥០០, ៥០៦ និងមាត្រា៥០៧ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ត្រូវកំណត់ថា

អតិបរមាត្រឹមទោសដាក់ពន្ធនាគារអស់មួយជីវិតអនុលោមតាមមាត្រា៣២នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងបញ្ជាក់បន្ថែមដោយមាត្រា៣៨និងមាត្រា៣៩នៃច្បាប់នេះ ។

**មាត្រា៩ថ្មី**

សាលាដំបូងជាអង្គជំនុំជម្រះវិសាមញ្ញ ដោយ ចៅក្រមវិជ្ជាជីវៈប្រាំរូបដែលរួមមានចៅក្រមខ្មែរបីរូប មួយរូបធ្វើជាប្រធាន និងមានចៅក្រមបរទេសពីររូប និងមានក្រឡាបញ្ជីមួយរូបឬច្រើនរូបតាមការចាត់តាំងរបស់ប្រធានចូលរួម ព្រមទាំងមានសហព្រះរាជអាជ្ញាដែលត្រូវដាក់ពាក្យប្តឹងនៅចំពោះមុខសាលាដំបូងនេះ ។

តុលាការកំពូលដែលជាកន្លែងទទួលពាក្យបណ្តឹងឧទ្ធរណ៍ផង និងសេចក្តីសម្រេចចុងក្រោយផង ជាអង្គជំនុំជម្រះវិសាមញ្ញ ដោយចៅក្រមប្រាំពីររូប ដែលរួមមានចៅក្រមខ្មែរបួនរូប ដែលមួយរូបធ្វើជាប្រធាន និងចៅក្រមបរទេសបីរូប និងមានក្រឡាបញ្ជីមួយរូបឬច្រើនរូបតាមការចាត់តាំងរបស់ប្រធានចូលរួម ព្រមទាំងមានសហព្រះរាជអាជ្ញាដែលត្រូវដាក់ពាក្យប្តឹងនៅចំពោះមុខតុលាការកំពូលនេះ ។

**មាត្រា១០ថ្មី**

ចៅក្រមជម្រះក្តីនៃអង្គជំនុំជម្រះវិសាមញ្ញត្រូវបានជ្រើសតាំងក្នុងចំណោមចៅក្រមក្នុងតំណែងបច្ចុប្បន្ននិងចៅក្រមដែលបានជ្រើសតាំងបន្ថែមតាមនីតិវិធីនៃការជ្រើសតាំងចៅក្រមជាធរមាន ហើយដែលមានចរិតលក្ខណៈនិងស្មារតីខ្ពស់មិនលំអៀងនិងសុចរិត មានបទពិសោធន៍ក្នុងការងារជំនាញ ជាពិសេសខាងច្បាប់ព្រហ្មទណ្ឌឬច្បាប់អន្តរជាតិ ក្នុងនោះរួមមានច្បាប់មនុស្សធម៌អន្តរជាតិនិងច្បាប់សិទ្ធិមនុស្សផង ។

ចៅក្រមជម្រះក្តីត្រូវឯករាជ្យក្នុងការបំពេញការងាររបស់ខ្លួន ហើយមិនត្រូវទទួលឬស្វែងរកការបង្គាប់បញ្ជាពីរដ្ឋាភិបាលណាមួយ ឬពីប្រភពណាមួយផ្សេងទៀតឡើយ ។

**មាត្រា១១ថ្មី**

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវជ្រើសតាំងចៅក្រមខ្មែរយ៉ាងតិចប្រាំពីររូបឲ្យធ្វើជាចៅក្រមជម្រះក្តីសម្រាប់អង្គជំនុំជម្រះវិសាមញ្ញ និងជ្រើសតាំងចៅក្រមជម្រះក្តីបម្រុងមួយចំនួនតាមតម្រូវការ ព្រមទាំងត្រូវជ្រើសតាំងផងដែរនូវប្រធាននៃអង្គជំនុំជម្រះវិសាមញ្ញក្នុងចំណោមចៅក្រមខ្មែរខាងលើតាមនីតិវិធីនៃការជ្រើសតាំងចៅក្រមជាធរមាន ។

ចៅក្រមបម្រុងខ្មែរត្រូវជំនួសចៅក្រមជម្រះក្តីខ្មែរពេញសិទ្ធិនៅពេលដែលចៅក្រមនេះអវត្តមានឬមានធុរៈ ។ ចៅក្រមជម្រះក្តីទាំងនេះអាចបន្តបំពេញការងារប្រចាំថ្ងៃនៅក្នុងសាលាជម្រះក្តីដែលខ្លួនកំពុងបំពេញ ។

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវជ្រើសតាំងយ៉ាងតិចបុគ្គលប្រាំរូបដែលមានសញ្ជាតិបរទេសឲ្យធ្វើជាចៅក្រមជម្រះក្តីបរទេសសម្រាប់អង្គជំនុំជម្រះវិសាមញ្ញ ក្រោយពីការជ្រើសរើសឲ្យឈរឈ្មោះដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

អគ្គលេខាធិការអង្គការសហប្រជាជាតិត្រូវរៀបចំបញ្ជីបេក្ខជនចៅក្រមបរទេសដែលមានចំនួនយ៉ាងតិចប្រាំពីររូបជូនរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ហើយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវជ្រើសតាំងចៅក្រមពេញសិទ្ធិប្រាំរូប និងចៅក្រមបម្រុងយ៉ាងតិចពីររូបពីក្នុងបញ្ជីឈ្មោះនោះ ។ បន្ថែមពីលើចៅក្រមបរទេសដែលចូលរួមក្នុងអង្គជំនុំជម្រះវិសាមញ្ញ និងដែលមានវត្តមាននៅគ្រប់ដំណាក់កាលនៃដំណើរការជំនុំជម្រះ ប្រធានអង្គជំនុំជម្រះវិសាមញ្ញអាចចាត់តាំងតាមករណីនីមួយៗនូវចៅក្រមបម្រុងបរទេសណាមួយរូបឬច្រើនរូបដែលត្រូវបានជ្រើសរើសរួចហើយដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមឲ្យមានវត្តមាននៅក្នុងដំណាក់កាលជំនុំជម្រះនីមួយៗ ហើយឲ្យជំនួសចៅក្រមបរទេសប្រសិនបើចៅក្រមរូបនោះពុំមានលទ្ធភាពអាចបន្តការជំនុំជម្រះតទៅទៀតបាន ។

**មាត្រា១៤ថ្មី**

១) ចៅក្រមទាំងអស់ត្រូវព្យាយាមសម្រេចឲ្យបាននូវភាពឯកច្ឆ័ន្ទក្នុងសេចក្តីសម្រេចរបស់ខ្លួន ។ ប្រសិនបើភាពឯកច្ឆ័ន្ទនេះពុំអាចរកបានទេត្រូវអនុវត្តគោលការណ៍ដូចខាងក្រោមៈ

ក) ការសម្រេចសេចក្តីដោយអង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូងតម្រូវឲ្យមានការបោះឆ្នោតគាំទ្រពីចៅក្រមបួនរូបយ៉ាងតិច ។

ខ) ការសម្រេចសេចក្តីដោយអង្គជំនុំជម្រះវិសាមញ្ញ

របស់តុលាការកំពូលតម្រូវឲ្យមានការបោះឆ្នោតគាំទ្រពីចៅក្រមប្រាំរូបយ៉ាងតិច ។

២) នៅពេលដែលពុំមានឯកភាពឯកច្ឆ័ន្ទនោះទេ សេចក្ដីសម្រេចនៃអង្គជំនុំជម្រះត្រូវកត់ត្រាទុកនូវយោបល់របស់មតិភាគច្រើននិងមតិភាគតិច ។

## មាត្រា១៧ថ្មី

សហព្រះរាជអាជ្ញានៃសាលាដំបូងមានសិទ្ធិប្ដឹងឧទ្ធរណ៍ពីសេចក្ដីសម្រេចនៃអង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូង ។

## មាត្រា១៨ថ្មី

ឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវជ្រើសតាំងព្រះរាជអាជ្ញានិងព្រះរាជអាជ្ញាបម្រុងខ្មែរមួយរូបតាមតម្រូវការពីក្របខណ្ឌចៅក្រមវិជ្ជាជីវៈខ្មែរ ។

ព្រះរាជអាជ្ញាបម្រុងត្រូវជំនួសព្រះរាជអាជ្ញាពេញសិទ្ធិនៅពេលដែលព្រះរាជអាជ្ញានោះអវត្តមានឬមានធុរៈ ។

ព្រះរាជអាជ្ញាទាំងនេះអាចបន្តបំពេញការងារប្រចាំថ្ងៃនៅក្នុងសាលាជំនុំជម្រះក្ដីដែលខ្លួនកំពុងបំពេញ ។

ព្រះរាជអាជ្ញាបរទេសមួយរូបដែលមានសមត្ថកិច្ចបង្ហាញខ្លួនក្នុងគ្រប់លំដាប់ថ្នាក់នៃអង្គជំនុំជម្រះវិសាមញ្ញ ត្រូវបានជ្រើសតាំងដោយឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រមក្រោយពីការជ្រើសរើសឲ្យឈរឈ្មោះដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

អគ្គលេខាធិការអង្គការសហប្រជាជាតិត្រូវរៀបចំបញ្ជីបេក្ខជនយ៉ាងតិចពីររូបជាសហព្រះរាជអាជ្ញាបរទេសជូនរាជរដ្ឋាភិបាលកម្ពុជា ហើយឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវជ្រើសតាំងព្រះរាជអាជ្ញាពេញសិទ្ធិមួយរូបនិងព្រះរាជអាជ្ញាបម្រុងមួយរូបចេញពីបញ្ជីបេក្ខជននេះ ។

## មាត្រា២០ថ្មី

សហព្រះរាជអាជ្ញាត្រូវធ្វើការចោទប្រកាន់ដោយអនុវត្តតាមនីតិវិធីដែលនៅជាធរមាន ។ ប្រសិនបើនីតិវិធីដែលមានស្រាប់ពុំបានចែងពីករណីពិសេសមួយ ឬប្រសិនបើមានភាពមិនច្បាស់លាស់ក្នុងការបកស្រាយឬអនុវត្តនីតិវិធីនោះ ឬប្រសិនបើមានបញ្ហាទាក់ទងទៅនឹងភាពសមស្របនៃនីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ ។

ក្នុងករណីដែលមានភាពខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា ត្រូវអនុវត្តគោលការណ៍ដូចខាងក្រោមៈ

ការចោទប្រកាន់ត្រូវបន្តដរាបណាសហព្រះរាជអាជ្ញាឬក៏សហព្រះរាជអាជ្ញាម្នាក់ពុំបានស្នើក្នុងរយៈពេលសាមសិបថ្ងៃថាភាពខ្វែងយោបល់គ្នាត្រូវបានដោះស្រាយដោយអនុលោមតាមបទបញ្ញត្តិដូចខាងក្រោមៈ

សហព្រះរាជអាជ្ញាត្រូវដាក់ជូននូវកំណត់ហេតុជាលាយលក្ខណ៍អក្សរអំពីអង្គហេតុនិងហេតុផលទាំងឡាយចំពោះគោលជំហរខុសគ្នារបស់គេដល់ប្រធានការិយាល័យរដ្ឋបាល ។

ភាពខ្វែងយោបល់គ្នាត្រូវតែដោះស្រាយភ្លាមដោយអង្គបុរេជំនុំជម្រះដែលមានចៅក្រមប្រាំរូប ចៅក្រមខ្មែរបីរូបត្រូវបានជ្រើសតាំងដោយឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រម ដោយមានចៅក្រមមួយរូបជាប្រធាន ហើយនិងចៅក្រមបរទេសពីររូបត្រូវបានជ្រើសតាំងដោយឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រមបន្ទាប់ពីមានការជ្រើសរើសឲ្យឈរឈ្មោះដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

ការជ្រើសរើសចៅក្រមខាងលើនេះត្រូវអនុវត្តតាមបទបញ្ញត្តិនៃមាត្រា១០នៃច្បាប់នេះ ។

បន្ទាប់ពីការទទួលបានកំណត់ហេតុដូចដែលមានចែងនៅក្នុងកថាខណ្ឌទី៣ ប្រធានការិយាល័យរដ្ឋបាលត្រូវកោះប្រជុំអង្គបុរេជំនុំជម្រះជាបន្ទាន់ ហើយត្រូវជូនដំណឹងអំពីកំណត់ហេតុដល់សមាជិកអង្គបុរេជំនុំជម្រះ ។

សេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះដែលពុំបើកផ្លូវឲ្យមានបណ្ដឹងឧទ្ធរណ៍ តម្រូវឲ្យមានសំឡេងវិជ្ជមានពីចៅក្រមបួនរូបយ៉ាងតិច ។ សេចក្ដីសម្រេចនេះត្រូវជូនដំណឹងដល់ប្រធានការិ-យាល័យរដ្ឋបាលដែលត្រូវផ្សព្វផ្សាយសេចក្ដីសម្រេចនេះ ហើយជូនដំណឹងដល់សហព្រះរាជអាជ្ញា ។ សហព្រះរាជអាជ្ញាត្រូវចាត់ការបន្តជាបន្ទាន់ដោយអនុវត្តតាមសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះ ។ ប្រសិនបើពុំមានមតិភាគច្រើនដូចតម្រូវឲ្យមានចំពោះការធ្វើសេចក្ដីសម្រេចទេ ការចោទប្រកាន់ត្រូវធ្វើបន្តទៅទៀត ។

ក្នុងពេលធ្វើការចោទប្រកាន់ សហព្រះរាជអាជ្ញាអាចស្វែង

រកការជួយឧបត្ថម្ភពីរាជរដ្ឋាភិបាលកម្ពុជា ប្រសិនបើការជួយឧបត្ថម្ភនេះពិតជាមានប្រយោជន៍ចំពោះការចោទប្រកាន់ ហើយការជួយឧបត្ថម្ភនេះត្រូវតែផ្តល់ជូន ។

## មាត្រា២១ថ្មី

សហព្រះរាជអាជ្ញាទាំងអស់ដែលស្ថិតក្រោមច្បាប់នេះមានឋានៈនិងលក្ខខណ្ឌការងារស្មើៗគ្នា ទៅតាមលំដាប់ថ្នាក់នៃអង្គជំនុំជម្រះវិសាមញ្ញនីមួយៗ ។

ព្រះរាជអាជ្ញាមួយរូបៗត្រូវបានជ្រើសតាំងសម្រាប់រយៈពេលនៃការជំនុំជម្រះ ។

ក្នុងករណីដែលព្រះរាជអាជ្ញាបរទេសអវត្តមានឬមានធុរៈ ត្រូវជំនួសដោយព្រះរាជអាជ្ញាបម្រុងបរទេស ។

## មាត្រា២២ថ្មី

សហព្រះរាជអាជ្ញាមួយរូបៗមានសិទ្ធិជ្រើសរើសព្រះរាជអាជ្ញារងមួយរូបឬច្រើនរូបដើម្បីជួយខ្លួនក្នុងការធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់នៅចំពោះមុខអង្គជំនុំជម្រះ ។ ព្រះរាជអាជ្ញារងបរទេសត្រូវតែងតាំងដោយសហព្រះរាជអាជ្ញាបរទេសពីបញ្ជីផ្តល់ដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

សហព្រះរាជអាជ្ញាត្រូវមានបុគ្គលិកខ្មែរនិងបុគ្គលិកអន្តរជាតិជាជំនួយការ ទៅតាមតម្រូវការជាក់ស្តែងសម្រាប់បម្រើការងារនៅក្នុងការិយាល័យរបស់ខ្លួន ។

ក្នុងការជ្រើសរើសបុគ្គលិកជាជំនួយការ ប្រធានការិយាល័យរដ្ឋបាលត្រូវធ្វើសម្ភាសន៍ក្នុងករណីចាំបាច់ និងត្រូវមានការយល់ព្រមពីសហព្រះរាជអាជ្ញាខ្មែរក្នុងការជួលបុគ្គលិកដែលត្រូវតែងតាំងដោយរាជរដ្ឋាភិបាលកម្ពុជា ។ អនុប្រធានការិយាល័យរដ្ឋបាលត្រូវទទួលខុសត្រូវចំពោះការជ្រើសរើសនិងការគ្រប់គ្រងបុគ្គលិកបរទេសទាំងអស់ ។ ចំនួនបុគ្គលិកជំនួយការត្រូវជ្រើសរើសតាមសមាមាត្រព្រះរាជអាជ្ញាខ្មែរនិងព្រះរាជអាជ្ញាបរទេស ។

បុគ្គលិកជាជំនួយការខ្មែរត្រូវជ្រើសរើសក្នុងចំណោមមន្ត្រីរាជការក្នុងក្របខ័ណ្ឌរដ្ឋឬជនជាតិខ្មែរដទៃទៀតដែលមានសមត្ថភាពក្នុងករណីចាំបាច់ ។

## មាត្រា២៣ថ្មី

រាល់ការស៊ើបអង្កេតគឺជាការទទួលខុសត្រូវរួមគ្នារបស់ចៅក្រមពីរនាក់ ម្នាក់ជាកម្ពុជានិងម្នាក់ទៀតជាបរទេស ដែលហៅថា “សហចៅក្រមស៊ើបអង្កេត” ដោយអនុវត្តតាមវិធីដែលនៅមានជាធរមាន ។ ប្រសិនបើនីតិវិធីដែលមានស្រាប់ពុំបានចែងអំពីករណីពិសេសមួយ ឬប្រសិនបើមានភាពមិនច្បាស់លាស់ក្នុងការបកស្រាយឬអនុវត្តនីតិវិធីនោះ ឬប្រសិនបើមានបញ្ហាទាក់ទងទៅនឹងភាពសមស្របនៃនីតិវិធីទាំងនេះជាមួយបទដ្ឋានអន្តរជាតិ សហចៅក្រមស៊ើបអង្កេតអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ ។

ក្នុងករណីដែលមានភាពមិនយល់ស្របគ្នារវាងសហចៅក្រមត្រូវអនុវត្តគោលការណ៍ដូចខាងក្រោមៈ

ការស៊ើបអង្កេតត្រូវធ្វើបន្តដរាបណាសហចៅក្រមស៊ើបអង្កេតទាំងពីរ ឬមួយក្នុងចំណោមពួកគេ ពុំបានប្តឹងមិនសុខចិត្តក្នុងរយៈពេលសាមសិបថ្ងៃថាភាពខ្វែងយោបល់គ្នាត្រូវបានដោះស្រាយដោយអនុវត្តតាមបទបញ្ញត្តិខាងក្រោមៈ

សហចៅក្រមស៊ើបអង្កេតត្រូវជូនកំណត់ហេតុជាលាយលក្ខណ៍អក្សរអំពីអង្គហេតុនិងហេតុផលទាំងឡាយចំពោះគោលជំហរខុសគ្នាដល់ប្រធានការិយាល័យរដ្ឋបាល ។

ភាពខ្វែងយោបល់គ្នាត្រូវដោះស្រាយភ្លាមដោយអង្គបុរេជំនុំជម្រះដូចមានចែងក្នុងមាត្រា២០ នៃច្បាប់នេះ ។

បន្ទាប់ពីទទួលបាននូវកំណត់ហេតុដូចមានចែងក្នុងកថាខ័ណ្ឌទី៣រួចមក ប្រធានការិយាល័យរដ្ឋបាលត្រូវកោះប្រជុំអង្គបុរេជំនុំជម្រះជាបន្ទាន់ ហើយជូនដំណឹងអំពីកំណត់ហេតុដល់សមាជិកអង្គបុរេជំនុំជម្រះ ។

សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះដែលពុំបើកផ្លូវឲ្យមានបណ្តឹងឧទ្ធរណ៍ តម្រូវឲ្យមានសំឡេងវិជ្ជមានពីចៅក្រមបួនរូបយ៉ាងតិច ។ សេចក្តីសម្រេចនេះត្រូវជូនដំណឹងដល់ប្រធានការិ-យាល័យរដ្ឋបាលដែលត្រូវផ្សព្វផ្សាយសេចក្តីសម្រេចនេះ ហើយជូនដំណឹងដល់សហចៅក្រមស៊ើបអង្កេត ។ សហចៅក្រមស៊ើបអង្កេតត្រូវចាត់ការបន្តជាបន្ទាន់ ដោយអនុវត្តតាមសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ។ ប្រសិនបើពុំមានមតិភាគច្រើនដូចដែលតម្រូវឲ្យមានចំពោះសេចក្តីសម្រេច ការស៊ើបអង្កេតត្រូវធ្វើបន្តទៀត ។

សហចៅក្រមស៊ើបអង្កេតអាចផ្អែកទៅលើមូលដ្ឋាននៃព័ត៌មានដែលទទួលបានពីស្ថាប័ននានា រួមមានរដ្ឋាភិបាល ស្ថាប័ននានារបស់អង្គការសហប្រជាជាតិ ឬអង្គការក្រៅរដ្ឋាភិបាលជាដើម ។

សហចៅក្រមស៊ើបអង្កេតមានអំណាចក្នុងការសួរចម្លើយជនសង្ស័យ ជនរងគ្រោះ និងស្តាប់ចម្លើយសាក្សី និងប្រមូលភ័ស្តុតាងដោយអនុវត្តតាមនីតិវិធីជាធរមាន ។ ក្នុងករណីដែលសហចៅក្រមស៊ើបអង្កេតយល់ថាជាការចាំបាច់ខានមិនបាន សហចៅក្រមស៊ើបអង្កេតអាចចេញដីកាសុំឲ្យសហព្រះរាជអាជ្ញាធ្វើការសាកសួរសាក្សីបន្ថែមបាន ។

ក្នុងការអនុវត្តភារកិច្ចនេះ សហចៅក្រមស៊ើបអង្កេតអាចស្វែងរកការជួយឧបត្ថម្ភពីរាជរដ្ឋាភិបាលកម្ពុជាបានប្រសិនបើយល់ឃើញថាសមស្របនិងមានប្រយោជន៍ដល់ការស៊ើបអង្កេត ហើយការជួយឧបត្ថម្ភនេះត្រូវតែបានផ្តល់ជូន ។

## មាត្រា២៤ថ្មី

ក្នុងដំណាក់កាលស៊ើបអង្កេត ជនសង្ស័យមានសិទ្ធិទទួលបានការការពារពីមេធាវីដែលជ្រើសរើសដោយខ្លួនឯងដោយខានមិនបាន និងមានជំនួយផ្នែកច្បាប់ដល់ពួកគេដោយឥតគិតថ្លៃ ប្រសិនបើខ្លួនគ្មានលទ្ធភាពគ្រប់គ្រាន់ដើម្បីពឹងមេធាវី ព្រមទាំងមានសិទ្ធិទទួលបាននូវការបកប្រែចាំបាច់ជាភាសាដែលជនសង្ស័យនិយាយនិងយល់បាន ។

## មាត្រា២៧ថ្មី

ចៅក្រមស៊ើបអង្កេតទាំងអស់ដែលស្ថិតក្រោមច្បាប់នេះមានឋានៈនិងលក្ខខណ្ឌការងារស្មើៗគ្នា ។

ចៅក្រមស៊ើបអង្កេតមួយរូបៗត្រូវបានជ្រើសតាំងសម្រាប់រយៈពេលនៃការស៊ើបអង្កេត ។

ក្នុងករណីដែលសហចៅក្រមស៊ើបអង្កេតបរទេសណាមួយអវត្តមានឬមានធុរៈ ត្រូវជំនួសដោយចៅក្រមស៊ើបអង្កេតបម្រុងបរទេស ។

## មាត្រា៣១ថ្មី

ប្រធានការិយាល័យរដ្ឋបាលត្រូវតែងតាំងដោយរាជរដ្ឋាភិបាលកម្ពុជាសម្រាប់រយៈពេល២ឆ្នាំ ហើយអាចត្រូវបានតែងតាំងបន្តទៀតបាន ។ ប្រធានការិយាល័យរដ្ឋបាលមានភារកិច្ចគ្រប់គ្រងទូទៅលើការងាររបស់ការិយាល័យរដ្ឋបាល ។ លើកលែងតែការងារដែលស្ថិតនៅក្រោមបទបញ្ញត្តិនិងតាមនីតិវិធីរបស់អង្គការសហប្រជាជាតិ ។

ប្រធានការិយាល័យរដ្ឋបាលត្រូវបានជ្រើសរើសក្នុងចំណោមអ្នកដែលមានបទពិសោធន៍ខ្ពស់ក្នុងការងាររដ្ឋបាលតុលាការមានភាពស្ទាត់ជំនាញលើភាសាណាមួយក្នុងចំណោមភាសាបរទេសដែលប្រើការក្នុងអង្គជំនុំជម្រះវិសាមញ្ញ ជាមនុស្សមានចរិតលក្ខណៈនិងស្មារតីខ្ពស់និងសុចរិត ។

អនុប្រធានបរទេសនៃការិយាល័យរដ្ឋបាលត្រូវជ្រើសតាំងដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ និងតែងតាំងដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងទទួលខុសត្រូវចំពោះការជ្រើសរើសនិងការគ្រប់គ្រងបុគ្គលិកអន្តរជាតិទាំងអស់ ដូចដែលបានតម្រូវឲ្យមានដោយសមាសភាគបរទេសនៃអង្គជំនុំជម្រះវិសាមញ្ញ សហចៅក្រមស៊ើបអង្កេត ការិយាល័យនៃសហព្រះរាជអាជ្ញា និងការិយាល័យរដ្ឋបាល ។ អនុប្រធានការិយាល័យរដ្ឋបាលត្រូវគ្រប់គ្រងប្រាក់ធនធានដែលផ្តល់ជូនតាមរយៈមូលនិធិស្ម័គ្រចិត្តនៃអង្គការសហប្រជាជាតិ ។

ការិយាល័យរដ្ឋបាលត្រូវមានបុគ្គលិកខ្មែរនិងបុគ្គលិកអន្តរជាតិជាជំនួយការតាមតម្រូវការជាក់ស្តែង ។

បុគ្គលិកខ្មែរទាំងអស់នៃការិយាល័យរដ្ឋបាលត្រូវតែងតាំងដោយរាជរដ្ឋាភិបាលកម្ពុជាតាមសំណើរបស់ប្រធានការិយាល័យ ។ បុគ្គលិកបរទេសត្រូវតែងតាំងដោយអនុប្រធានការិយាល័យរដ្ឋបាល ។

បុគ្គលិកខ្មែរត្រូវជ្រើសរើសក្នុងចំណោមមន្ត្រីរាជការក្នុងក្របខ័ណ្ឌរដ្ឋ ឬជនជាតិខ្មែរដទៃទៀតដែលមានសមត្ថភាពក្នុងករណីចាំបាច់ ។

## មាត្រា៣៣ថ្មី

អង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូងត្រូវប្រព្រឹត្តទៅឲ្យបានត្រឹមត្រូវនិងឆាប់រហ័សទៅតាមនីតិវិធីជាធរមាន ដោយមានការគោរពយ៉ាងពេញលេញនូវសិទ្ធិរបស់ជនត្រូវចោទ និងមានការការពារឲ្យបានត្រឹមត្រូវចំពោះជនរងគ្រោះនិងសាក្សី ។

ប្រសិនបើនីតិវិធីដែលមានស្រាប់ពុំបានចែងពីករណីពិសេសមួយ ឬប្រសិនបើមានភាពមិនច្បាស់លាស់ក្នុងការបកស្រាយឬអនុវត្តតាមនីតិវិធីនោះ ឬប្រសិនបើមានបញ្ហាទាក់ទងទៅនឹងភាពសមស្របនៃនីតិវិធីទាំងនេះជាមួយបទដ្ឋានអន្តរជាតិ គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ ។ អង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូងត្រូវអនុវត្តយុត្តាធិការរបស់ខ្លួនសមស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវ និងដំណើរការសមស្របនៃច្បាប់ ដូចដែលបានចែងក្នុងមាត្រា១៤និង១៥នៃអនុសញ្ញាអន្តរជាតិឆ្នាំ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋនិងនយោបាយ ។ ជនសង្ស័យដែលត្រូវបានចោទប្រកាន់ហើយត្រូវបានចាប់ខ្លួន ត្រូវបញ្ជូនខ្លួនមកសាលាដំបូងតាមនីតិវិធីជាធរមាន ។ រាជរដ្ឋាភិបាលត្រូវទទួលខុសត្រូវក្នុងការធានាសន្តិសុខចំពោះការចូលខ្លួន និងក្នុងការចាត់ការឲ្យចាប់ខ្លួនជនសង្ស័យដែលត្រូវបានចោទប្រកាន់តាមច្បាប់នេះ ។ នគរបាលយុត្តិធម៌ត្រូវបានជួយឧបត្ថម្ភដោយអង្គភាពអនុវត្តច្បាប់ផ្សេងៗទៀតរបស់រាជរដ្ឋាភិបាល ដែលរួមមានកងកម្លាំងប្រដាប់អាវុធ ដើម្បីធានាឲ្យជនដែលត្រូវបានចោទប្រកាន់ត្រូវបាននាំខ្លួនមកក្នុងមន្ទីរឃុំឃាំងភ្លាមៗ ។ លក្ខខណ្ឌនៃការចាប់ខ្លួននិងឃុំខ្លួនត្រូវអនុវត្តតាមច្បាប់ជាធរមាន ។

តុលាការត្រូវផ្តល់ការការពារដល់ជនរងគ្រោះនិងសាក្សី ។ វិធានការការពារទាំងនេះមិនត្រូវកម្រិតត្រឹមតែកិច្ចដំណើរការជំនុំជម្រះជាសម្ងាត់និងការការពារនូវអត្តសញ្ញាណរបស់ជនរងគ្រោះឡើយ ។

## មាត្រា៣៤ថ្មី

អង្គជំនុំជម្រះវិសាមញ្ញត្រូវធ្វើជាសាធារណៈនិងបើកចំហសម្រាប់តំណាងរបស់រដ្ឋបរទេស តំណាងរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ តំណាងបណ្តាញពត៌មាន និងតំណាងអង្គការក្រៅរដ្ឋាភិបាលជាតិនិងអន្តរជាតិ លើកលែងតែក្នុងកាលៈទេសៈពិសេស អង្គជំនុំជម្រះវិសាមញ្ញសម្រេចថាត្រូវជំនុំជម្រះជាសម្ងាត់ដោយមានមូលហេតុត្រឹមត្រូវ ដោយយោងតាមនីតិវិធីជាធរមានដែលការផ្សព្វផ្សាយជាសាធារណៈធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍យុត្តិធម៌ ។

## មាត្រា៣៥ថ្មី

ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សឥតទោសដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ ។

នៅក្នុងការចោទប្រកាន់មកលើខ្លួន ជនជាប់ចោទមានសិទ្ធិទទួលបាននូវការធានាជាអប្បបរមានិងស្មើៗគ្នា សមស្របតាមមាត្រា១៤នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយឆ្នាំ១៩៦៦:

ក) ទទួលពត៌មានភ្លាមៗនិងលម្អិតជាភាសាដែលខ្លួនយល់បាន អំពីប្រភេទនិងមូលហេតុនៃការចោទប្រកាន់ចំពោះខ្លួន

ខ) មានពេលវេលានិងលក្ខណៈគ្រប់គ្រាន់ដើម្បីរៀបចំការពារខ្លួន និងទាក់ទងជាមួយមេធាវីរបស់ខ្លួនដែលជ្រើសរើសដោយខ្លួនឯង

គ) ត្រូវបានទទួលការជំនុំជម្រះដោយគ្មានការអូសបន្លាយ

ឃ) ត្រូវបានជំនុំជម្រះដោយមានវត្តមានរបស់ជនសង្ស័យនិងការពារខ្លួនដោយខ្លួនឯង ឬតាមរយៈមេធាវីដែលជ្រើសរើសដោយខ្លួនឯង ត្រូវបានប្រាប់ឲ្យដឹងអំពីសិទ្ធិ និងទទួលបាននូវជំនួយផ្នែកច្បាប់ដោយឥតគិតថ្លៃប្រសិនបើជនជាប់ចោទគ្មានលទ្ធភាពជួលដោយខ្លួនឯង

ង) ពិនិត្យភ័ស្តុតាងដាក់បន្ទុក និងទទួលបាននូវការចូលរួមនិងការពិនិត្យភ័ស្តុតាងដាក់បន្ទុកក្នុងលក្ខខណ្ឌដូចគ្នានិងភ័ស្តុតាងដាក់បន្ទុកដែរ

ច) មានការជួយឧបត្ថម្ភដោយសេរីពីអ្នកបកប្រែភាសាប្រសិនបើជនជាប់ចោទមិនយល់ឬមិនអាចនិយាយនូវភាសាដែលប្រើនៅក្នុងតុលាការ

ឆ) មិនត្រូវបានគេបង្ខំឲ្យឆ្លើយប្រឆាំងនឹងខ្លួនឯង ឬបង្ខំឲ្យឆ្លើយសារភាពថាគ្មានកំហុស ។

## មាត្រា៣៦ថ្មី

អង្គជំនុំជម្រះវិសាមញ្ញនៃតុលាការកំពូលជំនុំជម្រះលើបណ្តឹងសាទុក្ខរបស់ជនជាប់ចោទ របស់ជនរងគ្រោះ និងរបស់សហព្រះរាជអាជ្ញា ពីសាលដីការបស់អង្គជំនុំជម្រះវិសាមញ្ញនៃសាលាដំបូង ក្នុងករណីនេះតុលាការកំពូលពិនិត្យសម្រេចជាចុងក្រោយទាំងអង្គហេតុទាំងអង្គច្បាប់ ដោយមិនបង្វិលសំណុំរឿង

មកអង្គជំនុំជម្រះវិសាមញ្ញនៃសាលាដំបូងវិញទេ ។

## មាត្រា៣៧ថ្មី

ប្រការដែលបានចែងនៅក្នុងមាត្រា៣៣, ៣៤ និង៣៥ ត្រូវអនុវត្តដូចគ្នាចំពោះការជំនុំជម្រះក្តី នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញនៃតុលាការកំពូល ។

## មាត្រា៤០ថ្មី

រាជរដ្ឋាភិបាលកម្ពុជាមិនអាចស្នើសុំឲ្យមានការលើកលែងទោសឬការអនុគ្រោះទោសដល់ជនទាំងឡាយណាដែលអាចត្រូវបានស៊ើបអង្កេតឬត្រូវបានផ្តន្ទាទោសអំពីឧក្រិដ្ឋកម្មដែលមានចែងក្នុងមាត្រា៣, ៤, ៥, ៦, ៧ និងមាត្រា៨ នៃច្បាប់នេះបានឡើយ ។ វិសាលភាពនៃការលើកលែងទោសឬអនុគ្រោះទោសដែលអាចត្រូវបានផ្តល់ឲ្យមុនការអនុម័តច្បាប់នេះគឺត្រូវសម្រេចដោយអង្គជំនុំជម្រះវិសាមញ្ញ ។

## មាត្រា៤២ថ្មី

១) ចៅក្រមខ្មែរ សហចៅក្រមស៊ើបអង្កេតខ្មែរ សហព្រះរាជអាជ្ញាខ្មែរ និងបុគ្គលិកខ្មែរ ត្រូវបានផ្តល់អភ័យឯកសិទ្ធិឲ្យរួចផុតពីដំណើរក្តីតាមផ្លូវច្បាប់ចំពោះពាក្យពេចន៍ដែលបាននិយាយឬសរសេរ និងសកម្មភាពទាំងអស់ដែលបានបំពេញក្នុងតំណែងផ្លូវការរបស់គេ ។ អភ័យឯកសិទ្ធិបែបនេះនៅតែមានបន្តក្រោយពីពួកគេបញ្ចប់ការងារជាមួយអង្គជំនុំជម្រះវិសាមញ្ញ អង្គបុរេជំនុំជម្រះ និងការិយាល័យរដ្ឋបាល ។

២) បុគ្គលិកអន្តរជាតិត្រូវបានផ្តល់បន្ថែមនូវៈ

ក) អភ័យឯកសិទ្ធិឲ្យរួចផុតពីការដំណើរក្តីតាមផ្លូវច្បាប់ចំពោះពាក្យពេចន៍ដែលបាននិយាយឬសរសេរ និងសកម្មភាពទាំងអស់ដែលបានបំពេញក្នុងតំណែងផ្លូវការរបស់ពួកគេ ។ អភ័យឯកសិទ្ធិបែបនេះនៅតែមានជាបន្តក្រោយពីពួកគេបញ្ចប់ការងារជាមួយសហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញា អង្គជំនុំជម្រះវិសាមញ្ញ អង្គបុរេជំនុំជម្រះ និងការិយាល័យរដ្ឋបាល

ខ) អភ័យឯកសិទ្ធិឲ្យរួចផុតពីការបង់ពន្ធលើប្រាក់បៀវត្សរ៍ភាជន៍ និងបរិលាភដែលបើកជូនគេដោយអង្គការសហប្រជាជាតិ ។

គ) អភ័យឯកសិទ្ធិឲ្យរួចផុតពីការដាក់កំហិតព្រំដែនអន្តោប្រវេសន៍ ។

ឃ) សិទ្ធិនាំចូលដោយរួចពន្ធអាករគ្រឿងសង្ហារឹមនិងសម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួនរបស់ពួកគេ លើកលែងតែការចំណាយសម្រាប់សេវាកម្មនៅពេលដែលមកទទួលភារកិច្ចផ្លូវការជាលើកដំបូងនៅប្រទេសកម្ពុជា ។

៣) មេធាវីរបស់ជនសង្ស័យឬជនជាប់ចោទដែលត្រូវបានទទួលស្គាល់ថាជាមេធាវីដោយអង្គជំនុំជម្រះ មិនត្រូវស្ថិតនៅក្រោមអំណាចរដ្ឋាភិបាលនូវវិធានការណាមួយដែលអាចប៉ះពាល់ដល់ការបំពេញមុខងារដោយសេរីនិងឯករាជ្យរបស់ខ្លួននៅក្រោមច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ។

ជាពិសេស មេធាវីត្រូវបានផ្តល់នូវៈ

ក) អភ័យឯកសិទ្ធិឲ្យរួចផុតពីការចាប់ឬឃុំខ្លួននិងការរឹបអូសរបស់របរផ្ទាល់ខ្លួន ក្នុងក្របខណ្ឌនៃការបំពេញភារកិច្ចរបស់ខ្លួនក្នុងរឿងក្តីនេះ

ខ) ភាពមិនអាចរំលោភបំពានបាននូវឯកសារទាំងអស់ដែលទាក់ទងដល់ការបំពេញមុខងាររបស់ខ្លួនជាមេធាវីរបស់ជនសង្ស័យឬជនជាប់ចោទ

គ) អភ័យឯកសិទ្ធិឲ្យរួចផុតពីយុត្តាធិការរដ្ឋប្បវេណីនិងព្រហ្មទណ្ឌចំពោះពាក្យពេចន៍ដែលបាននិយាយឬសរសេរ និងសកម្មភាពដែលបានបំពេញក្នុងតំណែងផ្លូវការរបស់គេក្នុងនាមជាមេធាវី ។ អភ័យឯកសិទ្ធិបែបនេះនៅបន្តផ្តល់ចំពោះពួកគេក្រោយពួកគេបញ្ចប់មុខងារជាមេធាវីរបស់ជនសង្ស័យឬជនជាប់ចោទ ។

៤) បណ្ណសារដ្ឋានរបស់សហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញា អង្គជំនុំជម្រះ វិសាមញ្ញ អង្គបុរេជំនុំជម្រះ និងការិយាល័យរដ្ឋបាល និងជាទូទៅឯកសារនិងសម្ភារៈទាំងអស់ដែលអាចរកបាន ហើយដែលជាកម្មសិទ្ធិរបស់អ្នកទាំងនោះ ឬប្រើប្រាស់ដោយអ្នកទាំងនោះ ទោះជាស្ថិតនៅកន្លែងណានៃព្រះរាជាណាចក្រកម្ពុជាក៏ដោយ និងគ្រប់គ្រងដោយជនណាក៏ដោយ គឺមិនអាចត្រូវបានរំលោភបំពានក្នុងរយៈពេលនៃកិច្ចដំណើរការជំនុំជម្រះនេះឡើយ ។

### មាត្រា៤៣ថ្មី

អង្គជំនុំជម្រះវិសាមញ្ញដែលធ្វើឡើងនៅថ្នាក់សាលាដំបូង និងតុលាការកំពូលមានទីតាំងនៅក្នុងទីក្រុងភ្នំពេញ ។

### មាត្រា៤៤ថ្មី

ការចំណាយនិងប្រាក់បៀវត្សរបស់អង្គជំនុំជម្រះវិសាមញ្ញមានៈ

១) ការចំណាយនិងប្រាក់បៀវត្សចំពោះមន្ត្រីរដ្ឋបាលនិងបុគ្គលិកខ្មែរ ចំពោះចៅក្រមជំនុំជម្រះក្តីនិងចៅក្រមជម្រះក្តីបម្រុង ចៅក្រមស៊ើបអង្កេតនិងចៅក្រមស៊ើបអង្កេតបម្រុង ព្រះរាជអាជ្ញានិងព្រះរាជអាជ្ញាបម្រុងខ្មែរទាំងអស់ ជាបន្ទុករបស់ថវិកាជាតិខ្មែរ ។

២) ការចំណាយចំពោះមន្ត្រីរដ្ឋបាលនិងបុគ្គលិកបរទេស ចៅក្រមជម្រះក្តី សហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេតបរទេសដែលបញ្ជូនមកដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ជាបន្ទុករបស់អង្គការសហប្រជាជាតិ ។

៣) មេធាវីការពារក្តីអាចទទួលប្រាក់កម្រៃពីកិច្ចការពារក្តីរបស់ខ្លួន ។

៤) ការចំណាយសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក៏អាចទទួលបន្ថែមនូវមូលនិធិស្ម័គ្រចិត្តដទៃទៀតដូចជា រដ្ឋាភិបាលបរទេស ស្ថាប័នអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាលនានា ហើយនិងបុគ្គលិកដែលមានបំណងចង់ជួយដល់កិច្ចដំណើរការនេះ ។

### មាត្រា៤៥ថ្មី

ភាសាដែលប្រើប្រាស់ជាផ្លូវការក្នុងការងាររបស់អង្គជំនុំជម្រះវិសាមញ្ញគឺភាសាខ្មែរ ភាសាអង់គ្លេស និងភាសាបារាំង ។

### មាត្រា៤៦ថ្មី

ដើម្បីធានាការអនុវត្តច្បាប់នេះបានទាន់ពេលវេលានិងមិនរអាក់រអួលក្នុងករណីដែលចៅក្រមជម្រះក្តី ឬចៅក្រមស៊ើបអង្កេត ឬព្រះរាជអាជ្ញាបរទេសណាមួយមិនបានចូលរួម ឬបដិសេធមិនចូលរួមក្នុងអង្គជំនុំជម្រះវិសាមញ្ញ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជ្រើសតាំងចៅក្រមជម្រះក្តី ឬចៅក្រមស៊ើបអង្កេត ឬព្រះរាជអាជ្ញាផ្សេងទៀត ឲ្យបំពេញកន្លែងទំនេរក្នុងចំណោមបញ្ជីបេក្ខជនបរទេសដែលមានចែងក្នុងមាត្រា១១ មាត្រា១៨ និងមាត្រា២៦ នៃច្បាប់នេះ ។ ក្នុងករណីដែលឈ្មោះក្នុងបញ្ជីត្រូវបានប្រើអស់ ហើយលោកអគ្គលេខាធិការអង្គការសហប្រជាជាតិពុំបានផ្តល់បញ្ជីឈ្មោះបេក្ខជនថ្មីបន្ថែម ឬក្នុងករណីដែលអង្គការសហប្រជាជាតិដកការគាំទ្រពីអង្គជំនុំជម្រះវិសាមញ្ញ កន្លែងទំនេរទាំងនោះត្រូវបំពេញបន្ថែមដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមពីបណ្តាបេក្ខជនដែលបានស្នើឡើងដោយរដ្ឋាភិបាលនៃបណ្តារដ្ឋជាសមាជិកនៃអង្គការសហប្រជាជាតិ ឬពីក្នុងចំណោមឥស្សរជនច្បាប់បរទេសដទៃទៀត ។

បន្ទាប់ពីអនុវត្តនីតិវិធីនេះហើយ បើនៅតែគ្មានចៅក្រមជម្រះក្តី ឬចៅក្រមស៊ើបអង្កេត ឬព្រះរាជអាជ្ញាបរទេសចូលរួមក្នុងការងាររបស់អង្គជំនុំជម្រះវិសាមញ្ញ ហើយគ្មានបេក្ខជនបរទេសណាត្រូវបានជ្រើសរើសឲ្យបំពេញតំណែងទំនេរនេះទេ នៅពេលនោះឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមអាចជ្រើសតាំងចៅក្រមជម្រះក្តី ឬចៅក្រមស៊ើបអង្កេត ឬព្រះរាជអាជ្ញាខ្មែរជំនួស ។

### មាត្រា៤៧ស្ទួន

ក្រោយពេលផ្តល់សច្ចាប័នសមស្របតាមបទបញ្ញត្តិនៃច្បាប់ព្រះរាជាណាចក្រកម្ពុជាទាក់ទងទៅនឹងសមត្ថកិច្ចនៃការចុះសន្ធិសញ្ញាកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ធ្វើនៅភ្នំពេញថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ ត្រូវអនុវត្តជាច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**ពន្យល់ពាក្យខ្មែរក្រហម**

- **មីទិញៈ** ការប្រជុំគ្នាដើម្បីសម្រេច និងប្តូរយោបល់គ្នាពីរឿងអ្វីមួយ ហើយប្រកាសឡើងតាមកាសែត ។
- **របនាសម្ព័ន្ធៈ** ការចងភ្ជាប់នៃកិច្ចដែលធ្វើឲ្យកើតឡើងឬមិត្តភាព ។
- **បក្សសម្ព័ន្ធៈ** ការចងភ្ជាប់ជាពួក ជាក្រុម ។
- **ទ្រឹស្តីៈ** វិជ្ជាសមត្ថភាពខាងវោហារ ។

*(ដកស្រង់ចេញពីសៀវភៅកំណត់ហេតុលេខ១១០)*

# អង្គការសង្គមស៊ីវិលអំពាវនាវឱ្យមានបទដ្ឋានអន្តរជាតិសម្រាប់តុលាការខ្មែរក្រហម

យើងខ្ញុំជាសមាជិកគណៈកម្មាធិការប្រព្រឹត្តិកម្មនិងអង្គការសង្គមស៊ីវិលដទៃទៀតសូមកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិ ដែលបានយកចិត្តទុកដាក់លើដំណើរការនៃការបង្កើតសាលាក្តីសម្រាប់កាត់ទោសអតីតមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ហើយឈានដល់ការចុះកិច្ចព្រមព្រៀងស្តីពីការកាត់ទោសចំពោះបទឧក្រិដ្ឋដែលប្រព្រឹត្តក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ។ យើងរំពឹងទុកថារាជរដ្ឋាភិបាលថ្មីនឹងបន្តដំរុញសាលាក្តីនេះឲ្យលេចជារូបរាងក្នុងពេលដ៏ឆាប់ខាងមុខ ហើយតុលាការយុត្តិធម៌គួរឲ្យទុកចិត្តបានមានតម្លាភាព និងឯករាជ្យ សម្រាប់កាត់ក្តីខ្មែរក្រហម អាចនាំមកនូវក្តីសង្ឃឹមថ្មីសម្រាប់សង្គមកម្ពុជា ដើម្បីរំដោះយើងចេញពីអតីតកាល និងឆ្ពោះដំណើរទៅអនាគត ។ ជាការចូលរួមចំណែកដើម្បីធានាឲ្យមានយុត្តិធម៌តាមបទដ្ឋានអន្តរជាតិសម្រាប់សាលាក្តីកាត់ទោសអតីតមេដឹកនាំខ្មែរក្រហម យើងខ្ញុំជាសមាជិកអង្គការសង្គមស៊ីវិលសូមអំពាវនាវដោយទទូចដូចខាងក្រោមៈ

**១) លក្ខណៈវិនិច្ឆ័យសម្រាប់ចៅក្រមៈ បេក្ខជនត្រូវតែជាបុគ្គលដែលមានចរិតលក្ខណៈស្មារតីខ្ពស់ មិនលម្អៀង សុចរិតទៀងត្រង់ និងមានការប៉ិនប្រសប់ ហើយឆ្លងកាត់ការបណ្តុះបណ្តាល ឬមានសមត្ថភាពខាងផ្លូវច្បាប់ ហើយត្រូវតែៈ**

◆ ជាបុគ្គលដែលមានក្រមសីលធម៌ខ្ពស់ មានសេចក្តីសុចរិតទៀងត្រង់ អព្យាក្រឹត មានការប៉ិនប្រសប់ ហើយជាបុគ្គលដែលត្រូវបានគេគោរព ។ ◆ បេក្ខជនត្រូវប្តេជ្ញាប្រកាន់ឯករាជ្យភាពក្នុងពេលបំពេញមុខងាររបស់ខ្លួន និងមិនអាចទទួលឬស្វះស្វែងរកការណែនាំពីរដ្ឋាភិបាលឬប្រភពណាមួយផ្សេងទៀតឡើយ ។ ◆ចៅក្រមមិនត្រូវជ្រើសរើសក្នុងចំណោមបុគ្គលដែលអាចវិសមិតលើរឿងក្តីដូចជាបុគ្គលណាដែលមានប្រយោជន៍ផ្ទាល់ខ្លួនលើរឿងក្តី ឬមានទំនាក់ទំនងផ្ទាល់ ឬបេក្ខជនដែលកន្លងមកធ្លាប់ពាក់ព័ន្ធនឹងរឿងក្តី ទោះក្នុងសមត្ថភាពអ្វីក៏ដោយ នៅក្នុងប្រទេសរបស់ខ្លួនដែលទំនងជានឹងត្រូវស៊ើបអង្កេតឬផ្តន្ទាទោសដោយតុលាការ ។ ◆ បេក្ខជនមិនត្រូវជាសមាជិករបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមទេ ។ ◆ បេក្ខជនត្រូវតែមានគុណសម្បត្តិដែលតម្រូវតាមប្រទេសរៀងៗខ្លួនសម្រាប់តែងតាំងឲ្យបម្រើការនៅក្នុងតុលាការ ។ ◆ បេក្ខជនត្រូវតែជាបុគ្គលមានបទពិសោធន៍ជាចៅក្រមបច្ចុប្បន្ន ឬជាអតីតចៅក្រម ឬមានបទពិសោធន៍ផ្នែកច្បាប់ព្រហ្មទណ្ឌ ច្បាប់អន្តរជាតិ រួមទាំងច្បាប់មនុស្សធម៌ និងច្បាប់សិទ្ធិមនុស្សអន្តរជាតិ ។ ◆បេក្ខជនសម្រាប់ការងារខាងតុលាការត្រូវតែបានបញ្ចប់វគ្គបណ្តុះបណ្តាលខាងផ្នែកច្បាប់ ហើយត្រូវមានបរិញ្ញាប័ត្រច្បាប់ ឬសញ្ញាប័ត្រស្មើ ។ ◆ បេក្ខជនត្រូវមានបទពសោធន៍ការងារក្នុងវិស័យច្បាប់យ៉ាងហោចណាស់ពីពឆ្នាំទៅ៧ឆ្នាំ ។

**២) បេក្ខជនត្រូវជ្រើសរើសតាមនីតិវិធីបើកចំហនិងត្រឹមត្រូវយុត្តិធម៌**

◆ ពត៌មានស្តីពីការជ្រើសរើសត្រូវប្រកាសផ្សព្វផ្សាយជាសាធារណៈ ◆ពាក្យសុំចូលធ្វើការត្រូវពិនិត្យពិច័យឲ្យបានហ្មត់ចត់ ◆ ពិគ្រោះយោបល់ជាមួយតំណាងសង្គមស៊ីវិល ◆ការជ្រើសរើសតែងតាំងចៅក្រមត្រូវជ្រើសរើសឲ្យបានត្រឹមត្រូវតាមទិសគោលដៅនិងមានតម្លាភាព ផ្អែកលើគុណសម្បត្តិវិជ្ជាជីវៈ និងមិនរើសអើងភេទ ហើយត្រូវជ្រើសរើសដោយស្ថាប័នឯករាជ្យដែលមានចៅក្រមជាសមាជិក ។ ◆ ការជ្រើសរើសបុគ្គលក្រសួងតុលាការត្រូវរក្សាតាមវិធីដូចខាងលើ ដោយប្រុងប្រយ័ត្នជានិច្ចកុំឲ្យមានការចាត់តាំងបុគ្គលិកដែលមានសមត្ថភាពពុំសមរម្យ ។ ក្នុងការជ្រើសរើសចៅក្រមពុំត្រូវមានការរើសអើងដោយសំអាងទៅលើពូជសាសន៍ ពណ៌សម្បុរ ភេទ សាសនា គោលជំហរនយោបាយ ឬទស្សនៈបុគ្គល ដើមកំណើតជាតិសាសន៍ ឬសង្គមទ្រព្យសម្បត្តិនិងកំណើត ឬស្ថានភាពអ្វីឡើយ ។

ជាចុងក្រោយ សមាជិកគណៈកម្មាធិការប្រព្រឹត្តិកម្មនិងអង្គការសង្គមស៊ីវិលទទូចសូមឲ្យដំណើរការជុំវិញការបង្កើតសាលាក្តីខ្មែរក្រហម ដូចជាការជ្រើសរើសចៅក្រម ព្រះរាជអាជ្ញាបុគ្គលិកតុលាការ ការធ្វើសេចក្តីព្រាងច្បាប់ និងនីតិវិធីផ្សេងៗទាក់ទងនឹងដំណើរការខ្មែរក្រហម ព្រមទាំងដំណើរការផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិ ត្រូវមានតម្លាភាពនិងបើកចំហ ហើយត្រូវសម្រួលឲ្យមានការចូលរួមពីអង្គការសង្គមស៊ីវិល ។

ភ្នំពេញ, ថ្ងៃទី៩ ខែសីហា ឆ្នាំ២០០៤



ព្រះសង្ឃសូត្រធម៌បង្សុកូលជូនដល់ព្រលឹងជនរងគ្រោះនៅមន្ទីរ ស-២១

# ការផ្សះផ្សានៅកម្ពុជា

(តចប់)

### ខ្មែរក្រហមឬបក្សកុម្មុយនិស្តកម្ពុជា

អតីតមេដឹកនាំខ្មែរក្រហមតែងតែប្រើប្រាស់យុទ្ធសាស្ត្របដិសេធមិនទទួលខុសត្រូវជាច្រើនលើកច្រើនសា ។ អតីតមេដឹកនាំទាំងនេះបដិសេធការពិតនៃអំពើឃោរឃៅ បដិសេធទំហំនៃអំពើឃោរឃៅ បដិសេធមិនដឹងមិនឮអំពីអ្វីដែលបានកើតឡើងនៅតាមមូលដ្ឋាន បដិសេធការជាប់ពាក់ព័ន្ធនឹងអ្វីៗទាំងអស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងបដិសេធចំពោះការចូលរួមជាបុគ្គលឬចំពោះការទទួលខុសត្រូវក្នុងនាមជាមេដឹកនាំ ។ តាមរយៈបទសម្ភាសន៍ផ្សេងៗដែលបានធ្វើឡើងកន្លងមកនេះ សម្រាប់មេដឹកនាំខ្មែរក្រហម ការផ្សះផ្សាជាតិមានអត្ថន័យថាអ្នកផ្សេងត្រូវតែទទួលស្គាល់ថាមេដឹកនាំខ្មែរក្រហមមិនមែនជាអ្នកធ្វើខុសទេ ហើយក្នុងគ្រប់ករណីទាំងអស់ រាល់ការឈឺចាប់ដែលបានកើតឡើងគឺជារឿងអចេតនា ជាភាពអកុសលដែលកើតចេញពីបំណងល្អរបស់កម្ពុជាប្រជាធិបតេយ្យ ។ ប្រជាជនកម្ពុជាត្រូវតែបណ្តោយឲ្យអតីតកាលកន្លងផុតទៅ ។ ជនរងគ្រោះនិងអ្នកនៅរស់ពីរបបកម្ពុជាប្រជាធិបតេយ្យគឺជាអ្នកដែលត្រូវតែស្វែងរកការអត់ឱននិងការផ្សះផ្សានៅក្នុងខ្លួនដោយខ្លួនឯង ដើម្បីអាចរស់នៅជាមួយគ្នាដោយសុខសាន្ត និងកសាងអនាគតដ៏រុងរឿងមួយសម្រាប់កម្ពុជា ។ តាមរយៈការចូលសារភាពនិងទទួលស្គាល់អំណាចរបស់ព្រះមហាក្សត្រនិងព្រះរាជាណាចក្រកម្ពុជា មេដឹកនាំនិងកងទ័ពខ្មែរក្រហមយល់ថា ខ្លួនបានធ្វើអ្វីដែលខ្លួនត្រូវធ្វើសម្រាប់ឲ្យមានការផ្សះផ្សាហើយ ។ មេដឹកនាំខ្មែរក្រហមគ្មានអារម្មណ៍ខ្មាសអៀនឬវិប្បដិសារីចំពោះការឈឺចាប់និងការបំផ្លិចបំផ្លាញជាតិដែលបានកើតឡើងទេ ។ កន្លងមកមាន "ការសុំអភ័យទោស"ខ្លះដែរ ឧទាហរណ៍ធ្វើដោយ នួន ជា និង ខៀវសំផន ។ ប៉ុន្តែអតីតមេដឹកនាំទាំងពីររូបនេះគ្រាន់តែបានបកស្រាយថា "អ្វីៗទាំងអស់គឺធ្វើឡើងក្នុងគោលបំណងល្អ" "ខ្ញុំមិនបានដឹងថាមានអ្វីកើតឡើងទេ" ឬថា "ខ្ញុំគ្មានពាក់ព័ន្ធអ្វីនឹងរឿងទាំងនោះទេ" ។ នៅក្នុងលិខិតរបស់ ខៀវ សំផន កាលពីថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៣ ទោះជាបានទទួលស្គាល់ថា ចលនាដែលគាត់ជាអ្នកដឹកនាំបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍ក៏ដោយ ក៏លិខិតនេះរៀបរាប់មិនខុសពីលិខិតមុនដែរ ។ កំហុសត្រូវបានចោទទៅលើអ្នកផ្សេង ពិសេសគឺវៀតណាមនិង ប៉ុលពត ដែលស្លាប់បាត់ទៅហើយ ។ មេដឹកនាំទាំងពីរបានលើកឡើងថា ចំណុចសំខាន់នោះមិនមែនថាតើត្រូវមានឬមិនមានតុលាការនោះទេ ប៉ុន្តែថាតើតុលាការនឹងនាំឲ្យមានការផ្សះផ្សាជាតិដែរឬក៏អត់ ។ ការគំរាមគំហែងដោយកំបាំងមុខឬជួនកាលដោយចំហថាអំពើហិង្សាអាចកើតឡើងសាជាថ្មី តែងតែត្រូវបានបញ្ចេញឡើងនៅពេលដែលមានការលើកឡើងអំពីការទទួលខុសត្រូវជាបុគ្គលចំពោះអំពើហិង្សាក្នុងរបបខ្មែរក្រហម ។

គួរឲ្យចាប់អារម្មណ៍ណាស់ដែលទង្វើនេះមិនត្រូវបានបញ្ជាក់នៅក្នុងបទសម្ភាសន៍ជាមួយនឹងកម្មាភិបាលខ្មែរក្រហមថ្នាក់ទាបដែលភាគច្រើនលើសលុបបានស្តីបន្ទោសមេដឹកនាំខ្មែរក្រហម និងបានព្យាយាមពន្យល់ថាការទទួលខុសត្រូវរបស់កម្មាភិបាលថ្នាក់ទាបមិនសំខាន់ទេ ដោយលើកហេតុផលថាពេលនោះខ្លួនគ្មានជម្រើស ដោយសារថ្នាក់លើគំរាមសម្លាប់ និងដោយសារការបំពាក់បំប៉ននយោបាយកម្រិតខ្ពស់ ។

### ១) ទស្សនាវដ្តីស្វែងរកការពិត

ទោះជាមានអ្នកឆ្លើយចំនួន៩,៤៨ភាគរយនិយាយថាបានអានទស្សនាវដ្តីស្វែងរកការពិតជាប្រចាំ និង៣៤,២៧ភាគរយទៀតថាបានអានម្តងម្កាលក៏ដោយ ក៏ចម្លើយទូទៅបញ្ជាក់ច្បាស់ថាទស្សនាវដ្តីស្វែងរកការពិតជាទស្សនាវដ្តីល្អនិងផ្តល់នូវព័ត៌មានដែលមានសារសំខាន់ ។ អ្វីដែលបោះពុម្ពផ្សាយនៅក្នុងទស្សនាវដ្តីនេះគឺជាក់ស្តែងនិងមានលក្ខណៈស្មោះត្រង់ (៧២,៧៥ភាគរយពោលថា ទស្សនាវដ្តីបង្ហាញអំពី "ជីវិតពិត" របស់ប្រជាជនកម្ពុជា

នៅក្រោមរបបខ្មែរក្រហម) ។ ៦២,៥០ភាគរយយល់ថា ទស្សនាវដ្តីស្វែងរកការពិតបានរួមចំណែកនៅក្នុងការព្យាបាលដំបៅសង្គមរបស់ប្រទេសកម្ពុជា ដែលទាក់ទងទៅនឹងចម្លើយនៅក្នុងសំណួរ១៥ ។ នៅក្នុងសំណួរ១៥ អ្នកឆ្លើយចំនួន៨៧,២២ ភាគរយយល់ថាទស្សនាវដ្តីមានសារសំខាន់ចំពោះប្រជាជនកម្ពុជាទូទៅ (ទោះជាមានតែ២៦,៩៧ភាគរយយល់ថាទស្សនាវដ្តីស្វែងរកការពិតបានរួមចំណែកនៅក្នុងការផ្សះផ្សាជាតិក៏ដោយ) ។ អ្នកឆ្លើយភាគច្រើន (៦៧,៦៣ភាគរយ) ចង់ឲ្យមានពត៌មានចម្រុះអំពីអ្វីៗដែលបានកើតឡើង ពោលគឺចង់ឲ្យចុះផ្សាយអំពីជនរងគ្រោះ ជនដៃដល់ និងទង្វើទូទៅដែលអ្នកទាំងនេះយល់ថាមានសារប្រយោជន៍ជួយបង្កើនល្បឿនផ្សះផ្សាជាតិ ។

អ្នកឆ្លើយលេខ២យល់ថាទស្សនាវដ្តីស្វែងរកការពិតបាននាំមកនូវភាពធូរស្បើយក្នុងអារម្មណ៍តាមរយៈ"ការបង្ហាញអំពីការពិតនៃអំពើប្រល័យពូជសាសន៍" ។ អ្នកឆ្លើយលេខ១១៦ រស់នៅទីក្រុងភ្នំពេញ យល់ថាទស្សនាវដ្តីរួមចំណែកដោយផ្ទាល់ដល់ដំណើរការផ្សះផ្សានៅក្នុងសង្គមកម្ពុជា ពីព្រោះថាទស្សនាវដ្តីនេះ"បង្ហាញដល់សហគមន៍ជាតិនិងអន្តរជាតិនូវរបបខ្មែរក្រហមសម្រាប់គោលបំណងព្យាបាលរបួសជាតិដែលនៅរ៉ាំរ៉ៃក្នុងសង្គមកម្ពុជាអស់រយៈពេលជាយូរមកហើយ" ។ អ្នកឆ្លើយលេខ២៧០ យល់ថា ទស្សនាវដ្តី"អនុញ្ញាតឲ្យប្រជាជនកម្ពុជាឃើញច្បាស់ថារាល់កម្មាភិបាលខ្មែរក្រហមទាំងអស់ក៏ជាជនរងគ្រោះដែរ ព្រោះថាបើមិនធ្វើតាមបញ្ជា កម្មាភិបាលទាំងនោះនឹងមានវាសនាដូចអ្នកផ្សេងដែរ ។ ហេតុនេះ កម្មាភិបាលទាំងនេះធ្វើអ្វីៗដើម្បីកុំឲ្យអង្គការចាប់កំហុសបានតែប៉ុណ្ណោះ ។ នៅពេលដែលមនុស្សគ្រប់រូបយល់ច្បាស់អំពីហេតុផលនេះ ការសងសឹកនិងការគុំកួននឹងរលាយសាបសូន្យ ។ ពេលនោះនឹងមានការយោគយល់គ្នាទៅវិញទៅមក ការអាណិតអាសូរគ្នា និងទីបញ្ចប់នៃការស្អប់ខ្ពើមដែលសុទ្ធតែជាកត្តាសំខាន់ក្នុងការព្យាបាលរបួសសង្គម" ។ អ្នកឆ្លើយជាច្រើនមានអារម្មណ៍ថាទស្សនាវដ្តីបង្ហាញអំពីការពិតនៃជីវិតនៅក្រោមរបបខ្មែរក្រហម ។ ឧទាហរណ៍ អ្នកឆ្លើយលេខ៨៨យល់ថា ទស្សនាវដ្តីបានពិភាក្សាអំពី"ជីវិតពិតនៅកម្ពុជា ដែលជាហេតុធ្វើឲ្យប្រជាជនយល់អំពីការពិតនៅក្នុងសង្គមខ្មែរបច្ចុប្បន្ន" ។ ដូចគ្នាដែរ អ្នកឆ្លើយលេខ៨៧យល់ថា ទស្សនាវដ្តី"ជួយប្រជាជនកម្ពុជាឲ្យចងចាំប្រវត្តិសាស្ត្រ និងឲ្យស្គាល់អំពីជីវិតពិតនៅក្នុងរបបប៉ុលពត" ។

អ្នកឆ្លើយចំនួន៥៤,៦៣ភាគរយចង់ឲ្យទស្សនាវដ្តីស្វែងរកការពិតដើរតួនាទីជាអ្នកផ្តល់ពត៌មានថ្មីៗទាក់ទងនឹងតុលាការខ្មែរក្រហម ហើយចង់ឲ្យទស្សនាវដ្តីនេះធ្វើជាប្រភពឯកសារនិងពត៌មានផ្នែកច្បាប់ទាក់ទងនឹងតុលាការខ្មែរក្រហម ។ ៤៥,២២ ភាគរយចង់ឲ្យទស្សនាវដ្តី"ដើរតួជាស្ពានឆ្លោះទៅរកការផ្សះផ្សាជាតិ" ។ ៥២,៩១ភាគរយទៀតចង់ឲ្យទស្សនាវដ្តីចុះផ្សាយអំពីអត្ថបទទាក់ទងទៅនឹងហេតុផលនៃ"ការធ្វើទារុណកម្មនិងកាប់សម្លាប់ប្រជាជនខ្មែរពីខ្មែរក្រហម" ។ ២៥,០៥ភាគរយចង់ឲ្យទស្សនាវដ្តីផ្សាយអំពី"ការបកស្រាយពន្យល់"របស់ខ្មែរក្រហម ។

មានចំណុចជាច្រើនទៀតដែលបញ្ជាក់ថាអ្នកឆ្លើយមានការយល់ច្រឡំអំពីតួនាទីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជានៅក្នុងការកាត់ទោសខ្មែរក្រហម ។ ឧទាហរណ៍អ្នកឆ្លើយចំនួន១៥,៣១ ភាគរយជ្រើសថា មជ្ឈមណ្ឌលគួរតែដើរតួជាអាជ្ញាកណ្តាលដឹកនាំការសម្រុះសម្រួលរវាងជនរងគ្រោះនិងជនដៃដល់ ។

## គ) ការរកឃើញផ្សេងទៀត

២៨ឆ្នាំបានកន្លងផុតទៅតាំងតែពីពេលដែលខ្មែរក្រហមផ្តើមបានអំណាច បន្ទាប់មកបំផ្លិចបំផ្លាញជីវិតជនរួមជាតិឯងអស់ជាច្រើនលាននាក់ ។ ការស្ទាបស្ទង់មតិរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្ហាញអំពីរូបភាពដ៏គួរឲ្យសោកសៅមួយនៃភាពខ្ទេចខ្ទាំក្នុងកម្រិតបុគ្គលដែលនៅតែលគោលក្នុងប្រទេសកម្ពុជារហូតមកដល់ថ្ងៃនេះ ។ អ្នកឆ្លើយជាច្រើនលើសលុបគឺ៨៩,៤២ភាគរយ បានបាត់បង់ញាតិសន្តានជាច្រើននាក់នៅក្នុងរបបខ្មែរក្រហម ដែលក្នុងនោះមាន៥៧,០២ភាគរយបានបាត់បង់ញាតិសន្តានយ៉ាងហោចណាស់ក៏ម្នាក់ដែរ ។ ៧៧,៣២ ភាគរយបានបញ្ជាក់អំពីការទទួលទារុណកម្ម ។ ការរំឭកអំពីរបបខ្មែរក្រហមធ្វើឲ្យអ្នកឆ្លើយចំនួន៦៣,២៨ភាគរយនឹកឃើញអំពីការកាប់សម្លាប់ ៣១,៥៣ភាគរយនឹកឃើញអំពីភាពស្រេកឃ្លានអាហារ ២៩,៨ភាគរយនឹកឃើញអំពីការបង្ខំឲ្យធ្វើការបាក់កម្លាំង និង២៣,១១ភាគរយនឹកឃើញអំពីការបែកបាក់

គ្រួសារ ។ ការស្ទាបស្ទង់មតិនេះបានរកឃើញថា មានអ្នកឆ្លើយចំនួន៥៨,៧៥ភាគរយនៅតែគិតអំពីអតីតកាល ហើយ៥៧,០២ភាគរយបកស្រាយថាមានបញ្ហាផ្ទាល់ខ្លួនដោយសារតែបានឃើញការកាប់សម្លាប់ ។ របបកម្ពុជាប្រជាធិបតេយ្យនៅតែជាស្រមោលអន្ធការតាមយាយីក្តីសង្ឃឹមរបស់ប្រជាជនកម្ពុជាគ្រប់ពេលវេលា ។ ទោះជាយ៉ាងណាក៏ដោយ យើងត្រូវកត់សម្គាល់ថា នៅក្នុងចម្លើយ ទស្សនៈទាំងអស់ផ្តោតទៅលើ“អ្វីដែលបានធ្វើមកលើយើង” និង “អ្វីដែលខ្មែរបានធ្វើមកលើខ្មែរ” ដែលផ្ទុយនឹងទស្សនៈថា “យើងបានធ្វើអ្វីខ្លះចំពោះអ្នកផ្សេង” ។ អ្នកផ្សេងនៅក្នុងនេះសំដៅទៅលើជាតិពន្ធវៀតណាមនិងចាមដែលរស់នៅក្នុងប្រទេសកម្ពុជា ។ អ្នកដែលត្រូវចាត់ទុកថាជា “អ្នកផ្សេង” ហាក់មិនត្រូវបានរាប់បញ្ចូលនៅក្នុងការផ្សះផ្សានិងបង្រួបបង្រួមជាតិទេ ។

ការផ្សះផ្សានៅក្នុងសង្គមបែកបាក់មួយអាចធ្វើបានលុះត្រាតែមានការវិវត្តន៍ខ្លះខាងផ្នែកសន្តិសុខតាំងតែពីពេលសោកនាដកម្មបានបញ្ចប់ម្ល៉េះ ។ អ្នកជំនាញមួយចំនួនបាននិយាយថា ដំបូង ប្រជាជនទាំងអស់ត្រូវជឿជាក់ថា ប្រភពដើមនៃការបែងចែកនិងការផាត់ចេញត្រូវបានកែប្រែ ហេតុនេះការឈឺចាប់របស់បុគ្គលនិងអតីតកាលទាំងមូលត្រូវបានទទួលស្គាល់ ។ នៅពេលដែលរៀបរាប់អំពីការផ្សះផ្សានិងបង្រួបបង្រួមជាតិ អ្នកឆ្លើយបានរៀបរាប់ដោយពាក្យពេចន៍ដែលបញ្ជាក់យ៉ាងច្បាស់ថា ការផ្សះផ្សានិងបង្រួបបង្រួមជាតិជាឧត្តមគតិដែលកម្ពុជាមិនទាន់សម្រេចបាននៅឡើយទេ ។ ឧត្តមគតិនេះស្ថិតនៅយ៉ាងឆ្ងាយពីអ្វី ដែលអ្នកនយោបាយកំពុងតែឃោសនា ។ កម្ពុជាកំពុងតែធ្វើដំណើរចេញពីភាពរន្ធត់នៃជម្លោះប្រដាប់អាវុធនិងការរំលោភសិទ្ធិមនុស្សជាមូលដ្ឋានធ្ងន់ធ្ងរបំផុត ឆ្ពោះទៅរកការស្តារនិងកសាងឡើងវិញនិងការអភិវឌ្ឍប្រទេស ក៏ប៉ុន្តែកម្ពុជានៅតែជាសង្គមបែកបាក់និងពោរពេញទៅដោយភាពហិង្សាដែលក្នុងសង្គមបែបនោះ សន្តិសុខក្នុងការរស់នៅនិងការបំពេញនូវតម្រូវការរបស់បុគ្គលនៅតែមានភាពមិនច្បាស់លាស់ ។ អ្នកនយោបាយអាចផ្សះផ្សាគ្នាដោយការចរចានយោបាយ ប៉ុន្តែប្រជាជនកម្ពុជាសាមញ្ញមិនមានអារម្មណ៍ថាបានផ្សះផ្សាឬបង្រួបបង្រួមឡើយ ឬគ្មានការជឿជាក់ទៅលើមេដឹកនាំរបស់ខ្លួនទេ ។ ទោះបីជាមានសញ្ញាថាមានការផ្សះផ្សាខ្លះនៅក្នុងកម្រិតមូលដ្ឋានក៏ដោយ ក៏កម្ពុជានៅតែជាសង្គមខូចខាតនិងបែកបាក់ដដែល ។

បទពិសោធន៍របស់អ្នកឆ្លើយសំណួរបានជះឥទ្ធិពលទៅលើទស្សនៈរបស់ខ្លួន ។ ប្រជាជនទូទៅសប្បាយចិត្តណាស់ដែលសង្គ្រាមត្រូវបានបញ្ចប់ជាមួយនឹងការព្រួយបារម្ភថាវាអាចកើតឡើងសាជាថ្មី ។ សឹងតែរាល់អ្នកឆ្លើយទាំងអស់ រៀបរាប់អំពីពាក្យសន្តិភាពក្នុងទម្រង់មួយដែលបង្ហាញថា សន្តិភាពគឺជាអ្វីដែលមិនងាយនឹងទទួលបាន ។ ក្រោយពីមានការបង្ហូរឈាមជាច្រើនឆ្នាំមក ច្បាស់លាស់ណាស់ថា ប្រជាជនកម្ពុជាមានការភ័យខ្លាចចំពោះអ្វីដែលអាចធ្វើឲ្យមានអំពើហិង្សាឡើងវិញ ។ ហេតុនេះប្រជាជនកម្ពុជាងាយនឹងទទួលយកយោបល់ថា តុលាការខ្មែរក្រហមអាច “ធ្វើឲ្យទូកឃ្លេងឃ្លោង” ហើយធ្វើឲ្យមានចលាចលក្នុងកម្រិតទាប និងជម្លោះប្រដាប់អាវុធសាជាថ្មីក្នុងកម្រិតធ្ងន់ ។ សម្តីនេះត្រូវបានបញ្ចេញជាញឹកញយពីរដ្ឋាភិបាលនិងអតីតមេដឹកនាំខ្មែរក្រហម ។ អ្នកសង្កេតការណ៍អន្តរជាតិបានវាយតម្លៃជាប្រចាំថា ការកើតឡើងជាថ្មីនៃអំពើហិង្សាត្រូវបានប្រើប្រាស់ជាលេសក្នុងបញ្ហាយុត្តិធម៌ ។ ចម្លើយដែលទទួលបានពីការស្ទាបស្ទង់ផ្សេងទៀតបានបញ្ជាក់ច្បាស់ណាស់ថា ភាពប្រថុយប្រថានដែលថាតុលាការខ្មែរក្រហមអាចធ្វើឲ្យខ្មែរក្រហមងាកទៅរកអំពើហិង្សាជាថ្មីគួរតែត្រូវពិចារណា ។ អ្នកឆ្លើយភាគច្រើននៅក្នុងការស្ទាបស្ទង់មតិនេះបានគាំទ្រចំពោះការបង្កើតតុលាការ ។ ៧២,០៥ភាគរយមិនយល់ថាអំពើហិង្សានឹងកើតឡើងសាជាថ្មីទេ ។ ១១,០៩ភាគរយបង្ហាញថាខ្លួនចង់បានតុលាការមួយ ប៉ុន្តែព្រួយបារម្ភថាតុលាការអាចធ្វើឲ្យមាន“ការកើតឡើងសាជាថ្មីនូវភាពចលាចល” ។

ក្រៅពីការចង់បានយ៉ាងលើសលប់នូវយុត្តិធម៌ចំពោះឧក្រិដ្ឋកម្មខ្មែរក្រហម មិនមានការស្រុះស្រួលគ្នាអំពីអ្វីដែលត្រូវធ្វើទេ ប្រហែលមកពីគ្មានដំណោះស្រាយល្អឥតខ្ចោះចំពោះស្ថានការណ៍បែបនេះ ។ ទោះបីជាដោយសារអ្វីដែលបានឆ្លងកាត់និងកំពុងបន្តឆ្លងកាត់ អ្នកឆ្លើយមានការជឿជាក់យ៉ាងមុតមាំថា

អនាគតដ៏រុងរឿងអាចកសាងបាន ។ ប្រវត្តិកម្ពុជាទាក់ទងនឹងការប្រើប្រាស់នយោបាយនៅក្នុងការផ្សះផ្សាដើម្បីបម្រើផលប្រយោជន៍ផ្ទាល់ខ្លួន មិនបានទប់ស្កាត់អ្នកឆ្លើយមិនឲ្យឆ្លើយនូវចម្លើយជាវិជ្ជមានអំពីការផ្សះផ្សាឡើយ ។ អ្នកឆ្លើយស្ទើរតែទាំងអស់យល់ថា ការផ្សះផ្សាមានសារសំខាន់ ។ អ្នកឆ្លើយទាំងនេះនៅតែមានក្តីសង្ឃឹមនិងស្រមើស្រមៃអំពីអនាគតកាន់តែប្រសើរ ហើយបានឆ្លើយទៅនឹងសំណួរទាំងឡាយដោយបញ្ចេញនូវភាពប្តូរផ្តាច់ថា ខ្លួនអាចធ្វើឲ្យកម្ពុជាងើបឈរឡើងវិញនិងដើរទៅមុខ ។ សម្រាប់អ្នកឆ្លើយខ្លះ ព្រះពុទ្ធសាសនាមានឥទ្ធិពលទៅលើអាកប្បកិរិយានិងទស្សនៈ ។ សម្រាប់អ្នកខ្លះទៀត ព្រះពុទ្ធសាសនាហាក់ដូចជាមានឥទ្ធិពលទៅលើទស្សនៈផ្ទាល់ខ្លួនតែមួយផ្នែកប៉ុណ្ណោះ ។ អ្វីដែលអ្នកឆ្លើយភាគច្រើនទំនងជាចង់បានគឺផ្លូវកណ្តាល ជាផ្លូវដែលមានការសម្រុះសម្រួលនិងអហិង្សា ហើយជាផ្លូវដែលនឹងនាំទៅរកការបំពេញបំណងប្រាថ្នា ។ ទស្សនៈរបស់អ្នកឆ្លើយចំពោះអនាគតរបស់ប្រទេសកម្ពុជាគឺចង់បាននូវជាតិមានសន្តិភាពមួយ ដែលពលរដ្ឋទាំងអស់រស់នៅដោយសុខស្រួល ចេះគោរពគ្នាទៅវិញទៅមក មានគុណធម៌ រស់នៅក្នុងភាពជឿនលឿន និងជាផ្នែកមួយនៃសង្គមមួយដែលមានភាពសុចរិតត្រឹមត្រូវដឹកនាំដោយធម្មាធិបតេយ្យ ។ ចំណាប់អារម្មណ៍របស់អ្នកឆ្លើយគឺអំពីការធ្វើអ្វីមួយថ្មីប្លែកនិងល្អសម្រាប់ប្រទេសកម្ពុជាជាជាងការកែកុនអ្វីៗ ដើម្បីឲ្យជីវិតងាកទៅរកសភាពដើមវិញ ។ ការចង់បាននេះអាចកើតឡើងដោយមូលហេតុបាត់បង់ធ្ងន់ធ្ងរពេក ដែលធ្វើឲ្យការនិយាយអំពី"ការស្តារឡើងវិញ" ឬ"ការជួសជុល" ឬ "ការត្រឡប់ទៅរកអ្វីដែលធ្លាប់មាន" ទៅជាអ្វីដែលមិនសមស្រប ហើយថែមទាំងជាការបញ្ឈឺថែមទៀតផង ។

ពត៌មានដែលប្រមូលបានមានភាពលើសលប់គឺថា ទោះបីជាមានការស្មុគស្មាញនិងល័ក្ខខ័ណ្ឌផ្សេងៗទាក់ទងនឹងការទទួលខុសត្រូវ ការអត់ឱន ការសុំទោស និងចំណុចផ្សេងទៀតដែលលេចឡើងក្រោយពីមានអំពើហិង្សាក្នុងទ្រង់ទ្រាយធំនិងអំពើឃោរឃៅក៏ដោយ ក៏ប្រជាជនកម្ពុជាចង់ផ្សះផ្សាជាមួយខ្មែរក្រហម ហើយធ្វើដំណើររួមគ្នាឆ្ពោះទៅរកអនាគតកាន់តែប្រសើរ ។ អ្វីដែលសំខាន់ហាក់ដូចជាមិនមែនជារឿងជនរងគ្រោះនិងជនដៃដល់ទៀតទេ ប៉ុន្តែជាការធ្វើនូវអ្វីដែលចាំបាច់សម្រាប់មនុស្សទាំងអស់ដើម្បីឲ្យជីវិតកាន់តែប្រសើរឡើង ។ ការអត់ឱនមានសារសំខាន់ណាស់ ហើយថែមទាំងត្រូវបានយល់ថាជាគន្លឹះនៃការផ្សះផ្សាថែមទៀត ប៉ុន្តែនៅពេលដែលពិចារណាអំពីបញ្ហាខ្មែរក្រហម អ្នកឆ្លើយភាគច្រើនបដិសេធការអត់ឱនថាជាទម្រង់មួយនៃការបំភ្លេចអតីតកាលចោល ។ នោះគឺអ្នកឆ្លើយពុំយល់ថាការអត់ឱនមានន័យថាជាការមិនទទួលខុសត្រូវជាបុគ្គលហើយធ្វើឲ្យវប្បធម៌នៃការរួចទោសរីកដុះដាលនោះទេ ។ បំណកស្រាយអំពីការអត់ឱនដែលបានរៀបរាប់នៅក្នុងចម្លើយក៏មិនមែនជាការអត់ឱនរវាងជនរងគ្រោះនិងជនដៃដល់ដែរ ផ្ទុយទៅវិញគឺជាការទទួលស្គាល់អ្វីដែលបានកើតឡើង ការដាក់មួយឡែកនូវអារម្មណ៍អវិជ្ជមានដែលធ្វើឲ្យខាតប្រយោជន៍ និងការធ្វើដំណើរទៅរកជីវភាពជាធម្មតានិងសុខស្រួលមួយបែប ។ អ្នកឆ្លើយមិនបានមើលឃើញការអត់ឱនជាការបំភ្លេចអតីតកាលឬជាការអនុញ្ញាតឲ្យជនដៃដល់រួចទោសនោះទេ ។ មនុស្សទាំងអស់ត្រូវតែរៀបចំខ្លួនជាស្រេចដើម្បីទទួលខុសត្រូវចំពោះអ្វីដែលខ្លួនបានធ្វើ ។ អ្នកឆ្លើយភាគច្រើនឲ្យអត្ថន័យចំណុចនេះថាជាការទទួលខុសត្រូវជាបុគ្គលនៅក្នុងតុលាការច្បាប់ ។

ការស្ទាបស្ទង់នេះក៏បានបង្ហាញនូវចម្លើយដ៏ស្មុគស្មាញនិងជូនកាលមានភាពប្រទូសរ៉ាយពីប្រជាជនដែលជីវិតរបស់គាត់ត្រូវបានធ្វើឲ្យមានស្លាកស្នាមដោយអំពើហិង្សានិងអំពើឃោរឃៅក្នុងទ្រង់ទ្រាយធំ ។ ចំណុចនេះបញ្ជាក់ថា ពេលវេលានិងការបញ្ចប់នូវការប្រឈមមុខដាក់គ្នាបានបើកបង្អួចឲ្យមានឱកាសមួយដែលក្នុងនោះការបន្ធូរបន្ថយអាកប្បកិរិយានិងការផ្សះផ្សាបានកើតឡើងនៅប្រទេសកម្ពុជាក្នុងកម្រិតមូលដ្ឋាន ។ អ្នកឆ្លើយមួយចំនួនបានបញ្ជាក់បែបនោះដែរ ។ ក្នុងការស្ទាបស្ទង់នេះនិងការស្ទាបស្ទង់មតិផ្សេងទៀត អ្នកឆ្លើយជាច្រើននៅតែមានកំហឹងចំពោះអ្វីដែលបានកើតឡើង ។ អារម្មណ៍ត្រូវបានផ្អឹបមិនបញ្ចេញ ហើយការមិនពេញចិត្តក៏ចេះតែបន្តមាន ។ អ្នកឆ្លើយលេខ២៧៧ បានទទួលស្គាល់ថា "យើងគួរជួយនិងអត់ឱនឲ្យគ្នា" ប៉ុន្តែអ្នកឆ្លើយរូបនេះមិនអាណិតអាសូរចំពោះអ្នកដែលបានប្រព្រឹត្ត "ការចាប់រំលោភ ការចាប់ជ្រមុជទឹក ការដកក្រចក

ការយកទារកទៅបោកនឹងគល់ឈើទេ តើមាននរណាអាចលើកដៃទៅធ្វើបែបនោះរួច? ប៉ុន្តែខ្មែរក្រហមធ្វើបានពីឆ្នាំ១៩៧៥ ដល់១៩៧៩ ។ ប្រសិនបើយើងគិតឲ្យជ្រៅទៅ មនុស្សជាងបីលាននាក់ដែលស្លាប់គឺសុទ្ធតែជាបងប្អូនឪពុកម្តាយរបស់ខ្មែរក្រហម» ។ អ្នកឆ្លើយលេខ៤១៣ជានារីអាយុ២១ឆ្នាំនៅទីក្រុងភ្នំពេញដែលបានបាត់បង់មីង បងប្រុស ពូ និងជីដូន ជីតា នៅក្នុងរបបខ្មែរក្រហម បានបន្ថែមថា «ដើម្បីសម្រេចឲ្យបាននូវការផ្សះផ្សា យើងទាំងអស់គ្នាត្រូវតែរៀនអត់ឱនឲ្យគ្នាទៅវិញទៅមក ហើយអនុញ្ញាតឲ្យជនទាំងនោះ (ខ្មែរក្រហម) ចូលមកសុំទោសចំពោះទង្វើរបស់ខ្លួនដែលបានធ្វើមកលើប្រជាជន» ។

អ្នកឆ្លើយជាច្រើនមិនអាចអត់ឱននិងអាណិតជនដៃដល់បានទេ ។ ផ្ទុយទៅវិញ អ្នកឆ្លើយចំនួនតិចប៉ុណ្ណោះចង់បានការសងសឹក និងភាគច្រើនចង់បាននូវធម្មាធិបតេយ្យ ដោយបញ្ជាក់អំពីការដោះស្រាយអ្វីៗទាំងអស់នៅក្នុងតុលាការ ។ អ្នកទាំងនេះដឹងជាស្រេចថា ការបញ្ចប់អតីតកាលនិងការគ្រប់គ្រងកំហឹងនិងអារម្មណ៍ចង់សងសឹក មានសារសំខាន់ចំពោះការផ្សះផ្សា ។ ដូចគ្នាដែរ ទស្សនៈចំពោះកម្មាភិបាលថ្នាក់ទាបដែលភាគច្រើននៃអ្នកឆ្លើយយល់ថាជាជនរងគ្រោះមួយបែប (៧១,២៨ភាគរយ) ហើយមានមួយចំនួនតូចអាចអត់ឱនឲ្យកម្មាភិបាលទាំងនេះ បញ្ជាក់យ៉ាងច្បាស់ថាការវិវត្តន៍កំពុងតែកកើតឡើងនៅក្នុងសង្គមកម្ពុជា ។ ការឆ្លើយបែបនោះបញ្ជាក់អំពី«ការទទួលស្គាល់ចំពោះការពិតមិនគ្រប់លក្ខណៈដែលទាមទារឲ្យមានការផ្លាស់ប្តូរអាកប្បកិរិយារបស់យើង សេចក្តីប្រាថ្នារបស់យើង អារម្មណ៍របស់យើង ហើយអាចរួមទាំងជំនឿរបស់យើងទៀតផង ។ ការផ្លាស់ប្តូរដ៏ខ្លាំងបែបនេះគឺជារឿងពិបាកនិងឈឺចាប់ដែលមិនអាចបង្ខំឲ្យធ្វើឲ្យបានលឿន ឬដាក់កំហិតឲ្យធ្វើឲ្យខាងតែបាននោះទេ ។ ហេតុនេះ នៅពេលដែលមានកត្តាបុគ្គលសំខាន់ចំពោះការផ្សះផ្សា ក៏មានកត្តាសហគមន៍ដែលទាមទារឲ្យមានការចោទសួរអំពីអាកប្បកិរិយាមិនល្អ ការប្រកាន់គ្នា និងអគតិដែលយើងទាំងអស់គ្នាមាននៅក្នុងអារម្មណ៍ចំពោះ«សត្រូវ» ។

អ្នកឆ្លើយជាច្រើនយល់យ៉ាងច្បាស់ថាដើម្បីសម្រេចឲ្យបាននូវសន្តិភាព ការបង្រួបបង្រួមនិងផ្សះផ្សាជាតិកម្ពុជា ប្រជាជនទាំងអស់ត្រូវតែកែប្រែនូវទង្វើរបស់បុគ្គលនិងសង្គម ។ ការអត់ឱនជាកត្តាមានសារសំខាន់មួយដែលជាមធ្យោបាយដឹកនាំប្រជាជនទៅរកគោលដៅនេះ ។ វាជាហេតុផលមួយដែលមនុស្សជាច្រើននាក់ដែលចង់បាននូវការទទួលខុសត្រូវសម្រាប់បទឧក្រិដ្ឋរបស់ខ្មែរក្រហម សុខចិត្តឲ្យកម្មាភិបាលថ្នាក់ទាបនៅក្រៅសំណាញ់ច្បាប់ ។ ហេតុផលនេះចង្អុលបង្ហាញអំពីការផ្លាស់ប្តូរបន្តិចម្តងៗ ដែលកំពុងតែកើតមាននៅក្នុងប្រទេសកម្ពុជា ។ ហាក់បីដូចជាមានការរំកិលពីអារម្មណ៍ចង់សងសឹកដាច់ណាត់នៅឆ្នាំ១៩៧៩ ទៅរកការមើលឃើញភាពជាមនុស្សនៅក្នុងខ្លួនជនដៃដល់ ។ ប៉ុន្តែយើងមិនត្រូវបំភ្លេចថា ការផ្សះផ្សាអាចកើតមានដោយមានឬគ្មានការអត់ឱនដោយជនទាំងឡាយណាដែលទទួលផលប៉ះពាល់ដោយផ្ទាល់ពីសោកនាដកម្ម ។ ការអត់ឱនជាបុព្វសិទ្ធិរបស់ជនរងគ្រោះ ។ អ្នកទាំងនេះអាចអត់ឱននៅថ្ងៃណាមួយដែលធ្វើឲ្យការផ្សះផ្សាកាន់តែងាយស្រួលថែមទៀត ប៉ុន្តែការបង្ខំឲ្យជនរងគ្រោះអត់ឱនជារឿងមិនត្រឹមត្រូវទាល់តែសោះ ពិសេសប្រសិនបើគ្មានការសោកស្តាយពិតប្រាកដដែលបង្ហាញដោយជនដៃដល់ ។ ភាពមិនទៀងទាត់ក៏អាចបញ្ជាក់ការពិតដែលមិនអាចនិយាយឲ្យបានទូទៅចំពោះអ្នកនៅថ្នាក់ទាប ដោយសារភាគច្រើនមានលក្ខណៈជាជនរងគ្រោះច្រើនជាងជនដៃដល់ ។ ខ្លះមានលក្ខណៈជាជនដៃដល់ច្រើនជាងជាជនរងគ្រោះ អ្នកខ្លះត្រូវបង្ខំដោយកាលៈទេសៈជាក់ស្តែង អ្នកខ្លះត្រូវបានអនុញ្ញាតដោយកាលៈទេសៈឲ្យធ្វើអ្វីមួយដោយគ្មានការទប់ស្កាត់ អ្នកខ្លះមានការទទួលខុសត្រូវជាងមេដឹកនាំខ្លួន ឯអ្នកខ្លះទៀតមិនសូវមានការទទួលខុសត្រូវប៉ុន្មានទេ ។

នៅក្នុងព្រះពុទ្ធសាសនា ការទទួលស្គាល់កំហុសជាការសំខាន់ណាស់ ប៉ុន្តែគ្មានការទាមទារផ្នែកជំនឿសាសនាឲ្យបញ្ចេញការសោកស្តាយតាមរយៈការនិយាយថា «ខ្ញុំសុំទោស» នោះទេ ។ ប្រជាជនកម្ពុជាជាច្រើនទទួលស្គាល់ថាមិនសូវមានការសុំអភ័យទោសទេនៅក្នុងសង្គមកម្ពុជា ដែលជាកត្តានាំឲ្យមានការមិនពេញចិត្តពីអ្នកដែលបានទទួលការឈឺចាប់ ។ អ្នកធ្វើខុសត្រូវតែសន្យាថាមិនប្រព្រឹត្តអំពើខុសឆ្គងបែបនោះទៀត រៀបចំខ្លួនទទួលរងផលនៃអំពើរបស់ខ្លួន ហើយចាប់ផ្តើមធ្វើអំពើល្អឡើងវិញ ។

មេត្តាធម៌ត្រូវតែបង្ហាញ ប៉ុន្តែមិនប្រាកដថាភាគីដែលបានទទួលការឈឺចាប់អាចអត់ឱនឲ្យបាននោះទេ ។ អ្នកឆ្លើយចំនួន១៦,២០ ភាគរយអាចអត់ឱនបានប្រសិនបើជនដៃដល់សារភាពហើយហាមាត់សុំឲ្យមានការអត់ឱនទោសជាសាធារណៈ ។ ភាពស្មោះត្រង់ជាកត្តាសំខាន់ណាស់ ប្រសិនបើចង់ឲ្យមានការផ្សះផ្សាជាតិតាមរយៈការសុំទោស ។ ផ្ទុយទៅនឹងអ្វីដែលអ្នកនយោបាយរៀបចំក្នុងគោលនយោបាយសម្រាប់ពលរដ្ឋសាមញ្ញ ការផ្សះផ្សាមិនអាចសម្រេចបានដោយការនិយាយពាក្យពីរបីម៉ាត់នោះទេ ។ មនុស្សទាំងអស់ត្រូវរៀបចំខ្លួនទទួលខុសត្រូវចំពោះអំពើអវិជ្ជមានទាំងអស់ដែលខ្លួនបានបង្ក ។ អ្នកឆ្លើយភាគច្រើនឲ្យតម្លៃចំណុចនេះទៅនឹងការទទួលខុសត្រូវបែបព្រហ្មទណ្ឌរបស់បុគ្គលនៅក្នុងតុលាការច្បាប់ ។ ការនិយាយពាក្យ“សុំទោស”ក្រោយពីមានសោកនាដកម្មហាក់មិនទាន់គ្រប់គ្រាន់ទេ ជាពិសេសប្រសិនបើការសុំអភ័យទោសត្រូវមើលឃើញថាមិនស្មោះត្រង់ ហើយធ្វើឡើងដើម្បីចៀសវាងការទទួលខុសត្រូវ ។

ព្រះពុទ្ធបានបង្រៀនពុទ្ធសាសនិកថា “ពៀររំងាប់ដោយការមិនចងពៀរ” ។ ជួនកាលឃ្លានេះត្រូវបានបកស្រាយថាជំនឿសាសនារបស់ប្រជាជនកម្ពុជាទាមទារឲ្យប្រជាជនកម្ពុជាអត់ឱននិងបំភ្លេចចោលនូវអតីតកាល បានសេចក្តីថា រឿងខ្មែរក្រហមមិនគួរលើកមកនិយាយឡើងវិញទេ ។ តាមការពិតមេដឹកនាំសាសនាព្រះពុទ្ធរបស់កម្ពុជាទូន្មានឲ្យបង្កើតដំណើរការទទួលខុសត្រូវមួយ ប៉ុន្តែត្រូវធ្វើឲ្យបានត្រឹមត្រូវនិងយុត្តិធម៌ ។ សម្តេចព្រះសង្ឃរាជបានលើកឡើងពីច្បាប់លោកនិងច្បាប់ធម៌ ។ ចំណុចរួមនៃច្បាប់ទាំងពីរគឺថាមនុស្សទាំងអស់ត្រូវតែទទួលខុសត្រូវចំពោះសកម្មភាពរបស់ខ្លួន ។ ប្រសិនបើធ្វើអាក្រក់ អ្នកនោះត្រូវតែទទួលផលអាក្រក់ ។ នៅក្នុងសាសនាព្រះពុទ្ធ ការកាត់ទោសដែលមានតម្លាភាពនិងមានយុត្តិធម៌មិនមែនមានន័យថាជាការសងសឹកនោះទេ ប៉ុន្តែមានន័យថាជាយុត្តិធម៌ទៅវិញ ។ ការកាត់ទោសដោយត្រឹមត្រូវធ្វើឲ្យវដ្តនៃការចងពៀរគ្នាត្រូវបញ្ចប់និងជាមធ្យោបាយសម្រាប់ឲ្យបុគ្គលទាំងអស់ទទួលខុសត្រូវ


ទូននិងហាកិមនៅគីឡូម៉ែត្រលេខ៩

ឬត្រូវបង្ខំឲ្យមកទទួលខុសត្រូវដែលជាផលនៃកម្មរបស់ខ្លួន ។ អ្នកឆ្លើយលេខ២៣៧ នៅខេត្តបាត់ដំបង បានពន្យល់យ៉ាងច្បាស់ថា «បើតាមច្បាប់ពុទ្ធសាសនា អ្នកធ្វើបាបកម្មត្រូវទទួលផលអកុសលមិនអាចចៀសវាងរួចជាដាច់ខាត ។ ដូច្នេះយើងរំងាប់ពៀរដោយការមិនចងពៀរ គឺត្រូវតែមានយុត្តិធម៌និងការជំនុំជម្រះទោសដោយភាពត្រឹមត្រូវមិនលម្អៀងទើបយើងរស់នៅបានសុខសប្បាយនិងអភិវឌ្ឍន៍សង្គមជាតិ ។»

មេដឹកនាំសាសនារបស់កម្ពុជាជាច្រើនរូបបានបកស្រាយពន្យល់ពីមូលហេតុដែលការកាត់ទោសដោយត្រឹមត្រូវមួយមានភាពសមស្របទៅនឹងធម៌របស់ព្រះពុទ្ធ ។ មេដឹកនាំខ្លះថែមទាំងបានផ្សារភ្ជាប់ធម៌ទៅនឹងការផ្សះផ្សាជាតិទៀតផង: «នៅពេលដែលជនដាប់ចោទត្រូវបានកាត់ទោស ប្រជាជននឹងសប្បាយចិត្តហើយឈប់ព្រួយបារម្ភ និងឈប់ចោទប្រកាន់គ្នាទៅវិញទៅមក ។ ទាល់តែធ្វើបែបនេះទើបកម្ពុជាអាចទទួលបាននូវសន្តិភាពនិងការផ្សះផ្សាជាតិយូរអង្វែង ប្រជាជនរាប់អានគ្នាឡើងវិញ អាណិតអាសូរគ្នា និងកសាងជាតិឲ្យរុងរឿងឡើងវិញ ។» ធម៌របស់ព្រះពុទ្ធគឺសមស្របទៅនឹងការយល់ត្រូវនៃធម្មាធិបតេយ្យដែលថែងថា ច្បាប់ជាអ្នកធ្វើឲ្យសង្គមមានសណ្តាប់ធ្នាប់ ហើយការរំលោភច្បាប់ត្រូវតែដោះស្រាយដោយវិធីសាស្ត្រត្រឹមត្រូវមិនលម្អៀងនៅក្នុងតុលាការ ។ គ្មានប្រទេសណាមួយក្នុងពិភពលោកដែលទាមទារឲ្យមានយុត្តិធម៌តាមវិធីសាស្ត្រសងសឹកចំពោះអ្នកធ្វើខុសតាមតុលាការនោះទេ ។

ចម្លើយប្រមូលកន្លងមកបញ្ជាក់ថា កំហឹង ការគុំកួន ការសងសឹក ដែលមាននៅក្នុងចិត្តរបស់អ្នកនៅរស់ដែលជាជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យ មិនមានលក្ខណៈលើសលប់ជាអាទិភាព ឬធ្វើឲ្យវិនាស ដូចដែលការសិក្សាមុនៗបានបកស្រាយនោះទេ ។ ៦៨,៩៥ភាគរយនិយាយថា ខ្លួននឹងមិនខឹងនិងមិនសងសឹកទេប្រសិនបើដឹងថាអ្នកភូមិជាមួយគ្នាជាឃាតករសម្លាប់បងប្អូនរបស់ខ្លួន ។ ឧទាហរណ៍ អ្នកឆ្លើយលេខ ១៥៤ពោលថា «នៅពេលខ្ញុំដឹងថាអ្នកភូមិខ្ញុំជាជនដៃដល់ដែលបានសម្លាប់សាច់ញាតិខ្ញុំ ខ្ញុំនឹងខឹងដូចគេដូចឯងដែរ» ។ ប៉ុន្តែអ្នកឆ្លើយរូបនេះបកស្រាយបន្តថា «ប្រសិនបើគិតឲ្យច្បាស់លាស់ទៅយើងមិនគួរខឹងទេ ពីព្រោះបើធ្វើបែបនោះប្រទេសយើងនឹងមិនធ្វើដំណើរទៅមុខឡើយ អំពើហិង្សានិងភាពច្របូកច្របល់នឹងមិនបញ្ចប់ទេ ។ ការសងសឹកគ្នាទៅវិញទៅមកមិនល្អទេ ។ ព្រះពុទ្ធមានពុទ្ធដីកាថា ពៀររំងាប់ដោយការមិនចងពៀរ ។» អ្នកឆ្លើយជាច្រើនដឹងយ៉ាងច្បាស់ថា ការដោះស្រាយបញ្ហាដោយខ្លួនឯងនឹងធ្វើឲ្យខ្លួនឯងក្លាយទៅជាជនដៃដល់ដែរ ។ អ្នកឆ្លើយលេខ៧២ពោលថា «ប្រសិនបើយើងសងសឹក យើងនឹងក្លាយជាឃាតករដូចតែគ្នា» ។ ការចង់សងសឹកប្រហែលជាអាចសាបរលាបទៅតាមពេលវេលា ពីព្រោះប្រជាជនបានបន្សាំខ្លួនទៅនឹងការរស់នៅដោយការបាត់បង់ធ្ងន់ធ្ងររួចទៅហើយ ។ នៅក្នុងករណីខ្លះ ជនរងគ្រោះថែមទាំងអាចទទួលស្គាល់ការពិតទៀតផង ។ ករណីនេះហាក់មិនមែនជារឿងជនរងគ្រោះនិងជនដៃដល់ទៀតទេ ប៉ុន្តែវាជាការធ្វើអ្វីៗដែលចាំបាច់ដើម្បីឲ្យជីវិតរស់នៅកាន់តែប្រសើរឡើង ។

អ្នកឆ្លើយភាគច្រើនឈប់ចាត់ទុកខ្មែរក្រហមថាជារូបវន្តដ៏ធំតែមួយដុំទៀតហើយ ។ អ្នកឆ្លើយចាប់អារម្មណ៍ទៅលើការទទួលខុសត្រូវរបស់បុគ្គលជាជាងការទទួលខុសត្រូវជាក្រុម ហើយអាចបែងចែកមេដឹកនាំធំៗដែលមានការទទួលខុសត្រូវខ្ពស់ចេញពីទាហានតូចតាចដែលជាអ្នកអនុវត្តផ្ទាល់ដៃ ។ លទ្ធភាពមើលឃើញកម្រិតនៃការទទួលខុសត្រូវនេះបានលេចចេញយ៉ាងច្បាស់នៅក្នុងយោបល់របស់អ្នកឆ្លើយចំពោះជនដៃដល់កម្រិតទាប (អ្នកឆ្លើយ៧១,២៤ភាគរយយល់ថា ជនដៃដល់ទាំងនេះជាជនរងគ្រោះមួយបែប) ។ ការស្ទាបស្ទង់ជាច្រើនបង្ហាញថាប្រជាជនខ្មែរភាគច្រើនចង់ឲ្យមេដឹកនាំខ្មែរក្រហមត្រូវនាំឡើងតុលាការគឺមិនមែនទាហានតូចតាចទេ ។ ការបែងចែកកម្រិតនៃពិរុទ្ធភាពបង្ហាញពីការទទួលស្គាល់អំពីជម្រើសពិបាកៗដែលប្រជាជនត្រូវតែជ្រើសរើសយកនៅក្នុងកាលៈទេសៈពិបាក និងបង្ហាញពីការសង្កេតឃើញភាពជាមនុស្សរបស់អ្នកធ្វើខុស ។ នេះជាការវិវត្តន៍ដ៏សំខាន់មួយក្នុងការបំបាត់ចោលនូវការយល់ឃើញមិនមានហេតុផលអំពីភាពឃោរឃៅ ដែលធ្វើឲ្យមានការគិតឃើញថារាល់សមាជិករបស់ក្រុម«ផ្សេង»សុទ្ធតែជាជនដៃដល់ទាំងអស់ ។ សំខាន់ជាងនេះទៀតនោះគឺថា មានអ្នកឆ្លើយ

ចំនួន២៥,០៥ភាគរយចង់ឲ្យមេដឹកនាំខ្មែរក្រហមពន្យល់អំពីទង្វើរបស់ខ្លួន ហើយ៧៣,៨៧ភាគរយទៀតយល់ថា ការដឹងអំពីការពិតនៃរបបខ្មែរក្រហមមានសារសំខាន់ណាស់ ។ ការចង់ដឹងចង់យល់អំពីភាគីម្ខាងទៀត បញ្ជាក់អំពីការទទួលស្គាល់ថាជនដៃដល់ជាមនុស្ស ចេះគិតគូរ មានវិចារណញាណដូចគេឯង និងមានហេតុផល ។ លទ្ធភាពមើលឃើញភាពជាមនុស្សនៃក្រុម «ផ្សេង» គឺជាសញ្ញាបញ្ជាក់អំពីការចង់ធ្វើដំណើរចេញពីការស្អប់ខ្ពើមនិងកំហឹង និងពន្យល់ពីការចង់ទទួលស្គាល់ការពិតពីអតីតកាល ។ អ្នកឆ្លើយខ្លះអាចអាណិតជនដៃដល់ដែរ អ្នកខ្លះទៀតអាចអត់ឱនឲ្យដល់ជនដៃដល់ ប៉ុន្តែអ្នកឆ្លើយមួយភាគធំមិនទាន់អាចអាណិតអាសូរឬអត់ឱនឲ្យនៅឡើយទេ ។ ប្រសិនបើយើងប្រៀបធៀបតួលេខដែលប្រមូលបានពីការស្ទាបស្ទង់មតិទៅនឹងការខឹងគុំកួនស្អប់ខ្ពើមខ្មែរក្រហមក្រោយពីរបបកម្ពុជាប្រជាធិបតេយ្យបានដួលរំលំនៅឆ្នាំ១៩៧៩ យើងនឹងសង្កេតឃើញការវិវត្តន៍ទៅមុខនៃទស្សនៈរបស់ប្រជាជន ។

ទោះបីជាមិនបានរៀបរាប់ពីពាក្យធម្មាធិបតេយ្យក៏ដោយ ក៏សម្តីរបស់អ្នកឆ្លើយបានបញ្ជាក់យ៉ាងច្បាស់ពីការសង្កត់ធ្ងន់ទៅលើការគាំទ្រធម្មាធិបតេយ្យ ។ នៅពេលគិតអំពីអត្ថន័យនិងផ្លូវឆ្ពោះទៅរកការផ្សះផ្សានិងបង្រួបបង្រួម អ្នកឆ្លើយដឹងយ៉ាងច្បាស់ថា ជាតិមួយដែលបង្កើតឡើងនិងពឹងផ្អែកទៅលើធម្មាធិបតេយ្យគឺជាជាតិដ៏ត្រឹមត្រូវ ។ នោះគឺជាប្រទេសដែលប្រជាជនចង់រស់នៅ ។ ធម្មាធិបតេយ្យគឺជាផ្លូវឆ្ពោះទៅរកការផ្សះផ្សាក៏ដូចជាសសរគ្រឹះនៃសង្គមជាតិទាំងមូលដែរ ។ នៅក្នុងកម្រងសំណួរមានរៀបរាប់អំពីការទទួលខុសត្រូវទាក់ទងទៅនឹងខ្មែរក្រហម ប៉ុន្តែចម្លើយដែលទទួលបានតែងតែមានលក្ខណៈទូលំទូលាយជាង មិនតែប៉ុណ្ណោះថែមទាំងមានរៀបរាប់អំពីវប្បធម៌នៃការរួចទោសសម្រាប់បទឧក្រិដ្ឋដែលកើតឡើងនាពេលបច្ចុប្បន្ននេះផង ។ ភាគច្រើនមិនត្រឹមតែបដិសេធការសងសឹកចំពោះជនដៃដល់ប៉ុណ្ណោះទេ ប៉ុន្តែអ្នកឆ្លើយចង់ធ្វើទៅតាមច្បាប់ដើម្បីបញ្ជាក់ថា កម្ពុជាគឺជាជាតិមួយដែលគ្រប់គ្រងដោយច្បាប់ ហើយមធ្យោបាយដ៏សមរម្យដើម្បីដោះស្រាយជាមួយនឹងឧក្រិដ្ឋជនគឺតាមរយៈប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ។ អ្នកឆ្លើយលេខ៥៧៨ពោលថា ការសងសឹកមិនមែនជាជម្រើសទេ ពីព្រោះ«ប្រទេសមានច្បាប់ ខ្ញុំមានគុណធម៌» ។ អ្នកឆ្លើយជាច្រើនបានចង្អុលបង្ហាញជាញឹកញយថា ប្រសិនបើដោះស្រាយបញ្ហាដោយខ្លួនឯងដូចជាការសងសឹកចំពោះការឈឺចាប់ ខ្លួនពិតជាមិនខុសពីជនដៃដល់នោះទេ ។ អ្នកឆ្លើយមួយភាគធំបានយកវិភាគទានរបស់ធម្មាធិបតេយ្យចំពោះការផ្សះផ្សាទៅភ្ជាប់នឹងការទទួលខុសត្រូវសម្រាប់បទឧក្រិដ្ឋរបស់ខ្មែរក្រហម ។ អ្នកឆ្លើយលេខ២៩១ អាយុ៥៩ឆ្នាំ ជាមន្ត្រីរាជការនៅខេត្តតាកែវ បង្ហាញថា «ការផ្សះផ្សាបង្រួបបង្រួមជាតិមិនមែនមានន័យថាឲ្យឧក្រិដ្ឋជនរួចទោសនោះទេ ។ យើងកាត់ទោសអ្នកទាំងនេះឲ្យរាងចាល កុំឲ្យអ្នកក្រោយយកតម្រាប់តាម ។ អ្នកដែលវង្វេងអាចកែប្រែខ្លួនមករួមរស់ក្នុងសង្គមជាតិវិញ ។»

ការស្ទាបស្ទង់មតិនេះនិងការសិក្សាផ្សេងទៀតបង្ហាញថា ទោះបីជាអ្នកឆ្លើយមានកម្រិតយល់ដឹងអំពី«យុត្តិធម៌»ប៉ុនណាក៏ដោយ ក៏ប្រជាជនកម្ពុជាភាគច្រើនចង់ឃើញអតីតមេដឹកនាំខ្មែរក្រហមត្រូវនាំឡើងតុលាការដែរ ។ អ្នកឆ្លើយលេខ១១០រស់នៅទីក្រុងភ្នំពេញ ពោលថា «ខ្ញុំចង់ឲ្យមានតុលាការកាត់ទោសដើម្បីឲ្យមនុស្សជំនាន់ក្រោយយល់អំពីរបបដ៏សាហាវប្រល័យពូជសាសន៍និងបំផ្លាញវប្បធម៌ អរិយធម៌ ព្រលឹងជាតិ ថែមទាំងបន្សល់ទុកនូវការបំផ្លាញខាងសតិបញ្ញាមនុស្សដែលនៅរស់និងមនុស្សជំនាន់ក្រោយទៀត ហើយម្យ៉ាងទៀតចង់ឲ្យមនុស្សគ្រប់រូបយល់ថា អំពើមនុស្សឃាត ឧក្រិដ្ឋកម្ម ឬអំពើផ្សេងទៀតទោះបីជាកន្លងផុតទៅហើយក៏ដោយ ក៏ច្បាប់មិនអនុគ្រោះដែរ» ។ សម្រាប់អ្នកឆ្លើយលេខ៩១ ដែលជាស្ត្រីមួយរូបនៅទីក្រុងភ្នំពេញ តុលាការខ្មែរក្រហមមានសារសំខាន់និងជាគំរូល្អសម្រាប់ក្មេងជំនាន់ក្រោយៈ «នៅពេលដែលមេដឹកនាំខ្មែរក្រហមធ្វើទារុណកម្មនិងកាប់សម្លាប់ប្រជាជនរាប់លាននាក់ហើយយើងអនុញ្ញាតឲ្យមេដឹកនាំទាំងនេះមានសេរីភាព នឹងបណ្តាលឲ្យមនុស្សជំនាន់ក្រោយធ្វើតាមដោយពុំខ្លាចអ្វី ។» គាត់ក៏បានបន្ថែមទៀតថា «ខ្ញុំចង់ឲ្យមានតុលាការឯករាជនិងយុត្តិធម៌កាត់ទោសមេដឹកនាំទាំងនេះ ពីព្រោះតុលាការជាតិបច្ចុប្បន្នមិនឯករាជ្យ ។ លើសពីនេះ ការសម្លាប់ប្រជាជនរាប់លាននាក់ត្រូវបានធ្វើឡើង

*និងឃុបឃិតដោយពួកបរទេសនិងប្រទេសផ្សេងៗ ហេតុដូចនេះ ការបង្កើតតុលាការអន្តរជាតិជាការត្រឹមត្រូវ ។ ការកាត់ទោសនឹងបង្ហាញថាកម្ពុជាជាប្រទេសមានច្បាប់ ។ ប្រសិនបើគ្មានការកាត់ទោសខ្មែរក្រហមទេ គួរតែរំលាយប្រព័ន្ធតុលាការចោលទៅ ៗ»*

យោបល់ផ្សេងទៀតដែលទទួលបានមានដូចខាងក្រោម ÷

*«ការផ្សះផ្សានិងបង្រួបបង្រួមជាតិមានន័យថាយើងគួរតែមានតុលាការដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហមឲ្យសមស្របនឹងអំពើដែលអ្នកទាំងនោះបានប្រព្រឹត្ត ដើម្បីឲ្យប្រជាជនសុខចិត្តនិងមានអារម្មណ៍ស្ងប់ចំពោះបញ្ហាការសម្លាប់មនុស្ស» ។ (អ្នកឆ្លើយលេខ៣១៨ ភេទប្រុសអាយុ២២ឆ្នាំ)*

*«រឿងផ្សះផ្សាបង្រួបបង្រួមជាតិជារឿងមួយ ប៉ុន្តែច្បាប់កាត់ទោសខ្មែរក្រហមត្រូវតែកាត់ទៅតាមលក្ខណៈជាអន្តរជាតិ ទើបប្រជាពលរដ្ឋខ្មែរមានអារម្មណ៍ស្ងប់» ។ (អ្នកឆ្លើយលេខ៣៣៤ អាយុ៣៦ឆ្នាំ ជាមន្ត្រីរាជការនៅខេត្តក្រចេះ)*

*«ពាក្យផ្សះផ្សានិងបង្រួបបង្រួមជាតិមានន័យថាជាការបង្រួបបង្រួមគ្នាហើយរស់នៅដោយសន្តិភាព ។ ដើម្បីសម្រេចបាននូវគោលដៅនេះរាជរដ្ឋាភិបាលត្រូវតែកាត់ទោសមេដឹកនាំខ្មែរក្រហមឲ្យបានឆាប់បំផុត ។ រដ្ឋាភិបាលត្រូវគោរពច្បាប់ដែលខ្លួនឯងបង្កើត ។ បើខ្លួនឯងជាអ្នកបង្កើតមិនគោរព តើឲ្យរាស្ត្រគោរពម៉េចនឹងបាន ។ រដ្ឋាភិបាលគួរដើរតួជាគំរូនៃច្បាប់កុំអនុវត្តច្បាប់ឲ្យត្រឹមត្រូវតែចំពោះរាស្ត្រ ចំណែកខ្លួនឯងជាផ្លែល្វា ៗ» (អ្នកឆ្លើយលេខ៣៩២ អាយុ២០ឆ្នាំ ជានិស្សិតនៅទីក្រុងភ្នំពេញ)*

ការទទួលស្គាល់និងការសុំទោសមានសារសំខាន់និងជាទង្វើល្អប្រសិនបើធ្វើឡើងដោយភាពស្មោះត្រង់និងដោយការភ្ញាក់ខ្លួន ប៉ុន្តែបើគ្រាន់តែសុំទោសគឺមិនទាន់គ្រប់គ្រាន់ទេ ដោយសារថាសោកនាដកម្មមានទំហំធំធេងពេក ។ មិនមានអ្នកឆ្លើយណាម្នាក់លើកឡើងអំពីគណៈកម្មការស្វែងរកការពិតមកប្រើប្រាស់នៅកម្ពុជាទេ ។ នៅពេលនិយាយអំពីរឿងខ្មែរក្រហម អ្នកឆ្លើយភាគច្រើនចាត់ទុកការអត់ឱនថាជាការរួចទោសឬកង្វះការទទួលខុសត្រូវ ។ អ្នកឆ្លើយមួយចំនួនធំបានបដិសេធការអត់ឱន ។ អ្វីដែលអ្នកឆ្លើយចង់បានគឺច្បាស់ក្រឡែតៈ មេដឹកនាំខ្មែរក្រហមត្រូវតែទទួលការកាត់ទោស ។

ប៉ុន្តែហេតុផលដែលចង់ឲ្យមានការកាត់ទោសតែងតែមិនសូវច្បាស់ ។ អ្នកខ្លះហាក់ដូចជាយល់ថាមានការដាក់ទណ្ឌកម្មនៅពីក្រោយការប្រកាសទាមទារឲ្យមានយុត្តិធម៌ព្រហ្មទណ្ឌ បានន័យថា អ្នកដែលបានប្រព្រឹត្តកំហុសធ្ងន់ធ្ងរគួរតែទទួលនូវការដាក់ទណ្ឌកម្មដែលសមនឹងទទួល ។ អ្នកឆ្លើយជាច្រើនបានលើកឡើងអំពីផលជាមេរៀននៃតុលាការខ្មែរក្រហម ដែលជាប្រយោជន៍ធំដែលគាត់យល់ឃើញថាមានភាពចាំបាច់សម្រាប់ការកែប្រែទង្វើរបស់មនុស្សជំនាន់ក្រោយ ។ តុលាការត្រូវបានមើលឃើញថាមានសារប្រយោជន៍ក្នុងការកាត់ផ្តាច់វដ្តនៃអំពើហិង្សានិងការរួចទោស ។ នេះគឺជាការប្រើប្រាស់ដំណើរការយុត្តិធម៌ជាមេរៀនអប់រំ ។ អ្វីដែលនឹងលេចឡើងនឹងធ្វើឲ្យភ្ញាក់ផ្អើលខ្លាំង ដែលអាចជាការបង្ហាញពីគ្រោះថ្នាក់នៃការគោរពតាមលទ្ធិណាមួយទាំងងងឹតងងល់ គ្រោះថ្នាក់ដ៏ធំធេងនៃការដឹកនាំបែបផ្តាច់ការ និងការដាក់ទណ្ឌកម្មទៅលើបុគ្គលជាប់ពាក់ព័ន្ធនៅក្នុងប្រព្រឹត្តិកម្មនៃអំពើឃោរឃៅ ។ គ្រាន់តែមានតុលាការមួយមុខ ដោយមិនខ្វល់ពីគុណភាពនៃនីតិវិធី អាចធ្វើឲ្យអ្នកឆ្លើយចំនួន៥៦,៥៩ ភាគរយអត់ឱនឲ្យអ្នកដែលបានធ្វើបាបមកលើខ្លួន ។ ជួនកាលអ្នកឆ្លើយហាក់បីដូចជាយល់ថា យុត្តិធម៌ព្រហ្មទណ្ឌមានឥទ្ធិពលធ្វើឲ្យកម្ពុជាមានតុល្យភាពឡើងវិញ ហើយលើកថា សកម្មភាពរបស់មនុស្សមួយចំនួនបានធ្វើឲ្យកម្ពុជាមានភាពច្របូកច្របល់ដើរខុសផ្លូវ ។ ការតម្រង់ផ្លូវសំខាន់បំផុតគឺការប្រើប្រាស់ច្បាប់ ។ បញ្ហាប្រចាំថ្ងៃរបស់ប្រទេសកម្ពុជាទាក់ទងទៅនឹងធម្មាធិបតេយ្យនិងការទាមទារចង់បាននូវការលុបបំបាត់ចោលការរួចទោសនិងភាពគ្មានច្បាប់ទម្លាប់ គឺមានលក្ខណៈស្របគ្នាទៅនឹងសម្តីខាងលើ ។ វាហាក់ដូជាថា «ប្រជាជនចង់បានការកាត់ទោស ពីព្រោះការកាត់ទោសទំនងជាផ្តល់នូវក្តីសង្ឃឹមជានិមិត្តរូបនៃការកែប្រែទំនាក់ទំនងអំណាចៈ អ្នកដែលមានអំណាចត្រូវធ្វើឲ្យគ្មានអំណាចវិញ» ។

ការចង់ឲ្យអង្គការសហប្រជាជាតិចូលរួមនិងយោបល់ដែលទទួលបានពីអ្នកឆ្លើយ បង្ហាញថា ប្រជាជនកម្ពុជាក៏ចង់ឲ្យ

តុលាការខ្មែរក្រហមមានកម្រិតគុណភាពទៅតាមស្តង់ដារមួយច្បាស់លាស់ ។ ប្រជាជនចង់បាន«បទដ្ឋានអន្តរជាតិ» ប៉ុន្តែភាគច្រើនមិនដឹងថាបទដ្ឋានអន្តរជាតិមានន័យបែបណានោះទេ ។ ឧទាហរណ៍ ក្នុងបទដ្ឋានអន្តរជាតិ បើតាមច្បាប់ នួន ជា, ខៀវ សំផន, ឌុច និង តាម៉ុក ត្រូវទទួលការចាត់ទុកថាគ្មានទោសទេ រហូតទាល់តែតុលាការចេញសាលក្រមថាមានទោស ។ ឃ្លា «បទដ្ឋានអន្តរជាតិ» នៅក្នុងបរិបទកម្ពុជាហាក់ដូចជាមានន័យថាជានីតិវិធីដែលមិនត្រូវបានគ្រប់គ្រងដោយអ្នកច្បាប់ក្នុងស្រុកដែលប្រជាជនមិនទុកចិត្ត ។ យើងមិនទាន់ដឹងថាតើប្រជាជនកម្ពុជានឹងឆ្លើយសំណួរជាក់ស្តែងថាៈ «ប្រសិនបើត្រូវជ្រើសរើសយកមួយរវាងតុលាការដែលមិនបំពេញតាមស្តង់ដារអន្តរជាតិនិងគ្មានតុលាការ តើអ្នកជ្រើសយកមួយណា?»

អ្វីដែលប្រជាជនកម្ពុជាកំពុងតែស្វែងរកតាមរយៈតុលាការហាក់ដូចជាការទទួលស្គាល់ចំពោះអតីតកាលជាសាធារណៈនិងការធ្វើជានិមិត្តរូបនៅលើតុលាការដែលខ្មែរក្រហមនិងមនោគមវិជ្ជារបស់របបនេះនឹងត្រូវដាក់ឲ្យគេឃើញតាមរយៈការកាត់ទោសមេដឹកនាំរបស់ខ្មែរក្រហម ។ ស្ទើរតែគ្រប់អ្នកឆ្លើយទាំងអស់យល់ថាមេដឹកនាំខ្មែរក្រហមមានការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋទាំងអស់មុនតុលាការកំណត់និងយល់ថាការចាត់ទុកថាគ្មានកំហុសជារឿងប្រឌិត ។ ឧទាហរណ៍ អ្នកឆ្លើយលេខ៥២៧ អាយុ៥៣ឆ្នាំ ភេទប្រុស រស់នៅខេត្តកំពង់ចាម ពោលថា «ដើម្បីសម្រេចបាននូវការផ្សះផ្សាជាតិ មេខ្មែរក្រហមធំៗត្រូវតែសារភាពនិងទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន» ។ ផលជានិមិត្តរូបនៃដំណើរការច្បាប់ហាក់ទាក់ទងទៅនឹងការនាំយកអ្នកមានអំណាចមកកាត់ទោស ហើយបញ្ជាក់ថាយុគនៃភាពឃោរឃៅហួសវិស័យនិងការប្រើប្រាស់អំណាចក្នុងផ្លូវខុសគឺត្រូវបានបញ្ចប់ហើយ ដែលទាំងនេះជាមេរៀនសម្រាប់មេដឹកនាំបច្ចុប្បន្ន ។ មេដឹកនាំខ្មែរក្រហមនឹងត្រូវឡើងបកស្រាយចំពោះការធ្វើឲ្យប្រជាជនឈឺចាប់ ត្រូវប្រឈមមុខនឹងភ័ស្តុតាងជាឯកសារជាច្រើនដែលបានបន្សល់ទុកពីរបបខ្មែរក្រហមនិងភ័ស្តុតាងដែលអ្នកនៅរស់រាប់លាននាក់អាចផ្តល់ឲ្យនូវអ្វីដែលខ្លួនបានឃើញនិងឆ្លងកាត់ ។ មេដឹកនាំអាចសារភាពនិងសុំទោសបានប្រសិនបើចង់ធ្វើបែបនោះ ប៉ុន្តែច្បាស់ជាត្រូវកាត់ទោសនៅលើតុលាការដែលនាំទៅរកការដាក់ពិរុទ្ធនិងការដាក់ទណ្ឌកម្ម ។

អ្នកខ្លះអាចឲ្យយោបល់ថា បើដូច្នោះតុលាការមិនបំពេញតាមស្តង់ដារណាមួយក៏ល្អដែរ ឲ្យតែមេដឹកនាំត្រូវនាំឡើងតុលាការ ។ យើងគួរតែដឹងដែរថា ការចង់ឲ្យអង្គការសហប្រជាជាតិចូលរួមនៅក្នុងតុលាការមិនមែនដោយសារមូលហេតុចង់បានជំនួយបច្ចេកទេសដើម្បីឲ្យស្របតាមស្តង់ដារដូចរៀបរាប់នៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយនោះទេ ។ ប្រជាជនចង់ឲ្យអង្គការសហប្រជាជាតិចូលរួមគឺដោយសារមិនទុកចិត្តអាជ្ញាធរកម្ពុជា ។ តុលាការអាចក្លាយទៅជាការកាត់ទោសឲ្យតែបានៗដូចតុលាការឆ្នាំ១៩៧៩ ។ តុលាការច្បាប់អាចត្រូវបានប្រើប្រាស់ជាមន្ទីរពិសោធន៍សម្រាប់ការជួសជុលសង្គម ជាជាងដើម្បីកំណត់ពីភាពមានឬគ្មានកំហុសនៃជនណាម្នាក់ទាក់ទងទៅនឹងការចោទប្រកាន់ទៅលើជននោះ ។ ការធ្វើដូចនេះអាចមានផលវិបាកធ្ងន់ធ្ងរយូរអង្វែងដោយកម្ពុជាកំពុងតែមានបញ្ហាខាងផ្នែកធម្មាធិបតេយ្យ ។ អ្នកខ្លះអាចយល់ថា ការកាត់ទោសគ្រាន់ជាការដាក់កំហុសទៅលើមនុស្សពីរបីនាក់ប៉ុណ្ណោះ ទោះបីជាអ្នកទាំងនោះគឺជនដែលមានការទទួលខុសត្រូវខ្ពស់បំផុតក៏ដោយ ។ ចំណែកអ្នកផ្សេងទៀតដែលជាប់ពាក់ព័ន្ធបានដើរចេញដោយមិនបានទទួលខុសត្រូវ ឬមិនបានត្រូវបង្ខំឲ្យទទួលខុសត្រូវនូវអ្វីដែលខ្លួនបានប្រព្រឹត្ត ។ ផ្ទុយទៅវិញ អ្នកប្រាកដនិយមដែលចាប់អារម្មណ៍ទៅលើស្ថានភាពទូទៅអាចទាញហេតុផលថា ទោះបីជានីតិវិធីតុលាការមានចំណុចខ្សោយក៏ដោយ ក៏នៅក្នុងរឿងក្តីមួយចំនួនគ្មាននីតិវិធីច្បាប់ណាមួយដែលល្អឥតខ្ចោះដែរ ហើយតែងតែមាននរណាមួយមិនពេញចិត្តជាដរាប ។ ឥទ្ធិពលធំធេងរបស់តុលាការខ្មែរក្រហមមានសារសំខាន់ណាស់ពីព្រោះវាបើកផ្លូវឲ្យមានការជួសជុលសង្គមដោយពិតប្រាកដនៅកម្ពុជា ។

លទ្ធផលនៃការស្ទាបស្ទង់មតិនេះនិងផ្សេងទៀត បានបញ្ជាក់ច្បាស់ថា ប្រជាជនកម្ពុជាមិនចង់បំភ្លេចអតីតកាលចោលទេ ។ ការស្ទាបស្ទង់មតិរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានរកឃើញថា មាន៧៣,៨៧ភាគរយនៃអ្នកឆ្លើយយល់ថា ការដឹង

អំពីការពិតនៃរបបខ្មែរក្រហមមានសារសំខាន់ ។ ៦៧,៦០ ភាគរយចង់យកបទពិសោធន៍ផ្ទាល់ខ្លួនមករៀបរាប់ឲ្យអ្នកដទៃបានដឹងពុ ។ សឹងតែគ្មានអ្នកឆ្លើយណាដែលមិនចង់និយាយអំពីអ្វីដែលបានកើតឡើង ចង់បំភ្លេចចោលអតីតកាល ហើយបន្តរស់នៅប្រចាំថ្ងៃហាក់ដូចជារបបខ្មែរក្រហមមិនធ្លាប់កើតមាន ។ ចំណុចនេះស្របគ្នាទៅនឹងយោបល់ដែលទទួលបានពីការស្ទាបស្ទង់ផ្សេងទៀតដែលបានយកមកពិនិត្យនៅក្នុងការស្រាវជ្រាវរបស់ខ្ញុំ ។ ដោយក្តីឈឺចាប់ អ្នកឆ្លើយភាគច្រើនចង់និយាយរៀបរាប់និងរៀនសូត្របន្ថែមដើម្បីយល់ឲ្យបានច្បាស់ថាហេតុអ្វីបានជាមានសោកនាដកម្ម ហើយធានាឲ្យប្រាកដថារបបបែបនេះនឹងមិនកើតឡើងជាថ្មីម្តងទៀតឡើយ ។ ប្រសិនបើអតីតមេដឹកនាំខ្មែរក្រហមទទួលស្គាល់ការឈឺចាប់ដែលខ្លួនបានបង្កនោះជាទង្វើល្អ ប៉ុន្តែអ្នកឆ្លើយមួយភាគធំមិនបានបង្ហាញអំពីតម្រូវការជាក់លាក់និងទូទៅសម្រាប់“ការទទួលស្គាល់ជាផ្លូវការ”នូវអ្វីដែលបានឆ្លងកាត់ ។ អ្វីដែលអ្នកឆ្លើយចង់បាននោះគឺបទពិសោធន៍របស់ប្រជាជនកម្ពុជាដែលបានឆ្លងកាត់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យត្រូវបានពិភពលោកដឹងពុនិងមិនបំភ្លេចចោលជារៀងរហូត ។

សារប្រយោជន៍នៃការអប់រំ ទោះក្នុងទម្រង់ជាផ្លូវការឬមិនផ្លូវការ ក្នុងសីលធម៌ឬសាសនាព្រះពុទ្ធ បានលេចឡើងជាច្រើនលើកច្រើនសានៅក្នុងការស្ទាបស្ទង់មតិនេះ ។ អ្នកឆ្លើយលេខ៨៦រស់នៅទីក្រុងភ្នំពេញយល់ថា អ្វីដែលសំខាន់បំផុតនោះគឺ“...ការបំពាក់បំប៉នប្រព័ន្ធអប់រំ ពីព្រោះការអប់រំគឺជាគ្រឹះសង្គម ។ សង្គមនឹងមានបញ្ហាប្រសិនបើគ្មានការអប់រំទេ” ។ អ្នកឆ្លើយលេខ១០ នៅភ្នំពេញ បានពោលថា “ដើម្បីសម្រេចបាននូវការផ្សះផ្សាជាតិ មនុស្សគ្រប់រូបត្រូវតែទទួលបាននូវការអប់រំទោះតាមផ្លូវសាសនាក្តីផ្លូវច្បាប់ក្តី” ។ អ្នកឆ្លើយលេខ៣៦នៅភ្នំពេញរៀបរាប់ថា “ដើម្បីសម្រេចឲ្យបាននូវការផ្សះផ្សាជាតិ ដំបូងមនុស្សទាំងអស់ត្រូវទទួលការអប់រំឲ្យបានជ្រៅជ្រះ ហើយចេះស្រលាញ់សន្តិភាព” ។ អ្នកឆ្លើយជាច្រើនចង់បាននូវការអប់រំដែលធ្វើឲ្យមានការប្រែប្រួលអត្តចរិតមនុស្សពីជំនាន់មួយទៅជំនាន់មួយ ហើយចង់ឲ្យអប់រំអំពីអ្វីដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងឲ្យប្រវត្តិសាស្ត្រនេះក្លាយទៅជាការចងចាំរួមសម្រាប់ក្មេងជំនាន់ក្រោយ ។ អ្នកឆ្លើយគាំទ្រចំពោះការឲ្យអប់រំជាផ្លូវការនិងមិនផ្លូវការនៅក្នុងថ្នាក់រៀនដើម្បីឲ្យក្មេងៗបានដឹងច្បាស់ ។ ការផ្លាស់ប្តូរទៅតាមជំនាន់កំពុងតែទាមទារឲ្យមាន ។ អ្នកឆ្លើយជាច្រើនមានការជឿជាក់ទៅលើអំណាចនៃការអប់រំក្នុងការធ្វើឲ្យក្មេងយល់ដឹងអំពីអតីតកាលដើម្បីទប់ស្កាត់មិនឲ្យអតីតកាលដូរចត់បែបនោះកើតឡើងម្តងទៀត ។ គាត់ក៏ជឿជាក់ដែរថា ប្រជាជនដែលមានការអប់រំជ្រៅជ្រះអំពីសោកនាដកម្មឆ្នាំ១៩៧៥ដល់១៩៧៩ នឹងពុំសូវទទួលឥទ្ធិពលពីការញុះញង់និងការបង្ខិតបង្ខំឡើយ ។ ចំណុចនេះត្រូវបានគាំទ្រដោយមតិដែលទទួលបាននៅក្នុងសំណួរទី១៨ ដែលក្នុងនោះមានអ្នកឆ្លើយចំនួន៧២,០៥ភាគរយយល់ថាតុលាការជាឧបករណ៍សម្រាប់ទប់ស្កាត់មិនឲ្យបទឧក្រិដ្ឋកើតឡើងតាមរយៈការផ្តល់គំរូជាមេរៀនសម្រាប់ក្មេងជំនាន់ក្រោយ ។

អ្នកឆ្លើយចំនួន៥៥,០៧ភាគរយចង់ដឹងអំពីតុលាការខ្មែរក្រហម ៥២,៩១ភាគរយចង់ដឹងពីមូលហេតុដែលខ្មែរក្រហមធ្វើទារុណកម្មនិងសម្លាប់ប្រជាជន ២៥,០៥ភាគរយចង់ស្តាប់ពីការបកស្រាយរបស់ខ្មែរក្រហម និង៣៧,៨០ភាគរយចង់ដឹងអំពីការទទួលខុសត្រូវនិងរបបខ្មែរក្រហម ។ ក្នុងការឆ្លើយទៅនឹងសំណួរ១២ អ្នកឆ្លើយ៧៣.៨៧ភាគរយចង់ដឹងអំពីការពិតក្នុងរបបខ្មែរក្រហម ។ ក៏ប៉ុន្តែ ពាក្យថា“ការពិត”មិនទាន់ត្រូវបានពន្យល់ច្បាស់លាស់នៅឡើយទេ ។ នៅក្នុងប្រទេសកម្ពុជា អ្វីដែលបានកើតឡើងត្រូវបានរៀបរាប់ចេញពីច្រើនប្រភពពីរដ្ឋាភិបាលពីអតីតខ្មែរក្រហម ពីអ្នកនៅរស់និងជនដែលទទួលផលប៉ះពាល់ដោយផ្ទាល់ ពីអ្នកសិក្សាស្រាវជ្រាវ និងពីសហគមន៍អន្តរជាតិ ។ លើសពីនេះ នៅមានការពិតមួយទៀតដែលត្រូវបានលាក់ទុកនៅក្នុងឯកសារចំនួនជិតមួយលានដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានប្រមូលទុក ។ បទពិសោធន៍បង្ហាញថា ក្រោយពីមានអំពើហិង្សារំលោភសិទ្ធិមនុស្សជាទ្រង់ទ្រាយធំ “ការពិត” ច្បាស់ជានឹងមិនដាច់ស្រេច ។ បញ្ហានៃការមានការពិតពីច្រើនប្រភពត្រូវតែដោះស្រាយឲ្យបាន ពីព្រោះថា ការផ្សះផ្សាពិតប្រាកដគឺកាន់តែពិបាកថែមទៀតនៅពេលដែលអ្វីដែលជាការពិតរបស់ភាគីមួយ

បែរជារឿងកុហករបស់ភាគីមួយទៀតទៅវិញ ។ សំណួរសំខាន់បំផុតមួយគឺៈ នៅក្នុងការស្វែងរក“ការពិត” តើនរណាជាអ្នកកំណត់ថាការពិតចេញពីប្រភពមួយត្រឹមត្រូវ?

ទស្សនៈចំពោះការពិតជាការបូកបញ្ចូលគ្នារវាងការពិតពីប្រភពផ្សេងគ្នា គឺខុសគ្នាទាំងស្រុងពីការអនុវត្តន៍តាមផ្លូវច្បាប់នៅលើតុលាការ ។ នៅលើតុលាការការពិតចេញពីប្រភពមួយត្រូវបានចាត់ថាត្រឹមត្រូវឬពិតតាមរយៈការពិសោធន៍ទៅលើភ័ស្តុតាងតាមវិធីសាស្ត្រដែលមានការទទួលស្គាល់ជាទូទៅ ។ ការធ្វើពិសោធន៍បែបនេះមានសារសំខាន់ ពីព្រោះមានអ្នកខ្លះប្រាប់អំពីការពិតដោយស្មោះត្រង់ ឯអ្នកខ្លះទៀតខំប្រឌិតរឿងទៅតាមស្ថានភាព ។ ដើម្បីទទួលបាននូវរូបភាពដ៏សមស្របមួយ យើងត្រូវយកទស្សនៈទាំងអស់ទៅពិចារណា ប៉ុន្តែបញ្ហាមួយចំនួននៅក្នុងប្រទេសកម្ពុជាអាចមានភាពត្រង់ៗ ។ តើខ្មែរសម្លាប់ខ្មែររហូតដល់ទៅ៣លាននាក់ ឬបរទេសដូចជាវៀតណាមជាអ្នកធ្វើ? តើប្រជាជនស្លាប់ដោយខ្លួនឯងឬ? តើឌុចពិតជាប្រធានមន្ទីរស-២១ដែលគ្រប់គ្រងការងារទាំងស្រុងនៅក្នុងគុកឬក៏មិនមែន? តើ នួន ជា, អៀង សារី និង ខៀវ សំផន ដែលជាអ្នកចេះដឹង ជាស្ថាបនិកនៃភាពវិនាសហិនហោចឬ? តើអ្នកទាំងបីរូបនេះដឹងច្បាស់អំពីអ្វីដែលបានកើតឡើងនៅជុំវិញខ្លួនឬទេ? តើជនទាំងបីនេះមានតួនាទីដឹកនាំ ដូចជាដាក់បញ្ជា គាំទ្រ និងជំរុញដល់ការសម្លាប់រង្គាលឬទេ? ចម្លើយនៃសំណួរទាំងអស់នេះ ទោះត្រូវរៀបរាប់ថាជា“ការពិត”ក៏មិនទាន់គ្រប់គ្រាន់សម្រាប់ការផ្សះផ្សាកាន់តែទូលំទូលាយ ឬសម្រាប់គោលដៅផ្នែកសង្គមនយោបាយដែរ ។ ការទទួលស្គាល់ការពិតនេះនឹងបង្កើតឲ្យមានការពិតពាក់កណ្តាល (ឬមួយផ្នែក) ឬអាក្រក់ជាងនេះទៅទៀត នោះគឺការកុហកមួយបែបថ្មី ។

បញ្ហាទាំងនេះបញ្ជាក់អំពីសារសំខាន់នៃដំណើរការកាត់ទោសដែលគួរឲ្យទុកចិត្តបាន ដែលក្នុងនេះការពិតដែលលើកឡើងដោយភាគីខុសគ្នាច្រើនអាចជាការពិតមែនតាមរយៈការវិភាគទៅលើឯកសារ ការបកស្រាយផ្ទាល់មាត់ និងភ័ស្តុតាងផ្សេងទៀត ជាពិសេសនោះតុលាការត្រូវមានបទដ្ឋានសម្រាប់ពិសោធន៍ភាពត្រឹមត្រូវនៃភ័ស្តុតាង ។ បច្ចុប្បន្ននៅក្នុងប្រទេសកម្ពុជាគ្មានបទដ្ឋានបែបនេះទេ ហើយក៏គ្មានគម្រោងនឹងបង្កើតដែរ ។ អង្គជំនុំជម្រះវិសាមញ្ញដែលមានដំណើរការត្រឹមត្រូវអាចបំពេញបាននូវតម្រូវការនេះខ្លះ ប៉ុន្តែក្នុងនាមជាតុលាការ អង្គជំនុំជម្រះវិសាមញ្ញនឹងត្រូវកំណត់ឲ្យស្វែងរកការពិតដែលទាក់ទងទៅនឹងការចោទទៅលើជនជាប់ចោទ ។ ភាពគួរឲ្យទុកចិត្តនៃការរកឃើញរបស់តុលាការមានទំនាក់ទំនងដោយផ្ទាល់ទៅនឹងគុណភាពនៃនីតិវិធី ។ លើសពីនេះមានអ្នកទុកចិត្តច្រើនជាងអ្នកមិនទុកចិត្តអំពីភាពត្រឹមត្រូវនៃអង្គជំនុំជម្រះវិសាមញ្ញ ។ គ្មានយន្តការស៊ើបអង្កេតជាផ្លូវការណាមួយត្រូវបានបង្កើតឡើងដើម្បីស្វែងរកការពិតដែលធ្វើឲ្យមានការយល់ដឹងជ្រាលជ្រៅទេ ។

ចម្លើយដែលទទួលបានបញ្ជាក់ថា ជាង២៥ឆ្នាំក្រោយការដួលរំលំ របបខ្មែរក្រហមនៅតែជាផ្នែកមួយនៃជីវិតប្រចាំថ្ងៃរបស់ប្រជាជនខ្មែរ ។ លើសពីការចង់ដឹងកាន់តែច្បាស់អំពីវគ្គនេះនៃប្រវត្តិសាស្ត្រកម្ពុជា គឺការចង់អប់រំឲ្យដឹង ចង់យល់ ចង់មាន“យុត្តិធម៌” និងចង់ធានាថាយុគដ៏ខ្មៅងងឹតនេះនឹងមិនត្រូវបំភ្លេចចោលនោះទេ ។ ការអើពើចំពោះអ្វីដែលបញ្ញាជនផ្នែកយុត្តិធម៌សម័យអន្តរកាលរៀបរាប់ថាជា“ការទទួលស្គាល់ជាផ្លូវការ” អាចមកពីមិនមានការទាមទារឲ្យបានច្បាស់លាស់ ។ “ការទទួលស្គាល់”បែបនេះអាចមិនសូវមានសារប្រយោជន៍ចំពោះប្រជាជនកម្ពុជា ។ ទោះជាការបដិសេធគឺជាយុទ្ធសាស្ត្រដ៏ច្បាស់ក្រឡែតមួយរបស់មេដឹកនាំខ្មែរក្រហមក៏ដោយ ក៏គ្មានអាថ៌កំបាំងធំធេងចំពោះអ្វីដែលបានកើតឡើងដែរ ។ ៨៩,៤២ភាគរយនៃអ្នកឆ្លើយបានបាត់បង់ញាតិសន្តានម្នាក់ឬច្រើន ហើយ៧៧,៣២ភាគរយបានរៀបរាប់ពីការធ្វើទារុណកម្មមកលើខ្លួន ។ ក្នុងកម្រិតជាតិនិងអន្តរជាតិ អំពើឃោរឃៅនៅកម្ពុជាត្រូវបានរៀបរាប់ម្តងហើយម្តងទៀតថាជាឧទាហរណ៍ដ៏ច្បាស់លាស់នៃភាពយង់ឃ្នងរបស់មនុស្សដែលធ្លាប់កើតមាន ។ ចំណុចពិស្តារនៃអំពើឃោរឃៅ សកម្មភាពការងាររបស់អង្គការខ្មែរក្រហម និងមេដឹកនាំ ព្រមទាំងមូលហេតុនៃអំពើឃោរឃៅ កំពុងស្ថិតនៅក្នុងភាពអាថ៌កំបាំងអស់រយៈពេលជាយូរមកហើយ ។ មានប្រជាជនខ្មែររាប់លាននាក់បានឆ្លងកាត់របបខ្មែរក្រហម ។ ហេតុនេះ កម្ពុជាមិនមែនកំពុងតែប្រឈមមុខនឹងស្ថានការណ៍



ព្រះសង្ឃជាអ្នកដែលបានរួមចំណែកយ៉ាងសំខាន់ក្នុងការផ្សះផ្សាជាតិនៅកម្ពុជា

ដែលត្រូវគេបង្ខំឲ្យបិទមាត់មិននិយាយពីអតីតកាល ឬជនរងគ្រោះត្រូវបានដាក់ឲ្យស្ថិតនៅក្រោមសង្គម ឬត្រូវបានបង្ខំឲ្យនៅស្ងៀមដោយខ្លាចថាមានការបង្ហូរឈាមបន្ថែមទេ ។ ទោះបីជារដ្ឋាភិបាលមិនយកចិត្តទុកដាក់ចំពោះរឿងខ្មែរក្រហម ហើយពុំសូវមានការពិភាក្សាវែកញែកជាសាធារណៈក្តី ក៏ប្រជាជនខ្មែរបានដដែកអំពីអ្វីដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជា-ធិបតេយ្យតាំងពីឆ្នាំ១៩៧៩មកម្ល៉េះ ដោយមានការគាំទ្រខ្លះពីរដ្ឋដើម្បីបម្រើផលប្រយោជន៍នយោបាយ ដូចជាការបង្កើត «ទិវាចងកំហឹង» ជាដើម ។

ការឈឺចាប់ដែលប្រជាជនកម្ពុជាបានទទួលរងមានទំហំធំហួសប្រមាណ ។ ការខំប្រឹងកែកុនស្ថានភាពតាមរយៈការកាត់ទោសមេដឹកនាំពីរបីនាក់ ការសុំទោស ការរៀបរាប់អំពីបទពិសោធន៍ផ្ទាល់ខ្លួននៅក្នុងគណៈកម្មការស្វែងរកការពិត ឬការកំណត់ថា“ការពិត”មានសភាពបែបណា ទាំងនេះគឺជាការសម្រាលទម្ងន់នៃការបាត់បង់និងការឈឺចាប់របស់ជនរងគ្រោះ ។ ការផ្សះផ្សាមិនគួរត្រូវបានលើកឡើងថាជាឱសថទិព្វឬជាកាតព្វកិច្ចផ្នែកសីលធម៌នោះទេ ។ ជនរងគ្រោះក៏មិនគួរត្រូវស្នើឲ្យស្រលាញ់អ្នកដែលធ្លាប់ធ្វើទារុណកម្មលើខ្លួនដែរ ។ ការផ្សះផ្សាគួរបង្ក



ឲ្យមានមូលដ្ឋាននៃការទុកចិត្តគ្នា ក្នុងកម្រិតអប្បបរមា ដើម្បីឲ្យមានការសហការគ្នាក្នុងកម្រិត មួយដែលនាំឲ្យប្រជាជនកម្ពុជាឆ្លងផុតពីការធ្វើទារុណកម្មលើ គ្នាទៅវិញទៅមក។ ប៉ុន្តែបុគ្គលទាំងឡាយណាដែលមិនអាច អត់ឱនឬផ្សះផ្សា មិនគួរត្រូវបានចាត់ទុកថាខ្វះការអនុគ្រោះ ខ្វះមនុស្សធម៌ ឬខ្វះមេត្តាធម៌ឡើយ។ ដូចគ្នាដែរ ជនដៃដល់ ក៏មិនត្រូវបង្ខំឲ្យសុំទោសទាំងមិនពេញចិត្តដែរ។ មិនត្រូវធ្វើឲ្យ ប្រជាជនកម្ពុជាសង្ស័យពីការកែប្រែឆាប់រហ័សតាមរយៈ ការរៀបរាប់មិនត្រឹមត្រូវ ខ្វះការពិចារណាម៉ត់ចត់អំពី ទ្រឹស្តីដ៏ស្មុគស្មាញនិងអរូបិយ នៃ “យុត្តិធម៌” “ការព្យាបាល” “ការអត់ឱន” “ការស្ដារបនាឡើងវិញ” និង “ការពិត”។ គ្មានចំណុចណាមួយខាងលើអាចនាំឲ្យមានការផ្សះផ្សានិងធ្វើឲ្យសង្គមវិលទៅរកភាពដើមវិញទេ ប៉ុន្តែចំណុចទាំងនេះសុទ្ធតែជាវិភាគទានសំខាន់ក្នុងការសម្រេចឲ្យបាននូវការផ្សះផ្សាជាតិ។

ការផ្លាស់ប្តូរត្រូវបានមើលឃើញយ៉ាងច្បាស់ក្នុងកម្រិតមូលដ្ឋាននៅកម្ពុជា។ មានអាកប្បកិរិយាវិជ្ជមានចំពោះការផ្សះផ្សា។ នៅត្រង់នេះមានអំណាចដ៏ធំមួយ ពីព្រោះការស្ទាបស្ទង់បានបង្ហាញថា អនាគតរបស់ប្រទេសកម្ពុជាស្ថិតនៅក្នុងដៃរបស់ប្រជាជនកម្ពុជា។ ការកេងយកប្រយោជន៍ពីធនធានដ៏ធំធេងនេះដែលជាបំណងល្អរបស់ប្រជាជនកម្ពុជាសាមញ្ញនិងសុឆន្ទៈសហការដើម្បីអនាគតរុងរឿង មានសារសំខាន់ណាស់សម្រាប់ការផ្សះផ្សានៅកម្ពុជា។ ការកាត់ទោសនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញនឹងផ្តល់នូវឱកាសមួយសម្រាប់ធ្វើឲ្យសុឆន្ទៈទាំងនេះក្លាយទៅជាការផ្សះផ្សាពិតប្រាកដនិងឋិតថេរ។ ឱកាសបានមកដល់ហើយ។ រាជរដ្ឋាភិបាលកម្ពុជាត្រូវតែក្តាប់ឱកាសនេះឲ្យបានដើម្បីប្រែក្លាយកម្ពុជាឲ្យទៅជាជាតិមួយដែលពលរដ្ឋកម្ពុជាគ្រប់រូបចង់រស់នៅ។

## III. ការផ្តល់អនុសាសន៍

### ១) រាជរដ្ឋាភិបាលកម្ពុជា

### សារប្រយោជន៍នៃយុទ្ធសាស្ត្រយុត្តិធម៌សម័យអន្តរកាលដ៏មានប្រសិទ្ធភាព

បរិយាកាសនយោបាយនៅកម្ពុជាមិនមានផលល្អសម្រាប់ដំណើរការពិតប្រាកដមួយដើម្បីបើកកកាយរឿងរ៉ាវទាំងស្រុងនៃការដួលរលំរបស់ខ្មែរក្រហមនៅកម្ពុជា ទោះតាមមធ្យោបាយយុត្តិធម៌ព្រហ្មទណ្ឌឬតាមគណៈកម្មការនៃការស៊ើបសួរក្តី។ ចំណុចនេះគឺផ្ទុយស្រឡះទៅនឹងចម្លើយដែលទទួលបាននៅក្នុងការស្ទាបស្ទង់មតិនិងការស្ទាបស្ទង់ផ្សេងទៀតដែលបានបង្ហាញថាប្រជាជនកម្ពុជាមួយភាគធំមិនចង់“ជីកកប់អតីតកាល”ទេ ផ្ទុយទៅវិញ គាត់ចង់ឲ្យរឿងរ៉ាវទាំងអស់ត្រូវបានលាតត្រដាង។

នេះជាពេលដែលរាជរដ្ឋាភិបាលកម្ពុជាគួរតែចាប់ផ្តើម

ដោះស្រាយតម្រូវការស្មុគស្មាញនិងសិទ្ធិពលរដ្ឋក្នុងរឿងខ្មែរក្រហមហើយ ។ មកទល់បច្ចុប្បន្ន រាជរដ្ឋាភិបាលបានបង្ហាញអំពីកង្វះខាតភាពបួរផ្តាច់និងស្មោះត្រង់នៅក្នុងការឆ្លើយតបទៅនឹងកាតព្វកិច្ចនេះនិងកាតព្វកិច្ចអន្តរជាតិរបស់កម្ពុជា ។ លើសពីអ្វីៗទាំងអស់ រដ្ឋាភិបាលចាំបាច់ត្រូវលុបបំបាត់ចោលនូវបរិយាកាសភ័យខ្លាច និងចាប់ផ្តើមបង្កើតមជ្ឈដ្ឋាននយោបាយចំហមួយដែលពិភាក្សានិងវែកញែកដោយស្មោះត្រង់អំពីអ្វីដែលបានកើតឡើង ព្រមទាំងយន្តការពិតប្រាកដសម្រាប់វិភាគអតីតកាលឲ្យមានប្រសិទ្ធភាព ។ ការរៀបចំនិងការអនុវត្តន៍ឡើងនូវយុទ្ធសាស្ត្រយុត្តិធម៌សម័យអន្តរកាលដ៏សមស្របមួយដែលទទួលស្គាល់ប្រយោជន៍ដ៏ធំធេងនៃដំណើការដាក់ឲ្យទទួលខុសត្រូវនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ព្រមទាំងដើរតួនាទីជាកាតាលីករសម្រាប់ការត្រួតពិនិត្យខ្លួនឯងទូទាំងប្រទេស ការជួសជុលសង្គម និងការនាំឲ្យមានការផ្លាស់ប្តូរ ត្រូវតែក្លាយទៅជាអាទិភាពរបស់រាជរដ្ឋាភិបាល ។ អយុត្តិធម៌នៃជីវិតនៅក្នុងប្រទេសកម្ពុជាគឺជាប្រភពនៃភាពចលាចលនៅពេលអនាគត ។ ការស្រាវជ្រាវបានបង្ហាញថា មេដឹកនាំកម្ពុជាគួរពិចារណាអំពីវិធីសាស្ត្រផ្សេងទៀតដែលមានលើសពីការកាត់ទោសជានិមិត្តរូបទៅលើមេដឹកនាំខ្មែរក្រហមពីរបីនាក់ នៅក្នុងដំណើរការកាត់ទោសមួយដែលមិនបំពេញតាមបទដ្ឋានអន្តរជាតិ ឬការមិនធ្វើអ្វីទាំងអស់ ។

ការទទួលខុសត្រូវនៅក្នុងតុលាការច្បាប់ដែលបំពេញទៅតាមបទដ្ឋានអន្តរជាតិ និងការទទួលយកជំហរជាគោលការណ៍ធូរបន្តិចទៅលើកម្រិតនៃការទទួលខុសត្រូវ ត្រូវបានមើលឃើញថាសំខាន់បំផុតនៅក្នុងប្រទេសកម្ពុជា ។ ការពិភាក្សាទៅលើយុត្តិធម៌សម័យអន្តរកាលទាក់ទងទៅនឹងទស្សនៈពីរគឺ ទស្សនៈទាមទារឲ្យមានការដាក់ទណ្ឌកម្មនិងកែប្រែជនល្មើសជាគោលដៅនយោបាយ និងទស្សនៈទាមទារដោះស្រាយភាពតានតឹងនៅក្នុងសង្គមតាមរយៈការខិតខំជួសជុលការខូចខាតឲ្យជនរងគ្រោះ ។ ទស្សនៈទាំងពីរនេះមានឥទ្ធិពលទៅលើអាកប្បកិរិយារបស់ប្រជាជនចំពោះការផ្សះផ្សា ហើយចំណុចសំខាន់គឺការស្វែងរកតុល្យភាពរវាងការលាក់បាំងការពិតនិងការដាក់ទណ្ឌកម្ម ។ ការស្ទាបស្ទង់បានបង្ហាញយ៉ាងច្បាស់ថា ទោះបីជាមានភាពខុសគ្នាអំពីអត្ថន័យនៃពាក្យផ្សះផ្សាក៏ដោយ ក៏មានសុឆន្ទៈចង់បានការផ្សះផ្សាដែរ បានសេចក្តីថា ប្រជាជនកម្ពុជាមានគំនិតច្រើនអំពីវិធីជួសជុលនិងអភិវឌ្ឍន៍សង្គមជាតិ ។ ដោយសារអង្គជំនុំជម្រះវិសាមញ្ញនឹងត្រូវបង្កើតក្នុងពេលឆាប់ៗខាងមុខនេះ ទោះបីជាអង្គជំនុំជម្រះនេះមិនមែនជាជម្រើសល្អបំផុតក៏ដោយ ក៏អង្គជំនុំជម្រះនេះនឹងផ្តល់នូវឱកាសមួយដើម្បីអនុវត្តគោលនយោបាយយុត្តិធម៌សម័យអន្តរកាលស្របតាមគោលការណ៍ និងផ្ការគោរពតាមដែលជំរុញឲ្យមានការជួសជុលសង្គម ។

យុទ្ធសាស្ត្រដ៏មានប្រសិទ្ធភាពមួយគួរតែមានយ៉ាងហោចណាស់គោលដៅសំខាន់ៗចំនួន៤គឺ ស្វែងរកយុត្តិធម៌ ផ្តល់ឲ្យជនរងគ្រោះនូវសិទ្ធិដឹងអំពីការពិត ផ្តល់សំណងជួសជុលការខូចខាតដល់ជនរងគ្រោះតាមរបៀបមួយដែលបង្ហាញអំពីការផ្តល់តម្លៃនិងសេចក្តីថ្លៃថ្នូរជាមនុស្សដល់ជនរងគ្រោះ និងបណ្តេញចេញចេញពីតំណែងសាធារណៈនូវបុគ្គលដែលជាប់ពាក់ព័ន្ធនឹងរបបជិះជាន់ ។ លើសពីនេះ គោលនយោបាយនេះគួរតែមានគោលដៅការពារការកើតឡើងសាជាថ្មីនៃអំពើហិង្សា និងជួសជុលការខូចខាតប្រសិនបើអាចធ្វើបាន ។ ភាពដែលអាចធ្វើបាននូវការផ្សះផ្សាកម្រិតបុគ្គលនិងកម្រិតសហគមន៍ដែលឋិតនៅក្នុងវប្បធម៌របស់កម្ពុជានិងប្រពៃណីព្រះពុទ្ធសាសនា ត្រូវយកទៅពិចារណាឲ្យកាន់តែល្អិតល្អន់ ។ យើងគួរពិចារណាអំពីការទទួលខុសត្រូវដោយផ្គួបជាមួយដំណើរការស្រាវជ្រាវអំពីប្រវត្តិសាស្ត្រទូលំទូលាយ ត្រឹមត្រូវ មិនលម្អៀង ពីព្រោះថា ដើម្បីស្វែងយល់អំពីវិធីកសាងសង្គមកម្ពុជាសាជាថ្មី យើងត្រូវយល់អំពីមូលហេតុដែលនាំឲ្យសង្គមមានវិបត្តិផង ។

កាលៈទេសៈជាក់ស្តែងនៅក្នុងប្រទេសកម្ពុជា ព្រមទាំងភាពគ្មានអំណាចរបស់ប្រជាជន ធ្វើឲ្យយុទ្ធសាស្ត្រយុត្តិធម៌សម័យអន្តរកាល និងការអនុវត្តន៍យុទ្ធសាស្ត្រនេះដែលជាគម្រោងរបស់កម្ពុជាបង្កើតដោយប្រជាជនកម្ពុជា (រួមទាំងការជួយជ្រោមជ្រែងពីបរទេស) ដើម្បីតម្រូវទៅតាមកាលៈទេសៈជាក់ស្តែងនៅក្នុងប្រទេសកម្ពុជា គឺជារឿងសំខាន់ណាស់ ។ ការទាមទារត្រូវមានភាពជាក់ស្តែងមិនស្រមើស្រមៃ ។ យុទ្ធសាស្ត្រយុត្តិធម៌សម័យអន្តរកាលមួយត្រូវតែផ្អែកទៅលើ “សីលធម៌ប្រជាធិបតេយ្យ”

ពោលគឺស្ថាប័នសំខាន់ៗមួយចំនួនត្រូវមានដំណើរការល្អ គោរពតាមបទដ្ឋានជាក់លាក់ណាមួយ ហើយត្រូវមាន«ការគោរពសិទ្ធិមនុស្ស យុត្តិធម៌ សេដ្ឋកិច្ច ធម្មាធិបតេយ្យ តម្លាភាពនៃអភិបាលកិច្ច និងសមភាពបែងចែកធនធាន ជាដើម» ។

### ចៀសវាងភាពស្មុគស្មាញ ញែកគោលដៅនីមួយៗឲ្យដាច់ពីគ្នា

នៅពេលពិចារណាអំពីយុទ្ធសាស្ត្រយុត្តិធម៌សម័យអន្តរកាល រដ្ឋាភិបាលគួរពិចារណាថា នៅក្នុងកាលៈទេសៈកម្ពុជាគួរបែងចែកគោលដៅនៃយុត្តិធម៌សម័យអន្តរកាលដែលពិបាកចេញឬអត់ ហើយស្វែងរកមធ្យោបាយបំពេញនូវគោលដៅនីមួយៗ«ដាច់ដោយឡែកពីគ្នា» ជាជាងការដាក់គោលដៅធំស្មុគស្មាញច្រើនហើយប្រើយន្តការតែមួយដើម្បីសម្រេចនូវគោលដៅទាំងនេះ ។

លទ្ធផលចុងក្រោយគួរតែទទួលបាននូវការពេញចិត្តច្រើន ប្រសិនបើកាតព្វកិច្ចត្រូវបានកំណត់ឲ្យមានលក្ខណៈសាមញ្ញ ។ ឧទាហរណ៍ ចំពោះគោលការណ៍នៃយុត្តិធម៌និងការទទួលខុសត្រូវ គួរបំពេញដោយដំណើរការយុត្តិធម៌ព្រហ្មទណ្ឌដែលគោរពទៅតាមបទដ្ឋានអន្តរជាតិ (អង្គជំនុំជម្រះវិសាមញ្ញអាចនឹងផ្តល់នូវលទ្ធផលបែបនេះ) ។ នៅក្នុងកាលៈទេសៈប្រទេសកម្ពុជា វាអាចមានសារសំខាន់ជាងបើយើងផ្តោតអារម្មណ៍ទៅលើការខំបំពេញទៅតាមគោលដៅនៃការកំណត់ការពិតដោយខ្លួនឯង ជាងការភ្ជាប់គោលដៅនេះទៅនឹងគោលដៅនយោបាយសង្គមដូចជាការផ្សះផ្សានិងការព្យាបាល ។ គោលដៅដ៏សំខាន់ទាំងពីរនេះត្រូវតែទាមទារតាមរយៈគម្រោងជួសជុលសង្គមដែលត្រូវបានរៀបចំឡើងជាពិសេស ។

ដោយការបង្កើតជាថ្មីនូវក្រមសីលធម៌ ឧត្តមភាពនៃច្បាប់និងការស្វែងរកយុត្តិធម៌ក្នុងរឿងក្តីបុគ្គលមានសារសំខាន់ យុត្តិធម៌ព្រហ្មទណ្ឌមិនអាចត្រូវសង្ឃឹមថាអាចផ្តល់នូវការព្យាបាលពីឋានសួគ៌សម្រាប់បញ្ហាទាំងអស់នៅក្នុងសង្គមកម្ពុជាឡើយ ។ យុត្តិធម៌ព្រហ្មទណ្ឌមិនដែលមានគោលដៅ«ផ្សារះរបួស»នរណាម្នាក់ ឬផ្តល់ជាមធ្យោបាយដោះទុក្ខ ឬ«បកស្រាយរឿងហេតុ» ទេ ។ ការកាត់ទោសជាទ្រង់ទ្រាយធំទៅលើរាល់ជនដៃដល់ខ្មែរក្រហមក៏មិនអាចធ្វើបានដែរ ។ ក៏ប៉ុន្តែ មិនត្រូវសន្និដ្ឋានថាការកាត់ទោសមេដឹកនាំខ្មែរក្រហមប៉ុន្មាននាក់ ជាពិសេសនៅក្នុងដំណើរការបំពេញតាមបទដ្ឋានអន្តរជាតិ នឹងផ្តល់នូវ«យុត្តិធម៌» ហើយ «ប្រែក្លាយ»ឬ«រំដោះ» ប្រជាជនកម្ពុជាចេញពីការឈឺចាប់ក្នុងដួងចិត្ត ឬដោះស្រាយបញ្ហានៃសង្គមបាក់បែកមួយនោះទេ ។

### ការបង្កើតគណៈកម្មការស៊ើបសួរ

ការអនុវត្តន៍នូវយុទ្ធសាស្ត្រយុត្តិធម៌សម័យអន្តរកាលមានសារសំខាន់ក្នុងការព្យាបាលបុគ្គលនិងសង្គមទាំងមូល ។ យុទ្ធសាស្ត្រនេះគួរធ្វើតាមរយៈការទទួលខុសត្រូវ ដោយផ្គួបជាមួយដំណើរការបង្កើតការស្រាវជ្រាវអំពីប្រវត្តិសាស្ត្រទូលំទូលាយ ត្រឹមត្រូវ មិនលម្អៀង ដែលបង្កឲ្យមានកម្មវិធីសុខភាពផ្លូវចិត្តនិងការស្តារនីតិសម្បទាសម្រាប់បុគ្គលនិងសង្គមនៅតាមមូលដ្ឋាន ។

នៅក្នុងកាលៈទេសៈប្រទេសកម្ពុជា គោលដៅស្វែងរកការពិតដ៏សំខាន់គួរត្រូវសម្រេចតាមគណៈកម្មការស៊ើបសួរ ដោយប្រើប្រាស់ធនធានដែលមានស្រាប់ដូចជាឯកសារនិងភស្តុតាងដែលមជ្ឈមណ្ឌលឯកសារកម្ពុជាប្រមូលបាន ព្រមទាំងសាក្សីជាច្រើននាក់ដើម្បីបង្កើតឡើងនូវសំណេរឯកសារប្រវត្តិសាស្ត្រជាតិទូលំទូលាយ ត្រឹមត្រូវ និងគួរទុកចិត្តបាន ។ គណៈកម្មការនេះគួរចាប់អារម្មណ៍ទៅលើការស៊ើបអង្កេតគោរពតាមបទដ្ឋាន និងអាចឆ្លើយទៅនឹងសំណួរ «ហេតុអ្វី» ទាក់ទងទៅនឹងសោកនាដកម្មកម្ពុជា ។ ស្ថាប័ននេះក៏អាចផ្តល់ជាអនុសាសន៍លើផ្នែកកំណែទម្រង់និងការកាត់ទោសដែរ ប៉ុន្តែយន្តការនេះមិនត្រូវប្រកួតប្រជែងជាមួយនឹងអង្គជំនុំជម្រះវិសាមញ្ញទេ ផ្ទុយទៅវិញ ត្រូវបំពេញកង្វះខាតរបស់អង្គជំនុំជម្រះនេះ ។

### ការអនុវត្តន៍គម្រោងបំពេញបន្ថែម ផ្តោតលើការជួសជុលសង្គម និងការស្តារនីតិសម្បទា ទ្រទ្រង់ដោយកម្មវិធីសុខភាពផ្លូវចិត្ត រៀបចំនិងអនុវត្តតាមបែបផែនត្រឹមត្រូវ

ការព្យាបាល ការផ្សះផ្សា និងគោលដៅនយោបាយសង្គមផ្សេងទៀត ទាមទារពេលវេលាមិនអាចបង្ខំបាន តែអាចជំរុញឲ្យបានលឿនតាមរយៈយុទ្ធសាស្ត្រយុត្តិធម៌សម័យអន្តរកាលដែលប្រើប្រាស់យន្តការមានប្រសិទ្ធភាពដើម្បីបង្កើតជាឱកាសជួសជុលសង្គម ។

បើតាមស្ថានភាពប្រទេសកម្ពុជាបច្ចុប្បន្ន គោលដៅអរូប និងស្មុគស្មាញទាំងនេះហាក់មិនអាចសម្រេចបានទេ ប្រសិនបើវាជាផ្នែកនៃយន្តការមួយដូចជា«គណៈកម្មការស្វែងរកការពិត» ។ អ្នកឆ្លើយមិនបានបញ្ចេញអំពីការចាប់អារម្មណ៍ចំពោះគណៈកម្មការបែបនោះទេ ។

ល្អបំផុត ត្រូវតែសម្រេចគោលដៅសង្គមនយោបាយទាំងនេះឲ្យបានតាមរយៈការអនុវត្តគម្រោងជួសជុលនិងស្តារនីតិសម្បទាសង្គមទូលំទូលាយ ដែលគាំទ្រដោយកម្មវិធីសុខភាពផ្លូវចិត្តធ្វើឡើងតាមបែបដែនត្រឹមត្រូវស្របទៅតាមវប្បធម៌សង្គម ។ គោលដៅទាំងនេះត្រូវស៊ីសង្វាក់គ្នា ដើម្បីអាចបំពេញឲ្យដំណើរការផ្សេងនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញឬគណៈកម្មការស៊ើបសួរ ។

## ការអនុវត្តន៍យន្តការទទួលខុសត្រូវបែបផ្សេងដែលផ្សាយប៉ះទង្គិចនឹងវប្បធម៌

កម្ពុជាមិនគួរបោះបង់ចោលយន្តការបែបថ្មីនិងផ្សាយប៉ះទង្គិចនឹងវប្បធម៌ ដែលអូសទាញជនដៃដល់ថ្នាក់ទាបឲ្យមកទទួលខុសត្រូវ ហើយបំពេញសំណងជួសជុលការខូចខាតក្នុងទម្រង់មួយដោយផ្ទាល់ទៅកាន់សហគមន៍ដែលបានរងគ្រោះឡើយ ។ ឧទាហរណ៍ ពីរនៃការធ្វើបែបនេះគឺដំណើរការផ្សះផ្សាសហគមន៍នៅទីម័រខាងកើតនិងតុលាការ«កាឆាឆា» របស់ប្រទេសវ៉្វាន់ដាដែលដើរតួជាយន្តការដាក់ឲ្យមានការទទួលខុសត្រូវ ។ យន្តការទទួលខុសត្រូវផ្សេងទៀតមានសារសំខាន់ជាពិសេសនៅពេលពិចារណាអំពីលទ្ធផលនៃការស្ទាបស្ទង់នេះ ចំនួនដ៏ច្រើននៃបុគ្គលដែលជាប់ពាក់ព័ន្ធនៅក្នុងឧក្រិដ្ឋកម្មរបស់កម្ពុជាប្រជាធិបតេយ្យ និងឆន្ទៈរបស់កម្មាភិបាលថ្នាក់ទាបជាច្រើនរូបដែលអាចជួយមជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងការផ្សារដាក់ឲ្យមានការទទួលខុសត្រូវរបស់មជ្ឈមណ្ឌល ។ ការចង់បានការផ្សះផ្សាត្រូវដើរទន្ទឹមនឹងការទាមទារឲ្យមានសំណងជួសជុលចំពោះអ្វីដែលបានកើតឡើងតាមរយៈយន្តការពិសេសមួយបង្កើតឡើងដើម្បីតែបំពេញតម្រូវការរបស់ប្រទេសកម្ពុជា ។

ផលល្អដែលកប់នៅក្នុងវប្បធម៌និងសាសនាកម្ពុជាត្រូវស្រាវជ្រាវឲ្យបានជ្រាលជ្រៅ ។ សហគមន៍អាចទទួលជំនួយនៅក្នុងការបង្កើតដំណើរការធ្វើឲ្យមានការទុកចិត្តនិងដំណោះស្រាយជម្លោះ ដោយផ្អែកទៅលើទ្រឹស្តីព្រះពុទ្ធសាសនា ។ បើអាចធ្វើបាន ដំណើរការនេះគួរមានទីតាំងនៅជិតវត្តអារាម និងដឹកនាំដោយចាស់ព្រឹទ្ធាចារ្យក្នុងសហគមន៍ ។

## ការលើកលែងទោស

ការលើកលែងទោសសម្រាប់បទឧក្រិដ្ឋប្រល័យពូជសាសន៍ ការធ្វើទារុណកម្ម ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺផ្ទុយស្រឡះទៅនឹងកាតព្វកិច្ចអន្តរជាតិរបស់រដ្ឋ ។ ទោះបីជាមានភាពធ្ងន់ធ្ងរមិនអាចថ្លែងបាននៃបទឧក្រិដ្ឋដែលប្រព្រឹត្តឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មេដឹកនាំកម្ពុជាបានប្រើប្រាស់ការលើកលែងទោសនិងការអនុគ្រោះទោសជាកត្តាសំខាន់នៃយុទ្ធសាស្ត្ររំលាយខ្មែរក្រហមរបស់ខ្លួន ដើម្បីបញ្ចប់សង្គ្រាម ។ មេដឹកនាំខ្មែរយល់ថា សន្តិភាពកើតឡើងនៅលើទឹកដីកម្ពុជាតាមរយៈ«ការផ្សះផ្សា»ជាមួយនឹងខ្មែរក្រហម ។

ដោយសារវប្បធម៌នៃការរួចទោស ភាពគ្មានច្បាប់ និងកង្វះការទទួលខុសត្រូវ ការបន្តប្រើប្រាស់ការលើកលែងទោសជាឧបករណ៍សម្រាប់ជួសជុលសង្គម អាចរុញច្រានធម្មាធិបតេយ្យឲ្យខិតកាន់តែឆ្ងាយ ហើយពង្រឹងអនាធិបតេយ្យ ។ ប្រទេសកម្ពុជាពិតជាប្រឈមមុខនឹងបញ្ហាដ៏ធំដោយសារជនដៃដល់មានចំនួនច្រើន ដែលក្នុងនោះមានទាំងពត៌មានសំខាន់ទាក់ទងទៅនឹងអ្វីដែលបានកើតឡើង ។ ប្រវត្តិសាស្ត្រប្រហែលជាសរសេរឡើងផ្អែកលើជនទាំងនេះនិងប្រភពផ្សេងទៀត ។ ការចង់ឮ «ការពិត» ពីជនដៃដល់មិនមែនជាការគាំទ្រការលើកលែងទោសទេ ។ នៅកម្ពុជា ការលើកលែងទោសមិនគួរជាផ្នែកមួយនៃគោលនយោបាយយុត្តិធម៌សម័យអន្តរកាលឡើយ ។

## ៧) អង្គការក្រៅរដ្ឋាភិបាល

សង្គមស៊ីវិលដ៏ក្មេងខ្ចីនិងកំពុងរីកលូតលាស់របស់កម្ពុជាគឺជាកម្លាំងដ៏ធំមួយរបស់ប្រទេសនេះ ។ សង្គមស៊ីវិលជាប្រភពគំនិត ជំនាញ និងការដឹកនាំល្អៗ ។ សង្គមស៊ីវិលមានតួនាទីសំខាន់នៅក្នុងការជំរុញ ការដាក់សម្ពាធ និងការជួយរដ្ឋដើម្បីបង្កើតយុទ្ធសាស្ត្រយុត្តិធម៌សម័យអន្តរកាលគួរជាទីចង់បានមួយ ។ យុទ្ធសាស្ត្រយុត្តិធម៌សម័យអន្តរកាលនេះគួរធ្វើឡើងដោយយក

សហគមន៍ជាធំ រួមទាំងការបង្កើតយន្តការសម្រាប់ការទទួលខុសត្រូវព្រហ្មទណ្ឌ និងយន្តការមួយទៀតដែលអាចបង្កើតឯកសារប្រវត្តិសាស្ត្រជាផ្លូវការនិងត្រឹមត្រូវ ព្រមទាំងកម្មវិធីពិសេសផ្សេងទៀតទាក់ទងនឹងការជួសជុលសង្គម ។ ទោះជារដ្ឋអាចធ្វើបានក៏ដោយ ក៏សង្គមស៊ីវិលអាចសម្រេចបានជោគជ័យច្រើនជាងក្នុងកម្រិតមូលដ្ឋានក្នុងការបំពេញចន្លោះប្រហោងបង្កើតឡើង ដោយដំណើរការដាក់ឲ្យទទួលខុសត្រូវដើម្បីបំពេញការងារផ្នែកផ្សះផ្សានិងជួសជុលសង្គមដោយផ្ទាល់ ។

## ការបង្កើតយុទ្ធសាស្ត្ររួមដើម្បីទាញប្រយោជន៍ពីអ្វីដែលមានស្រាប់

អ្វីដែលសំខាន់ជាងគេគឺអង្គការក្រៅរដ្ឋាភិបាលរបស់កម្ពុជាត្រូវបង្កើតយុទ្ធសាស្ត្ររួមដើម្បីទាញប្រយោជន៍ពីការងារដែលកំពុងធ្វើដោយអង្គការជាច្រើន ហើយដើម្បីស្វែងរកចំណុចរួមយកមកបំពេញឲ្យការរកឃើញនៅក្នុងសៀវភៅនេះដែលថាប្រជាជនកម្ពុជាគឺជាអ្នកដែលកំណត់អនាគតរបស់ប្រទេសកម្ពុជា មិនមែនតែមេដឹកនាំទេ ។

យុទ្ធសាស្ត្រអង្គការក្រៅរដ្ឋាភិបាលល្អត្រូវពិចារណាអំពីការទទួលខុសត្រូវរបស់សង្គមស៊ីវិលប្រសិនបើរាជរដ្ឋាភិបាលនិងអង្គការសហប្រជាជាតិបរាជ័យមិនបានផ្ដល់ដំណើរការយុត្តិធម៌នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ។ សង្គមស៊ីវិលត្រូវពិចារណាថាតើកម្មវិធីណាដែលសង្គមស៊ីវិលគួរអនុវត្តនៅពេលរដ្ឋមិនចាត់វិធានការជួសជុលសង្គម ដោយយោលតាមអនុសាសន៍នៅក្នុងសៀវភៅនេះឬសៀវភៅផ្សេង ។ យុទ្ធសាស្ត្រនោះនឹងត្រូវដោះស្រាយចំពោះការមិនគាំទ្ររាល់ដំណើរការទទួលខុសត្រូវពិតប្រាកដណាមួយ ឬការដោះស្រាយរឿងអតីតកាលដែលមិនគាំទ្រដោយរដ្ឋ ។

## បំពេញចន្លោះប្រហោងនៅក្នុងការតំណាងជនរងគ្រោះ

មានចន្លោះប្រហោងដ៏ធំមួយនៅក្នុងសង្គមស៊ីវិល នោះគឺអវត្តមាននៃអង្គការក្រៅរដ្ឋាភិបាលឯកទេសដែលតំណាងផ្ទាល់មុខឲ្យជនរងគ្រោះនិងអ្នកនៅរស់ពីរបបខ្មែរក្រហម ។ ជាច្រើនឆ្នាំមកហើយ អង្គការសិទ្ធិមនុស្សបានធ្វើការងារនេះ ប៉ុន្តែអ្វីដែលចាំបាច់នោះគឺជាស្ថាប័នមួយ (ឬច្រើន) ដែលផ្ដោតទៅលើការឆ្លើយតបទៅនឹងសេចក្ដីត្រូវការនិងការចង់បានរបស់ជនរងគ្រោះនិងអ្នកនៅរស់ ។ ស្ថាប័នបែបនេះ ដែលអាចមានអ្នកគាំទ្ររហូតដល់ទៅរាប់សែននាក់នៅតាមមូលដ្ឋាន អាចមានឥទ្ធិពលខ្លាំងទៅលើការពិត យុត្តិធម៌ និងការទទួលខុសត្រូវនៅកម្ពុជា ។

## អង្គជំនុំជម្រះវិសាមញ្ញ

ទោះជាមានចំណុចខ្សោយច្រើនក្ដី ក៏ដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញនៅកម្ពុជាត្រូវតែបានទទួលការគាំទ្រ ពីព្រោះពេលវេលាកាន់តែខើច ហើយអ្វីដែលបានព្រមព្រៀងគ្នាហាក់ដូចជាជម្រើសល្អបំផុតដែលអាចធ្វើបានដោយភាគីទាំងសងខាង ។ មានសំណើនិងគំនិតជាច្រើនដាក់ចេញពីអង្គការក្រៅរដ្ឋាភិបាលដែលអាចជាជំនួយដល់ដំណើរការតុលាការ ។ គម្រោងការឃ្លាំមើលតុលាការជាឧទាហរណ៍មួយ ។ ប៉ុន្តែការងាររបស់អង្គការក្រៅរដ្ឋាភិបាលទាមទារឲ្យមានយុទ្ធសាស្ត្រដ៏មានប្រសិទ្ធភាពសម្រាប់ជួយដល់ការងាររបស់តុលាការ ដូចជាជួយជ្រោមជ្រែងដល់ដំណើរការកាត់ទោស និងបង្កើនជាអតិបរមានូវការជួសជុលសង្គមដែលអង្គជំនុំជម្រះអាចមាន ។

ការកាត់ទោសដែលមានលក្ខណៈពិសេសនិង«ធ្វើតែម្ដង» មិនបង្កើតឲ្យមានផលប្រយោជន៍យូរអង្វែងដល់ការបង្កើនធនធានមនុស្សទេ ។ សង្គមស៊ីវិលកម្ពុជានិងប្រព័ន្ធផ្គត់ផ្គង់អន្តរជាតិត្រូវតែប្រុងប្រយ័ត្នចំពោះគ្រោះថ្នាក់នៃការបង្វែរចំណាប់អារម្មណ៍និងធនធានទាំងអស់ទៅក្នុងសកម្មភាពរយៈពេលខ្លីលើដំណើរការកាត់ទោសខ្មែរក្រហម ដោយដកធនធានចេញពីការងាររកសាងធនធានរយៈពេលវែងដែលជួយពង្រឹងប្រព័ន្ធចាស់ ។ អាចទាញហេតុផលថា រាល់ប្រាក់មួយសេនដែលបានចំណាយទៅលើអង្គជំនុំជម្រះវិសាមញ្ញគឺជាប្រាក់ដែលគួរតែចំណាយទៅលើការអភិវឌ្ឍប្រព័ន្ធយុត្តិធម៌កម្ពុជាក្នុងរយៈពេលវែង ។ ច្បាស់ណាស់ការកាត់ទោសខ្មែរក្រហមមានសារសំខាន់ ប៉ុន្តែរាល់នីតិវិធីផ្សេងទៀតដែលធ្វើឡើងនៅកម្ពុជា ទោះទាក់ទងជាមួយអ្នកមានឋានៈខ្ពស់ឬគ្មាន អាចមិនបំពេញតាមបទដ្ឋានអន្តរជាតិទេ ។ បរាជ័យមិនទទួលបានយុត្តិធម៌ដែលបង្កឡើងដោយឥទ្ធិពលពីខាងក្រៅ ព្រមទាំងកង្វះសីលធម៌របស់បុគ្គល គឺជារឿងសាមញ្ញ



ជនរងគ្រោះជាស្ត្រីភេទ



# ភាពរន្ធត់និងការឈឺចាប់ដែលខ្ញុំបានជួបប្រទះជាលើកទី១ ហើយដែលមិនអាចបំភ្លេចបាន

ឆ្នាំ១៩៧៥ ខ្ញុំនៅវ័យកុមារនៅឡើយ ហើយរស់នៅក្នុងឋានៈខ្ពង់ខ្ពស់ដោយសារប៉ាជាមន្ត្រីរាជការមានឋានន្តរសក្តិក្នុងជួរយោធា ។ ខ្ញុំជាកូនពៅក្នុងចំណោមបងប្អូនប្រាំបួននាក់ (ប្រុស៧ ស្រី២) ។

ម៉ាក់តែងតែទាមទារឲ្យប៉ានាំក្រុមគ្រួសារយើងទៅរស់នៅក្រៅប្រទេស ព្រោះលោកអ៊ំប្រុសខាងប៉ាដែលធ្វើទូតនៅប្រទេសជប៉ុនបានទូរលេខឲ្យប៉ានាំប្រពន្ធកូនចាកចេញជាប្រញាប់ ព្រោះស្រុកទេសនឹងកើតសង្គ្រាមហើយប្រែទៅជាកុម្មុយនិស្តស៊ីអង្ករកំប៉ុង ប៉ុន្តែប៉ាចចេសមានះមិនព្រមចាកចេញទេ ។ គាត់មានប្រសាសន៍ថា «គ្មានប្រទេសណាដែលស្រួលរស់នៅជាងប្រទេសយើងទេ» ។

ថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៧៥ ក្រុមគ្រួសារខ្ញុំត្រូវបង្ខំចិត្តចេញពីផ្ទះទៅស្នាក់នៅផ្ទះបងប្អូននៅម្តុំផ្សារអូរឫស្សី ព្រោះផ្ទះរបស់ខ្ញុំជាមុខសញ្ញាដែលគេត្រូវផ្ទោងគ្រាប់កម្ទេច (ជាផ្ទះរដ្ឋនៅក្នុងបន្ទាយឃ្លាំងរំសេវ) ។ យើងពុំបានយកទ្រព្យសម្បត្តិអ្វីទាំងអស់ក្រៅពីគ្រឿងអលង្ការដែលពាក់ជាប់នឹងខ្លួន ។

ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ក្រោយពីឈរទះដៃអបអរសាទរជ័យជម្នះរបស់ខ្មែរក្រហម ប្រជាជនត្រូវបានជម្លៀសចេញពីទីក្រុង ។ គ្រួសារខ្ញុំគ្មានសម្ភារអ្វីជាប់ខ្លួនក្រៅពីឡានបីគ្រឿងម៉ាកមែរសីដេស ហ៊ឹមប៊ឹរស្ព័រ និងអូស៊ីន ដែលផ្ទុកលោកតាខាងប៉ាដែលឈឺស្ទាប់មួយចំហៀងខ្លួន សមាជិកគ្រួសារមានគ្នា១៣នាក់ និងក្រុមគ្រួសារមិត្តភក្តិរបស់ម៉ាក់ដែលជម្លៀសខ្លួនពីតាខ្មៅចំនួន២២នាក់ទៀត ។

ប៉ាបានជូនឡានអូស៊ីនដល់មិត្តភក្តិរបស់ម៉ាក់ដើម្បីងាយស្រួលក្នុងការធ្វើដំណើររួមគ្នា ។ អ្នកដែលពេញកម្លាំងត្រូវជួយរុញឡាន ។ អ្នកដែលមានសិទ្ធិអង្គុយនៅក្នុងឡានមានតែក្មេងតូចៗ អ្នកកូនខ្ចី ចាស់ជរា និងម៉ាក់ តែប៉ុណ្ណោះ ចំណែកបងស្រីជាអ្នកកាន់ចង្កូត ។ យើងធ្វើដំណើរដោយប្រើកម្លាំងមិនបានប្រើម៉ាស៊ីនទេព្រោះតាមផ្លូវកកស្ទះទៅដោយមនុស្ស ។ ពីផ្សារអូរឫស្សីដល់វង់មូលក្បាលថ្នល់ត្រូវចំណាយពេលមួយថ្ងៃពេញ ។ នៅតាមផ្លូវយើងគ្មានអ្វីទទួលទានក្រៅពីទឹកបន្តិចបន្តួចដើម្បីផ្សើមបំពង់ក ។ ខ្ញុំនិងក្មេងៗរួមដំណើរឃ្លានខ្លាំងណាស់ យំទ្រហឹងពេញឡាន ។ លោកយាយអាណិតពួកយើងក៏ដាច់ចិត្តដើរទៅសុំបាយអ្នកដទៃ ប៉ុន្តែមិនឃើញគាត់វិលត្រឡប់មករកឡានវិញទេ ហើយយើងក៏បែកគ្នារហូតដល់ពេលនេះ ។ ពេលនោះប៉ាខឹងណាស់ ហើយហាមផ្តាច់មិនឲ្យនរណាម្នាក់ចាកចេញឆ្ងាយពីឡានទេបើគ្មានការអនុញ្ញាតពីគាត់ ទោះជាឃ្លានយ៉ាងណាក៏ដោយ ។ យប់មកដល់យើងត្រូវផ្អាកដំណើរដើម្បីរកកន្លែងសម្រាក ។ ខ្ញុំយំរហូតគេងលក់ ព្រោះតាំងពីកើតមក នេះជាលើកដំបូងហើយដែលខ្ញុំជួបហេតុការណ៍បែបនេះ ។ ក្រោយភ្ញាក់ពីដេកខ្ញុំលែងយំហើយ ទោះបីជាឃ្លានខ្លាំងក៏ត្រូវអត់ទ្រាំដែរ ព្រោះមេឃងងឹតខ្ញុំខ្លាចខ្មោច ហើយនៅជុំវិញខ្លួនសុទ្ធតែសាកសពហើមស្តុរភាយក្លិនស្អុយតិចៗ ។ ប៉ាបាននាំបងប្រុសធំទាំងពីរចេញទៅបាត់មួយសន្ទុះធំក៏ត្រឡប់មកវិញនាំមកជាមួយនូវអង្ករមួយបាវ ទឹកពីរយួរ ទឹកត្រីមួយយួរ ឆ្នាំងពីរ កំសៀវមួយ ។ មួយសន្ទុះធំយើងក៏បានញ៉ាំបាយ ប៉ុន្តែគ្មានម្ហូបទេ គឺញ៉ាំជាមួយទឹកត្រី ។ ទាហានខ្មែរក្រហមបានមកឆែកឆេរឡានរបស់យើង រួចហើយសើចចំអកឲ្យយើង ព្រោះថាគ្មានអ្វីសោះក្រៅពីឆ្នាំងបាយនិងកំសៀវទឹក ។ ម៉ាក់នៅខឹងប៉ាដែលពុំស្តាប់តាមគាត់ ម្ល៉េះហើយគាត់ពុំសូវនិយាយស្តីទេក្រៅតែពីសម្រក់ទឹកភ្នែក ។ ប៉ាតែងតែលួងលោមម៉ាក់ថា «បដិវត្តន៍សង្គមនិយមមិនសម្លាប់ជាតិឯងទេ យ៉ាងច្រើនគេធ្វើឲ្យស្មើភាព គ្មានអ្នកមាន គ្មានអ្នកក្រ ។ យើងមានផ្ទះមានឡាន២-៣អីចឹង អង្គការនឹងដកទុកឲ្យយើងតែផ្ទះមួយឡានមួយប៉ុណ្ណោះ ។ ម៉ាក់មានគម្រោងចង់ធ្វើដំណើរតាមផ្លូវជាតិលេខ១ ប៉ុន្តែប៉ាជំទាស់ដាច់ខាត ព្រោះគាត់ជានាយទាហានធ្លាប់ច្បាំង ។ មូលហេតុ ទី១ ប៉ាស្អប់យួន ទី២ ប៉ាយល់ថាធ្វើដំណើរតាមផ្លូវទឹក

ប្រសើរជាង ដូចពាក្យស្លោកថា "ស៊ូអត់បាយកុំឲ្យតែអត់ទឹក" ។ យើងក៏ធ្វើដំណើរតាមផ្លូវព្រៃកប្រាដែលនៅប្របផងទន្លេ ។

នៅតាមផ្លូវ ប៉ាបានដាក់ខ្លួនទៅជួយលីអង្ករ ថ្នាំជក់ ដើម្បីដូរយកអង្ករ ត្រី ប្រហុក ទៅតាមសេចក្តីអាណិតអាសូររបស់អ្នកមូលដ្ឋាន ។ ប៉ាលាក់ប្រវត្តិរូបដោយប្រាប់អ្នកដទៃថាគាត់ជានាយផ្នែកខាងកីឡាបាល់ទះ ។

យើងគ្មានទិសដៅពិតប្រាកដទេ ព្រោះស្រុកកំណើតជាអ្នកភ្នំពេញ ម្ល៉ោះហើយប៉ាបានសុំប្រធានភូមិពោធិអណ្តែត ស្រុកស្អាង ខេត្តកណ្តាល ដើម្បីស្នាក់នៅបណ្តោះអាសន្ន រង់ចាំអង្គការអនុញ្ញាតឲ្យត្រឡប់មកផ្ទះវិញ ។ ប្រធានភូមិបានអនុញ្ញាតឲ្យខ្ញុំ បងស្រីរបស់ខ្ញុំ កុមារតូចៗ និងមីងម្នាក់ដែលមានកូនខ្ចី ស្នាក់នៅផ្ទះរបស់គាត់ ចំណែកប៉ាម៉ាក់ខ្ញុំនិងមនុស្សចាស់ផ្សេងទៀតស្នាក់នៅក្រោមដើមឈើក្បែរវត្តពោធិអណ្តែត ។ ប្រធានភូមិនោះចូលចិត្តប៉ាណាស់ ព្រោះឃើញប៉ាខស្សាហ៍និងចេះជួយអ្នកដទៃដោយមិនប្រកាន់ខ្លួន ។ មិនបានមួយខែផងប្រវត្តិរូបរបស់ប៉ាត្រូវបែកការណ៍ដោយសារមីងមានកូនខ្ចីដែលរួមដំណើរជាមួយយើងចាញ់ការលួងលោមរបស់ប្រធានភូមិនោះហើយបាននិយាយប្រាប់អំពីប្រវត្តិរបស់ប៉ា ។ បងស្រីខ្ញុំបានស្តាប់ឮការសន្ទនានោះ ។ គាត់ភិតភ័យយ៉ាងខ្លាំង ហើយធ្វើពុតជាចុកពោះដើម្បីចេញពីផ្ទះទៅផ្តល់ដំណឹងដល់ប៉ាម៉ាក់ដែលនៅក្រោមដើមឈើ ។ ម៉ាក់បានអង្វរប៉ាឲ្យជួលទូកជិះរត់ទៅប្រទេសវៀតណាម ប៉ុន្តែប៉ាប្រកែកមិនព្រមទៅជាដាច់ខាត ។

យប់មួយនោះ ម៉ាក់និងបងៗនាំគ្នាដើរសួរអ្នកស្រុកពេញភូមិព្រោះបាត់ប៉ា ។ សូម្បីតែប្រធានភូមិនិងកងឈ្លបក៏នាំគ្នាជួយរកប៉ាដែរ ។ លុះរំលងអធ្រាត្រទើបមានអ្នកមកប្រាប់ថា ប៉ាត្រូវកងពិសេសមកពីភ្នំពេញហៅទៅសួរប្រវត្តិរូបនៅលើវិហារ សូម្បីតែពួកគេក៏ពុំអាចចូលទៅបានដែរ (នេះជាបញ្ហាអង្គការមជ្ឈិម) ។ ម៉ាក់លែងធ្វើអ្វីកើតក្រៅតែពីអង្គុយយំ ។ ប្រធានភូមិបានធានាជួយតាមដានរឿងនេះឲ្យ ។ ជិតភ្លឺទើបឃើញប៉ាត្រឡប់មកវិញ ។ ទាំងប្រធានភូមិទាំងកងឈ្លបបានមកសួរដេញដោលប៉ាពីរឿងអង្គការហៅទៅ ។ ប៉ាប្រាប់ថាអង្គការច្រឡំបងប្រុសរបស់គាត់ដែលជាអ្នកការទូត ហើយស្រពេចស្រពិលថាគាត់មិនមែនជាជនស៊ីវិល គឺជាទាហាន ហើយព្យាយាមសួរប៉ាជាច្រើនលើក ប៉ុន្តែប៉ានៅតែឆ្លើយថាគាត់ជាគ្រូកីឡា ។ គាត់បានប្រាប់ប្រធានភូមិថា ពេលគាត់ធុញនឹងសំណួរដដែលៗ គាត់ក៏សួរទៅពួកគេវិញថា "បើគាត់ជាជនស៊ីវិលវាយ៉ាងម៉េច? បើគាត់មានសក្តិជាទាហានវាយ៉ាងម៉េច?" ពួកគេតបថា "អង្គការចង់ដឹងឲ្យច្បាស់ ហើយនាំចូលធ្វើការតាមមុខតំណែងវិញ" ។ ប៉ានៅតែឆ្លើយចម្លើយដដែលទើបពួកគេឲ្យប៉ាត្រឡប់មកវិញ ។ ម៉ាក់ស្តាប់យ៉ាងយកចិត្តទុកដាក់ ហើយអង្វរប៉ាឲ្យនាំគ្នាគេចពីភូមិនេះ ប៉ុន្តែប៉ាមិនត្រឹមតែខឹងទេ ថែមទាំងចេសខ្លាំងណាស់ ។ គាត់អះអាងថា គ្មាននរណាសម្លាប់ជាតិសាសន៍ឯងទេ យ៉ាងច្រើនគេយកទៅអប់រំប៉ុណ្ណោះ ។

ដូចម៉ាក់បានគិតបារម្ភមែន មិនបានប៉ុន្មានផង ប្រធានភូមិបានមកហៅប៉ាឲ្យរៀបចំខោអាវដោយប្រាប់ថា "អង្គការហៅឲ្យទៅរៀនសូត្រ" ។ ប៉ាគ្មានខោអាវរៀបទេ ។ ទាំងអស់នាំគ្នាយំ មានតែប៉ាម្នាក់ទេដែលនៅតែរឹងមាំដដែល ។ ប៉ានិយាយដោយម៉ឺងម៉ាត់ថា "ម៉ាក់នាំកូនៗឆ្លត" ។ ពាក្យដែលគាត់និយាយដដែលៗគឺ "កុំភ័យ អង្គការមិនសម្លាប់ជាតិសាសន៍ខ្លួនឯងទេ" ។ ប៉ាទៅបាត់មួយថ្ងៃ ម៉ាក់បានយកគ្រឿងអលង្ការទៅសូកប្រធានភូមិដើម្បីឲ្យគាត់ជូនបងប្រុសធំទៅមើលប៉ា ។ បងប្រុសបាននាំដំណឹងថា "ប៉ានៅមន្ទីរស្រុកមានគ្នាប្រហែល៥០នាក់ទៅជាមួយ ដូចជា ទាហាន គ្រូបង្រៀន ពេទ្យ..." ។ ម៉ាក់បានធូរចិត្តបន្តិចព្រោះគិតថា គេមិនដែលយកគ្រូនិងពេទ្យទៅសម្លាប់ទេ ។ បងប្រុសធំក៏សុំម៉ាក់ទៅជាមួយប៉ាដើម្បីបានជាគ្នា ។ ម៉ាក់ក៏សុំយោបល់ពីប្រធានភូមិ ប្រធានភូមិក៏ទៅសុំគណៈស្រុក ហើយក៏បានទទួលការអនុញ្ញាត ។ រហូតមកដល់ពេលនេះ ប៉ានិងបងប្រុសធំបាត់ដំណឹងសូន្យ ។ លោកតាបានស្លាប់នៅទីនោះដោយរោគរបស់គាត់និងគ្មានថ្នាំព្យាបាល ។ ប្រហែលបីអាទិត្យក្រោយមក មាននាវាធំៗចូលចតនៅមាត់ប្រាំងដើម្បីដឹកអ្នកថ្មីឲ្យទៅរស់នៅតាមទឹកន្លែងវិញ ។ ម៉ាក់អរណាស់ព្រោះគាត់ចង់ចាកចេញពីភូមិនេះយូរហើយ ។ ប្រពន្ធប្រធានភូមិបានមកឱ្យបម៉ាក់កុំឲ្យចាកចេញ ព្រោះអង្គការពុំបាននាំយើងទៅផ្ទះទេ ប៉ុន្តែម៉ាក់គិតថា នៅក៏ស្លាប់ទៅក៏ស្លាប់ ដូច្នេះគាត់ក៏សម្រេចចិត្តទៅ ។ នាវាទាំងអស់

មាន៤គ្រឿង ហើយបានដាក់អ្នកជម្លៀសពេញព្រៀបទាំង៤ សូម្បីតែនៅលើដំបូលក៏មានមនុស្សដែរ ។ ពេលមកដល់ទន្លេបួនមុខ មានភ្លៀងធំហើយមានខ្យល់ខ្លាំងផង នាវាមួយគ្រឿងបានលិចដោយសារប្រជាជនជ្រួលច្របល់ខ្លាំងពេក ។ ពេលនោះខ្ញុំពុំដឹងថាអ្នកណាស្លាប់អ្នកណារស់ទេ ព្រោះគ្មានអ្នកណាអើពើ ។ យើងនាំគ្នាឱបរឹតគ្នាយ៉ាងតឹងព្រោះរងាដោយទឹកភ្លៀង និងខ្លាចប៉ើងតាមខ្យល់ធ្លាក់ទឹក ព្រោះមានក្មេងជាច្រើនបានប៉ើងធ្លាក់ទឹក ចំណែកម្តាយបានត្រឹមតែយំសោកព្រោះគ្មានអ្នកណាជួយ ។ ភ្លៀងរាំង យើងដោះខោអាវពូតឲ្យស្ងួត ។ យើងគ្មានខោអាវសម្រាប់ផ្លាស់ប្តូរទេ សំណាងល្អដែលម៉ាក់បានដាក់ថ្នាំតាមខ្លួនខ្លះឲ្យយើងលេបបង្ការគ្រុន ។

ពេញ២ថ្ងៃ១យប់ទើបយើងទៅដល់ខេត្តកំពង់ឆ្នាំង ។ ទាហានខ្មែរក្រហមឲ្យពួកយើងចុះពីនាវា រួចបញ្ជូនយើងទៅស្នាក់នៅតាមផ្ទះទឹកមួយយប់ ព្រឹកឡើងបញ្ជូនតាមឡានទៅខេត្តពោធិសាត់ ។ ទៅដល់ទីនោះ យើងត្រូវស្នាក់នៅហាលភ្លៀងហាលខ្យល់ពីរយប់តាមគែមផ្លូវរថភ្លើង ទើបមានរថភ្លើងមកដឹកទៅខេត្តបាត់ដំបង ។ ពេលនោះខ្ញុំនិងបងប្រុសទី២វិះតែព្រាត់ពីម៉ាក់ ព្រោះខ្ញុំរាកបងនាំទៅលាងទឹក ហើយរថភ្លើងចេញចោលបានអ្នកនៅចុងទូឈោងទាញដៃបងប្រុសខ្ញុំដែលពខ្ញុំរត់តាម ។ ដល់រទេះភ្លើងឈប់ទើបខ្ញុំនិងបងប្រុសដើររកម៉ាក់ឃើញ ។ ទៅដល់ខេត្តបាត់ដំបង ខ្មែរក្រហមចែកប្រជាជនថ្មីជាក្រុមៗ ហើយបញ្ជូនឡើងឡានទ្រុងទៅតាមស្រុកភូមិចុងកាត់មាត់ញក ។ ក្រុមគ្រួសារខ្ញុំជិះរទេះគោមករស់នៅភូមិចារ ឃុំអន្លង់រុន ស្រុកតាប៉ុន ខេត្តបាត់ដំបង ។ ផ្ទះក្បឿងមួយខ្នងនៅជុំគ្នា៧គ្រួសារមានអ្នកថ្មី (អ្នក១៧មេសា) និងអ្នកមូលដ្ឋានចាស់ ក្នុងនោះក៏មានគ្រួសារកងឈ្លបដែរ ។ យើងបានជួបជុំគ្នាតែមួយយប់ប៉ុណ្ណោះ ។ ព្រឹកស្អែកឡើង អង្គការបានមកយកបងៗខ្ញុំទៅការដ្ឋានអស់ នៅតែខ្ញុំនិងម៉ាក់ ។ ដំបូងខ្ញុំត្រូវចូលរៀន ប៉ុន្តែខ្ញុំចេះអក្សរខ្លះហើយ (ព្រោះខ្ញុំរៀនថ្នាក់ទី១០ចាស់) ។ ម៉ាក់ត្រូវអង្គការចាត់តាំងឲ្យទៅដកស្ទូងតាមភូមិ ។ ម៉ាក់អត់ស្គាល់សំណាបទេ ហើយគាត់ត្រូវប្រធានកងកាត់របបជាញឹកញាប់ដោយចោទថាធ្វើពុត ។ ដោយម៉ាក់ចេះតែឲ្យមាសពេជ្រទៅប្រធានកង ណាមួយដោយសារម៉ាក់ពិការជើងម្ខាងផង ទើបប្រធានកងឲ្យម៉ាក់មកមើលក្មេងៗក្បែររោងបាយ ។ មិនបានប៉ុន្មានថ្ងៃផងអង្គការបានបញ្ជូនខ្ញុំទៅកងកុមារ ។ ខ្ញុំបានរត់មករកម៉ាក់ជាញឹកញាប់ហើយត្រូវប្រធានកងមកតាមចាប់វាយបណ្តើរទៅវិញ ។ ទម្រាំខ្ញុំទម្លាប់បានខ្ញុំត្រូវមេកងវាយទ្រោមខ្លួន ហើយធ្លាក់ខ្លួនគ្រុនស្ទើរគ្មានពេលរស់ ។ ពេលដែលខ្លួនខ្ញុំឡើងកម្តៅខ្លាំងស្ទើរឆេះ ខ្ញុំគ្មានគិតអ្វីក្រៅពីហក់ចូលទឹកស្ទឹងដើម្បីសម្រន់កម្តៅឡើយ ។ ម៉ាក់តែងតែលួចលាក់យកមាសពេជ្រដែលមានជាប់ខ្លួនទៅដូរដោះយកម្ហូបអាហារសម្រាប់គាត់និងខ្ញុំ ។ បងៗរបស់ខ្ញុំពុំដឹងទៅដល់ទីណាទេ ។ ខ្ញុំលួចរត់មករកម៉ាក់ជារៀងរាល់យប់ ហើយត្រឡប់ទៅវិញក្រោយពីជួបម៉ាក់មួយភ្លែតព្រោះខ្លាចមេកងវាយធ្វើបាបទៀត ។ ក្មេងៗជាច្រើនត្រូវអង្គការបំពាក់បំប៉ន ហើយរាយការណ៍អំពីឪពុកម្តាយរបស់ខ្លួនឯង ប៉ុន្តែខ្ញុំចេះដឹងខ្លះ ខ្ញុំមិនដែលស្តាប់ការបំពាក់បំប៉នទាំងនោះទេ ។

ឆ្នាំ១៩៧៧ ខ្ញុំត្រូវអង្គការអនុញ្ញាតឲ្យចូលភូមិវិញដើម្បីកើបអាចម៍គោនិងកាប់ដើមទន្ទ្រានខេត្ត ។ ខ្ញុំឃើញបងស្រីរបស់ខ្ញុំដេកឈឺស្គមកំព្រឹងរាកមួលគ្មានអ្នកថែទាំ ។ គាត់ស្លាប់ដោយមាត់ទន្ទេញតែពាក្យថាចង់ញ៉ាំពងទាចៀនស្ពៃ ។ បន្ទាប់មក បងប្រុសទី២ក៏ត្រូវបញ្ជូនមកវិញក្នុងសភាពខ្វិនជើងដោយសារដំបៅរលានៅត្រង់ជង្គង់និងភ្នែកគោរ ហើយក៏ស្លាប់ទៀត ។

រវាងឆ្នាំ១៩៧៧និង១៩៧៨ ភូមិរបស់ខ្ញុំត្រូវលិចទឹកគ្មានសល់ ។ ពេលនោះខ្ញុំឃើញអង្គការបញ្ជូនបងប្រុសខ្ញុំទាំង៥នាក់មកភូមិវិញក្នុងសភាពដុនដាបជាខ្លាំង គឺហើមនិងរាកមួល ។ ម៉ាក់មិនបានជួយអ្វីបងខ្ញុំក្រៅពីបង្ហូរទឹកភ្នែកដោយក្តីអាណិតអាសូរ ។ នៅទីបំផុតបងៗទាំង៥បានបញ្ចប់ជីវិតក្នុងខែតែមួយ ។ ម៉ាក់ប្រៀបដូចជានាងបដាចារ ។ អារម្មណ៍លែងនឹងន ព្រោះសពអ្នកទាំង៥ត្រូវបណ្តែតទៅតាមទឹកដោយគ្មានដីកប់ ។ បើកុំតែសល់ខ្ញុំម្នាក់ កុំអីម៉ាក់ប្រហែលជាវិកលចរិតហើយ ។ ពេលនោះខ្ញុំគ្រាន់តែដឹងថាស្រុកភូមិហាក់ដូចជាត្រូវផ្លាស់ប្តូរ ។ អង្គការបានបណ្តោយឲ្យប្រជាជនធ្វើអ្វីៗតាមចិត្ត គឺមានសិទ្ធិដើរពីភូមិមួយទៅភូមិមួយ ។ ប្រជាជននៅក្នុងភូមិខ្ញុំដែលសល់ពីស្លាប់ទាំងអ្នកចាស់និងអ្នកថ្មី បាននាំគ្នាជម្លៀសខ្លួនទៅរស់នៅដីគោក គឺប្រមូល

ផ្ញុំទៅនៅដីទួលក្នុងវត្តមួយដែលខ្ញុំមិនចាំឈ្មោះ ។ ពេលនោះខ្ញុំឃើញប្រជាជនធ្វើដំណើរស្រទៅស្រមកដូរដោះគ្នាតាមទំនើងចិត្ត គឺគ្មានអ្នកណាត្រួតត្រាអ្នកណាទេ គឺរករស់រៀងៗខ្លួន ។ ក៏ប៉ុន្តែសេរីភាពនេះមិនស្ថិតស្ថេរបានយូរទេ ។ អង្គការថ្មីមកពីនិរតីបានប្រមូលប្រជាជនឲ្យចូលភូមិវិញ ។ ទឹកចាប់ផ្ដើមស្រកជាបណ្ដើរៗ ។ ប្រជាជននៅក្នុងភូមិមិនថាចាស់មិនថាថ្មី បានស្លាប់បន្តបន្ទាប់ដោយអត់ឃ្លានផងដោយការសម្លាប់ផង ។ ខ្ញុំកើតដំបៅឆ្នាពេញខ្លួន ប៉ុន្តែសំណាងល្អមិនប៉ះចំកន្លែងសំខាន់ដូចជាបងប្រុសរបស់ខ្ញុំ ទើបខ្ញុំចៀសផុតពីសេចក្ដីស្លាប់ ។ ដំបៅខ្ញុំជាដោយសារឈ្លើងទាមផង ដោយការស្ងោរស្លឹកអម្ពិលលាងផង និងកម្ទេចសត្វគីង្គក់បុកឲ្យហ្មត់រោយពីលើផង ហើយបន្សល់ស្លាកស្នាមធំៗពេញទាំងខ្លួន ។

យប់មួយ ម៉ាក់ត្រូវអង្គការបណ្ដើរយកទៅដោយសារតែខ្ញុំ ។ គាត់បានពឹងអ្នកភូមិឲ្យជួយដូរមាន់មួយ ហើយគាត់ចែកឲ្យមនុស្សទាំងអស់ដែលនៅក្នុងផ្ទះជាមួយគ្នា ទុកតែភ្លៅសម្រាប់គាត់និងខ្ញុំ ។ ខ្ញុំញ៉ាំមិនឆ្អែតក៏រករឿងគាត់ ហើយត្រូវគាត់ក្ដិចឲ្យយំ ។ គាប់ជួនអង្គការដើរមកដល់ឮខ្ញុំយំ ក៏ហៅម៉ាក់ឲ្យចុះដី រួចបណ្ដើរម៉ាក់ទៅក្នុងព្រៃ ។ អ្នកនៅក្នុងផ្ទះបានបន្ទោសខ្ញុំគ្រប់ៗគ្នាថាជាអ្នកធ្វើឲ្យម៉ាក់ស្លាប់ ។ ពេលនោះខ្ញុំរន្ធត់ខ្លាំងណាស់ ខ្ញុំរត់ទៅរកម៉ាក់បណ្ដើរ ស្រែកយំខ្លាំងៗប្រាប់អង្គការបណ្ដើរថា «ខ្ញុំយំដោយខ្លួនឯង ម៉ាក់មិនបានធ្វើអីខ្ញុំទេ» ប៉ុន្តែខ្ញុំរត់រកម៉ាក់មិនឃើញឡើយ ។ ខ្ញុំចាំម៉ាក់នៅមាត់ជណ្ដើរស្រែកយំថា «គាត់គ្មានកំហុស» រហូតដល់គេងលក់ ។ ខ្ញុំដឹងខ្លួនវិញនៅពេលមានតំណក់ទឹកក្ដៅខណ្ឌៗធ្លាក់ចំថ្ពាល់ទើបខ្ញុំបើកភ្នែកឃើញម៉ាក់កំពុងយំឱបខ្ញុំ ។ ខ្ញុំអរខ្លាំងណាស់ប្រៀបដូចជាមានជីវិតម្ដងទៀត ។

ម៉ាក់បានប្រាប់ថា អង្គការចាប់គាត់បណ្ដើរទៅក្នុងព្រៃក្រោយភូមិ ។ ទៅដល់ទីនោះ កងឈ្លបបានចងភ្នែកគាត់ ។ ពេលនោះប្រធានឈ្លបក៏ទៅដល់ ហើយចងម៉ាក់ទុកចោលនៅនឹងដើមឈើមួយសន្ទុះធំ ទើបអ្នកទាំងអស់នោះត្រឡប់ទៅវិញស្រាយចំណងឲ្យម៉ាក់ហើយប្រាប់ថា «ត្រូវកែខ្លួន ឈប់ធ្វើបាបកូនរបស់អង្គការ» ។ ចាប់ពីថ្ងៃនោះមកខ្ញុំឈប់រករឿងម៉ាក់ ទោះជាឃ្លានស្ទើរដាច់ពោះស្លាប់ក៏ខ្ញុំស៊ូទ្រាំដែរ ព្រោះខ្ញុំខ្លាចបាត់បង់ម៉ាក់ទៀត ។

នៅចុងឆ្នាំ១៩៧៨ ភូមិរបស់ខ្ញុំមានភាពវឹកវរម្ដងទៀត ។ អង្គការមកពីនិរតីរៀបចំរត់គេចខ្លួន ។ ឆ្លៀតពេលនោះម៉ាក់ក៏នាំខ្ញុំរត់គេចដែរ ។ យើងធ្វើដំណើរតាមគេតាមឯងរហូតមកដល់ភូមិល្បើកព្រៃក្នុងខេត្តសៀមរាប ដែលជាភូមិមួយដាច់ស្រយាល ហើយជាតំបន់យោធា ។ ទីនេះគ្មានអ្នក១៧មេសាទេ មានតែខ្ញុំនិងម៉ាក់ រួមទាំងមីងម្នាក់ទៀតដែលដើរតាមគ្រួសារមួយឈ្មោះគួន ដែលមានបងស្រីម្នាក់ឈ្មោះ គូ នៅទីនោះ ។ ប្រធានភូមិបានស្វាគមន៍យើងទាំងអស់គ្នាហើយដាំបាយឲ្យហូប ។ ខ្ញុំហូបបាយទាល់តែឆ្អែតហល់រកកល់ស្លាប់ ទាល់តែបានចាស់ៗចាប់ដើងសំយុងក្បាលរលាក់ឲ្យក្អួតមកខ្លះទើបធូរ ។ យើងញ៉ាំឆ្អែតដេកស្រួលបានតែមួយអាទិត្យប៉ុណ្ណោះ ក៏ត្រូវអង្គការមកប្រមូលដឹកតាមរទេះគោយកទៅដាក់នៅភូមិត្រយូងដែលជាកន្លែងដែលយើងត្រូវកសាងខ្លួន ។ អ្នកនៅទីនោះមិនអាចជជែកគ្នាបានទេ ហើយអង្គការកំណត់កន្លែងឲ្យដើរ ។ ពេលទៅដួសទឹកឬទៅធ្វើការត្រូវយកខ្សែចងជើងជាប់គ្នាប្រវែង៣ម៉ែត្រ និងមានកងឈ្លបក្មេងៗស្ពាយកាំភ្លើងមិនផុតពីដី ជាអ្នកត្រួតពិនិត្យ ។ ឈ្លបក្មេងៗទាំងនោះសាហាវខ្លាំងណាស់ ។ ជារៀងរាល់ថ្ងៃឮសូរតែស្នូរគ្រាប់កាំភ្លើងបាញ់អ្នកលួចរត់និងអ្នកមិនធ្វើការតាមបញ្ជា ។ ទោះជាហត់ហេវយ៉ាងណាក៏ខ្ញុំនិងម៉ាក់ខំត្រដររដែរដើម្បីរក្សាជីវិត ។ ពេលឡើងភ្នំកាប់ទន្រ្ទានខេត្ត ខ្ញុំតែងតែលួចឡើងបេះផ្លែពុទ្រាព្រៃម្កាក់ព្រៃ និងវល្លិ៍ផ្អែម ផ្ញើម៉ាក់ជានិច្ច ។ ថ្ងៃមួយ ឈ្លបមកទាន់ខ្ញុំកំពុងតែនៅលើដើមពុទ្រា ក៏ឡើងទៅវាយខ្ញុំនៅលើដើមពុទ្រារហូតខ្ញុំធ្លាក់មកដី ហើយចុះមកវាយក្បាលជង្គង់ខ្ញុំរហូតហើមដើរលែងរួច ។ មេកងចងខ្ញុំបង្អត់បាយ៣ថ្ងៃដើម្បីជាគំរូដល់អ្នកផ្សេង ។ ដោយឈឺជើងផងហេវស្ទើរដាច់ខ្យល់ស្លាប់ម្ដងៗផង ខ្ញុំចង់តែស្លាប់ភ្លាមៗដើម្បីឲ្យផុតកម្ម ប៉ុន្តែខ្ញុំមិនអាចធ្វើបាន ។ ម៉ាក់បានត្រឹមតែឈរយំពីចម្ងាយ ។ រយៈពេល៣ថ្ងៃ មេកងបានដោះលែងខ្ញុំឲ្យមានសេរីភាពវិញ ប៉ុន្តែខ្ញុំត្រូវកាត់របបព្រោះខ្ញុំឈឺទៅធ្វើការមិនកើត ។ ម៉ាក់បានយករបបរបស់គាត់ឲ្យខ្ញុំ ។ ពេលឈប់សម្រាក ម៉ាក់បានទៅកាច់ស្លឹកកំភ្លងមកដុតឲ្យក្ដៅរួចយកមករុំជង្គង់ឲ្យខ្ញុំអស់រយៈពេលមួយសប្ដាហ៍ទើបខ្ញុំដើរបាន

តិចៗ ។ ខ្ញុំត្រូវបង្ខំចិត្តទៅធ្វើការទាំងឈឺដើម្បីដូរយករបបអាហារ ។ នៅទីនោះខ្មែរក្រហមបាញ់សម្លាប់មនុស្សនៅនឹងមុខប្រជាជនដោយឥតញញើតដៃ ។ ឈ្លបទាំងនោះសុទ្ធតែជាកងកុមារដាច់ខាតរបស់អង្គការ ។

ថ្ងៃមួយ មេកងបានអនុញ្ញាតឲ្យប្រជាជនឈប់សម្រាកមួយថ្ងៃ ហើយធ្វើបបរគ្រឿងយ៉ាងរាវកក្កុកឲ្យញ៉ាំ ព្រោះជាថ្ងៃបុណ្យប៉ុន្តែមិនដឹងជាថ្ងៃបុណ្យស្អីទេ ។ ថ្ងៃនោះយើងមានសិទ្ធិជជែកគ្នា ។ ខ្ញុំឮចាស់ៗខ្សឹបគ្នាថា អ្នកចាស់ៗត្រូវសម្លាប់ជិតអស់ហើយ អ្នកថ្មីមានមុខកាន់តែច្រើន ។ ពេលនោះ មីងគួន ដែលមានបងស្រីឈ្មោះ គូ នៅភូមិល្បើកព្រៃ បានពកូនមករកម៉ាក់ ។ គាត់បានខ្សឹបជាមួយម៉ាក់ ឲ្យម៉ាក់អង្វរខ្ញុំឲ្យរត់ជាមួយកូនស្រីធំរបស់គាត់ដើម្បីរក្សាពូជម្នាក់មួយ ព្រោះថាបើមិនឲ្យពួកខ្ញុំរត់ទេ ពួកយើងនឹងត្រូវស្លាប់ដាច់ពូជទាំងអស់ ព្រោះគាត់ចាស់ៗគ្មានសង្ឃឹមនឹងរត់រួចទេ មានតែក្មេងៗនេះហើយដែលងាយស្រួលរត់ព្រោះខ្មែរក្រហមពុំបានចងជើងឬចែកដីឲ្យដើរដូចជាមនុស្សចាស់ ។ ពីដំបូងខ្ញុំមិនព្រមរត់ចោលម៉ាក់ទេ ព្រោះយើងនៅសល់តែពីរនាក់ម្ដាយនិងកូន ស្លាប់ឬរស់ត្រូវស៊ូនៅជួបជុំគ្នា ប៉ុន្តែម៉ាក់បានអង្វរខ្ញុំនិងពន្យល់ជាច្រើនសា នៅទីបំផុតខ្ញុំក៏យល់ព្រម ។ ម៉ាក់មិចភ្នែកដាក់ មីងគួន ជាសញ្ញាថាស្អែកព្រឹកនឹងឲ្យកូនៗរត់ ។ ម៉ាក់បានយកមាសពេជ្រដែលសេសសល់មកដេរហោប៉ៅដាក់ក្នុងខោស្លឹបរបស់ខ្ញុំ ហើយយើងទាំងពីរនាក់ស្លៀកសម្លៀកបំពាក់ត្រួតគ្នា (យើងមានសម្លៀកបំពាក់តែពីរសម្រាប់ទេ) ។ ព្រហាមស្រាងៗម៉ាក់បានដាស់ខ្ញុំ ។ យើងយំឱបលាគ្នា ប៉ុន្តែពុំហ៊ានយំឮទេព្រោះខ្លាចបែកការណ៍ ។ មីងគួនបានធ្វើសញ្ញាឲ្យម៉ាក់បង្ខំទៅឲ្យលឿនឲ្យទាន់ពេលឈ្លបនាំអ្នកទោសស្រាលទៅធ្វើការនៅខាងក្រៅ ។ ពេលដែលមេកងរាប់ចំនួនរួចហើយ ខ្ញុំនិងនាងគួក៏បន្ទំខ្លួនចូលក្នុងជួរ រួចធ្វើដំណើរចេញពីជំរំជាមួយអ្នកផ្សេងទៀត ។ ចេញផុតពីជំរំ ខ្ញុំនិងនាងគួបានគេចពីហ្វូងមនុស្ស ។ ដោយសារមេឃនៅងងឹតនៅឡើយ និងដោយសារមានចាស់ៗមួយចំនួនជួយយកអាសា ទើបយើងងាយស្រួលក្នុងការគេចចេញ ។ ឈ្លបខ្មែរក្រហមមានគ្នាតែពីរនាក់ទេ គឺម្នាក់ដើរខាងមុខជួរនិងម្នាក់ដើរខាងក្រោយជួរ ហើយមនុស្សដែលត្រូវនាំចេញសុទ្ធតែចាស់ៗនិងត្រូវដាក់ខ្នោះច្រវាក់ជាប់គ្នា ទើបឈ្លបមិនពិបាកត្រួតពិនិត្យ មិនចំណាយគ្នាច្រើន និងមិនចាប់អារម្មណ៍ខ្ញុំទាំងពីរនាក់ ។

ខ្ញុំនិងនាងគួបានគេចពីកងឈ្លបដោយសុវត្ថិភាព ហើយធ្វើដំណើរតាមផ្លូវជាតិឆ្លងស្ពានតាប៉ុន រួចដើរតាមផ្លូវរទេះគោសំដៅទៅភូមិល្បើកព្រៃដែលនាងគួធានាថាចាំផ្លូវច្បាស់ ។

នាងគួនិងខ្ញុំបានវង្វេងក្នុងព្រៃអស់២ថ្ងៃ ហើយបរិភោគតែផ្លែរពាក់និងផ្លែតង្កៀបក្ដាមជាអាហារ ។ ពេលយប់យើងទាំងពីរនាក់ឡើងដេកលើចុងឈើ ។ ខ្ញុំសង្វេគនឹកម៉ាក់ចង់ត្រឡប់ក្រោយវិញ ប៉ុន្តែខ្លាចខ្មែរក្រហមសម្លាប់ព្រោះយើងរត់ចេញបីថ្ងៃហើយ ។ នៅយប់ទី៣ខ្ញុំឡើងដើមឈើសម្លឹងរកមើលភ្លើងដើម្បីរកភូមិ គាប់ជួនខ្ញុំឃើញភ្លើងគោមមួយចេះតែរសាត់មកជិតឡើងៗ ។ ខ្ញុំនិងនាងគួនាំគ្នាបិទភ្នែកព្រោះគិតថាខ្មោច ។ លុះឮសំឡេងដេញគោទើបដឹងថាមនុស្ស ក៏ហក់ចុះពីលើដើមឈើសុំដោយសាររទេះគោ ។ ម្ចាស់រទេះបានសួរនាំយើងទាំងពីរនាក់ ។ យើងប្រាប់ថាម្ដាយរបស់យើងស្លាប់អស់ហើយ ហើយយើងវង្វេងផ្លូវក៏នាំគ្នាទៅរកភូមិល្បើកព្រៃដែលមានអ៊ំស្រីរស់នៅទីនោះ ។ ម្ចាស់រទេះគោគឺជាប្រធានភូមិល្បើកព្រៃនោះឯង ។ គាត់និយាយថា គាត់អត់ចំណាំយើងទាំងពីរនាក់ទេ (ព្រោះយើងរុំកន្សែងជិតមុខ) ។ គាត់បានដឹកយើងទៅដាក់នៅផ្ទះអ៊ំរបស់នាងគួ ។ ម្ដងនេះខ្ញុំលែងខ្វល់អ្វីហើយព្រោះបានញ៉ាំឆ្អែត តែខ្ញុំនឹកដល់ម៉ាក់ខ្លាំងណាស់ ពុំដឹងជាគាត់ជួបទុក្ខបែបណាខ្លះទេ ។ នាងគួត្រូវបានអ៊ំស្រីយកទៅចិញ្ចឹម ចំណែកខ្ញុំរស់នៅជាមួយប្អូនស្រីរបស់ប្រធានភូមិ ។ យាយតានិងឪពុកម្ដាយធម៌របស់ខ្ញុំស្រលាញ់ថ្នាក់ថ្នមខ្ញុំដូចកូនបង្កើត លែងឲ្យទៅធ្វើការទៀត គឺដាក់ប្អូននៅពីមុខគិតតែពីញ៉ាំ ។ នៅទីនោះគ្មានអ្នក១៧មេសាទេ ។ ប្រជាជននៅទីនោះញ៉ាំរួមមែន ប៉ុន្តែបើមិនឆ្អែតអាចលួចដាំបាយញ៉ាំនៅក្នុងផ្ទះបាន ។ ពេលដែលខ្ញុំបានញ៉ាំឆ្អែតញ៉ាំឆ្ងាញ់ ខ្ញុំតែងនឹកឃើញដល់ម៉ាក់ដែលអត់ឃ្លានជានិច្ច ។ ខ្ញុំនឹកម៉ាក់ខ្លាំងណាស់ ។ ខ្ញុំនៅតែលាក់ថាម៉ាក់ស្លាប់ ដោយខ្លាចប្រធានភូមិបញ្ជូនខ្ញុំទៅសម្លាប់ឬធ្វើបាបព្រោះខ្ញុំជាអ្នក១៧មេសា ។

នៅថ្ងៃរំដោះ១៩៧៩ ខ្ញុំមិនដឹងថាទៅរកម៉ាក់ឯណាទេ

មិនដឹងជាគាត់ស្លាប់ឬក៏រស់ ទៅរកនាងគួក៏បាត់ ។ ខ្ញុំក៏សម្រេចចិត្ត ទៅតាមម្តាយចិញ្ចឹមរបស់ខ្ញុំ ។

ថ្ងៃមួយ ពេលដែលខ្ញុំកំពុងពបួនចិញ្ចឹមលេងលោតមីក ខ្ញុំឮសំឡេងប្លែកស្រែកហៅឈ្មោះពិតរបស់ខ្ញុំ "អាណែតកូន!" ។ ប្រធានភូមិបានបន្ទឹបន្ថែម "មីងើត! ម៉ែហងមករក" (នៅភូមិនេះ គ្រប់គ្នាហៅខ្ញុំថា មីងើត) ។ ខ្ញុំបែរកសំឡេងទាំងរន្ធត់ចិត្ត ។ ពុទ្ធោ! ម៉ាក់ខ្ញុំមែន ទាំងសាច់ទាំងឈាម ។ ខ្ញុំបែរជាឈរទ្រឹងពុំរត់ទៅរកម៉ាក់ទេ ព្រោះរន្ធត់ខ្លាំង អរខ្លាំងពេក ខ្មាសក៏ខ្លាំង ព្រោះភរគេថាម៉ាក់ស្លាប់ ។ ម៉ាក់ឱបខ្ញុំយ៉ាងខ្លាំង ទឹកភ្នែកស្រក់ដោកក្បាលខ្ញុំ ។ គាត់និយាយទាំងសំឡេងញ័រ "តោះកូនយើងទៅភ្នំពេញវិញ ទៅរកប៉ានិងបង១" ។ មុនដំបូងខ្ញុំអង្វរឲ្យម៉ាក់រស់នៅភូមិល្បើកព្រៃ ព្រោះទីនោះសម្បូរញាំ ។

ខ្ញុំមិនចង់ទៅតាមម៉ាក់វិញទេ ព្រោះខ្លាចអត់ឃ្លាននិងខ្លាចត្រូវខ្មែរក្រហមវាយធ្វើបាបទៀត ។ កុំតែម៉ាក់នៅសល់តែខ្ញុំម្នាក់ កុំអីម្តាយឪពុកនិងយាយតាចិញ្ចឹមរបស់ខ្ញុំមិនឲ្យខ្ញុំទៅម៉ាក់វិញទេ ព្រោះគាត់ទាំងអស់ស្រឡាញ់ខ្ញុំណាស់ ។ យើងរស់រានមានជីវិតម្តងទៀតហើយ ។ ប្រជាជនមីរដេរដាសធ្វើដំណើរតាមផ្លូវជាតិ ទៅរកស្រុកភូមិរបស់ខ្លួនវិញ ។

គ្រួសារមួយមានសមាជិក២២នាក់ដែលបានរួមដំណើរ ជាមួយក្រុមគ្រួសារខ្ញុំពីភ្នំពេញទៅរស់នៅក្នុងភូមិជាមួយគ្នា បានស្លាប់អស់មួយពូជ ។ ចំណែកម្តាយមីងដែលក្រុមគ្រួសារខ្ញុំស្នាក់នៅជាមួយនៅអូរឫស្សីនោះក៏ត្រូវខ្មែរក្រហមយកទៅសម្លាប់ទាំងពូជដែរព្រោះប្តីគាត់ជាគយ ។ ខ្ញុំគ្មានសល់អ្វីទេក្រៅពីជីវិត ម្តាយនិងកូនកម្សត់តែលតោល គ្មានផ្ទះសម្បែង គ្មានទីពឹង ។ ខ្ញុំនិងម៉ាក់បានចូលទៅមើលគុកទួលស្លែងរកមើលរូបថតប៉ានិងបងប្រុស ប៉ុន្តែអត់ឃើញ ឃើញតែមិត្តភក្តិរបស់គាត់ ។ (ប៉ាខ្ញុំឈ្មោះ ឌឿ គីមសៀវ ស័ក្តិ៥) ។

ខ្ញុំមិនចង់ចងចាំរឿងរ៉ាវខ្មែរក្រហមនៅក្នុងខួរក្បាលទេ ព្រោះវាឈឺចាប់ណាស់ ប៉ុន្តែខ្ញុំក៏មិនអាចបំភ្លេចទិដ្ឋភាពទាំងនោះបានដែរ ។ វាហាក់ដូចជានៅតែតាមលងខ្ញុំរៀងរាល់ថ្ងៃ ។

**ឌឿ សេរីឡែន**

# ខ្ញុំបានឃើញឈ្មោះបងស្រីនៅក្នុងបញ្ជីឈ្មោះអ្នកទោសគុកទួលស្លែង

ថ្មគោល ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៤

ខ្ញុំឈ្មោះ ឈន ច័ន្ទមករា អាយុ៤៥ឆ្នាំ រស់នៅភូមិតាសី ឃុំតាម៉ឺន ស្រុកថ្មគោល ខេត្តបាត់ដំបង ។ ខ្ញុំសូមជម្រាបលោកប្រធានមជ្ឈមណ្ឌលឯកសារកម្ពុជាថា ÷

គ្រួសារខ្ញុំមានសមាជិកចំនួន១៦នាក់កាលពីឆ្នាំ១៩៧៥ ។ លុះឆ្នាំ១៩៧៩ យើងក៏បានត្រឡប់មកស្រុកកំណើតវិញដូចប្រជាជនកម្ពុជាដទៃទៀត ។ ពេលមកដល់ឃើញថា ក្រុមគ្រួសារខ្ញុំបានបាត់បង់បងស្រីខ្ញុំ ប្តីរបស់គាត់ និងកូនស្រី២នាក់ ។ បងថ្លៃរបស់ខ្ញុំជាអ្នកបើកបររថភ្លើងភ្នំពេញ-បាត់ដំបង ។ តាមការសាកសួរមិត្តភក្តិខ្លះដែលនៅរស់ គេបានប្រាប់ថា អ្នកធ្វើការខាងបើកបររថភ្លើងមួយចំនួនត្រូវអង្គការចាត់តាំងទៅនៅភ្នំពេញ តាំងពីចុងឆ្នាំ១៩៧៦ម៉្លេះ ។ លុះដើមឆ្នាំ១៩៨០ ខ្ញុំបានធ្វើដំណើរទៅភ្នំពេញ ហើយបានឆ្លៀតចូលទៅសួរនៅមុំទួលគោក ជាកន្លែងដែលបុគ្គលិកកម្មកររថភ្លើងរស់នៅ មានអ៊ំស្រីម្នាក់បានប្រាប់ថា ឈ្មោះ ឈួន ឈឿន ត្រូវអាខ្មៅចាប់យកទៅដាក់គុកទួលស្លែង ។ ពេលដែលរដ្ឋាភិបាលបើកគុកទួលស្លែងឲ្យប្រជាជនចូលមើលជាសាធារណៈ ខ្ញុំបានដើររកមើលឈ្មោះនិងរូបថតរបស់គ្រួសារបងខ្ញុំ ប៉ុន្តែរកពុំឃើញ ។ ខ្ញុំបានឃើញតែឈ្មោះលោក ពឹង គីមស៊ា, លោក យឹម គីមសាន អតីតវេជ្ជបណ្ឌិតនៅបាត់ដំបង, រស់ ញឹម ហៅ មូល សម្បត្តិ គណៈភូមិភាគពាយ័ព្យ ឆ្នាំ១៩៧៥-១៩៧៧ ប៉ុន្តែមិនដែលបានឃើញឈ្មោះបងប្អូនខ្ញុំសោះ ។ គ្រួសារបងខ្ញុំមានគ្នា៤នាក់ៈ បងស្រីខ្ញុំឈ្មោះ កែវ ចាន់សាយ បងថ្លៃឈ្មោះ ឈួន ឈឿន កូនស្រីបងឈ្មោះ ស្រីទូច កើតចុងឆ្នាំ១៩៧២ និងស្រីម៉ៅ កើតនៅឆ្នាំ១៩៧៥ ខែ៧ ។ ខ្ញុំបានចូលមើលគុកទួលស្លែងបីដង ប៉ុន្តែពុំដែលប្រទះឈ្មោះក្រុមគ្រួសារខ្ញុំទេ ទើបតែពេលថ្មីៗនេះ កាលពីថ្ងៃទី៧

ខែកក្កដា ឆ្នាំ២០០៤ ប្អូនខ្ញុំបានទូរស័ព្ទពីបរទេសមកថាបានឃើញឈ្មោះបងស្រីយើងក្នុងបញ្ជីគុកទួលស្លែង ។ ក្នុងសៀវភៅស្វែងរកការពិតលេខ៤៩ ខែមករា ឆ្នាំ២០០៤ ត្រង់ទំព័រទី៦ បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរ ស-២១ (ទួលស្លែង) លេខរៀង១១៥៦ ចាន់ សាយ (ស្រី) ជាប្រពន្ធរបស់ ឈួន ឈឿន រទេះភ្លើង ថ្ងៃចូល២៨-១០-៧៦ ថ្ងៃកម្ទេច ៣០-១០-៧៦ ។ តាមឯកសារខាងលើ នៅថ្ងៃទី៣០ ខែ១០ ឆ្នាំ១៩៧៦នោះ គឺ១ថ្ងៃពួកគេសម្លាប់ឡើង៤០នាក់ឯណោះ ក្នុងនោះមាន៣២នាក់ជាអ្នកធ្វើការនៅរទេះភ្លើង ។

ក្នុងសំបុត្រនេះខ្ញុំចង់សាកសួរលោក យិន នាន ដែលជាអ្នកចងក្រងឯកសារបញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅគុកទួលស្លែង តើលោកមានប្រទះឃើញឈ្មោះ ÷

១) ឈួន ឈឿន ប្រុស អាយុជាង៤០ឆ្នាំ (១៩៧៦)

២) កូនស្រីឈ្មោះ ស្រីទូច អាយុ៣ឆ្នាំកន្លះ (១៩៧៦)

៣) កូនស្រីឈ្មោះ ស្រីម៉ៅ អាយុ១ឆ្នាំកន្លះ (១៩៧៦)

នៅក្នុងបញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចដែរឬទេ? បើសិនបងប្អូនញាតិមិត្តណាបានដឹងដំណឹង ឬបានស្គាល់ក្មេងតូចទាំងពីរ មេត្តាឲ្យដំណឹងដល់ខ្ញុំបាទជាឪពុកមាផង រាល់ថ្ងៃខ្ញុំបាទរស់នៅតាមអាសយដ្ឋានខាងលើ ។

ម្តាយខ្ញុំមានអាយុ៧៥ឆ្នាំហើយ រាល់ថ្ងៃគាត់នៅតែសង្ឃឹមថាកូននិងចៅរបស់គាត់នឹងវិលមករកគាត់វិញ ។ ថ្មីៗនេះពេលដែលខ្ញុំជម្រាបគាត់ទាំងអួលដើមកតាមរយៈឯកសារសៀវភៅទស្សនាវដ្តីស្វែងរកការពិត ទឹកភ្នែករបស់គាត់រមៀលលើផែនថ្ពាល់ដ៏ជ្រីវជ្រួញ គាត់និយាយមិនរួចឡើយ ។ គាត់ទទូចឲ្យខ្ញុំសរសេរផ្សព្វផ្សាយដំណឹងឡើង ។ ចុងក្រោយនេះ ខ្ញុំសូមចូលរួមការងារជាមួយអស់លោកដែលកំពុងបំពេញការងារក្នុងសៀវភៅទស្សនាវដ្តីនិងផែនការស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ប្រសិនបើអស់លោកត្រូវការខ្ញុំពេលណាមួយ ។ សូមឲ្យបានជួបតែនឹងសេចក្តីសុខនិងភាពរីកចម្រើនក្នុងការងារនិងការរស់នៅរបស់អស់លោក ។ **ពីខ្ញុំបាទ មករា**

# ជូនចំពោះលោក ឈន ច័ន្ទមករា

លោក មករា ជាទីរាប់អាន!

ខ្ញុំបានទទួលលិខិតរបស់លោកដែលសំណូមពរឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជាជួយស្រាវជ្រាវរកឈ្មោះបងថ្លៃនិងក្មួយៗរបស់លោក ។ ខ្ញុំបានរកឃើញបញ្ជីកម្ទេចនិងប្រវត្តិរូបបងស្រីនិងបងថ្លៃរបស់លោក ប៉ុន្តែគួរឲ្យសោកស្តាយដែលខ្ញុំរកមិនឃើញឯកសារពាក់ព័ន្ធក្មួយស្រីទាំងពីររបស់លោកឡើយ ។ នៅក្នុងប្រវត្តិរូបបងថ្លៃរបស់លោកដែលមានបិទរូបថតផង មានសរសេរថា ឈ្មោះ ឈួន ឈឿន អាយុ៣៣ឆ្នាំ ជនជាតិខ្មែរ ភេទប្រុស ទីលំនៅកំណើតនៅភូមិពោធិតូច ឃុំកំពង់លួង ស្រុកពញាឮ ខេត្តកណ្តាល, ឪពុកឈ្មោះ ឈួន ឈុំ ម្តាយឈ្មោះ កែវ បូរ, ក្រោយថ្ងៃ១៧-៤-៧៥ពុំបានត្រូវជម្លៀសទេ គឺនៅរទេះភ្លើងបាត់ដំបង នាទីជាអ្នកបើកបររថភ្លើង, ប្រពន្ធឈ្មោះ កែវ ចាន់សាយ កើតនៅភូមិជ្រោយម្ទេស ឃុំតាម៉ឺន ស្រុកបាត់ដំបង ខេត្តបាត់ដំបង, មានកូនស្រីចំនួន២នាក់, ទីកន្លែងឃាត់ខ្លួននៅរទេះភ្លើងភ្នំពេញ ឃាត់ខ្លួនថ្ងៃទី២៨ ខែ១០ ឆ្នាំ១៩៧៦, ឃុំនៅផ្ទះ ឆ បន្ទប់ធំលេខ៣ បន្ទប់តូចលេខ១៥ ។ នៅក្នុងប្រវត្តិរូបបងស្រីរបស់លោកក៏សរសេរពត៌មានដូចគ្នានេះដែរ ។ បងថ្លៃរបស់លោកត្រូវអង្គការចាប់ខ្លួននៅថ្ងៃជាមួយគ្នានឹងបងស្រីរបស់លោក ប៉ុន្តែគាត់ត្រូវសម្លាប់នៅថ្ងៃទី២៨ ខែ១ ឆ្នាំ១៩៧៧ (ឈ្មោះរបស់គាត់មាននៅក្នុងបញ្ជីឈ្មោះអ្នកទោសគុកទួលស្លែងដែលចុះផ្សាយនៅក្នុងទស្សនាវដ្តីស្វែងរកការពិតលេខ៥៦នេះ) ។

សូមលោកទាក់ទងមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ដើម្បីទទួលយកឯកសារអំពីសាច់ញាតិរបស់លោក ។ សូមអរគុណ ។ **សាន់ កល្យាណ (ប្រធានក្រុមទស្សនាវដ្តីស្វែងរកការពិត)**

# លិខិតពីស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ

*ព្រះវិហារ ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៤*

*លោកប្រធានមជ្ឈមណ្ឌលស្វែងរកការពិតជាទីរាប់អានកក់ក្តៅ!*

*ជាបឋម ខ្ញុំបាទសូមថ្លែងនូវអំណរសាទរនិងកោតសរសើរដោយស្មោះចំពោះមជ្ឈមណ្ឌលស្វែងរកការពិតរបស់លោកដែលបាន និងកំពុងស្រាវជ្រាវជាប្រចាំដើម្បីស្វែងរកយុត្តិធម៌ជូនជនរងគ្រោះក្នុងរបបមហាលោតផ្លោះមហាអស្ចារ្យ“អាវខ្មៅ” ។ ខ្ញុំបាទបានអានសៀវភៅរបស់មជ្ឈមណ្ឌលស្វែងរកការពិតឃើញថា ភ័ស្តុតាងកន្លងមកហាក់ដូចជានៅថ្មីៗ តែសេចក្តីសង្ឃឹមហាក់ដូចជាការស្រមៃនៅឡើយ ។*

*លោកប្រធានមជ្ឈមណ្ឌល ខ្ញុំបាទសូមផ្ញើសំណូមពរមួយ ។ សូមលោកមេត្តាស្រាវជ្រាវនិងយកមកចុះក្នុងទស្សនាវដ្តីស្វែងរកការពិត នូវឧបទ្ទវហេតុនៅថ្ងៃ...ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលក្រុមរបស់ខ្មែរក្រហមបានចាប់យន្តហោះ ក្នុងនោះខ្មែរក្រហមសម្លាប់អស់១០នាក់ (ក្នុងនោះមានលោក ហែម ប៊ុនហេង អភិបាលរងខេត្តសៀមរាប និងអាកាសយានិក៤នាក់ប៉ុណ្ណោះដែលរស់រានមានជីវិតហើយបានមកដល់ភ្នំពេញនៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ១៩៩៧) ។ តើភ័ស្តុតាងក្រោយនេះអាចយកទៅបញ្ជាក់នៅពេលមានតុលាការកាត់ទោសបានឬទេ? តើក្រុមលោកណា (ខ្មែរក្រហម) ជាអ្នកទទួលខុសត្រូវបញ្ហានេះ? តើលោក នួន ជា, លោក អៀង សារី, លោក ខៀវ សំផន ដឹងទេ?*

*សូមលោកទទួលនូវសេចក្តីគោរពរាប់អានពីខ្ញុំបាទ ។*

**យឹម ណារិន**



*យុទ្ធជនខ្មែរក្រហមនៅអន្លង់វែង*
*រូបថត: ចូសេហ្វ កុហ្ស៊ាន់*


ស្រង់ឆ្អឹងចេញពីអណ្តូង (រូបថតឆ្នាំ១៩៧៩)

ដើម្បីឧបត្ថម្ភការបោះពុម្ពនិងចែកចាយដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំនៅទូទាំងព្រះរាជាណាចក្រកម្ពុជា
ទស្សនាវដ្តីចំនួន១០០០ច្បាប់ជារៀងរាល់លេខនឹងដាក់លក់តែនៅក្នុងរាជធានីភ្នំពេញប៉ុណ្ណោះ មួយច្បាប់តម្លៃ ៧០០០រៀល

មជ្ឈមណ្ឌលឯកសារកម្ពុជាអំពាវនាវដល់រដ្ឋាភិបាល មូលនិធិនានា និងសាធារណជនគ្រប់រូប សូមជួយឧបត្ថម្ភការបោះពុម្ពផ្សាយទស្សនាវដ្តីនេះទៅតាមលទ្ធភាពដែលអាចធ្វើបាន ។
ព័ត៌មានបន្ថែមចំពោះការបោះពុម្ពផ្សាយទស្សនាវដ្តីស្វែងរកការពិត សូមមេត្តាទាក់ទងមកនាយកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥ ។ សូមអរគុណ!

The Documentation Center of Cambodia would like to appeal to governments, foundations and individuals for support of the publication of Searching for the Truth!. For contribution, please contact (855) 23 211 875 or By Email: dccam@online.com.kh. Thank you.

**A magazine of the Documentation Center of Cambodia: *Searching for the truth*. Number 56, August 2004.**
**Funded by Germany, Norway, Sweden, the Netherlands, and USA.**